# សិក្សាព្រះសុត្រ

## ភាគ ២

## បុព្វកម្មបិលោតិជាដើម

វត្តនិគ្រោធវ័ន

រៀបរៀងដោយ

ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

ពុទ្ធសករាជ ២៥៥៥

-សៀវភៅ **សិក្សាព្រះសូត្រ ភាគ៣**

-រៀបរៀងដោយភិក្ខុ **សុវណ្ណជោតោ ឈួន-សុវណ្ណ**

ជាអាចារ្យបង្រៀនព្រះវិន័យ ឧត្តមសិក្សាវត្តនិគ្រោធវ័ន

-ទីកន្លែងធ្វើ **វត្តនិគ្រោធវ័ន "គល់ទទឹង" រាជធានីភ្នំពេញ**

-សម្រាប់ជាធម្មទាន

-ពុទ្ធសករាជ ២៥៥៥

# សន្លឹកប្រាប់មាតិកា

**មាតិកា** **ទំព័រ**

## សិក្សាព្រះសូត្រ ភាគ៣


១-បុព្វកម្មបិលោតិ នាម ពុទ្ធាបទាន ...................... ០១

២-បព្វជ្ជាសូត្រ ................................................ ០៦

៣-អាឡវកសូត្រ ............................................ ១០

៤-ទានសូត្រ .................................................. ១៧

៥-បុញ្ញកិរិយាវត្ថុសូត្រ ....................................... ២៤

៦-សុខបត្ថនាសូត្រ ........................................... ៣៥

៧-បញ្ចបុព្វនិមិត្តសូត្រ ....................................... ៤៦

៨-ព្រហ្មសូត្រ ................................................ ៦៩

៩-ឧបការគុណនៃមាតាបិតា ............................... ៧១

១០-គង្គមាលជាតក .......................................... ៧៣

១១-រឿង ភិក្ខុរូបណាមួយ ................................... ១០០

១២-រឿងសត្វទទា ........................................... ១១៨

១៣-ទូតជាតក ................................................. ១២១

១៤-មហាធម្មបាលជាតក ................................... ១២៦

**មាតិកា** **ទំព័រ**


១៥-ជាណុស្សោណិព្រាហ្មណ៍ ................................ ១៤២

១៦-រឿងបិដ្ឋធីតលិកប្រេត .................................. ១៤៦

១៧-រឿងចូឡសេដ្ឋីប្រេត .................................... ១៤៧

១៨-រឿងរាជបុត្តប្រេត ....................................... ១៥០

១៩-រឿងសានុវាសិ ............................................ ១៥២

២០-រឿងឃតបណ្ឌិត .......................................... ១៥៩

២១-ឧរគជាតក ................................................ ១៨៥

២២-រឿងប្រេតជាមាតានៃព្រះសារីបុត្ត ទី២ ............. ២០០

២៣-រឿងកុមារប្រេត ទី៥ .................................... ២០៣

២៤-រឿងសេរិនីប្រេត ទី៦ .................................. ២០៦

២៥-និធិកណ្ឌសូត្រ ............................................. ២០៩

២៦-វេលាមសូត្រ .............................................. ២១៥

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស
សូមនមស្ការ ចំពោះព្រះមានព្រះភាគ
ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

## ១-បុព្វកម្មបិលោតិ នាម ពុទ្ធាបទាន

(សុត្តន្តបិដក លេខ៧៤ ទំព័រ១២៤)

ព្រះលោកនាយក មានភិក្ខុសង្ឃច្រើនចោមរោម ទ្រង់គង់លើផ្ទៃនៃថ្ម ជាទីរីករាយ ជិតស្រះអនោតត្ត រុងរឿងដោយរតនៈផ្សេងៗ ក្នុងចន្លោះនៃព្រៃ មានក្លិនផ្កាផ្សេងៗ ទ្រង់ព្យាករ-ណ៍នូវបុព្វកម្មរបស់ព្រះអង្គ ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវអំពើរបស់តថាគតដែលបានធ្វើទុកមកហើយ ដូចតទៅនេះ តថាគតបានឃើញនូវភិក្ខុមួយរូបនៅក្នុងព្រៃ ហើយបានប្រគេនកំណាត់សំពត់ ។ ក្នុងកាលនោះ តថាគតបានប្រាថ្នាជាព្រះសម្ពុទ្ធជាដំបូង ដើម្បីការត្រាស់ដឹង ឯសេចក្តីប្រាថ្នានោះ ក៏ឲ្យផលក្នុងការបានត្រាស់ជាព្រះពុទ្ធដោយអំណាចនៃបិលោតិកម្ម ។

ក្នុងកាលមុន តថាគតកើតជានាយគោបាល គៀងមេគោទៅកាន់ទីគោចរ បានឃើញមេគោកំពុងផឹកទឹកល្អក់ ហើយដេញចេញ ។ ដោយវិបាកនៃកម្មនោះ ក្នុងបច្ឆិមភពនេះ តថាគតស្រេកទឹកហើយ មិនបានផឹកដូចសេចក្ដីប្រាថ្នា ។

កាលភពមុន ក្នុងជាតិដទៃ តថាកតជាអ្នកលេង ឈ្មោះ **បុនាលិ** បានពោលបង្កាច់ព្រះបច្ចេកពុទ្ធព្រះនាម**សុរភី** ព្រះអង្គជាបុគ្គលមិនប្រទូស្តឡើយ ។ ដោយវិបាកនៃកម្មនោះ តថាគតអន្ទោលទៅក្នុងនរកអស់កាលដ៏យូរ រងទុក្ខវេទនាអស់ពាន់នៃឆ្នាំដ៏ច្រើន ។ ដោយសំណល់នៃកម្មនោះ ក្នុងបច្ឆិមភពនេះ តថាគតបាននូវការពោលបង្កាច់ ព្រោះហេតុនៃនាងសុន្ទរិកា ។

មួយទៀត តថាគតពោលបង្កាច់សាវកឈ្មោះនន្ទ របស់ព្រះពុទ្ធ ទ្រង់គ្រប់សង្កត់នូវសត្វលោកទាំងពួង តថាគតបានអន្ទោលទៅ ក្នុងនរកអស់កាលដ៏យូរ ព្រោះការពោលបង្កាច់នូវសាវកនោះ ។ តថាគតបានអន្ទោលទៅក្នុងនរកអស់កាលដ៏យូរ ចំនួនមួយហ្មឺនឆ្នាំ លុះតថាគតបានមកជាមនុស្ស ក៏បាននូវការពោលបង្កាច់ជាច្រើន ។ ដោយសំណល់នៃកម្មនោះ

នាងចិញ្ចមានវិកា មកពោលបង្កាច់តថាគតក្នុងប្រជុំជន ដោយពាក្យមិនពិត ។

តថាគតកើតជាព្រាហ្មណ៍ តែងជាអ្នកចេះមន្តមានគេធ្វើសក្ការបូជា បង្ហាញមន្តដល់មាណព ៥០០ នាក់ ក្នុងព្រៃធំ ។ **ឥសីភិមៈ** បានអភិញ្ញា ៥ មានឫទ្ធិច្រើន មកក្នុងទីនោះ តថាគតបានឃើញឥសីនោះ លោកជាអ្នកមិនប្រទូស្តនិមន្តមក ក៏បានពោលបង្កាច់ ។ លំដាប់នោះ តថាគតនិយាយនឹងពួកសិស្សថា ឥសីនេះ ជាអ្នកបរិភោគកាម កាលតថាគតនិយាយប្រាប់ ឯពួកមាណព ក៏បានរីករាយតាម ។ លំដាប់នោះ មាណពទាំងអស់ត្រាច់ទៅសូមក្នុងត្រកូលតូចធំ និយាយប្រាប់មហាជនថា ឥសីនេះ ជាអ្នកបរិភោគកាម ។ ដោយវិបាកនៃកម្មនោះ ភិក្ខុទាំងអស់ចំនួន ៥០០ នេះ ក៏បាននូវការពោលបង្កាច់ ព្រោះហេតុនៃនាងសុន្ទរិកា ។

កាលកពមុន តថាគតសម្លាប់បងប្រុសម្នាក់ មានមាតាផ្សេងគ្នា ព្រោះហេតុនៃទ្រព្យ ហើយបោះចោលទៅក្នុងជ្រោះភ្នំឲ្យប៉ះនឹងថ្ម ។ ដោយវិបាកនៃកម្មនោះ ទេវទត្តបានប្រមៀលថ្មដុំថ្មក៏រមៀលមកប៉ះអង្គុដ្ឋបាទ (មេជើង) នៃតថាគត ។

កាលពីជាតិមុន តថាគតជាទារក កំពង់លេងក្នុងផ្លូវធំ បានឃើញព្រះបច្ចេកពុទ្ធ ក៏ដុតព្រៃទាំងមូលក្បែរផ្លូវ ។ ដោយវិបាកនៃកម្មនោះ ក្នុងបច្ចិមភពនេះ ទេវទត្តក៏ប្រើខ្មាន់ធ្នូឲ្យសម្លាប់តថាគត ។

កាលពីជាតិមុន តថាគតកើតជាហ្មដំរី បានបរដំរីបំព្រួចព្រះបច្ចេកមុនីដ៏ឧត្តម ព្រះអង្គកំពុងត្រាច់ទៅដើម្បីបិណ្ឌបាត ដោយវិបាកនៃកម្មនោះ ដំរីនាឡាគិរីចុះប្រេងកាច ចូលមកព្រួចតថាគត ក្នុងគិរិព្វជបុរីដ៏ប្រសើរ (រាជគហ:) ។

តថាគតកើតជាស្តេច ឈ្មោះបត្តិក: បានលំពែងសម្លាប់បុរសទាំងឡាយ ដោយវិបាកនៃកម្មនោះ តថាគតឆេះក្នុងភ្លើងនរកក្លាខ្លាំង ។ ដោយសំណល់នៃកម្មនោះ ក្នុងកាលឥឡូវនេះ កម្មវិបាកនោះ ក៏ធ្វើឲ្យរបកស្បែកជើងទាំងអស់របស់តថាគត ព្រោះថាកម្មនៅតែមិនទាន់វិនាស ។

តថាគតកើតជាទារកនៃព្រានត្រី ក្នុងកេវដ្តគ្រាម បានឃើញពួកជនអ្នកសម្លាប់ត្រី ក៏កើតសោមនស្ស ។ ដោយវិបាកនៃកម្មនោះ ស្តេចវិដដុភ:សម្លាប់ពួកសក្យ: ក្នុងកាលណា ទុក្ខក្នុងក្បាលក៏មានដល់តថាគត (ក្នុងកាលនោះ) ព្រោះពួកសក្យ:

ត្រូវគេសម្លាប់ ។

តថាគត បានពោលផ្តន្ទានូវពួកសាវ័កក្នុងសាសនានៃព្រះពុទ្ធ ព្រះនាមផុស្សៈថា ចូរលោកទាំងឡាយទំពាស៊ី បរិភោគនូវបាយដំណើបចុះ កុំបរិភោគនូវបាយស្រូវសាលីឡើយ ។ ដោយវិបាកនៃកម្មនោះ ក្នុងកាលនោះ តថាគតនៅក្នុងស្រុកវេរញ្ជា ព្រាហ្មណ៍និមន្តឲ្យឆាន់តែបាយដំណើបអស់ ៣ ខែ ។

តថាគតបានហាមឃាត់កូនអ្នកចំបាប់ ក្នុងកាលដែលគ្មានព្រះពុទ្ធត្រាស់ ដោយវិបាកនៃកម្មនោះ ជំងឺខ្នងក៏កើតឡើងដល់តថាគត ។

តថាគតកើតជាពេទ្យ បានដាក់ថ្នាំបញ្ចុះសេដ្ឋីបុត្រ ដោយវិបាកនៃកម្មនោះ ជំងឺចុះឈាមក៏កើតឡើងដល់តថាគត ។

ក្នុងភពមួយនោះ តថាគតកើតជាជោតិបាល បានផ្ចាញ់ផ្ចាលព្រះសុគតព្រះនាមកស្សបៈថា ព្រោះអ្វីក៏ថា ត្រាស់ដឹងពោធិញ្ញាណ ជាទីផ្លូវផង់ គេរកបានដោយកម្រក្រៃលែង ។ ដោយវិបាកនៃកម្មនោះ តថាគតប្រព្រឹត្តទុក្ករកិរិយាជាច្រើន ក្នុងឧរុវេលប្រទេសអស់ ៦ វស្សា ទើបបានត្រាស់ដឹងឡើង ។ តថាគតមិនបាននូវពោធិញ្ញាណ ដ៏ឧត្តមដោយផ្លូវនុ៎ះទេ តថាគត

ហេតុតែបុព្វកម្មនោះជាស់តឿន ក៏ស្វែងរកតាមផ្លូវខុស ។

តថាគតមានបុណ្យនឹងបាបអស់រលីងហើយ បានវៀរ-បង់នូវកំដៅទាំងពួង មិនមានសេចក្តីសោក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានអាសវៈ នឹងបរិនិព្វាន ។ ព្រះជិនស្រីទ្រង់ដល់នូវអភិញ្ញា និងពលៈទាំងពួង បានព្យាករណ៍ដោយសេចក្តីពិស្តារដល់ភិក្ខុសង្ឃ ជិតមហាស្រះឈ្មោះអនោតត្ត ដូចរៀបរាប់មកនេះឯង ។

បានឮថា ព្រះមានព្រះភាគ បានសម្តែងនូវពុទ្ធាបទានឈ្មោះបុព្វកម្មបិលោតិ ជាធម្មបរិយាយ ដែលជាបុព្វចរិតរបស់ព្រះអង្គ ដោយប្រការដូច្នេះ ។

ចប់ បុព្វកម្មបិលោតិ នាម ពុទ្ធាបទាន ។

## ២-បព្វជ្ជាសូត្រ

(សុត្តន្តបិដក លេខ៥៤ ទំព័រ១៣១)

(ព្រះអានន្ទដ៏មានអាយុ ពោលថា) ខ្ញុំនឹងសម្តែងនូវបព្វជ្ជា ដែលព្រះពុទ្ធមានចក្ខុនោះ បានទ្រង់ព្រះផ្នួសហើយដោយប្រការយ៉ាងណា ទ្រង់ពិចារណាឃើញយ៉ាងណា ទើប

ទ្រង់ពេញព្រះហឫទ័យនឹងបព្វជ្ជា ។ ព្រះអង្គទ្រង់ឃើញថា ឃរាវាសនេះ ចង្អៀតចង្អល់ ជាទីកើតនូវធូលីគឺកិលេស មួយទៀត ទ្រង់ឃើញថា បព្វជ្ជាមានឱកាសទូលាយ ទើបទ្រង់ព្រះផ្នួស ។ លុះព្រះអង្គទ្រង់ព្រះផ្នួសហើយ វៀរចាកបាបកម្ម ដោយកាយ លះបង់ការប្រព្រឹត្តអាក្រក់ ដោយវាចា ជម្រះអាជីវៈឲ្យបរិសុទ្ធ ។ ព្រះពុទ្ធមានលក្ខណៈដ៏ប្រសើរ បរិបូរណ៍ ទ្រង់យាងទៅកាន់ក្រុងរាជគ្រឹះ មានភ្នំព័ទ្ធជុំវិញ ដូចជាក្រោលរបស់ពួកអ្នកមកធ: ទ្រង់យាងបិណ្ឌបាត ។ ព្រះរាជាពិម្ពិសារ ទ្រង់ឋិតលើប្រាសាទ បានទតឃើញនូវព្រះពុទ្ធនោះ លុះទ្រង់ឃើញព្រះពុទ្ធទ្រង់បរិបូរណ៍ដោយលក្ខណៈហើយ ទើបត្រាស់សេចក្ដីនេះ (ចំពោះអមាត្យទាំងឡាយ) ថា នែអ្នកទាំងឡាយដ៏ចម្រើន អ្នកទាំងឡាយចូរមើលសមណៈនេះ (សមណៈនេះ) មានរូបល្អ បរិបូរណ៍ដោយកំពស់និងទំហំ មានសម្បុរស្អាត ទាំងបរិបូរណ៍ដោយដំណើរដ៏សមរម្យ ក្រឡេកឡៀងមើលត្រឹមមួយជួរនឹម មានចក្ខុក្រឡេកចុះក្រោម មានស្មារតី សមណៈនេះ ដូចជាមិនមែនចេញចាកត្រកូលថោកទាបមក (បួស) ទេ ពួករាជទូត ចូរស្ទុះតាមទៅ (ឲ្យដឹងថា) ភិក្ខុ(នេះ)នឹងទៅក្នុង

ទីណា ។ រាជទូតទាំងនោះ ដែលព្រះរាជាទ្រង់បញ្ជូនទៅហើយ ក៏ដើរប្រកិតទៅតាមក្រោយ (ដើម្បីឲ្យដឹងថា) ភិក្ខុ(នេះ) នឹងទៅក្នុងទីណា ការនៅនឹងមានក្នុងទីណា ។ (ព្រះពោធិសត្វ) ទ្រង់អាចទៅកាន់ទីសព្វប្រក ទ្រង់គ្រប់គ្រងទ្វារ សង្រួមល្អ ព្រះអង្គមានសម្បជញ្ញៈ មានស្មារតី បានញ៉ាំងបាត្រឲ្យពេញជាឆាប់ គឺទ្រង់ទទួលតែល្មម ។ ព្រះពោធិសត្វ ជាអ្នកប្រាជ្ញ នោះលុះទ្រង់ត្រាច់បិណ្ឌបាតហើយ ក៏ស្តេចចេញអំពីនគរ យាងឡើងកាន់ភ្នំបណ្ឌវៈដោយគិតថា ការនៅនឹងមានក្នុងទីនុ៎ះ។

ពួកទូត ៣ នាក់ លុះបានឃើញហើយ ក៏ចូលទៅរកព្រះអង្គដែលទៅគង់ក្នុងទីនោះ ចំណែកទូតម្នាក់បានមកក្រាបទូលស្តេចថា បពិត្រមហារាជ ភិក្ខុនោះ អង្គុយក្នុងញកភ្នំបណ្ឌវៈ បែរមុខទៅខាងកើត (ឥតរន្ធត់) ដូចខ្លាធំ គោឧសភ និងសីហៈ ។

លុះព្រះមហាក្សត្រិយ៍ ទ្រង់ព្រះសណ្តាប់ពាក្យរាជទូតហើយ ទ្រង់ប្រញាប់រួសរាន់យាងចេញទៅកាន់ភ្នំបណ្ឌវៈដោយព្រះរាជយានដ៏ប្រសើរ ។ ព្រះមហាក្សត្រិយ៍នោះ លុះយាងផុតទីដែលទៅដោយយានហើយ ក៏ចុះចាកយាន ស្តេចយាងចូល

ទៅដោយព្រះបាទ បានដល់ហើយក៏ចូរទៅរកព្រះពោធិសត្វ ។ ព្រះរាជាទ្រង់គង់ហើយ ទ្រង់ថ្លែងសំណេះសំណាល ដោយព្រះបន្ទូលគួររលឹក លុះទ្រង់បញ្ចប់ព្រះបន្ទូលនោះហើយត្រាស់សេចក្ដីនេះថា ខ្លួនលោកនៅកំពុងពេញវ័យ នៅក្មេងកំឡោះជំទង់ ទើបកើតឡើងបានត្រឹមតែបឋមវ័យ នៅជំទង់ បរិបូរណ៍ដោយសម្បុរនិងកំពស់ ដូចជាមានជាតិជាក្សត្រិយ៍ លោកចូរញុំាងជន ជាប្រធាននៃសេនា (មេទាហាន) ឲ្យរុងរឿងហើយចូរជាបុគ្គលមានពួកជន អ្នកមិនធ្វើអំពើអាក្រក់ជាបរិវារ ចូរបរិភោគនូវភោគៈទាំងឡាយចុះ ខ្ញុំឲ្យដល់លោក កាលបើខ្ញុំសួរហើយ លោកចូរប្រាប់ជាតិដល់ខ្ញុំ ។

(ព្រះពោធិសត្វត្រាស់ថា) បពិត្រមហារាជ ត្រង់ទៅមានជនមួយ នៅប្របភ្នំហិមវន្ត ជាជនបទបរិបូរណ៍ដោយទ្រព្យនិងជនអ្នកមានព្យាយាម អាស្រ័យនៅនឹងដែនកោសល (មានជនមួយពួក) មានគោត្រជាអាទិច្ចគោត្រ មានជាតិជាសាកិយៈ អាត្មាភាពបានឃើញទោសក្នុងកាមទាំងឡាយ បានឃើញនូវការចេញចាកកាមថា ជាគ្រឿងក្សេម នឹងទៅប្រឹងប្រកបព្យាយាម ចិត្តរបស់អាត្មាភាព ត្រេកអរក្នុងព្យាយាមនុ៎ះ ។

## ៣-អាឡវកសូត្រ

*(សុត្តន្តបិដក លេខ២៥៤ ទំព័រ៦២)*

*ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងសំណាក់អាឡវកយក្ស ក្បែរក្រុងអាឡវី ។ គ្រានោះឯងអាឡវកយក្សចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ពោលនឹងព្រះមានព្រះភាគ ដូច្នេះថា នែសមណៈ ចូរចេញទៅ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ប្រពៃហើយអាវុសោ ហើយក៏ស្តេចចេញទៅ ។ អាឡវកយក្សពោលថា នែសមណៈ ចូរចូលមកវិញ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ប្រពៃហើយអាវុសោ ហើយក៏ស្តេចចូលមក ។ អាឡវកយក្ស ពោលនឹងព្រះមានព្រះភាគ ដូច្នេះទៀតជាគំរប់ ២ ដងថា នែសមណៈ ចូរចេញទៅ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ប្រពៃហើយអាវុសោ ហើយក៏ស្តេចចេញទៅ ។ អាឡវកយក្សពោលថា នែសមណៈ ចូរចូលមកវិញ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ប្រពៃហើយអាវុសោ ហើយក៏ស្តេចចូលមក ។ អាឡវកយក្សនោះ ពោលនឹងព្រះមានព្រះភាគ ដូច្នេះទៀត ជាគំរប់ ៣ ដងថា នែសមណៈ ចូរចេញទៅ ។ ព្រះមានព្រះភាគ*

ទ្រង់ត្រាស់ថា ប្រពៃហើយអាវុសោ ហើយក៏ស្តេចចេញទៅ ។ អាឡវកយក្សពោលថា នែសមណៈ ចូរចូលមកវិញ ។ ព្រះ-មានព្រះភាគ ទ្រង់ត្រាស់ថា ប្រពៃហើយអាវុសោ ហើយក៏ស្តេចចូលមកវិញ ។ អាឡវកយក្សពោលនឹងព្រះមានព្រះភាគដូច្នេះទៀត ជាគំរប់ ៤ ដងថា នែសមណៈ ចូរចេញទៅ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអាវុសោ តថាគតមិនចេញទៅទេ អំពើណាដែលអ្នកត្រូវធ្វើ ចូរអ្នកធ្វើអំពើនោះចុះ ។ នែសមណៈខ្ញុំនឹងសួរប្រស្នានឹងលោក បើលោកមិនដោះ-ស្រាយឲ្យយើងទេ យើងនឹងធ្វើចិត្តលោកឲ្យរវើរវាយ ឬហែកហឫទ័យរបស់លោក ឬក៏ចាប់ជើងគ្រវែងចោលទៅត្រើយម្ខាងទន្លេគង្គា ។ ម្នាលអាវុសោ តថាគតមិនឃើញអ្នកណាដែលធ្វើចិត្តនៃតថាគតឲ្យរវើរវាយបាន ក្នុងមនុស្សលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឡើយ ម្នាលអាវុសោ អ្នកប្រាថ្នានឹងសួរយ៉ាង-ណា ចូរសួរមកចុះ ។ គ្រានោះឯង អាឡវកយក្ស បានពោលនឹងព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

កឹ សូធ វិត្តំ បុរិសស្ស សេដ្ឋំ
កឹ សុ សុចិណ្ណំ សុខមាវហាតិ
កឹ សុ ហវេ សាទុតរំ រសានំ
កថំ ជីវឹ ជីវិតមាហុ សេដ្ឋំ

ក្នុងលោកនេះ អ្វីជាទ្រព្យដ៏ប្រសើររបស់បុរស, អ្វីដែលគេប្រព្រឹត្តល្អហើយ តែងនាំសេចក្ដីសុខមកឲ្យ, អ្វីមានរសឆ្ងាញ់ពិសាជាងរសទាំងឡាយ, បណ្ឌិតហៅជីវិតនៃអ្នករស់នៅបែបណា ថាជាជីវិតប្រសើរ ។

ព្រះមានព្រះភាគត្រាស់ថា ៖

សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
សច្ចំ ហវេ សាទុតរំ រសានំ
បញ្ញាជីវឹ ជីវិតមាហុ សេដ្ឋំ ។

ក្នុងលោកនេះ សទ្ធាជាទ្រព្យដ៏ប្រសើររបស់បុរស, ធម៌ដែលគេប្រព្រឹត្តល្អហើយ តែងនាំសេចក្ដីសុខមកឲ្យ, ពាក្យសត្យមានរសឆ្ងាញ់ពិសាជាងរសទាំងឡាយ, បណ្ឌិតហៅ

ជីវិតនៃអ្នករស់នៅដោយបញ្ញា ថាជាជីវិតដ៏ប្រសើរ ។

<u>អាឡវកយក្ស ទូលសួរថា</u> ៖

កថំ សុ តរតិ ឱឃំ  កថំ សុ តរតិ អណ្ណវំ
កថំ សុ ទុក្ខមច្ចេតិ  កថំ សុ បរិសុជ្ឈតិ ។

បុគ្គលឆ្លងអន្លង់បានដោយអ្វី ឆ្លងមហាសមុទ្របានដោយអ្វី កន្លងសេចក្តីទុក្ខបានដោយអ្វី បរិសុទ្ធបានដោយអ្វី ។

<u>ព្រះមានព្រះភាគត្រាស់ថា</u> ៖

សទ្ធាយ តរតិ ឱឃំ  អប្បមាទេន អណ្ណវំ
វីរិយេន ទុក្ខមច្ចេតិ  បញ្ញាយ បរិសុជ្ឈតិ ។

បុគ្គលឆ្លងអន្លង់បានដោយសទ្ធា ឆ្លងមហាសមុទ្របានដោយសេចក្តីមិនប្រមាទ កន្លងសេចក្តីទុក្ខបាន ដោយព្យាយាម បរិសុទ្ធបាន ដោយប្រាជ្ញា ។

<u>អាឡវកយក្ស ទូលសួរថា</u> ៖

កថំ សុ លភតេ បញ្ញំ  កថំ សុ វិន្ទតេ ធនំ
កថំ សុ កិត្តឹ បប្បោតិ  កថំ មិត្តានិ គន្ថតិ
អស្មា លោកា បរំ លោកំ កថំ បេច្ច ន សោចតិ។

បុគ្គលបាននូវប្រាជ្ញាដោយអ្វី បាននូវទ្រព្យដោយអ្វី ដល់នូវសេចក្ដីសរសើរដោយអ្វី ចងនូវមិត្តទាំងឡាយបានដោយអ្វី បុគ្គលចេញចាកលោកនេះ ទៅកាន់លោកខាងមុខហើយ មិនសោយសោក ក្នុងលោកខាងមុខដោយអ្វី ។

ព្រះមានព្រះភាគត្រាស់ថា ៖

សទ្ទហានោ អរហតំ ធម្មំ និព្វានបត្តិយា
សុស្សូសំ លភតេ បញ្ញំ អប្បមត្តោ វិចក្ខណោ ។
បដិរូបការី ធុរវា ឧដ្ឋាតា វិន្ទតេ ធនំ
សច្ចេន កិត្តឹ បប្បោតិ ទទំ មិត្តានិ គន្ថតិ ។
យស្សេតេ ចតុរោ ធម្មា សទ្ធស្ស ឃរមេសិនោ
សច្ចំ ធម្មោ ធិតិ ចាគោ ស វេ បេច្ច ន សោចតិ។

បុគ្គលជឿធម៌របស់ព្រះអរហន្ត ស្ដាប់ដោយគោរព ជាអ្នកមិនប្រមាទ មានបញ្ញាពិចារណា រមែងបាននូវប្រាជ្ញា[1] ដើម្បីដល់ព្រះនិព្វាន, បុគ្គលមានការងារដ៏សមគួរ មាន

១. ហេតុឱ្យបានបញ្ញា ៤ យ៉ាង គឺ ១-សទ្ធា, ២-ស្ដាប់ដោយគោរព, ៣-អប្បមាទ, ៤-វិចក្ខណ (ការពិចារណា) ។

*ធុរៈ (ព្យាយាមផ្លូវចិត្ត) មានព្យាយាមប្រឹងប្រែង (ព្យាយាមផ្លូវកាយ) រមែងបាននូវទ្រព្យ, បុគ្គលដល់នូវសេចក្តីសរសើរ ដោយសច្ចៈ, បុគ្គលកាលឲ្យ រមែងចងនូវមិត្តទាំងឡាយបាន ។ ធម៌ទាំង ៤ នេះ គឺ**សច្ចៈ** ១ **ធម្មៈ** (បញ្ញា) ១ **ធិតិ** (ព្យាយាម) ១ **ចាគៈ** (ការបរិច្ចាគ) ១ របស់បុគ្គលណា មានសទ្ធានៅគ្រប់គ្រងផ្ទះ បុគ្គលនោះឯង រមែងមិនសោយសោកក្នុងលោកខាងមុខ ។*

ឥង្ឃ អញ្ញេបិ បុច្ឆស្សុ បុថុ សមណព្រាហ្មណេ
យទិ សច្ចា ទមា ចាគា ខន្ត្យា ភិយ្យោធ វិជ្ជតិ ។

*អញ្ជើញអ្នក ទៅសួរសមណព្រាហ្មណ៍ជាច្រើនដទៃទៀតចុះ បើមានធម៌ដទៃទៀតក្នុងលោកនេះ ឲ្យក្រៃលែងជាង សច្ចៈ ទមៈ ចាគៈ ខន្តិ ទៅទៀត ។*

***អាឡវកយក្ស ពោលថា ៖***

កថំ នុ ទានិ បុច្ឆេយ្យំ បុថុ សមណព្រាហ្មណេ
យោហំ អជ្ជ បជានាមិ យោ អត្ថោ សម្បរាយិកោ
អត្ថាយ វត មេ ពុទ្ធោ វាសាយាឡវិមាគមា ។

យោហំ អជ្ជ បជានាមិ   យត្ថ ទិន្នំ មហប្ផលំ
សោ អហំ វិចរិស្សាមិ   គាមា គាមំ បុរា បុរំ
នមស្សមានោ សម្ពុទ្ធំ   ធម្មស្ស ច សុធម្មតន្តិ ។

*ឥឡូវនេះ ខ្ញុំចាំបាច់សួរសមណព្រាហ្មណ៍ជាច្រើនអ្វីទៀត (ព្រោះ) ក្នុងថ្ងៃនេះ ខ្ញុំដឹងប្រយោជន៍ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខច្បាស់ហើយ ព្រះពុទ្ធទ្រង់ស្តេចមកកាន់ក្រុង-អាឡវី ដើម្បីគង់នៅជាប្រយោជន៍ដល់ខ្ញុំព្រះអង្គហើយ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គដឹងច្បាស់ហើយថា ទានដែលបុគ្គលឲ្យហើយចំពោះព្រះសម្ពុទ្ធណា ថាជាទានមានផលច្រើន ខ្ញុំព្រះ-អង្គនឹងត្រាច់ទៅអំពីស្រុកទៅកាន់ស្រុក អំពីបុរីទៅកាន់បុរី សូមថ្វាយបង្គំនូវព្រះសម្ពុទ្ធ (នោះ)ផង នូវសភាពដ៏ល្អរបស់ព្រះធម៌នោះផង ។*

*ចប់ អាឡវកសូត្រ ។*

## ៤.ទានសូត្រ

*(សុត្តន្តបិដក លេខ៥៣ ទំព័រ២៥)*

*ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។*

ឯវញ្ចេ, ភិក្ខវេ, សត្តា ជានេយ្យុំ ទានសំវិភាគស្ស វិបាកំ យថាហំ ជានាមិ, ន អទត្វា ភុញ្ជេយ្យុំ, ន ច នេសំ មច្ឆេរមលំ ចិត្តំ បរិយាទាយ តិដ្ឋេយ្យ ។ *ម្នាលភិក្ខុទាំងឡាយ បើពួកសត្វដឹងផលនៃការចែកទាន ដូចជាតថាគតដឹងដូច្នោះ បើមិនទាន់ឲ្យទានទេ ក៏មិនហ៊ានបរិភោគឡើយ មួយទៀត មន្ទិលគឺសេចក្តីកំណាញ់របស់សត្វទាំងនោះ ក៏មិនគ្របសង្កត់ចិត្តបានឡើយ ។*

*ទោះបីពំនូតបាយជាដំបូង ដុំបាយជាដំបូងឯណា របស់សត្វទាំងឡាយនោះ សត្វទាំងឡាយមិនបានរំលែកអំពីពំនូតបាយនោះ ក៏មិនបរិភោគឡើយ បើសត្វទាំងនោះ មានបដិគ្គាហកបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ តថាគតដឹងផលនៃការឲ្យនិងការចែករំលែកយ៉ាងណា សត្វទាំងឡាយមិនដឹងយ៉ាងនោះទេ ព្រោះហេតុណា ហេតុនោះ សត្វទាំងឡាយមិនបាន*

ឲ្យទានហើយ ទើបហៅនបរិភោគ មួយទៀត មន្ទិលគឺសេចក្តីកំណាញ់ ក៏តែគ្របសង្កត់ចិត្តសត្វទាំងឡាយនោះ ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា ៖

បើសត្វទាំងឡាយ គប្បីដឹងផលនៃការចែករលែកថាមានផលច្រើន ដូចព្រះពុទ្ធទ្រង់ស្វែងរកគុណដ៏ធំ ត្រាស់ទុកហើយយ៉ាងនេះ សត្វទាំងឡាយមានចិត្តជ្រះថ្លា គប្បីបន្ទោបង់មន្ទិល គឺសេចក្តីកំណាញ់ចេញ ទានដែលគេឲ្យហើយដល់ព្រះអរិយៈទាំងឡាយណា រមែងមានផលច្រើន បុគ្គលទាំងឡាយ គួរឲ្យទានដល់ព្រះអរិយៈទាំងនោះ ក្នុងកាលដ៏គួរ មួយទៀត ជនច្រើននាក់ ឲ្យបាយជាទក្ខិណាទាន ដល់ទក្ខិណេយ្យបុគ្គលទាំងឡាយ ទាយកទាំងឡាយ លុះច្យុតអំពីអត្តភាពជាមនុស្សនេះហើយ រមែងទៅកាន់ឋានសួគ៌ ទាយកទាំងនោះ លុះទៅកាន់ឋានសួគ៌ ជាអ្នកមានចំណង់ក្នុងកាម រមែងរីករាយក្នុងស្ថានសួគ៌នោះ សត្វទាំងឡាយមិនកំណាញ់ រមែងសោយផលនៃការចែករលែក ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះ-

ភាគ បានត្រាស់ទុកហើយ ។

## អដ្ឋកថាទានសូត្រ

បទថា **ឯវំ** ក្នុងបទថា **ឯវញ្ច** នេះ ប្រព្រឹត្តទៅក្នុងសេចក្តីឧបមា ។ បទថា **ចេ** ជានិបាតចុះក្នុងបរិកប្ប ។ បទថា **សត្តា** បានដល់ អ្នកជាប់ជំពាក់ គឺអ្នកជាប់ទៅក្នុងអារម្មណ៍មានរូបជាដើម ។ បទថា **ជានេយ្យុំ** ប្រែថា គប្បីដឹង ។ បទថា **ទានសំវិភាគស្ស** បានដល់ ចេតនាដែលរួបរួមទេយ្យធម៌មានបាយជាដើម ឲ្យដល់ជនដទៃដោយការអនុគ្រោះ និងការបូជាយ៉ាងណាមួយ ឈ្មោះថា **ទាន** ។ ចំណែកចេតនាដែលបែងចែកដោយឯកទេស (ចំណែកមួយ) នៃវត្ថុដែលខ្លួនកាន់យកទុកបរិភោគហើយឲ្យ ឈ្មោះថា **សំវិភាគ** (ការបែងចែក) ។ បទថា **វិបាកំ** គឺផល ។ បទថា **យថាហំ ជានាមិ** បានដល់ ដូចជាតថាគតដឹង ។ ខនេះ ព្រះមានព្រះភាគ ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ បើពួកសត្វដឹងផលនៃការចែកទាន ដូចតថាគតដឹងដោយកម្លាំងញាណដែលជាផលនៃកម្ម ដោយប្រ-ចក្សក្នុងឥឡូវនេះ មានជាដើមថា ទក្ខិណាមានគុណមួយរយ

ដោយឲ្យទានសូម្បីដល់សត្វតិរច្ឆាន ហើយសោយសុខប្រព្រឹត្ត ទៅក្នុងមួយរយអត្តភាព” ដូច្នេះ ។ បទថា **ន អទត្វា ភុញ្ជេយ្យុំ** សេចក្តីថា សត្វទាំងឡាយមិនឲ្យរបស់ដែលគួរបរិភោគ ដែលមាននៅដល់ខ្លួន ដល់អ្នកដទៃមុនហើយក៏នឹងមិនបរិភោគ ចំពោះកាលឲ្យហើយទើបបរិភោគ ។ បទថា **ន ច នេសំ មច្ឆេរមលំ ចិត្តំ បរិយាទាយ តិដ្ឋេយ្យ**ម្យ៉ាងទៀត សេចក្តីកំណាញ់ដែលជាមន្ទិល មិនគ្របសង្កត់ចិត្តរបស់សត្វទាំងនោះ សេចក្តីថា សេចក្តីកំណាញ់ដែលជាមន្ទិលយ៉ាងណាមួយ បណ្តាធម៌ផ្នែកខ្មៅដែលជាឧបក្កិលេស ប្រទូសដល់សេចក្តីផូរផង់ចិត្ត មានលក្ខណៈមិនព្រមឲ្យសម្បត្តិរបស់ខ្លួនទូទៅដល់ជនដទៃ ។ ម្យ៉ាងទៀត សេចក្តីកំណាញ់និងមន្ទិល មានឥស្សាលោភៈ និងទោសៈជាដើមដែលធ្វើអន្តរាយដល់ទានសូម្បីដទៃនឹងមិនគប្បីគ្របសង្កត់ចិត្តរបស់សត្វទាំងនោះ ដោយអាការដែលមិនមានចេតនានឹងឲ្យ ឬមានចេតនាមិនបរិសុទ្ធ ។ ក៏អ្នកណាសោត កាលដឹងផលរបស់ទានដោយប្រពៃនឹងគប្បីឲ្យឱកាសដល់សេចក្តីកំណាញ់ ដែលជាមន្ទិលក្នុងចិត្តរបស់ខ្លួន

បាន ។ បទថា **យោបិ នេសំ អស្ស ចរិមោ អាលោបោ** បានដល់ គប្បីមានដុំបាយក្រោយបង្អស់របស់សត្វទាំងនោះ ។ បទថា **ចរិមំ កពឡំ** ជាវេយ្យាករណ៍របស់ពាក្យថា **អាលោបោ** នោះឯង ។ ខនេះ លោកអធិប្បាយថា តាមប្រក្រតីសត្វទាំងនេះមានជីវិតនៅបានដោយខ្លួនឯង ដោយដុំបាយត្រឹមប៉ុនណា ដុំបាយទុកមួយដុំក្នុងដុំបាយទាំងនោះ ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឲ្យដុំបាយទាំងអស់អំពីដែលសល់ទុកដុំបាយមួយនោះដល់ជនដែលត្រូវការដែលមករក ដុំបាយដែលសល់ទុកនោះ ឈ្មោះថា ដុំបាយក្រោយក្នុងទីនេះ ។ បទថា **តតោបិ ន អសំវិភជិត្វា ភុញ្ជេយ្យុំ, សចេ នេសំ បដិគ្គាហកា អស្សុ :** សត្វទាំងឡាយមិនបានរំលែកអំពីពំនូតបាយនោះ ក៏មិនគប្បីបរិភោគឡើយ បើសត្វទាំងនោះមានបដិគ្គាហកៈបុគ្គល សេចក្ដីថា បដិគ្គាហកៈរបស់សត្វទាំងនោះគប្បីមាន សត្វទាំងឡាយគប្បីបែងចែក សូម្បីអំពីដុំបាយមានប្រមាណតាមដែលពោលហើយ គប្បីឲ្យចំណែកមួយហើយទើបបរិភោគ សត្វទាំងឡាយគប្បីដឹងដូចដែលតថាគតដឹងផល

របស់ការបែងចែកទាន ដោយប្រចក្សដូច្នោះ ។ ដោយបទថា **យស្មា ច ខោ** ជាដើម ព្រះមានព្រះភាគ ទ្រង់ញ៉ាំងសេចក្ដីតាមព្រះពុទ្ធប្រាថ្នា ឲ្យសម្រេចដោយហេតុថា សត្វទាំងនេះមិនដឹងផលក្នុងការបែងចែកទានយ៉ាងនេះ ព្រោះផលរបស់កម្មនៅមិនទាន់ប្រចក្ស ដោយបទនេះគប្បីឃើញថា ព្រះអង្គទ្រង់សម្ដែងដល់ហេតុនៃការមិនបដិបត្តិក្នុងបុណ្យដទៃទៀត និងនៃការបដិបត្តិក្នុងវត្ថុមិនមែនបុណ្យ ។

ក្នុងគាថាទាំងឡាយមានអធិប្បាយដូចតទៅនេះ ៖

បទថា **យថាវុត្តំ មហេសិនា** សេចក្ដីថា ដូចដែលព្រះមានព្រះភាគ ទ្រង់ស្វែងរកគុណដ៏ធំត្រាស់ហើយដោយន័យមានជាដើមថា "ទក្ខិណាមានគុណមួយរយ ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះសត្វតិរច្ឆាន" ដូចនេះ ឬដោយន័យមានជាដើមក្នុងសូត្រនេះថា **"ឯវញ្ច សត្តា ជានេយ្យុំ :** បើសត្វទាំងឡាយដឹងផលនៃការចែកទានយ៉ាងនេះ" ដូច្នេះ អធិប្បាយថា ដូចដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយដោយព្រះញាណ គឺទ្រង់ជ្រាបផ្លូវចិត្ត ។ បទថា **វិបាកំ**

**សំវិភាគស្ស** បានដល់ ផលនៃការបែងចែក, ក៏នឹងនិយាយ ទៅថ្វីដល់ទានសោត ។ បទថា **យថា ហោតិ មហប្ផលំ** គួរចងជាសេចក្តីថា បើថាសត្វទាំងឡាយពួកនេះ គប្បីដឹង ដោយវិធីដែលផលនោះជាផលធំសោត ។ បទថា **វិនេយ្យ មច្ឆេរមលំ** សេចក្តីថា សត្វទាំងឡាយគប្បីកំចាត់សេចក្តី កំណាញ់ដែលជាមន្ទិល មានចិត្តថ្លាផូរផង់ ដោយចំពោះយ៉ាង ក្រៃលែងដោយការជឿផលនៃកម្ម និងដោយការជឿក្នុងព្រះ-រតនត្រៃ គប្បីឲ្យទានដែលឲ្យហើយសូម្បីតិចក៏មានផលច្រើន ក្នុងព្រះអរិយបុគ្គលដែលបរិបូរណ៍ដោយគុណ មានសីលជា ដើម ព្រោះជាអ្នកឆ្ងាយចាកកិលេសទាំងឡាយតាមកាលដែល គួរ ។ អ្នកគួរដល់ទក្ខិណាទាន ព្រោះធ្វើឲ្យមានផលច្រើន ឈ្មោះថា ទក្ខិណេយ្យបុគ្គល, គឺជាអ្នកបដិបត្តិប្រពៃ ។ ឲ្យទក្ខិណា គឺទេយ្យធម៌ដែលអ្នកឲ្យជឿលោកខាងមុខ ក្នុង ទក្ខិណេយ្យបុគ្គលទាំងនោះដោយទាននោះជាទានធំ ។ មួយវិញ ទៀត សួរថា បុគ្គលឲ្យបាយដល់ជនច្រើន ចុះបុគ្គលគួរ នឹងឲ្យទានដូចម្តេច ។ ឆ្លើយថា គួរឲ្យទក្ខិណាទានក្នុងទក្ខិ-

ណោយបុគ្គល ។ មួយ៉ាងទៀត អ្នកឲ្យច្យុតចាកភាពជាមនុស្ស នេះហើយរមែងទៅកាន់ឋានសួគ៌ ដោយការបដិសន្ធិ ។ បទថា **កាមកាមិនោ** សេចក្ដីថា ទាយកអ្នកប្រាថ្នាកាម គឺអ្នកមាន សេចក្ដីដល់ព្រមក្នុងកាមគ្រប់យ៉ាង ព្រោះជាអ្នកធ្វើសេចក្ដីល្អ ដោយបានទទួលកម្មដែលជាសម្បត្តិ នៃទេវសម្បត្តិយ៉ាងធំ ដែលគួរប្រាថ្នា រមែងរីករាយ គឺបានទទួលការទំនុកបម្រុងតាម សេចក្ដីគាប់ចិត្ត ។

ចប់ អដ្ឋកថាទានសូត្រទី ៦ ។

## ៥_បុញ្ញកិរិយាវត្ថុសូត្រ

(សុត្តន្តបិដក លេខ៥៣ ទំព័រ៦៩)

ខ្ញុំបានស្ដាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្ដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុនេះមាន ៣ ។ បុញ្ញកិរិយាវត្ថុ ៣ តើដូចម្ដេច ។ គឺទានមយបុញ្ញកិរិយាវត្ថុ ១ សីលមយបុញ្ញកិរិយាវត្ថុ ១ ភាវនាមយបុញ្ញកិរិយាវត្ថុ ១ ។ ម្នាលភិក្ខុទាំងឡាយ បុញ្ញ-

កិរិយាវត្ថុមាន ៣ នេះឯង ។ លុះព្រះដ៏មានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា ៖

បុញ្ញមេវ សោ សិក្ខេយ្យ អាយតគ្គំ សុខិន្ទ្រិយំ
ទានញ្ច សមចរិយញ្ច មេត្តចិត្តញ្ច ភាវយេ
ឯតេ ធម្មេ ភាវយិត្វា តយោ សុខសមុទ្ទយេ
អព្យាបជ្ឈំ សុខំ លោកំ បណ្ឌិតោ ឧបបជ្ជតិ ។

កុលបុត្រអ្នកប្រាថ្នាប្រយោជន៍ គួរសិក្សានូវបុណ្យ ដែលមានផលបរិបូរណ៍ មានវិបាកជាសុខ គឺគួរចម្រើនទានផង ការប្រព្រឹត្តិស្មើ គឺសីលផង មេត្តាចិត្តផង លុះចម្រើនធម៌ទាំង ៣ នេះ ដែលមានអានិសង្សជាសុខហើយ រមែងចូលទៅកាន់លោកដែលជាសុខ ឥតមានការបៀតបៀន ។

**នៅក្នុងគម្ពីរបរមត្ថទីបនី-អដ្ឋកថា ពន្យល់ថា ៖**

ពាក្យថា **បុញ្ញកិរិយាវត្ថុ** នេះ សេចក្តីថា កុសលទាំង-ឡាយដែលឲ្យកើតផលក្នុងភពដែលគួរបូជា ឬជម្រះសន្តានរបស់ខ្លួន ព្រោះដូច្នោះ ទើបឈ្មោះថា **បុញ្ញ** បុញ្ញទាំងនោះផង

ឈ្មោះថា **ជាកិរិយា** ព្រោះត្រូវធ្វើដោយហេតុ ដោយបច្ច័យ ទាំងឡាយផង ព្រោះហេតុនោះ ទើបឈ្មោះថា បុញ្ញកិរិយា, បុញ្ញកិរិយានោះឯង ឈ្មោះថា **បុញ្ញកិរិយាវត្ថុ** ព្រោះជាទីតាំង នៃអានិសង្សនោះៗ ។

ពាក្យថា **ទានមយំ** បានដល់ ចេតនាជាគ្រឿងបរិច្ចាគ ទេយ្យធម៌របស់ខ្លួនដល់អ្នកដទៃ ដោយអំណាចនៃការអនុគ្រោះ ឬដោយអំណាចនៃការបូជា របស់អ្នកដែលកាត់ឫសគល់ គឺ កពនៅមិនទាន់ដាច់ ឈ្មោះថា **ទាន** ព្រោះជាហេតុនៃការឲ្យ ។ ទាននោះឯង ឈ្មោះថា **ទានមយ** ។ ចេតនាដែលប្រព្រឹត្តទៅ ហើយក្នុងកាលទាំង ៣ គឺ ក្នុងកាលដែលជាចំណែកខាងដើម តាំងអំពីការឲ្យបច្ច័យ ៤ ទាំងនោះកើតឡើង ១ ក្នុងវេលា បរិច្ចាគ ១ ក្នុងការសោមនស្សចិត្ត រលឹកដល់ខាងក្រោយ (អំពីទីឲ្យហើយ) ១ របស់អ្នកឲ្យវត្ថុនោះៗ បណ្ដាបច្ច័យ ៤ មានចីវរជាដើម ឬបណ្ដាទានវត្ថុ ១០ យ៉ាង មានបាយជាដើម ឬបណ្ដាអារម្មណ៍ ៦ មានរូបជាដើម ឈ្មោះថា បុញ្ញកិរិយាវត្ថុ ដែលសម្រេចដោយការឲ្យទាន ។

ពាក្យថា **សីលមយ** បានដល់ ចេតនាដែលប្រព្រឹត្តទៅហើយ ដល់បុគ្គលអ្នកសមាទានសីល ៥ សីល ៨ ឬសីល ១០ ដោយអំណាចនៃការកំណត់ឲ្យជានិច្ចសីល និង ឧបោសថសីលជាដើម ឬអ្នកគិតថា យើងនឹងបួសដើម្បីបំពេញសីលឲ្យបរិបូរណ៍ ហើយទៅកាន់វិហារបួស នឹងញ៉ាំងមនោរថឲ្យដល់ទីបំផុត រលឹកថា យើងបួសហើយជាការល្អ ហើយអប់រំ បំពេញបាតិមោក្ខសំវរសីលឲ្យបរិបូរណ៍ ដោយសទ្ធាពិចារណាបច្ច័យ ៤ មានចីវរជាដើម ដោយបញ្ញា សង្រួមចក្ខុទ្វារជាដើម ក្នុងរូបជាដើមដែលមកកាន់គន្លង ដោយសតិនិងជម្រះអាជីវបារិសុទ្ធិសីល ដោយសេចក្តីព្យាយាម រមែងតាំងមាំ ព្រោះដូច្នោះ ចេតនានោះ ទើបឈ្មោះថា បុញ្ញកិរិយាវត្ថុសម្រេចដោយសីល ។

ចេតនា របស់អ្នកពិចារណាឃើញច្បាស់នូវចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ មនៈ ដោយ(ជារបស់)មិនទៀង ជាទុក្ខ ជាអនត្តា ដោយវិបស្សនាមគ្គ ដែលពោលហើយ ក្នុងបដិសម្ភិទា ១ ចេតនារបស់អ្នកពិចារណាឃើញច្បាស់នូវរូបទាំងឡាយ ។ល។ ធម៌ទាំងឡាយ, ចក្ខុវិញ្ញាណ ។ល។ មនោ-

វិញ្ញាណ ។ ចក្ខុសម្ផស្ស ។ល។ មនោសម្ផស្ស, ចក្ខុសម្ផស្ស ជាវេទនា (វេទនាកើតពីចក្ខុសម្ផស្ស) ។ល។ មនោសម្ផស្ស ជាវេទនា ។ រូបសញ្ញា (សេចក្ដីសម្គាល់នូវរូបារម្មណ៍) ។ល។ ធម្មសញ្ញា ។ (និង) ជរាមរណៈ ដោយជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ១ ឈានចេតនាដែលប្រព្រឹត្តទៅហើយក្នុង អារម្មណ៍ ៣៨ ប្រការ មានបឋវីកសិណជាដើម ១ ចេតនា ដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃការសន្សំ (បរិច្ចយ) និង មនសិការជាដើម ដែលមិនមានទោស ១ យ៉ាងណា អ្នក ញុំាងចេតនាទាំងអស់នោះឲ្យចម្រើន ដោយបុញ្ញកិរិយាវត្ថុនេះ ព្រោះដូច្នោះ ទើបឈ្មោះថា បុញ្ញកិរិយាវត្ថុដែលសម្រេច ដោយភាវនា តាមន័យដែលពោលហើយដូច្នេះឯង ។

ក៏បណ្ដាកម្មទាំង ៣ យ៉ាងនេះ កាលធ្វើកម្មយ៉ាង ដោយកាយ ចាប់ផ្ដើមតាំងពីចំណែកខាងដើម តាមសមគួរ កម្មជាកាយកម្ម ។ កាលថ្លែងវាចាដែលជាប្រយោជន៍ដល់កម្ម នោះ កម្មជាវចីកម្ម កាលមិនញុំាងអង្គគឺកាយ និងអង្គគឺវាចា ឲ្យកម្រើក គិតដោយចិត្ត (តែម្យ៉ាង) កម្មជាមនោកម្ម ។ ម្យ៉ាងទៀត ក្នុងវេលាដែលអ្នកឲ្យបាយជាដើមឲ្យ (ទាន)

ដោយគិតថា យើងនឹងឲ្យបាយនិងទឹកជាដើមក្តី ដោយរលឹកដល់ទានបារមីក្តី បុញ្ញកិរិយាវត្ថុ ជាទានមយ ។ កាលឲ្យទានដោយតាំងនៅក្នុងវត្តបដិបត្តិ បុញ្ញកិរិយាវត្ថុ ជាសីលមយ ។ អ្នកឲ្យ (ទាន) ដោយផ្តើមតាំងការពិចារណា (នាមរូប) ដោយសេចក្តីអស់ទៅ ដោយសេចក្តីសាបសូន្យទៅ ដោយកម្មបុញ្ញកិរិយាវត្ថុ ជាភាវនាមយ ។ បុញ្ញកិរិយាវត្ថុ ៧ យ៉ាងដទៃទៀត គឺ បុញ្ញកិរិយាវត្ថុដែលសហគតដោយសេចក្តីកោត-ក្រែង (ការគោរព) ១ ដែលសហគតដោយការខ្វល់ខ្វាយ ១ ការផ្តើមឲ្យនូវចំណែកបុណ្យ ១ ការទទួលអនុមោទនា ១ សម្រេចដោយការសម្តែងធម៌ ១ សម្រេចដោយការស្តាប់ធម៌ ១ សេចក្តីឃើញត្រង់ ១ ។ ក៏សូម្បីការដល់ព្រះរតនត្រ័យ ថាជាសរណៈ រមែងសង្គ្រោះចូលដោយការធ្វើសេចក្តីឃើញឲ្យត្រង់នោះឯង, ក៏ពាក្យដែលគួរពោលក្នុងរឿងនេះ នឹងមានជាក់ច្បាស់ខាងមុខ ។

បណ្តាបុញ្ញកិរិយាវត្ថុ ៧ យ៉ាងនោះ បុញ្ញកិរិយាវត្ថុដែលសម្រេចដោយអបចាយនៈ (ការគោរព) គប្បីជ្រាបដោយអំណាចនៃការឃើញភិក្ខុចាស់ជាង ហើយក្រោកទទួល ទទួល

*បាត្រ និងចីវរ ថ្វាយបង្គំ និងឲ្យផ្លូវជាដើម ។*

*បុញ្ញកិរិយាវត្ថុ ដែលប្រកបព្រមដោយការខ្វល់ខ្វាយ គប្បីជ្រាបដោយអំណាចនៃការធ្វើវត្តបដិបត្តិ ដល់ភិក្ខុចាស់ជាង ដោយអំណាចនៃការដែលឃើញភិក្ខុចូលទៅក្នុងស្រុក ដើម្បីបិណ្ឌបាត ទទួលបាត្រ (របស់លោក) ហើយបញ្ចុះភិក្ខា សូម្បីក្នុងស្រុកឲ្យរៀបរយ នាំចូលទៅថ្វាយ និងដោយអំណាចនៃការប្រញាប់នាំយកបាត្រមកឲ្យជាដើម ដោយបានឮ (ពាក្យបង្គាប់)ថា ចូរទៅនាំយកបាត្ររបស់ភិក្ខុទាំងឡាយមក ដូច្នេះ ។*

*បុញ្ញកិរិយាវត្ថុ គឺការអនុមោទនា (បុណ្យ) គប្បីជ្រាបដោយអំណាចនៃការអនុមោទនាចំណែកបុណ្យ ដែលអ្នកដទៃឲ្យហើយ ឬបុណ្យដែលអ្នកដទៃធ្វើហើយទាំងអស់ថា **សាធុ** (ល្អហើយ) ។*

អត្តនោ បគុណធម្មំ អបច្ចាសីសន្តោ ហិតជ្ឈាសយេន បរេសំ ទេសេតិ ៖ ឥទំ **ទេសនាមយំ** បុញ្ញកិរិយវត្ថុ នាម ។ យំ បន ឯកោ "ឯវំ មំ ធម្មកថិកោតិ ជានិស្សន្តី"តិ ឥច្ឆាយ បត្វា លាភ-

សក្ការសិលោកសន្និស្សិតោ ធម្មំ ទេសេតិ, តំ ន មហប្ផលំ ហោតិ ។

*ភិក្ខុកាលមិនប្រាថ្នាការស្គាត់ជំនាញក្នុងធម៌ ដើម្បីខ្លួនសម្ដែងធម៌ដល់អ្នកដទៃ ដោយអធ្យាស្រ័យពេញទៅដោយការអនុគ្រោះ នេះឈ្មោះថា បុញ្ញកិរិយាវត្ថុសម្រេចដោយការសម្ដែងធម៌ ។ តែថា កាលដែលភិក្ខុមួយរូបតាំងសេចក្ដីប្រាថ្នាទុកថា ជនទាំងឡាយនឹងដឹងថា យើងជាធម្មកថិកដោយវិធីយ៉ាងនេះ ហើយអាស្រ័យលាភសក្ការៈ និងសេចក្ដីសរសើរ (សិលោក) សម្ដែងធម៌មិនមានផលច្រើនឡើយ ។*

"អត្ថា អយំ អត្តហិតបរហិតានំ បដិបជ្ជ-ន្ធចាយោ"តិ យោនិសោមនសិការបុរេចារិកហិតផរ-ណេន មុទុចិត្តេន ធម្មំ សុណាតិ, ឥទំ **សវនមយំ** បុញ្ញកិរិយវត្ថុ ហោតិ ។ *ការដែលស្ដាប់ធម៌ដោយចិត្តទន់ភ្លន់ ប្រាថ្នាផ្សាយប្រយោជន៍អនុគ្រោះ មានយោនិសោ-មនសិការទៅថា នេះជាឧបាយឲ្យបានបំពេញប្រយោជន៍ខ្លួននិងប្រយោជន៍អ្នកដទៃ យ៉ាងពិតប្រាកដ នេះជាបុញ្ញកិរិយាវត្ថុដែលសម្រេចដោយការស្ដាប់ធម៌ ។*

យំ បនេកោ "ឥតិ មំ សទ្ធោតិ ជានិស្សន្តី"តិ សុណាតិ, តំ ន មហប្ផលំ ហោតិ ។ *តែការដែលអ្នកណាមួយ សតាប់ធម៌ដោយគិតថា "ជនទាំងឡាយចូរស្គាល់យើងថា ជាអ្នកមានសទ្ធាដោយវិធីនេះ" មិនមានផលច្រើនឡើយ ។*

ទិដ្ឋិយា ឧជុគមនំ **ទិដ្ឋិជុកតំ,** "អត្ថិ ទិន្ន"ន្តិ-អាទិនយប្បវត្តស្ស សម្មាទស្សនស្ស ឯតំ អធិវចនំ ។

*ការដែលទិដ្ឋិ ដំណើរទៅត្រង់ ឈ្មោះថា **ការឃើញត្រង់** (ទិដ្ឋិជុកម្ម), ពាក្យថា **ទិដ្ឋិជុគតំ** នេះ ជាឈ្មោះរបស់សម្មាទស្សនៈ ដែលប្រព្រឹត្តទៅហើយដោយន័យមានជាដើមថា "ទានដែលឲ្យហើយ មានផល" ។ ព្រោះថា ការឃើញត្រង់នេះ សូម្បីជាញាណវិប្បយុត្ត ក្នុងចំណែកខាងដើម ឬខាងក្រោយ តែក្នុងវេលាធ្វើការឃើញឲ្យត្រង់ហើយ ក៏ជាញាណសម្បយុត្ត នោះឯង ។*

*តែអាចារ្យពួកមួយពោលថា ទស្សនៈ គឺការឃើញដោយអំណាចនៃការដឹងច្បាស់ និងការដឹងជាក់ ១ វិញ្ញាណ*

ដែលជាកុសល ១ កម្មស្សកតាញាណជាដើម ១ ជាសម្មា-
ទស្សនៈ ។ បណ្ដាធម៌ ៣ យ៉ាង មានទស្សនៈជាដើមនោះ
សូម្បីក្នុងកាលញាណនៅមិនទាន់កើតឡើង ក៏មានការសង្គ្រោះ
ហេតុដែលសមគួរដល់ហេតុ ជាគ្រឿងរឭកដល់បុណ្យដែល
ខ្លួនបានធ្វើទុកហើយ ចូលជាមួយវិញ្ញាណដែលជាកុសលបាន។
មានការសង្គ្រោះចូលជាមួយកម្មស្សកតាញាណ គឺ ការឃើញ
ប្រពៃ តាមផ្លូវរបស់កម្មបាន ។ តែការឃើញត្រង់ក្រៅនេះ
មានការកំណត់ធម៌ទាំងពួង ជាលក្ខណៈ ។ ព្រោះថា ការធ្វើ
បុណ្យយ៉ាងណានីមួយ បុណ្យនោះក៏មានផលច្រើន ព្រោះ
ហេតុដែលទិដ្ឋិទាំងឡាយត្រង់នោះឯង ។

តែថា មានការសង្គ្រោះបុញ្ញកិរិយាវត្ថុ ៧ យ៉ាងទាំងនេះ
ចូលជាមួយបុញ្ញកិរិយាវត្ថុ ៣ យ៉ាងខាងដើមមានទានមយៈ
ជាដើម ។ អធិប្បាយថា បណ្ដាបុញ្ញកិរិយាវត្ថុ ៧ យ៉ាង នោះ
បត្តិទានមយៈ និង អនុមោទនាមយៈ ពីរយ៉ាងនេះ សង្គ្រោះ
ចូលក្នុងទានកុសល ឈ្មោះថា **ទានមយៈ** ។

អបចាយនៈ និងវេយ្យាវច្ចៈ ពីរយ៉ាងនេះ សង្គ្រោះចូល
ក្នុងសីលកុសល ឈ្មោះថា **សីលមយៈ** ។

ធម្មទេសនា (ការសម្ដែងធម៌) ធម្មស្សវន (ការស្ដាប់ធម៌) និង ទិដ្ឋុជុកម្ម (ការឃើញត្រង់) បីយ៉ាងនេះ សង្គ្រោះចូលក្នុងភាវនាកុសល ឈ្មោះថា **ភាវនាមយៈ** ។

(ម្យ៉ាងទៀត) ទិដ្ឋុជុកម្ម សង្គ្រោះចូលក្នុងបុញ្ញកិរិយាវត្ថុទាំង ៣ យ៉ាង ។

ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុនេះ មាន ៣ យ៉ាង, ៣ យ៉ាងតើដូចម្ដេច ? គឺ ទានមយបុញ្ញកិរិយាវត្ថុ ១ សីលមយបុញ្ញកិរិយាវត្ថុ ១ ភាវនាមយបុញ្ញកិរិយាវត្ថុ ១ ដូច្នេះ ។

ក៏ក្នុងអធិការនេះ បុញ្ញកិរិយាវត្ថុទាំង ៣ យ៉ាង មានការប្រព្រឹត្តទៅដោយអំណាចនៃកុសលចេតនា ដែលជាកាមាវចរ ៨ ដួង ។ ឧបមាថា កាលបុគ្គលសម្ដែងធម៌ដែលស្ទាត់ជំនាញ ក៏មិននឹកដល់អនុសន្ធិឡើយ ធម៌ពួកខ្លះ ក៏វៀរទៅបាន យ៉ាងណា កាលព្រះយោគាវចរប្រកបរឿយៗ នូវសមថភាវនា និងវិបស្សនាភាវនាដែលជំនាញ មនសិការដោយចិត្តដែលជាញាណវិប្បយុត្ត ក៏ប្រព្រឹត្តទៅបានក្នុងចន្លោះៗ (តែ) ទាំងអស់នោះ ជាបុញ្ញកិរិយាវត្ថុដែលសម្រេចដោយចេតនាម្យ៉ាង

ដោយអំណាចនៃកុសលចេតនាដែលជាមហគ្គតៈ មិនជាបុញ្ញកិរិយាវត្ថុក្រៅនេះទេ (ទានមយៈ សីលមយៈ) ។

(បាអដ្ឋកថា បរមត្ថទីបនី)

## ៦_សុខបត្ថនាសូត្រ

(សុត្តន្តបិដក លេខ៥៣ ទំព័រ៩១)

ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតកាលប្រាថ្នាសេចក្តីសុខ ៣ យ៉ាងនេះ គួរតែរក្សាសីល។ សេចក្តីសុខ ៣ យ៉ាង តើដូចម្តេច ។ គឺបណ្ឌិតគប្បីរក្សាសីលដោយបំណងថា សូមឲ្យសេចក្តីសរសើរមកដល់អាត្មាអញ ១ បណ្ឌិតគប្បីរក្សាសីលដោយបំណងថា សូមឲ្យភោគៈទាំង-ឡាយ កើតឡើងដល់អាត្មាអញ ១ បណ្ឌិតគប្បីរក្សាសីលដោយបំណងថា អាត្មាអញ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតឯសុគតិសួគ៌ទេវលោក ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតកាលប្រាថ្នាសេចក្តីសុខ ៣ យ៉ាង នេះឯងគួរតែរក្សាសីល ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះ

ហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា ៖

បណ្ឌិតកាលប្រាថ្នានូវសេចក្ដីសុខ ៣ យ៉ាង គឺសេចក្ដីសរសើរ ១ ការបានទ្រព្យ ១ ការលះលោកនេះហើយរីករាយក្នុងស្ថានសួគ៌ ១ គួរតែរក្សាសីល ។ កាលបើបុគ្គលមិនធ្វើបាបទេ តែទៅសេពគប់នឹងបុគ្គលធ្វើបាប បុគ្គលនោះត្រូវអ្នកផងរង្កៀស ព្រោះអំពើអាក្រក់ផង តំណិះដំនៀលរមែងចម្រើនឡើងដល់បុគ្គលនោះផង ។ បុគ្គលយកបុគ្គលបែបណាជាមិត្តផង សេពគប់នូវមិត្តបែបណាផង បុគ្គលនោះឯងនឹងប្រាកដស្មើដោយមិត្តនោះៗ ព្រោះការនៅរួមនឹងក្លាយទៅជាបែបគ្នានោះពិត ។ បុគ្គលបាប កាលបើបុគ្គលស្អាតដទៃមកសេពគប់ហើយ បុគ្គលបាបត្រូវបុគ្គលស្អាត(នោះ) មកកប់ប្រសព្វហើយ រមែងប្រឡាក់នូវបុគ្គលមកកប់ប្រសព្វ (នោះ) ដែលគេមិនបានប្រឡាក់ (ដោយបាបធម៌) ផង ដូចព្រួញដែលគេលាបថ្នាំពិស កាលប្រឡាក់នូវបំពង់ព្រួញដូច្នោះឯង ។ អ្នកប្រាជ្ញព្រោះខ្លាចការប្រឡាក់ (ដោយបាបធម៌) ទើបមិនយកបុគ្គលបាបជាសំឡាញ់ឡើយ ។ នរជនណាខ្ចប់ត្រីស្អុយដោយចុងស្បូវ ស្បូវក៏មានក្លិនស្អុយផ្សាយ

ចេញទៅ យ៉ាងណាមិញ ការសេពគប់នឹងបុគ្គលពាល ក៏យ៉ាងនោះដែរ ។ នរជនណា ខ្ចប់ខ្ទឹមក្រស្នាដោយស្លឹក-ឈើ ស្លឹកឈើក៏មានក្លិនក្រអូបផ្សាយទៅ យ៉ាងណាមិញ ការសេពនឹងអ្នកប្រាជ្ញក៏យ៉ាងនោះដែរ ។ ហេតុនោះ បណ្ឌិត ដឹងនូវការសម្រេចនៃផលរបស់ខ្លួន ដូចជាកញ្ចប់នៃស្លឹក-ឈើហើយ មិនគប្បីសេពគប់នឹងពួកអសប្បុរសឡើយ គួរ សេពគប់តែនឹងពួកសប្បុរស ។ (ព្រោះ)ពួកអសប្បុរស តែងនាំទៅកាន់នរក ពួកសប្បុរស តែងញ៉ាំងសត្វឲ្យទៅ កាន់ស្ថានសួគ៌ ។

## អដ្ឋកថា

បទថា **សុខានិ** បានដល់ ហេតុនៃសេចក្តីសុខ ។ បទថា **បត្ថយមានោ** សេចក្តីថា សេចក្តីប្រាថ្នា គឺ ចំណង់ប្រាថ្នា ។ បទថា **សីលំ** បានដល់ ទាំងសីលរបស់គ្រហស្ថ និងសីល របស់បព្វជិត អធិប្បាយថា បើជាគ្រហស្ថ ក៏ត្រូវរក្សាសីល របស់គ្រហស្ថ បើជាបព្វជិត ក៏ត្រូវរក្សាចតុប្បារិសុទ្ធិសីល ។ បទថា **រក្ខេយ្យ** សេចក្តីថា សមាទានហើយមិនប្រព្រឹត្តកន្លង

រក្សាទុកដោយល្អនោះឯង ។

បទថា បសំសា មេ អាគច្ឆតុ សេចក្ដីថា អ្នកឆ្លៀវឈ្លាសគឺអ្នកមានបញ្ញាប្រាថ្នាថា សូមកិត្តិសព្ទដែលល្អរបស់យើងចូរមកដល់ដូចនេះ រក្សាសីល ។ អធិប្បាយថា កិត្តិសព្ទដ៏ល្អរបស់គ្រហស្ថអ្នកមានសីល រមែងខ្ចរខ្ចាយទៅក្នុងកណ្ដាលបរិស័ទ ដោយន័យមានជាដើមថា បុត្ររបស់ត្រកូលឯណោះឈ្មោះឯណោះ ជាអ្នកមានសីល មានកល្យាណធម៌ មានសទ្ធាសេចក្ដីជ្រះថ្លាហើយ ជាអ្នកឲ្យ (ទាន) ជាអ្នកបំពេញ (បុណ្យ) ដូចនេះមុន, កិត្តិសព្ទដ៏ល្អរបស់បព្វជិត រមែងខ្ចរខ្ចាយទៅក្នុងកណ្ដាលបរិស័ទ ដោយន័យមានជាដើមថា ភិក្ខុឈ្មោះឯណោះជាអ្នកមានសីល បរិបូរណ៍ដោយវត្ត ស្ងប់ស្ងាត់ នៅរួមដោយសប្បាយ មានសេចក្ដីគោរព មានសេចក្ដីកោតក្រែង ដូចនេះៗសមដូចដែលត្រាស់ទុកថា "ម្នាលគហបតីទាំងឡាយ នៅមានទៀត បុគ្គលមានសីល ឬបរិបូរណ៍ដោយសីលហើយ តែងមានកិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ" ដូច្នេះ ។

ម្យ៉ាងទៀត ដូចដែលត្រាស់ទុកមានជាដើមថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញគប្បីជាទីស្រឡាញ់ ជាទីគាប់ចិត្ត ជាទីគោរព ជាទីសរសើរនៃសព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុនោះ គួរជាអ្នកបំពេញក្នុងសីលទាំងឡាយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា ភោគា មេ ឧប្បជ្ជន្តុ នេះដូចតទៅនេះ មុនដំទៃកាលគ្រហស្ថជាអ្នកមានសីល មានកល្យាណធម៌ គេចិញ្ចឹមជីវិតដោយសិល្បៈ និងសេចក្តីព្យាយាមណាៗ ដូចជាកសិកម្ម ពាណិជ្ជកម្ម បម្រើរាជការ កាលជាដូចនោះ ភោគៈទាំងឡាយដែលមិនទាន់កើត រមែងកើតឡើងដល់គេ និងភោគៈដែលកើតឡើងហើយនឹងដល់សេចក្តីចម្រើនឡើង ព្រោះសេចក្តីជាអ្នកមិនប្រមាទក្នុងសិល្បៈ និងសេចក្តីព្យាយាមនោះ តាមកាលនិងតាមវិធី ។ ចំណែកបព្វជិត កាលបរិបូរណ៍ដោយសីលាចារវត្ត មានប្រក្រតីមិនប្រមាទ មនុស្សទាំងឡាយអ្នកជ្រះថ្លាហើយ ក្នុងការដល់ព្រម

ដោយសីល និងគុណមានសេចក្ដីប្រាថ្នាតិចជាដើម របស់បព្វជិតអ្នកបរិបូរណ៍ដោយសីល នឹងនាំបច្ច័យមកឲ្យដ៏លើស-លប់ កាលជាដូច្នោះ ភោគៈដែលមិនទាន់កើត រមែងកើតឡើងដល់បព្វជិតនោះ និងដែលកើតឡើងហើយក៏នឹងមាំទាំ សមដូចដែលត្រាស់ទុកថា "ម្នាលគហបតីទាំងឡាយ មួយទៀតបុគ្គលមានសីល ឬបរិបូរណ៍ដោយសីល ក្នុងលោកនេះ តែងបាននូវគំនរនៃសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្ដីមិនប្រមាទ" ដូច្នេះ ។ ម្យ៉ាងទៀត បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញ គួរជាបុគ្គលបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារ ដូចនេះសោត ភិក្ខុនោះ គួរជាអ្នកធ្វើឲ្យបរិបូរណ៍ក្នុងសីលទាំងឡាយ ដូច្នេះ ។ ពាក្យដ៏សេសមានន័យដូចពោលហើយទាំងនោះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា បត្ថយានោ បានដល់ បដ្ឋយន្តោ ប្រែថា ប្រាថ្នា ។ បទថា តយោ សុខេ ប៉ុននឹង តីណិ សុខានិ ប្រែថា សេចក្ដីសុខ

៣ ប្រការ ។ បទថា **ចិត្តលាភំ** សេចក្តីថា បានទ្រព្យ អធិប្បាយថា ការកើតឡើងនៃភោគទ្រព្យ ។ ក៏ដោយសេចក្តីផ្សេងគ្នា បណ្តាសេចក្តីសុខទាំង ៣ យ៉ាងនេះ គប្បីជ្រាបថា ទ្រង់កាន់យក **ចេតសិកសុខ** ដោយការសរសើរ **កាយិកសុខ** ដោយភោគៈ, **ឧបបត្តិសុខ** ដោយសព្ទក្រៅនេះ ម្យ៉ាងទៀត គប្បីជ្រាបថា ទ្រង់កាន់យកសុខក្នុងបច្ចុប្បន្ន ដោយសព្ទដំបូង សុខក្នុងសម្បរាយិកភព ដោយសព្ទទី ៣ សុខទាំងពីរយ៉ាង ដោយសព្ទទី ២ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងការវៀរចាកបាបមិត្ត និងការគប់រកកល្យាណមិត្ត ដែលជាហេតុវិសេស របស់ការសរសើរជាដើម ដូចសីលដែលជាហេតុ (ធម្មតា) របស់ការសរសើរជាដើម ព្រមដោយទោស និងអានិសង្ស ទើបត្រាស់ពាក្យមានជាដើមថា អកេរោន្តោ ដូច្នេះ។

បណ្តាបទទាំងនោះ បទថា **សង្កិយោ** សេចក្តីថា គេគប្បីត្រូវរង្កៀសក្នុងព្រោះអំពើអាក្រក់ថា អ្នកនេះធ្វើអាក្រក់មក

ហើយ ឬនឹងធ្វើតទៅជាប្រាកដ ។ ម្យ៉ាងទៀត ព្រោះគេទៅមករកនៅជាមួយមនុស្សអាក្រក់ទាំងឡាយ ។

បទថា អសន្ត សេចក្ដីថា ការពោលទោសសូម្បីមិនមានពិត រមែងរីកទូលាយ គឺដល់សេចក្ដីរីកទូលាយបរិបូរណ៍ បានដល់ ផ្សាយទៅខាងលើ របស់បុគ្គលអ្នកគប់រកមនុស្សអាក្រក់នេះ ឬបុគ្គលនោះ ព្រោះគប់រកសមាគមជាមួយមនុស្សអាក្រក់ជាប្រក្រតី ។ ម្យ៉ាងទៀត បទថា អសន្ត ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ បានសេចក្ដីថា ក្នុងបុគ្គលនោះ ។ បទថា សវេ តាទិសកោ ហោតិ សេចក្ដីថា អ្នកណាគប់និងចូលទៅគប់រកបាបមិត្ត ឬកល្យាណមិត្ត យ៉ាងណា បុគ្គលក៏នឹងជាដូចនោះ គឺមានបាបធម៌ ឬមានកល្យាណធម៌ ដូចជាទឹកដែលស្អាតនឹងមិនល្អ ដោយអំណាចនៃផែនដី។ ព្រោះហេតុអ្វី? ព្រោះការនៅរួមគ្នាជាហេតុឲ្យជាដូចនោះ។ អធិប្បាយថា បានដល់ ការនៅរួមគ្នាជាមួយមនុស្សអាក្រក់ មិនគួរធ្វើ ព្រោះការនៅរួមគ្នា គឺការប្រឡូកប្រឡំគ្នា បានដល់ ការស្និទ្ធស្នាលគ្នា

ជាហេតុឲ្យទទួលយកកិរិយាអាការរបស់អ្នកដែលគប់រក ដែលជាឧបនិស្ស័យរបស់បុគ្គល ដូចកែវផលិក និងកែវមណីដែលនៅរួមគ្នាដូច្នោះ ។

បទថា **សេវមានោ សេវមានំ** សេចក្តីថា មនុស្សអាក្រក់ កាលគប់រកបុគ្គលដទៃដែលបរិសុទ្ធិតាមប្រក្រតី ដែលគប់រកខ្លួននៅរហូតអស់កាលវេលា ឬដែលគេគប់រក (រមែងធ្វើឲ្យគេមិនស្អាត) ។ បទថា **សម្ផុដ្ឋោ សម្ផុសំ** សេចក្តីថា មនុស្សអាក្រក់ដែលបុគ្គលបរិសុទ្ធិតាមប្រក្រតី ពាល់ត្រូវចូលដោយការនៅរួមគ្នា គឺគប់រកសមាគមគ្នា សូម្បីខ្លួនឯង កាលពាល់ត្រូវនៅយ៉ាងនោះ ។ បទថា **សរោ ទុដ្ឋោ កលាបំ វា** សេចក្តីថា ឧបមាដូចថា កូនសរស្រោចគឺប្រឡាក់ថ្នាំពិសនឹងមិនស្អាតបំពង់ព្រួញ គឺដែលរួម (បំពង់) កូនសរសូម្បីដែលមិនស្អាត ដែលខ្លួនពាល់ត្រូវហើយយ៉ាងណា ខ្លួនឯងក៏យ៉ាងនោះ រមែងមិនស្អាតអ្នកដទៃដែលបរិសុទ្ធិដោយប្រក្រតី ព្រោះសេចក្តីអាក្រក់ ។ បទថា **ឧបលេបភយា ធីរោ**

សេចក្តីថា មនុស្សឈ្មោះថា ធីរៈ ព្រោះជាអ្នកបរិបូរណ៍ដោយបញ្ញាគ្រឿងទ្រទ្រង់ចាំ គឺមនុស្សដែលជាបណ្ឌិត មិនគួរមានមនុស្សអាក្រក់ជាសម្លាញ់ ។ បទថា ប្លូតិមច្ឆំ កុសគ្គេន សេចក្តីថា អ្នកណាយកចុងស្បៀងនិងស្មៅ ចងត្រីដែលស្អុយ ដោយជារបស់គួររង្កៀស គឺចងដោយចំណងឲ្យជាកញ្ចប់ ស្បៀងទាំងនោះរបស់អ្នកនោះ សូម្បីមិនស្អុយ ក៏ឈ្មោះថាធំស្អុយ ព្រោះកញ្ចប់ត្រីស្អុយចូលទុក នឹងបញ្ចេញក្លិនស្អុយផ្សាយទៅតែម្តងយ៉ាងណា ។ បទថា ឯវំ ពាលូបសេវនា សេចក្តីថា ការគប់រកសមាគមជាមួយបុគ្គលពាល គប្បីឃើញថា មានឧបមាយ៉ាងនោះ ។ បទថា ឯវំ ធីរូបសេវនា សេចក្តីថា ការគប់រកសមាគមជាមួយបណ្ឌិត របស់អ្នកមិនមានសីលតាមប្រក្រតី រមែងជាហេតុឲ្យក្លិនសីលខ្ចរខ្ចាយទៅ ដោយអំណាចនៃការសមាទានសីលជាដើម ។ ដូចស្លឹកឈើសូម្បីមិនមានក្លិនក្រអូប តែក៏ឈ្មោះថាមានក្លិនក្រអូបខ្ចរខ្ចាយទៅ ព្រោះកញ្ចប់ក្រស្នាទុកដូច្នោះ ។

បទថា **តស្មា** សេចក្ដីថា ព្រោះហេតុដែលការគប់មិត្ត ដែលមិនល្អ មានទោសដូចនេះ និងការគប់មិត្តដែលល្អ មាន អានិសង្សយ៉ាងនេះ គឺដូចនេះ ដូច្នោះ បណ្ឌិតដឹងផលរបស់ខ្លួន ដោយការប្រៀបធៀបប្រៀបប្រហល់គ្នា នៃវត្ថុដែលមានក្លិនស្អុយនិងក្លិន- ក្រអូប និងការគប់រកសមាគមជាមួយមនុស្សល្អនិងមនុស្ស- មិនល្អ ដូចកញ្ចប់ (ត្រីស្អុយនិងក្រស្នា) ដោយស្លឹកឈើ គឺដូចកញ្ចប់ត្រីស្អុយនិងក្រស្នា (ដោយស្លឹកឈើ) ។ បទថា **ញត្វា សម្បាកមត្តនោ** សេចក្ដីថា បណ្ឌិតដឹងគឺជ្រាបសេចក្ដី សម្រេចផលរបស់ខ្លួនដែលមានទុក្ខជាកម្រៃ និងមានសុខជា កម្រៃហើយ មិនគួរគប់រកអសប្បុរស គឺមិត្តអាក្រក់ គួរសេព គប់តែសប្បុរសគឺបណ្ឌិតអ្នកស្ងប់រម្ងាប់ហើយ អ្នកដែលទោស ខ្ចាក់ចោលហើយ ឬអ្នកដែលអ្នកប្រាជ្ញសរសើរហើយ ។ សមដូចព្រះមានព្រះភាគ ត្រាស់ទុកថា អសប្បុរស នាំទៅ កាន់នរក ចំណែកសប្បុរសឲ្យដល់សុគតិ ។

ព្រោះដូចនោះ ព្រះមានព្រះភាគ គ្រាទ្រង់សម្ដែងហេតុនៃ

សេចក្ដីសុខ ៣ យ៉ាង តាមដែលពោលមកហើយ ដោយគាថាដំបូង ហើយទ្រង់សម្ដែងហេតុជាទីមកនៃសេចក្ដីសុខ សេចក្ដីសរសើរ ព្រមដោយការវៀរធម៌ដែលជាបដិបក្ខ (ចំពោះសេចក្ដីសុខ) ដោយព្រះគាថា ៥ គាថា តអំពីនោះហើយ ទើបទ្រង់សម្ដែងសេចក្ដីសុខចុងបំផុត ព្រមដោយហេតុជាទីប្រសព្វសេចក្ដីសុខសួម្បីទាំង ៣ យ៉ាង ដោយព្រះគាថាចុងបំផុត ។

ចប់ អដ្ឋកថា សុខសូត្រទី ៧ ។

## ៧-បញ្ចបុព្វនិមិត្តសូត្រ

(សុត្តន្តបិដក លេខ៥៣ ទំព័រ១០២)

ម្នាលភិក្ខុទាំងឡាយ ទេវតាមានការច្យុតជាធម្មតា ចាកពួកទេវតា ក្នុងកាលណា បុព្វនិមិត្ត ៥ យ៉ាង តែងកើតឡើងប្រាកដដល់ទេវតានោះ (ក្នុងកាលនោះ) គឺកម្រងផ្កាទាំងឡាយស្វិតស្រពោន ១ សំពត់ទាំងឡាយសៅហ្មង ១ ញើសទាំងឡាយតែងហូរចេញអំពីក្លៀក ១ សម្បុរមិនល្អតាំងឡើងក្នុងកាយ ១ ទេវតាមិនត្រេកអរក្នុងទេវាសនៈរបស់ខ្លួន ១ ។

ម្នាលភិក្ខុទាំងឡាយ ទេវតាទាំងឡាយ តែងដឹងនូវបុព្វនិមិត្ត នោះថា ទេវបុត្តនេះ មានការច្យុតជាធម្មតា ហើយក៏អនុមោទនា ដោយវាចា ៣ បទថា ម្នាលអ្នកដ៏ចម្រើន សូមអ្នកច្យុតអំពី ទេវលោកនេះ ទៅកាន់សុគតិចុះ លុះអ្នកទៅកាន់សុគតិហើយ សូមឲ្យមានលាភដែលបានដោយងាយចុះ លុះមានលាភដែល បានដោយងាយហើយ សូមតាំងនៅដោយប្រពៃចុះ ។

កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុ ១ រូប ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គ ដ៏ចម្រើន ចុះអ្វីហៅថា ដំណើរទៅកាន់សុគតិរបស់ទេវតាទាំង-ឡាយ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហៅថាលាភដែលបានដោយ ងាយរបស់ទេវតាទាំងឡាយ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហៅថា ការតាំងនៅដោយប្រពៃនៃទេវតាទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ ភាពនៃមនុស្ស (នេះ) ឯង ដែល ហៅថា ដំណើរទៅកាន់សុគតិ របស់ទេវតាទាំងឡាយ លុះបាន កើតជាមនុស្សហើយបានចំពោះនូវសទ្ធា ក្នុងធម្មវិន័យណា ដែលតថាគតសម្ដែងហើយ ម្នាលភិក្ខុទាំងឡាយ ការបាននូវ

សទ្ធានេះឯង ហៅថា លាភដែលបានដោយងាយ របស់ទេវតាទាំងឡាយ ឯសទ្ធារបស់គេនោះ ជាសទ្ធាខ្ជាប់ខ្ជួនកើតជាឫសគល់តាំងនៅមាំមួន ដែលបុគ្គលណាមួយ ទោះជាសមណៈ ឬព្រាហ្មណ៍ ឬទេវតា ឬមារ ឬព្រហ្ម ក្នុងលោក មិនអាចនឹងនាំយកទៅបាន ម្នាលភិក្ខុទាំងឡាយ ការតាំងមាំនៃសទ្ធានេះឯង ហៅថា ការតាំងនៅដោយប្រពៃរបស់ទេវតាទាំងឡាយ ។

ទេវតាច្យុតចាកពួកទេវតា ព្រោះអស់ទៅនៃអាយុ ក្នុងកាលណា សំឡេង ៣ យ៉ាង របស់ពួកទេវតា កាលអនុមោទនា តែងលាន់ឮឡើង (ក្នុងកាលនោះ) ថា ម្នាលអ្នកដ៏ចម្រើន សូមអ្នកច្យុតអំពីទេវលោកនេះ ទៅកាន់សុគតិ ជាមួយនឹងពួកមនុស្សចុះ លុះអ្នកបានកើតជាមនុស្សហើយ សូមឲ្យបាននូវសទ្ធាដ៏ប្រសើរ ក្នុងព្រះ-សទ្ធម្មចុះ ក៏សទ្ធារបស់អ្នកនោះ ជាសទ្ធាខ្ជាប់ខ្ជួន ដែលបានជាឫសគល់ តាំងនៅមាំមួន ក្នុងព្រះសទ្ធម្មដែលតថាគតសម្តែងហើយដោយប្រពៃ ដែលបុគ្គលណាមួយ

មិនអាចនាំយកទៅបានដរាបអស់ជីវិត ។ អ្នកត្រូវលះកាយទុច្ចរិត លះវចីទុច្ចរិត លះមនោទុច្ចរិត លះអំពើដទៃដែលប្រកបដោយទោសផង ធ្វើកុសលដោយកាយ ធ្វើកុសលដោយវាចា ធ្វើកុសលដោយចិត្តឲ្យច្រើន ប្រមាណមិនបាន បរិសុទ្ធ មិនមានគ្រឿងសៅហ្មង ។ លំដាប់នោះអ្នកប្រាជ្ញត្រូវធ្វើបុណ្យដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ននោះឲ្យច្រើនដោយទាន ហើយញុំាងពួកសត្វដទៃ ឲ្យតាំងនៅក្នុងព្រះសទ្ធម្ម ដែលជាព្រហ្មចរិយៈ ទេវតាទាំងឡាយដឹងច្បាស់នូវទេវតាកាលច្យុត ក្នុងកាលណា ក៏អនុមោទនា (ក្នុងកាលនោះ) ដោយសេចក្តីអនុគ្រោះនេះថាម្នាលទេវតា ចូរអ្នកមកឲ្យរឿយៗ ។

## អដ្ឋកថា បញ្ចបុព្វនិមិត្តសូត្រ

បទថា **យទា** ប្រែថា ក្នុងកាលណា ។ បទថា **ទេវោ** បានដល់ ទេវតាពួកឧបបត្តិទេព ។ ក៏ទេវតាមាន ៣ គឺ សម្មតិទេព ១ ឧបបត្តិទេព ១ វិសុទ្ធិទេព ១ ។ ក្នុងទេវតាទាំង ៣

ពួកនោះ ក្សត្រដែលជាព្រះរាជាទាំងឡាយ ឈ្មោះថា សម្មតិទេព ទេវតាដែលខ្ពស់ជាងនោះឡើងទៅ ចាប់ផ្ដើមតាំងពីទេវតាជាន់ចាតុម្មហារាជិកាជាដើម ឈ្មោះថា ឧបបត្តិទេព ។ ព្រះខីណាស្រព ឈ្មោះថា វិសុទ្ធិទេព ។ តែក្នុងព្រះសូត្រនេះ ទ្រង់ប្រាថ្នាយកទេពជាន់កាមាវចរ ។ ដោយហេតុនោះ ខ្ញុំទើបពោលថា បទថា **ទេវោ** បានដល់ **ឧបបត្តិទេព** ។

បទថា **ទេវកាយា** សេចក្ដីថា ចាកជំនុំនៃទេវតា ឬអំពីកន្លែងនៃទេវតា, អធិប្បាយថា ចាកទេវលោក ។ ព្រោះថា **កាយ** សព្ទនេះ ចែកបានដល់ការនៅជាមួយគ្នាជាក្រុម ។ បទថា **ចវនធម្មោ** មានសេចក្ដីថា មានការស្លាប់ជាធម្មតា អធិប្បាយថា មានមរណៈប្រាកដហើយ ព្រោះអស់អាយុ ឬព្រោះអស់បុណ្យ ។

បទថា **បញ្ចស្ស បុព្វនិមិត្តានិ បាតុភវន្តិ** មានសេចក្ដីថា បុព្វនិមិត្តនៃសេចក្ដីស្លាប់ ៥ ប្រការ រមែងកើតឡើង ឬប្រាកដដល់ទេវតានោះ អ្នកមានមរណៈប្រាកដហើយ ។ បទថា **មាលា**

**មិលាយន្តិ** មានសេចក្តីថា ផ្កាឈើដែលទេវបុត្តនោះប្រដាប់ស្រពោន អស់ភាពស្រស់ស្អាត ដូចបោះទៅក្នុងកំដៅថ្ងៃ ក្នុងវេលាថ្ងៃត្រង់ ។ បទថា **វត្ថានិ កិលិស្សន្តិ** មានសេចក្តីថា (អាករណៈគឺ) សំពត់ដែលទេវតានោះស្លៀកដណ្តប់ហើយ មានពណ៌ដូចព្រះអាទិត្យស្រទន់អស្តង្គត់ ដែលចែងចាំងរស្មីនៅក្នុងអាកាសដែលប្រាសចាកពពកក្នុងសរទសម័យ មានពណ៌ផ្សេងៗ ស្បើយចុះ មិនចិញ្ចាំងចិញ្ចែង សៅហ្មង ដូចត្រូវបោះចុះទៅក្នុងភក់ហើយញាំញីក្នុងខណៈនោះឯង ។ បទថា **កច្ឆេហិ សេទា មុច្ចន្តិ** មានសេចក្តីថា ក្នុងខណៈនោះញើសក្លៀក ហូរចេញអំពីក្លៀកទាំងពីរខាង ទេវបុត្តដែលមានរាងកាយប្រាសចាកញើសក្អែលមកពីពេលមុន ដូចកែវមណីដោយកំណើតដែលបរិសុទ្ធល្អ នឹងដូចជារូបមាសដែលអ្នកសិប្បៈជាអ្នកជំនាញកាត់តែងហើយ ក៏មិនមែនហូរចេញអំពីក្លៀកតែម្យ៉ាងប៉ុណ្ណោះ សូម្បីតែញើសក៏ហូរចេញអំពីសរីរៈទាំងអស់ របស់ទេវបុត្តនោះ កាយរបស់ទេវបុត្តដូចជាធូន់ដោយបណ្តាញ ដែលប្រដាប់ទៅដោយបណ្តាញមុក្តា ដែលខ្ជូនប្រដាប់ហើយ ។

បទថា **កាយេទុព្វណ្ណិយំ ឱក្កន្តិ** សេចក្តីថា ចាប់ផ្តើមអំពីបដិសន្ធិ រាងកាយនឹងផ្សាយរស្មីទៅក្នុងទីប្រមាណ ១ យោជន៍ខ្លះ ២ យោជន៍ខ្លះ ដរាបដល់ប្រមាណ ១២ យោជន៍ខ្លះ តាមអានុភាព(របស់ខ្លួន) នឹងប្រាសចាកជរាភាព មានធ្មេញបាក់និងស្បែកជ្រួញជាដើម ការរង៉ា ការក្តៅ ក៏មិនអាចចូលទៅប៉ះខ្ទប់ ប្រៀបដូចទេពធីតាក្រមុំអាយុ ១៦ ឆ្នាំ និងដូចជាទេវបុត្តកំលោះអាយុ ២០ ឆ្នាំ (តែ) ក្នុងខណៈនោះឯង សេចក្តីប្រែប្រួលនៃរាងកាយ នឹងចូលមកជំនួស គឺស្ថិតនៅក្នុងកាយដែលអស់រស្មី អស់តេជ ។ បទថា **សកេ ទេវោ ទេវាសនេ នាភិរមតិ** មានសេចក្តីថា នឹងមិនត្រេកអរ គឺមិនបានរីករាយចិត្តក្នុងទិព្វាសនៈ សម្រាប់កំសាន្តលេងនិងសម្រាប់បម្រើ ជាមួយពួកទេពអប្សររបស់ខ្លួន ។

បានឮថា សេចក្តីស្លាប់នឹងមានដល់ទេវបុត្តនោះ ដោយ ៧ ថ្ងៃទៀត ដោយការរាប់ថ្ងៃរបស់មនុស្ស ព្រោះដូច្នោះបុព្វនិមិត្តនេះ ទើបប្រាកដដោយការកើតឡើងនៃបុព្វនិមិត្តនោះ

ទេវបុត្តនោះ រមែងត្រូវសេចក្ដីសោកដ៏មានកម្លាំងគ្របសង្កត់ដោយគិតថា យើងត្រូវប្រាសចាកអំពីសម្បត្តិមានសភាពបែប-នេះ ។ ដោយហេតុនេះ សេចក្ដីខ្វល់ខ្វាយយ៉ាងធំក្រៃលែងកើតឡើងក្នុងកាយរបស់ទេវបុត្តនោះ ដោយហេតុនោះ ញើសទើបហូរចេញអំពីដងខ្លួនដោយប្រការទាំងពួង ។ ទេវបុត្តអង្គខ្លះដែលមានទុក្ខមិនសន្សំជុំវិញហើយអស់កាលយូរ កាលមិនអាចនឹងគ្របសង្កត់ទុក្ខនោះទុកបាន ក៏កន្ទក់កន្ទេញ ខ្សឹកខ្សួលថា "យើងក្ដៅៗ" មិនមានសេចក្ដីរីករាយក្នុងទីណាៗ ពោល-រៀយៗ រវើរវាយ ត្រាច់ទៅក្នុងទីនោះៗ ។ អង្គខ្លះតាំងសតិបានសូម្បីមិនបានសម្ដែងការខុសប្រក្រតីតាមផ្លូវកាយវាចា កាលអត់សង្កត់នូវសេចក្ដីទុក្ខ គឺការព្រាត់ប្រាសរបស់ជាទីស្រឡាញ់មិនបាន នឹងក្ដៅក្រហាយហើយត្រាច់ទៅ ។

បុព្វនិមិត្តទាំងនេះ រមែងប្រាកដចំពោះទេវតាដែលជាធំទាំងឡាយប៉ុណ្ណោះ ដូចនិមិត្តទាំងឡាយ មានឧក្កាបាត (គប់-ភ្លើងដែលធ្លាក់ពីអាកាស) ញ័រផែនដី និងចន្ទគ្រាសជាដើម នឹង

ប្រាកដដល់អ្នកមានបុណ្យធំក្នុងលោក ដូចព្រះរាជា និងរាជ-អាមាត្យជាដើម មិនប្រាកដដល់មនុស្សទូទៅទេ ។ ក៏ទេវតាពួកខ្លះ ដឹងនិមិត្តនោះដែលកើតហើយថា និមិត្តទាំងនេះ ឈ្មោះថា ជាបុព្វនិមិត្តនៃមរណៈ មិនមែនដឹងគ្រប់អង្គនោះទេ ចំពោះទេវបុត្តទាំងនោះ ទេវបុត្តដែលកើតដោយកុសលធម៌ទន់ខ្សោយ ក៏ភ័យខ្លាចថា ឥឡូវនេះ នណាទឹងដឹងថា យើងនឹងកើតក្នុងទីណា ? ចំណែកពួក(ទេវតា)ដែលមានបុណ្យច្រើន ក៏មិនខ្លាចមិនញាប់ញ័រ ដោយគិតថា យើងបានឲ្យទាន បានរក្សាសីលបានសន្សំបុណ្យទុកមកច្រើនហើយ យើងច្យុតអំពីទេវលោកនេះហើយ ប្រាកដបានសុគតិតែម្តង ។ ក៏ទេវតាទាំងឡាយកាលកាន់យកនិមិត្តដែលប្រាកដឡើងយ៉ាងនេះហើយ រមែងចូលទៅកាន់សួននន្ទនវ័ន សួននន្ទនវ័នដែលមានប្រចាំនៅក្នុងទេវលោកគ្រប់ជាន់នោះឯង ។

បទថា **តីហិ វាចាហិ អនុមោទន្តិ** សេចក្តីថា ទេវតាទាំង-ឡាយរមែងអនុមោទនា ដោយពាក្យទាំង ៣ ដែលខ្ញុំនឹងពោល

ក្នុងកាលឥឡូវនេះ គឺរមែងញុំាងសេចក្ដីត្រេកអរ រីករាយចិត្ត ឲ្យកើតឡើង រមែងឲ្យសប្បាយចិត្ត ឬធ្វើការរីករាយដ៏សមគួរដល់សភាពការណ៍ក្នុងខណៈនោះ ដោយអំណាចនៃការសប្បាយចិត្តនោះ ។ ចំណែកអាចារ្យពួកខ្លះ ពោលសេចក្ដីរបស់បទថា **អនុមោទន្តិ** ជា **ឱវទន្តិ** ។ បទថា **ឥតោ** សេចក្ដីថា ចាកទេវលោក ។ បទថា **ភោ** ជាអាលបនៈ ។ បទថា **សុគតឹ** បានដល់ គតិដែលល្អ អាចារ្យទាំងឡាយពោលសំដៅដល់មនុស្សលោក ។ បទថា **គច្ឆ** មានសេចក្ដីថា ចូលដល់ ដោយអំណាចនៃការបដិសន្ធិ ។

បទថា **ឯវំ វុត្តេ** មានសេចក្ដីថា កាលព្រះមានព្រះភាគត្រាស់ដល់ពាក្យសំដី ដែលទេវតានោះនឹងគប្បីពោលដល់ទេវបុត្តនោះ ដោយន័យមានជាដើមថា លោកច្យុតចាកទេវ-លោកនេះហើយ ចូលទៅកាន់សុគតិចុះ ក្នុងគ្រានោះយ៉ាងនេះ។ ភិក្ខុណាមួយរូប ដែលមិនប្រាកដដោយនាមនិងគោត្រ អង្គុយនៅក្នុងបរិស័ទនោះ ជាអ្នកឈ្លាសក្នុងអនុសន្ធិ បានក្រាបទូល

ពាក្យមានជាដើមថា **កិន្នុ ខោ ភន្តេ** (បពិត្រព្រះអង្គដ៏ចម្រើន ចុះអ្វី) នេះ ដោយបំណងថា ព្រះមានព្រះភាគ ត្រាស់សុគតិទាំងនេះទុកដោយមិនប្លែកគ្នា មិនជាក់ច្បាស់ឡើយ កុំដូច្នោះឡើយ យើងនឹងអារាធនាឲ្យព្រះអង្គ ត្រាស់សុគតិជាដើមនោះឲ្យជាក់ច្បាស់ (ជាងនេះទៀត) ភាពជាមនុស្សដែលទេវតាទាំងឡាយបំណងក្រៃលែង ដោយហេតុនៃការបានចំពោះគុណវិសេស មានសទ្ធាជាដើម និងនៃការចូលដល់ភាពជាទេវតា ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា "**មនុស្សត្តំ ខោ ភិក្ខវេ ទេវានំ សុគតិគមនសង្ខាតំ** : ម្នាលភិក្ខុទាំងឡាយ ភាពនៃមនុស្ស(នេះ)ឯង ដែលហៅថា ដំណើរទៅកាន់សុគតិរបស់ទេវតាទាំងឡាយ" ដូច្នេះ ។

បទថា **សុគតិគមនសង្ខាតំ** មានសេចក្តីថា ដែលព្រះមានព្រះភាគ ត្រាស់ទុកហើយដោយប្រពៃថា ទៅកាន់សុគតិ អធិប្បាយថា ទ្រង់សរសើរ គឺសរសើរហើយ ។ បទថា **យំ** ក្នុងពាក្យថា **យំ មនុស្សភូតោ** នេះ ជាកិរិយាបរាមាស ។ ដោយ

បទថា **យំ** នោះលោកបំណាងដល់កិរិយា គឺការបានចំពោះ, ក្នុងបទថា **បដិលភតិ** នេះ អធិប្បាយថា បានចំពោះនូវសទ្ធា ។ បទថា **មនុស្សភូតោ** មានសេចក្ដីថា កើតហើយក្នុងមនុស្សទាំងឡាយ, ម្យ៉ាងទៀត បានដល់ភាពជាមនុស្ស ។ ព្រោះហេតុដែលអ្នកដែលកើតក្នុងទេវលោក ដោយលំបាក ដោយច្រើនបានស្ដាប់ព្រះធម្មទេសនារបស់ព្រះតថាគតជាម្ចាស់, មិនដូចមនុស្សទាំងឡាយ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **មនុស្សភូតោ** ដូច្នេះ ។ បទថា **តថាគតប្បវេទិតេ ធម្មវិនយេ** សេចក្ដីថា ក្នុងពាក្យប្រៀនប្រដៅដែលសង្គ្រោះដោយសិក្ខា ៣ ដែលព្រះតថាគត គឺព្រះមានព្រះភាគ ទ្រង់សម្ដែងហើយ ។

ព្រោះថា ពាក្យប្រៀនប្រដៅនេះ លោកហៅថា **ធម្មវិន័យ** ព្រោះឈ្មោះថា **ធម្ម** ហេតុដែលមិនប្រាសចាកទៅអំពីធម៌, និងឈ្មោះថា **វិន័យ** ព្រោះទូន្មានវេនេយ្យសត្វ តាមសមគួរដល់អធ្យាស្រ័យ ។ ម្យ៉ាងទៀត លោកហៅថា **ធម្មវិន័យ** ព្រោះ

ណែនាំបុគ្គលអ្នកមានកំណើត អ្នកមានធូលីតិចក្នុងភ្នែក ដែលឈ្មោះថា ជាធម៌ ព្រោះមិនប្រាសចាកទៅអំពីធម៌ ហេតុដែលបរិបូរណ៍ទៅដោយឧបនិស្ស័យ ។ ម្យ៉ាងទៀត លោកហៅថា **ធម្មវិន័យ** ព្រោះទូន្មានដោយធម៌តែម្យ៉ាង មិនមែនទូន្មានដោយដំបងនិងសស្ត្រា ។ ម្យ៉ាងទៀត លោកហៅថា **ធម្មវិន័យ** ព្រោះការទូន្មាននោះប្រកបដោយធម៌ ។ ម្យ៉ាងទៀត លោកហៅថា **ធម្មវិន័យ** ព្រោះនាំចូលទៅរកធម៌ ដើម្បីមគ្គផល និងនិព្វានតាមលំដាប់, ម្យ៉ាងទៀត លោកហៅថា **ធម្មវិន័យ** ព្រោះជាគ្រឿងណែនាំដែលប្រព្រឹត្តទៅហើយដោយធម៌ មានមហាករុណា និងព្រះសព្វញ្ញុតញ្ញាណជាដើម ។ ម្យ៉ាងទៀត លោកហៅថា **ធម្មវិន័យ** ព្រោះព្រះធម៌ជាគ្រឿងនាំចូលទៅរកធម៌របស់ព្រះមានព្រះភាគ ដែលជាអគ្គធម៌ ជាធម្មកាយ ជាធម្មស្សាមី មិនមែននាំចូលទៅរកធម៌នៃអ្នកតក្កវិជ្ជា[១]ទាំងឡាយ ។

---

១ វិជ្ជាត្រិះរិះ គឺចំណេះខាងពិចារណារិះរកហេតុផល ដែលប្លែកឱ្យឃើញប្រាកដដោយគំនិតខ្លួនឯង ។

ម្យ៉ាងទៀត លោកហៅថា **ធម្មវិន័យ** ព្រោះជាគ្រឿងណែនាំដែលប្រព្រឹត្តហើយក្នុងធម៌ គឺ មគ្គផល ឬក្នុងធម៌ ដែលជាវិស័យដែលនឹងគប្បីឲ្យសម្រេច ។ ក្នុងធម្មវិន័យនោះ ។

បទថា **សទ្ធំ បដិលភតិ** មានសេចក្ដីថា ញុំាងសទ្ធាឲ្យកើតឡើងដោយន័យមានជាដើមថា **ស្វាក្ខាតោ ភគវតា ធម្មោ** (ធម៌ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សម្ដែងល្អហើយ) អធិប្បាយថា អ្នកមានសទ្ធា កាលបដិបត្តិក្នុងធម្មវិន័យនេះ តាមដែលទ្រង់ប្រៀនប្រដៅទុក រមែងញុំាងចិត្តឲ្យត្រេកអរក្នុងទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍ ។ ក្នុងបទថា **សុលទ្ធលាភសង្ខាតំ** នេះ មានអធិប្បាយថា កាលប្រើប្រាក់ មាស ស្រែ និងចម្ការជាដើម រមែងនាំសេចក្ដីសុខ ក្នុងការប្រើប្រាស់មកឲ្យសព្វសត្វ ហាមឃាត់សេចក្ដីទុក្ខមានការឃ្លាននិងការស្រេកជាដើម បន្ទោបង់នូវការទាល់ក្រ(ខ្វះខាត)ទ្រព្យចេញបាន, ជាហេតុឲ្យបាននូវរតនៈ មានកែវមុក្តាជាដើម និងនាំមកនូវសន្តិសុខក្នុងលោកឲ្យ,

យ៉ាងណា សូម្បីសទ្ធាដែលជាលោកិយៈ និងលោកុត្តរក៏ដូច្នោះ នឹងនាំវិបាកសុខដែលជាលោកិយៈ និងលោកុត្តរមកឲ្យ តាមដែលកើតឡើង និងហាមឃាត់ទុក្ខមានជាតិ ជរាជាដើមចេញបាន នឹងរម្ងាប់ការខ្វះខាតនូវគុណធម៌ចេញបាន នឹងជាហេតុឲ្យបានទទួលនូវរតនៈ មានសតិសម្ពោជ្ឈង្គជាដើម នឹងនាំមកនូវសន្តិសុខក្នុងលោក ដល់ពួកជនអ្នកបដិបត្តិ ដោយសទ្ធាធុរៈ ។ សមពិតដូចព្រះមានព្រះភាគត្រាស់ទុកថា ៖

**សទ្ធោ សីលេន សម្បន្នោ យសោ ភោគសមប្បិតោ**
**យំ យំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។**

បុគ្គលមានសទ្ធា បរិបូរណ៍ដោយសីល ស្កប់ស្កល់ដោយយសនិងភោគៈ នៅក្នុងប្រទេសណាៗ ក៏ជាអ្នកដែលបូជាហើយក្នុងប្រទេសនោះៗ តែម្តង ដូច្នោះ ។

គប្បីជ្រាបនូវការបានដោយចំពោះនូវសទ្ធា ជាលាភដែលបុគ្គលបានដោយល្អ ដូចពណ៌នាមកនេះ ។

ក៏ព្រោះហេតុនៃការបានចំពោះនូវសទ្ធានេះ ជាលាភដែល

ជាប់តាមខ្លួនទៅ មិនទូទៅដល់ជនដទៃ ជាហេតុឲ្យបានសម្បត្តិគ្រប់យ៉ាង នឹងជាហេតុនៃការបាននូវលោកិយទ្រព្យ មានមាសប្រាក់ជាដើម អធិប្បាយថា អ្នកមានសទ្ធាប៉ុណ្ណោះ នឹងធ្វើបុណ្យមានទានដើមបាន ហើយនឹងជួបប្រសព្វទ្រព្យដែលជាឧបករណ៍គ្រឿងរីករាយនៃចិត្តដ៏លើសលុប នឹងញុំាងប្រយោជន៍ខ្លួនឯងនិងប្រយោជន៍អ្នកដទៃនោះឯង ឲ្យដល់ព្រមដោយបុណ្យនោះ តែបុណ្យទាំងនោះ នឹងមិនផ្ដល់ប្រយោជន៍ទាំងក្នុងលោកនេះនិងលោកខាងមុខ ដល់អ្នកមិនមានសទ្ធាឡើយ ។ គប្បីជ្រាបសទ្ធាជាលាភដែលបានដោយល្អ ដោយប្រការដូចពណ៌នាមកនេះ ។ ពិតយ៉ាងនោះ លោកពណ៌នាសទ្ធាទុក ដោយហេតុមិនមែនតិច ក្នុងឋានៈផ្សេងៗគ្នាថា "សទ្ធា ពន្ធតិ បាថេយ្យំ : សទ្ធារួបរួមទុកនូវស្បៀង"១ៈ "សទ្ធា ទុតិយា បុរិសស្ស ហោតិ : សទ្ធាជាសម្លាញ់ទីពីររបស់បុរស"២ៈ "សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ : សទ្ធាជាទ្រព្យដ៏ប្រសើររបស់បុរស ក្នុងលោក"៣ៈ "សទ្ធាហត្ថោ មហានាគោ : ដំរីដ៏ប្រសើរមានសទ្ធា

ជាប្រមោយ”ខ្វះ “**សទ្ធា ពីជំ តបោ វុដ្ឋិ** : សទ្ធាជាពូជ ជាតបះ ជាភ្លៀង”ខ្វះ “**សទ្ធសិកោ ភិក្ខវេ អរិយសាវកោ** : ម្នាល ភិក្ខុទាំងឡាយ អរិយសាវកស្ថិតនៅក្នុងសទ្ធា”ខ្វះ “**សទ្ធាយ តរតិ ឱឃំ** : រមែងឆ្លងឱឃៈបានដោយសទ្ធា”ខ្វះ ដូច្នេះ ។

ឥឡូវនេះ ព្រះមានព្រះភាគ ត្រាស់ពាក្យមានជាដើមថា **សា ខោ បនស្ស** ដូច្នេះ ដើម្បីនឹងទ្រង់សម្ដែងដល់សទ្ធាប្រភេទដែលឈានចុះជ្រៅដែលជាហេតុឲ្យឈ្មោះថា ជាអ្នកតម្កល់នៅមាំក្នុងកុសលធម៌ ក្នុងព្រះសាសនា ។

បណ្ដាបទទាំងនោះ បទថា **អស្ស** នេះ មានសេចក្ដីថា ស្មើគ្នានឹង **ភវេយ្យ** ប្រែថា គប្បីកើត ។ បទថា **និវិដ្ឋា** មានសេចក្ដីថា តាំងមាំ គឺជ្រែកចូលទៅកាន់សន្ដាចិត្ត ។ បទថា **មូលជាតា** បានដល់ មានឫសគល់កើតហើយ ។ សួរថា អ្វីឈ្មោះថា ជាឫសរបស់សទ្ធា ? ឆ្លើយថា ការធ្វើទុកក្នុងចិត្តដោយឧបាយ ដែលជាហេតុនៃការជឿ ក្នុងវត្ថុដែលគួរជឿ ជាឫសគល់របស់ សទ្ធា ។ម្យ៉ាងទៀត គប្បីជ្រាបអង្គនៃសោ-

តាបត្តិមគ្គ ៤ យ៉ាងគឺ ការសេពគប់សប្បុរស ១ ការស្តាប់ធម៌ (របស់សប្បុរស) ១ ការធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនង ១ ការបដិបត្តិធម៌ដ៏សមគួរដល់ធម៌ ១ ជាជាឫសគល់នៃសទ្ធា ។ បទថា **បតិដ្ឋិតា** បានដល់ ឈានចុះហើយជាភាវៈដែលនណាៗឲ្យញាប់ញ័រមិនបាន ព្រោះសម្រេចអរិយមគ្គ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **ទលឡ្ហា អសំហារិយា** ដូច្នេះ ។ បទថា **ទឡ្ហា** ប្រែថា មាំមួន ។ បទថា **អសំហារិយា** សេចក្តីថា ជាវត្ថុដែលនណាៗ មិនអាចដើម្បីនឹងនាំទៅបាន ឬឲ្យវិនាសទៅ ឬនាំចេញទៅបាន ។

ទេវតាទាំងនោះ ប្រាថ្នាឲ្យទេវបុត្តនោះ បានសម្រេចសោតាបត្តិផល ទើបពោលយ៉ាងនេះ ដោយប្រការដូច្នេះ ។ ព្រោះថា ទេវតាទាំងនោះ ប្រាថ្នាព្រះអរិយបុគ្គលអ្នកសមគួរដល់ការចូលទៅសោយកាមសុខ ក្នុងទេវលោករបស់ខ្លួនប៉ុណ្ណោះ ។ ដោយហេតុនោះ លោកទើបពោលថា “**ឯហិ ទេវ បុនប្បុនំ :** ម្នាលទេវតា អ្នកចូលមករឿយៗ” ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះតទៅ : សូម្បីការស្លាប់ព្រោះអស់បុណ្យ រមែងមានបានដោយការចូលទៅកាត់ផ្តាច់នៃជីវិតិន្ទ្រិយ៍ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា "**ចវតិ អាយុសង្ខយា** : រមែងច្យុតព្រោះអស់អាយុ" ។ បទថា **អនុមោទតំ** មានសេចក្តីថា អ្នកអនុមោទនា ។ បទថា **មនុស្សានំ សហព្យតំ** បានដល់ ភាពជាអ្នកនៅរួមជាមួយមនុស្សទាំងឡាយ ។ ឈ្មោះថា **សហព្យៈ** ព្រោះអត្ថថា នៅរួមបានដល់ ប្រព្រឹត្តទៅជាមួយគ្នា ភាវៈនៃសហព្យៈនោះ ឈ្មោះថា **សហព្យតា** ។ បទថា **និវិដ្ឋស្ស** មានសេចក្តីថា គប្បីជាគុណជាតិតាំងមាំ ។ បទថា **យាវជីវំ** សេចក្តីថា ដរាបការប្រព្រឹត្តិទៅនៃជីវិត, អធិប្បាយថា ដរាបដល់បរិនិព្វាន ។ បទថា **អប្បមាណំ** មានសេចក្តីថា វៀរចាកប្រមាណ ដោយអំណាចនៃការធ្វើឲ្យច្រើន ឲ្យឱឡារិក និងធ្វើឲ្យច្រើនគ្រា ដោយសេចក្តីគោរព ។ បទថា **និរុបធី** សេចក្តីថា វៀរចាកឧបធិគឺកិលេសូបធិ អធិប្បាយថា បរិសុទ្ធយ៉ាងក្រៃលែង គឺ

ប្រាសចាកមន្ទិលនិងទោស ។

ក៏ព្រោះហេតុដែលទេវតាទាំងនោះ មិនប្រាថ្នាមហគ្គតកុសល ព្រោះនៅមិនទាន់ចង់រួចផុតទៅអំពីកាមលោក រមែងប្រាថ្នាចំពោះបុណ្យដែលជាកាមាវចរតែម្យ៉ាង ដូច្នោះ ក្នុងព្រះសូត្រនេះ គប្បីជ្រាបសេចក្ដីយ៉ាងនេះថា លោកច្យុតចាកទេវលោកនេះហើយ កើតក្នុងពួកមនុស្ស ដឹងក្ដីហើយ លះទុច្ចរិតគ្រប់យ៉ាងមានកាយទុច្ចរិតជាដើម សន្សំសុចរិតទាំងពួង មានកាយសុចរិតជាដើម ឲ្យឧឡារិក ឲ្យពេញបរិបូរណ៍ ហើយចូរជាអ្នកមានសទ្ធា ដែលមកហើយដោយអរិយមគ្គ ។ ក៏ព្រោះហេតុដែលទេវតាទាំងនោះ នៅប្រាថ្នាបឋមមគ្គខ្លះ ទុតិយមគ្គខ្លះ ក្នុងលោកុត្តរធម៌ទាំងឡាយ ព្រោះហេតុដែលខ្លួននៅកន្លងការកើតក្នុងលោកមិនទាន់បាន ដូច្នោះ គប្បីជ្រាបសេចក្ដីនៃបទទាំងឡាយថា **អប្បមាណំ និរូបធឹ** ដោយអំណាចនៃកុសលទាំងនោះថា កុសលឈ្មោះថា ប្រមាណមិនបាន ព្រោះចូលទៅកាត់កិលេសទាំងឡាយ មានកាមរាគៈយ៉ាងគ្រោតគ្រាត ដែល

តាំងនៅក្នុងទីជាមួយគ្នាក្នុងឋានៈជាសត្រូវជាដើម ដែលធ្វើនូវប្រមាណ, មយ៉ាងទៀត ឈ្មោះថា រកឧបធិមិនបាន ព្រោះលះខន្ធូបធិដែលគួរដល់ការកើតឡើង អំពីភពទី ៧ និងអភិសង្ខារូបធិ ដែលកើតអំពីខន្ធូបធិនោះ ទាំងកិលេសូបធិ ដែលមគ្គនោះៗ គប្បីសម្លាប់ នឹងព្រោះអាស្រ័យព្រះនិព្វានពោលគឺធម្មជាតិដែលមិនមានឧបធិ ហេតុដែលឧបធិទាំងនោះកើតឡើងមិនបាន ។

ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងកម្មដែលបិទទ្វារអបាយទុក ដោយចំណែកមយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងកម្មដែលនឹងឲ្យកើតសួគ៌សម្បត្តិ ទើបត្រាស់ពាក្យមានជាដើមថា **តតោ ឱបធិកំ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឱបធិកំ** បានដល់ ឲ្យកើតផលជាឧបធិ ។ អធិប្បាយថា ឲ្យកើតសម្បត្តិគឺអត្តភាព និងភោគសម្បត្តិ ។ ក៏អត្តភាពលោកហៅថា ឧបធិ ។ ដូចដែលត្រាស់ទុកថា "កម្មសមាទានដ៏លាមកពួកខ្លះ មានឧបធិសម្បត្តិ

រាំង មិនឲ្យផល ក៏មាន" ដូច្នោះ ។ សូម្បីកាមគុណ ក៏ត្រាស់ហៅថា **ឧបធិ** ដូចដែលត្រាស់ទុកថា សេចក្ដីសោសៅរបស់នរជនមានព្រោះ **ឧបធិ** ។

ក្នុងពាក្យថា **ឧបធីហិ នរស្ស សោចនំ** នេះ មានអត្ថវចនៈ ដូចតទៅនេះ អត្ថកាពនិងកាមគុណ ឈ្មោះថា **ឧបធិ** ព្រោះជាទីដែលសត្វទ្រទ្រង់ទុកនូវសុខនិងទុក្ខ ។ បុគ្គលដែលឈ្មោះថា **ឱបធិកៈ** ព្រោះមានឧបធិជាហេតុ ជាប្រក្រតី ឬគួរដល់ឧបធិ ធ្វើបុណ្យនោះឲ្យច្រើន គឺឲ្យឱឡារិក ។

សួរថា ធ្វើយ៉ាងណា ? ឆ្លើយថា ធ្វើដោយទាន ។ ព្រោះថា ទានបុគ្គលក្រៅនេះធ្វើបានងាយ ព្រោះដូច្នោះ ទើបលោកពោលយ៉ាងនេះ ។ ម្យ៉ាងទៀត ដោយបទថា **ទានេន** ព្រះមានព្រះភាគ សំដៅយកអភ័យទានផង ។ មិនមែនត្រាស់អាមិស-ទានប៉ុណ្ណោះ ព្រោះដូច្នោះ គប្បីជ្រាបថា ទ្រង់សង្គ្រោះយកសីលចូលទុកផង ។

ក៏ព្រោះហេតុដែលទេវតាទាំងនោះ ប្រាថ្នាសេចក្ដីវិនាស

នៃកាយអសុរៈ និងសេចក្ដីបរិបូរណ៍របស់កាយទិព្វ ដោយចំណែកមួយប៉ុណ្ណោះ ទើបប្រកបទេវបុត្តទុកក្នុងធម្មទាន ដោយបាទនៃគាថាថា **អញ្ញេបិ មច្ចេ សទ្ធម្មេ ព្រហ្មចរិយេ និវេសយ** (ញុំាងពួកសត្វដទៃ ឲ្យតាំងនៅក្នុងព្រះសទ្ធម្ម ដែលជាព្រហ្មចរិយៈ) ដូច្នេះ ។

បទថា **យទា វិទូ** សេចក្ដីថា វេលាណាទេវតាទាំងឡាយគប្បីដឹង គឺគប្បីជ្រាបទេវតាអ្នកច្យុតិ វេលានោះ ទេវតាទាំង-ឡាយនឹងអនុមោទនា ដោយសេចក្ដីអនុគ្រោះ គឺដោយភាពជាអ្នកប្រាថ្នាដើម្បីបំបាត់ទុក្ខ តាមដែលពោលហើយ នេះថា "**ទេវ ឥមេ ទេវកាយេ បុនប្បុនំ ឧប្បជ្ជនវសេន ឯហិ អាគច្ឆាហិ** : ម្នាលទេវៈ អ្នកចូរមក គឺចូរត្រឡប់មកកាន់ទេវកាយនេះរឿយៗ" ដូច្នេះ ។

ចប់ អដ្ឋកថា ចវមានសូត្រទី ៤ ។

# ៨-ព្រហ្មសូត្រ

*(សុត្តន្តបិដក លេខ៥៣ ទំព័រ១៨២)*

*ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតា ក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅជាមួយនឹងព្រហ្ម ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតាក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងបុព្វទេវតា (ទេវតាដើម) ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតាក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងបុព្វាចារ្យ (អាចារ្យដើម) ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតាក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងអាហុនេយ្យបុគ្គល (បុគ្គលគួរបូជា) ។*

*ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រហ្មន៎ុះ ជាឈ្មោះរបស់មាតាបិតា ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុព្វទេវាន៎ុះ ជាឈ្មោះរបស់មាតាបិតា ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អាហុ-នេយ្យន៎ុះ ជាឈ្មោះរបស់មាតាបិតា ។ ដំណើរនោះព្រោះហេតុ*

*អ្វី ។ ម្នាលភិក្ខុទាំងឡាយ (ព្រោះ) មាតាបិតាមានឧបការៈ-ច្រើន ជាអ្នកបីបាច់(ឲ្យគង់ជីវិត) ជាអ្នកចិញ្ចឹម(ឲ្យធំ) ទាំងជាអ្នកបង្ហាញនូវលោកនេះ ដល់កូនទាំងឡាយ ។*

ព្រហ្មាតិ មាតាបិតរោ បុព្វាចរិយាតិ វុច្ចរេ
អាហុនេយ្យា ច បុត្តានំ បជាយ អនុកម្បកា។
តស្មា ហិ នេ នមស្សេយ្យ សក្ករេយ្យ ច បណ្ឌិតោ
អន្នេន អថ បានេន វត្ថេន សយនេន ច
ឧច្ឆាទនេន ន្ហាបនេន បាទានំ ធោវនេន ច ។
តាយ នំ បារិចរិយាយ មាតាបិតូសុ បណ្ឌិតា
ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតីតិ ។

*មាតាបិតាទាំងឡាយ ដែលហៅថា ព្រហ្មក្តី បុព្វាចារ្យក្តី អាហុនេយ្យក្តី (សុទ្ធតែ) ជាអ្នកអនុគ្រោះដល់ពួកសត្វ គឺកូន ។ ព្រោះហេតុនោះឯង អ្នកប្រាជ្ញ គួរនមស្ការ គួរធ្វើសក្ការៈដល់មាតាបិតាទាំងនោះ ដោយបាយ ទឹក សំពត់ គ្រឿងដេក គ្រឿងអប់ គ្រឿងផ្ងូតទឹក និងទឹកសម្រាប់លាងជើង ។ ព្រោះការដែលបានទំនុកបម្រុងមាតាបិតានោះហើយ បានជាអ្នកប្រាជ្ញ*

ទាំងឡាយសរសើរនូវបុគ្គលនោះក្នុងលោកនេះឯង បុគ្គលនោះ លុះលះលោកនេះទៅហើយ រមែងរីករាយក្នុងឋានសួគ៌ ។

## ៩~ឧបការគុណនៃមាតាបិតា

(សុត្តន្តបិដក លេខ៤០ ទំព័រ១៣៧-១៣៨)

ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា កុលបុត្តមិនងាយនឹងធ្វើការតបគុណ ដល់បុគ្គលពីរពួកបានទេ ។ បុគ្គលពីរពួកតើនរណាខ្លះ ។ គឺ មាតា ១ បិតា ១ ។

ម្នាលភិក្ខុទាំងឡាយ កុលបុត្តមានអាយុ ១០០ ឆ្នាំ រស់នៅអស់រវាង ១០០ ឆ្នាំ គប្បីបញ្ជិះមាតា ដោយស្មាម្ខាង បញ្ជិះបិតា ដោយស្មាម្ខាង កុលបុត្តនោះ បម្រើមាតាបិតាទាំងពីរនោះ ដោយការដុសជម្រះបំបាត់ក្លិនអាក្រក់ រិតនួតដៃ ផ្ងូតទឹក គក់ច្របាច់ដៃជើង ឯមាតាបិតាទាំងពីរនោះ ក៏បន្ទោបង់មូត្រករីសលើស្មាកុលបុត្តនោះឯង ម្នាលភិក្ខុទាំងឡាយ (ហេតុមានប្រមាណប៉ុណ្ណេះ) គង់មិនទាន់ហៅថាធ្វើ ឬថា ធ្វើតបដល់មាតានិងបិតាឡើយ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តតម្កើងមាតានិងបិតា ឲ្យតាំងនៅក្នុងរាជសម្បត្តិ មានឥស្សរភាព

ជាអធិបតីលើផែនដីធំ ដែលមានកែវទាំង ៧ ប្រការ ច្រើននេះ ម្នាលភិក្ខុទាំងឡាយ (ហេតុមានប្រមាណប៉ុណ្ណេះ) គង់មិនទាន់ហៅថាធ្វើ ឬថាធ្វើតបដល់មាតានិងបិតាឡើយ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា មាតានិងបិតាមានឧបការៈច្រើនដល់បុត្រទាំងឡាយ ព្រោះជាអ្នកថែរក្សាចិញ្ចឹមបង្ហាញនូវលោកនេះ ។

ម្នាលភិក្ខុទាំងឡាយ (បើ) កុលបុត្តណាមួយដឹកនាំមាតានិងបិតា ដែលមិនមានសទ្ធា ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងសទ្ធាសម្បទា បើទ្រុស្តសីល ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងសីលសម្បទា បើកំណាញ់ ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងចាគសម្បទា បើឥតបញ្ញា ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងបញ្ញាសម្បទា ម្នាលភិក្ខុទាំងឡាយ ហេតុមានប្រមាណប៉ុណ្ណេះ ទើបហៅថាធ្វើ ឬថាធ្វើតបដល់មាតានិងបិតាមែន ។

## ១០_គង្គមាលជាតក

*(សុត្តន្តបិដក លេខ៥៩ ទំព័រ១២១)*

*ព្រះសាស្ដា កាលទ្រង់គង់នៅក្នុងព្រះវិហារជេតវន ទ្រង់ប្រារព្ធឧបោសថកម្ម ទើបត្រាស់រឿងនេះ មានពាក្យចាប់ផ្ដើមថា* ***អង្គារជាតា*** *ដូច្នេះ ។*

*សេចក្ដីថា ថ្ងៃមួយព្រះសាស្ដាត្រាស់ហៅពួកឧបាសកអ្នករក្សាឧបោសថមកហើយត្រាស់ថា* "ឧបាសកា សាធុរូបំ វោ កតំ ឧបោសថំ ឧបវសន្តេហិ, ទានំ ទាតព្វំ, សីលំ រក្ខិតព្វំ, កោធោ ន កាតព្វោ, មេត្តា ភាវេតព្វា, ឧបោសថវាសោ វសិតព្វោ, ពោរាណក-បណ្ឌិតា ហិ ឯកំ ឧបឌ្ឍុបោសថកម្មំ និស្សាយ មហាយសំ លភឹសុ *: ម្នាលឧបាសកទាំងឡាយ លោកទាំងឡាយ ធ្វើឧបោសថកម្មឲ្យសម្រេចល្អហើយ អ្នកដែលរក្សាឧបោសថ គួរឲ្យទាន រក្សាសីល មិនក្រោធ ចម្រើនមេត្តា នៅរក្សាឧបោសថ ក៏បោរាណកបណ្ឌិតបានយសធំ ព្រោះអាស្រ័យឧបោសថកម្ម ដែលរក្សាកន្លះថ្ងៃ" ដូច្នេះ ពួកឧបាសក*

ទាំងនោះ ក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះ ៖

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិនៅក្នុងនគរពារាណសី ក្នុងព្រះនគរនោះមានសេដ្ឋីម្នាក់ ឈ្មោះថា **សុចិបរិវារ** មានសម្បត្តិ ៨០ កោដិ ជាអ្នកត្រេកអរក្នុងបុណ្យកុសល មានឲ្យទានជាដើម ។ បុត្រភរិយាក្តី បរិវារជនរបស់គាត់ក្តី ដោយហោចទៅសូម្បីក្មេងចិញ្ចឹមគោក្នុងផ្ទះនោះក្តី ទាំងអស់នាំគ្នានៅរក្សាឧបោសថមួយខែ ៦ ថ្ងៃ ។ គ្រានោះព្រះពោធិសត្វកើតក្នុងត្រកូលអ្នកទុរគតមួយ ធ្វើការឈ្នួលចិញ្ចឹមជីវិត រស់នៅដោយសេចក្តីលំបាក ។ ព្រះពោធិសត្វគិតថា យើងនឹងធ្វើការស៊ីឈ្នួល ទើបបានទៅកាន់ផ្ទះរបស់សុចិបរិវារសេដ្ឋី សំពះហើយឈរក្នុងទីដ៏សមគួរមួយកន្លែង កាលលោកសេដ្ឋីសួរថា លោកមកធ្វើអ្វី ? ទើបពោលថា មកដើម្បីទទួលស៊ីឈ្នួលធ្វើការងារក្នុងផ្ទះរបស់លោក។ លោកសេដ្ឋីធ្លាប់បាននិយាយប្រាប់ដល់កូនឈ្នួលដទៃៗ ទុកក្នុងថ្ងៃដែលមកដល់ថា អ្នកដែលធ្វើការងារក្នុងផ្ទះនេះ រក្សាសីលគ្រប់គ្នា កាលលោកអាចរក្សាសីលបាន ក៏ចូរធ្វើការងារចុះ ។

តែសម្រាប់ព្រះពោធិសត្វ លោកសេដ្ឋីមិនបានប្រាប់ឲ្យរក្សាសីល ។ ពោលទទួលព្រះពោធិសត្វថា ល្អហើយបា លោកចូរនៅទទួលស៊ីឈ្នួលធ្វើការងារចុះ ។

រាប់អំពីនោះមក ព្រះពោធិសត្វជាអ្នកប្រដៅងាយ ឲ្យហើយនូវជីវិត មិនបានគិតឃើញដល់សេចក្ដីនឿយហត់លំបាករបស់ខ្លួន ធ្វើការងារគ្រប់យ៉ាងឲ្យលោកសេដ្ឋី ។ ព្រះពោធិ-សត្វទៅធ្វើការងារអំពីព្រឹកព្រលឹម ក្នុងពេលល្ងាចទើបត្រឡប់មក ។

លំដាប់តមក ក្នុងថ្ងៃមួយគេប្រកាសមហោស្រពក្នុងព្រះនគរ ។ មហាសេដ្ឋីហៅនាងទាសីមកបង្គាប់ថា ថ្ងៃនេះជាថ្ងៃឧបោសថ អ្នកឯងចូរចំអិនភត្តឲ្យពួកកម្មករក្នុងផ្ទះអំពីព្រឹកតែម្ដង ដល់វេលាគេនឹងបានស៊ី ហើយរក្សាឧបោសថ ។ ព្រះពោធិសត្វ ក្រោកឡើងអំពីព្រឹកព្រលឹមទៅធ្វើការងារ ។ មិនមានអ្នកណាប្រាប់ ដល់ព្រះពោធិសត្វថា ថ្ងៃនេះ លោកគប្បីរក្សាឧបោសថ ។ ពួកកម្មករដ៏សេសបរិភោគអាហារអំពីព្រឹកហើយរក្សាឧបោសថ ។ សូម្បីលោកសេដ្ឋីព្រមដោយកូនប្រពន្ធ បរិវារជន បានអធិដ្ឋានឧបោសថ ។ ពួកអ្នកដែលរក្សា

ឧបោសថសូម្បីទាំងអស់ ទៅកន្លែងនៅរបស់ខ្លួនៗ អង្គុយពិចារណាសីល ។ ព្រះពោធិសត្វធ្វើការងាររហូតដល់អស់មួយថ្ងៃ ត្រឡប់មកក្នុងវេលាដែលព្រះអាទិត្យលិចហើយ ។ លំដាប់នោះ ពួកអ្នកធ្វើភត្តបានឲ្យទឹកលាងដៃដល់ព្រះពោធិសត្វ ហើយរៀបបាយដាក់ថាសបញ្ជូនឲ្យ ។ ព្រះពោធិសត្វសួរថា "ថ្ងៃដទៃៗ ក្នុងវេលាដូច្នេះបានមានសំឡេងខ្លាំង តែថ្ងៃនេះគេទៅណាអស់" កាលបានស្ដាប់ថា គ្រប់គ្នាសមាទានឧបោសថ ទៅទីនៅរបស់ខ្លួនៗ ទើបគិតថា យើងជាអ្នកទ្រុស្តសីលម្នាក់ នឹងនៅមិនបានក្នុងក្រុមរបស់បុគ្គលអ្នកមានសីលទាំងនេះ កាលយើងអធិដ្ឋានអង្គឧបោសថ ឥឡូវនេះ នឹងជាឧបោសថកម្មឬទេហ្ន៎ គិតដូច្នេះហើយ ទើបទៅសួរលោកសេដ្ឋី ។ លំដាប់នោះ លោកសេដ្ឋីពោលនឹងព្រះពោធិសត្វថា នែបា នឹងជាឧបោសថកម្មទៅទាំងអស់មិនបានទេ ព្រោះមិនបានអធិដ្ឋានអំពីព្រឹក តែជាឧបោសថកម្មកន្លះថ្ងៃប៉ុណ្ណោះ ។ ព្រះពោធិសត្វពោលថា "ឯត្តកម្បិ ហោតុ ត្រឹមតែប៉ុណ្ណោះចុះ" បានសមាទានសីលក្នុងសំណាក់របស់លោកសេដ្ឋី អធិដ្ឋានឧបោសថ ហើយចូលទីនៅរបស់ខ្លួន ដេកពិចារណាដល់

សីល ។ កាលរាត្រីកន្លងចូលបច្ឆិមយាម ខ្យល់សត្ថកវាត ក៏កើតឡើងដល់ព្រះពោធិសត្វ ព្រោះអត់អាហារមករហូតអស់មួយថ្ងៃ ។ សូម្បីលោកសេដ្ឋីប្រកបភេសជ្ជៈផ្សេងៗ នាំមកឲ្យបរិភោគ ព្រះពោធិសត្វ ក៏ពោលថា ខ្ញុំសមាទានឧបោសថហើយ ដោយព្រមលះបង់ជីវិត ដោយគិតថា នឹងមិនទម្លាយឧបោសថ ។ វេទនាខ្លាំងក្លាបានកើតឡើង ។ វេលារុណរះឡើង ព្រះពោធិសត្វមិនអាចតាំងសតិទុកបាន បុគ្គលទាំងឡាយ គិតថា ព្រះពោធិសត្វនឹងស្លាប់ក្នុងឥឡូវនេះ ទើបបាននាំទៅឲ្យដេកនៅក្នុងរោងរក្សាអាហារ ។

ខណៈនោះ ព្រះបាទពារាណសី ទ្រង់រថព្រះទីនង្គ ធ្វើប្រទក្សិណ ព្រះនគរដោយបរិវារធំ ស្ដេចដល់ទីនោះ ។ ព្រះពោធិសត្វ បានឃើញសិរីរាជសម្បត្តិរបស់ព្រះបាទពារាណសីកើតសេចក្ដីលោភ ប្រាថ្នាចង់បានរាជសម្បត្តិ។ កាលវលត់ចិត្តហើយ បានទៅបដិសន្ធិក្នុងគភ៌អគ្គមហេសី របស់ព្រះបាទពារាណសី ដោយអានិសង្សនៃឧបោសថកម្មកន្លះថ្ងៃ ។ ព្រះអគ្គមហេសីបានពគភ៌បរិហារហើយ លុះគ្រប់ទសមាស (១០ ខែ) ក៏ប្រសូតព្រះរាជឱរស ។ ព្រះញាតិទាំងឡាយនាំគ្នា

ថ្វាយព្រះនាមថា ឧទ័យកុមារ ។ ឧទ័យកុមារនោះ កាល
ចម្រើនវ័យហើយ សម្រេចការសិក្សាសិល្បៈគ្រប់យ៉ាង រលឹក
ដល់បុព្វកម្មរបស់ខ្លួនបាន ដោយញាណជាគ្រឿងរលឹកជាតិ
ទើបបន្លឺឧទានរឿយៗថា នេះជាផលកម្មបន្តិចបន្តួចរបស់យើង
ដូច្នេះ ។ កាលព្រះរាជបិតាសុគតហើយ បានគ្រងរាជសម្បត្តិ
ទតព្រះនេត្រមើលសិរីរាជសម្បត្តិ ដ៏ធំក្រៃលែងរបស់ព្រះអង្គ
ហើយបន្លឺឧទានដូច្នោះទៀត ។

ថ្ងៃមួយជាលំដាប់មក អ្នកក្រុងត្រៀមការលេងមហោ-
ស្រព ក្នុងព្រះនគរ ។ មហាជននាំគ្នាដាក់ចិត្តមើលការលេង ។
គ្រានោះ បុរសទទួលធ្វើការឈ្នួលម្នាក់ នៅជិតទ្វារទិសឧត្តរ
ក្រុងពារាណសី រក្សាទ្រព្យកន្ទះមាសក ដែលបានមកដោយ
ការស៊ីឈ្នួលដងទឹកទុកក្នុងចន្លោះឥដ្ឋកំពែងក្រុង បាននៅរួម
ជាមួយនឹងស្រីកំព្រាម្នាក់ ដែលចិញ្ចឹមជីវិតដោយការទទួល
ស៊ីឈ្នួលដងទឹកដូចគ្នា ក្នុងព្រះនគរនោះ ។ ស្រីនោះពោល
នឹងគេថា នាយក្នុងព្រះនគរគេមានមហោស្រព បើលោកមាន
ទ្រព្យខ្លះ សូម្បីយើងទាំងពីរក៏នឹងត្រាច់ទៅលេងជាមួយគ្នា ។
គេឆ្លើយថា អើយើងមានទ្រព្យ ។ មានប៉ុន្មាននាយ ? មាន

កន្ទះមាសក ។ ទ្រព្យនោះនៅទីណា? ខ្ញុំរក្សាទុកក្នុងចន្លោះឥដ្ឋជិតទ្វារទិសឧត្តរ កន្លែងរក្សាទ្រព្យឆ្ងាយពីទីដែលយើងនៅនេះ ១២ យោជន៍ ក៏ទ្រព្យក្នុងដៃរបស់នាងមានខ្វះឬ ? ចាំមាន ។ មានប៉ុនណា ? មានកន្ទះមាសក ដូចគ្នា ។ ទ្រព្យរបស់លោកកន្ទះមាសក របស់ខ្ញុំកន្ទះមាសក រួមជាមួយមាសក យើងនឹងយកទ្រព្យនោះមួយចំណែកទិញផ្កាឈើ មួយចំណែកទិញរបស់ក្រអូប មួយចំណែកទិញសុរា ហើយត្រាច់ទៅលេងជាមួយគ្នា លោកចូរទៅនាំទ្រព្យកន្ទះមាសកដែលរក្សាទុកមកចុះ។

បុរសអ្នកធ្វើការស៊ីឈ្នួលរីករាយត្រេកអរថា ភរិយាជឿកាន់តាមពាក្យរបស់យើង ទើបពោលថា ម្នាលប្អូនសម្លាញ់ កុំគិតឡើយ ខ្ញុំនឹងទៅនាំយកទ្រព្យនោះមក ដូច្នេះហើយជៀសចេញទៅ ។ ភតិកបុរស (បុរសអ្នកធ្វើការឈ្នួល) មានកម្លាំងប៉ុនដំរីសារ ដើរកន្លងផ្លូវទៅបាន ៦ យោជន៍ ក្នុងវេលាពាក់កណ្តាលថ្ងៃត្រង់ (មជ្ឈន្តិកសមយេ) ដើរជាន់ខ្សាច់ក្តៅដូចជារងើកភ្លើង គេកាលត្រេកអរព្រោះប្រាថ្នាចង់បានទ្រព្យ ស្លៀកដណ្តប់កំណាត់សំពត់កាសាវៈ ប្រដាប់ស្លឹកត្នោតត្រង់ត្រចៀក

ដើរច្រៀងដោយទំនុកទៅតែម្នាក់ឯង ដើរកន្ទងទៅតាមផ្លូវព្រះរាជវាំង ។

ព្រះបាទឧទ័យរាជ បើកសីហបញ្ជរប្រថាប់ឈរទតព្រះនេត្រ ឃើញបុរសអ្នកធ្វើការឈ្នួល ដើរមកយ៉ាងនោះ ទ្រង់ត្រិះរិះថា អ្វីហ្ន៎ដែលធ្វើឲ្យបុរសនេះ មិនអើពើចំពោះខ្យល់និងកំដៅថ្ងៃបែបនោះ មានសេចក្ដីរីករាយត្រេកអរ ដើរស្រែកច្រៀងទៅ យើងនឹងសួរគេមើល ដូច្នេះ ហើយទ្រង់បញ្ជូនបុរសម្នាក់ឲ្យទៅហៅមក ។ កាលបុរសនោះ ទៅប្រាប់ថា ព្រះរាជាត្រាស់ហៅលោក គេឆ្លើយថា ព្រះរាជា ជាអ្វីនឹងយើង យើងមិនស្គាល់ព្រះរាជា ដូច្នេះ ។ ទើបត្រូវនាំខ្លួនទៅ ដោយការប្រើកម្លាំង ឈរក្នុងទីដ៏សមគួរមួយ ។ លំដាប់នោះ ព្រះរាជាកាលនឹងត្រាស់សួរគេ បានត្រាស់គាថាពីរគាថា សេចក្ដីថា ៖

អង្គារជាតា បថវី កុក្កុឡានុគតា មហី
អថ គាយសិ វត្តានិ ន តំ តបតិ អាតបោ ។

ប្រថពី ជាផែនដីក្ដៅដូចរងើកភ្លើង ប្រកបដោយដីខ្សាច់ (ក្ដៅ) ដូចផេះ (ដែលភ្លើងឆេះ) អ្នកច្រៀងនូវទំនុកទាំងឡាយ កំដៅថ្ងៃ មិនដុតកំដៅអ្នកទេឬ ។

ឧទ្ធំ តបតិ អាទិច្ចោ អធោ តបតិ វាលុកា
អថ គាយសិ វត្តានិ ន តំ តបតិ អាតបោ។

ព្រះអាទិត្យក្តៅខាងលើ ដីខ្សាច់ក្តៅខាងក្រោម អ្នកច្រៀងនូវទំនុកទាំងឡាយ កំដៅថ្ងៃ មិនដុតកំដៅអ្នកទេឬ ។

បណ្តាបទទាំងនោះ បទថា **អង្គារជាតា** សេចក្តីថា នៃបុរសដ៏ចម្រើន ផែនដីនេះក្តៅដូចផេះរងើកភ្លើង ។ បទថា **កុក្កុឡានុគតា** សេចក្តីថា ជាសទៅដោយខ្សាច់ក្តៅ ដូចផេះពោលគឺផេះដែលក្តៅទូទៅហើយ ។ បទថា **វត្តានិ** សេចក្តីថា អ្នកឯងនៅធ្វើជាមិនដឹងក្តៅ ស្រែកច្រៀងទៅបាន ។

បុរសអ្នកធ្វើការឈ្នួលនោះ បានស្តាប់តម្រាស់របស់ព្រះរាជាហើយ បានក្រាបទូលជាគាថាទី ៣ សេចក្តីថា ៖

ន មំ តបតិ អាតបោ អាតបា តបយន្តិ មំ
អត្ថា ហិ វិវិធា រាជ តេ តបន្តិ ន អាតបោ។

កំដៅថ្ងៃ មិនដុតកំដៅខ្ញុំព្រះអង្គបានទេ កំដៅគឺកាមទាំងឡាយ ទើបញុំាងខ្ញុំព្រះអង្គឲ្យក្តៅបាន បពិត្រព្រះរាជា ប្រយោជន៍ទាំងឡាយ មានប្រការផ្សេងៗ ប្រយោជន៍

ទាំងនោះ តែងដុតកំដៅ ឯងកំដៅថ្ងៃ មិនដុតកំដៅ (ខ្ញុំព្រះអង្គ) ទេ ។

បណ្តាបទទាំងនោះ បទថា **អាតប្បា** បានដល់ វត្ថុកាម និងកិលេសកាម ក៏វត្ថុកាមនិងកិលេសកាមទាំងនោះ រមែង ដុតរោលបុរស ព្រោះហេតុនោះ បុរសអ្នកធ្វើការឈ្នួល ទើប ហៅវត្ថុកាម និងកិលេសកាមទាំងនោះថា **អាតប្បា** ។

បទថា **អត្ថា ហិ វិវិធា** សេចក្តីថា បពិត្រមហារាជ សេចក្តីប្រាថ្នាច្រើនយ៉ាង ពោលគឺកិច្ចការផ្សេងៗ ដែលត្រូវធ្វើ ព្រោះអាស្រ័យវត្ថុកាមនិងកិលេសកាម របស់ខ្ញុំព្រះអង្គមាន វត្ថុកាមនិងកិលេសកាមទាំងនោះ ដុតខ្ញុំព្រះអង្គ ចំណែក កំដៅថ្ងៃ មិនឈ្មោះថា ដុតខ្ញុំព្រះអង្គទេ ។

លំដាប់នោះ ព្រះរាជាត្រាស់សួរបុរសអ្នកធ្វើការឈ្នួល ថា សេចក្តីប្រាថ្នារបស់អ្នកឯងតើយ៉ាងណា ?

គេក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គនៅរួម ជាមួយនឹងស្រីកំព្រាជិតទ្វារទិសទក្សិណ នាងនោះសួរខ្ញុំព្រះអង្គ ថា នាយយើងនឹងទៅមើលការលេងមហោស្រព លោកមាន ទ្រព្យនៅក្នុងដៃខ្លះទេ ? ខ្ញុំព្រះអង្គ បានពោលនឹងនាងថា ទ្រព្យ

យើងកប់រក្សាទុកត្រង់ចន្លោះកំពែងជិតទ្វារ ផ្នែកខាងទិសឧត្តរ នាងពោលថា លោកចូរទៅនាំទ្រព្យនោះមក យើងទាំងពីរ នឹងទៅមើលការលេងមហោស្រព ហើយបញ្ជូនខ្ញុំព្រះអង្គមក ពាក្យរបស់នាងនោះ ចាប់ចិត្តខ្ញុំព្រះអង្គ កាលខ្ញុំព្រះអង្គ រលឹកដល់ពាក្យរបស់នាងនោះ សេចក្តីក្តៅគឺកាមរមែងដុតកំដៅ សេចក្តីប្រាថ្នារបស់ខ្ញុំព្រះអង្គ ជាយ៉ាងនេះព្រះអង្គ ។

ព្រះរាជាត្រាស់ថា បើកាលអ្នកឯងមិនអើពើចំពោះខ្យល់ និងកំដៅថ្ងៃបែបនេះ អ្វីជាហេតុឲ្យអ្នកឯងត្រេកអរដើរស្រែក-ច្រៀង ។ បុរសនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គនាំទ្រព្យដែលកប់ទុកនោះមកបានហើយ នឹងអភិរម្យជាមួយនឹងនាងនោះ ដោយហេតុដូចក្រាបទូលមកនេះ ខ្ញុំព្រះអង្គទើបត្រេកអរស្រែកច្រៀង ។ ព្រះរាជាត្រាស់សួរថា នែបុរសដ៏ចម្រើន ក៏ទ្រព្យដែលកប់រក្សាទុកជិតទ្វារខាងទិសឧត្តរ មានប្រមាណមួយសែនឬ ? គេក្រាបទូល មិនមានដល់ (មួយ-សែនទេ) ព្រះអង្គ ។ ព្រះរាជាត្រាស់សួរដោយលំដាប់ថា បើដូច្នោះ មានប្រាំម៉ឺន បួនម៉ឺន បីម៉ឺន ពីរម៉ឺន មួយម៉ឺន ៥ ពាន់ ៥ រយ បួនរយ បីរយ ពីររយ មួយរយ ប្រាំ បួន បី ពីរ

មួយកហាបណៈ កន្លះកហាបណៈ មួយបាទ បួនមាសក បី ពីរ មួយមាសក ។ បុរសអ្នកធ្វើការឈ្នួល បដិសេធ គ្រប់ទាំងអស់ កាលព្រះរាជាត្រាស់ថា កន្លះមាសក គេក្រាបទូលថា មែនហើយព្រះអង្គ ទ្រព្យរបស់ខ្ញុំព្រះអង្គមានត្រឹមតែប៉ុណ្ណោះ ខ្ញុំព្រះអង្គដើរមក ដោយនឹកក្នុងចិត្តថា នាំទ្រព្យមកបានហើយ នឹងអភិរម្យជាមួយនឹងនាងដូច្នេះ ដោយបីតិសោមនស្សនោះ ខ្យល់និងកំដៅថ្ងៃនោះ ទើបមិនឈ្មោះថាដុតពោលខ្ញុំព្រះអង្គ ។

លំដាប់នោះ ព្រះរាជាត្រាស់ចំពោះបុរសនោះថា នែបុរសដ៏ចម្រើន កំដៅថ្ងៃក្ដៅបែបនេះ អ្នកឯងកុំទៅទីនោះឡើយ យើងនឹងឲ្យទ្រព្យកន្លះមាសកដល់អ្នកឯង ។ គេក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គនឹងតាំងនៅក្នុងព្រះតម្រាស់របស់ព្រះអង្គ ទទួលយកទ្រព្យកន្លះមាសកនោះ និងនឹងមិនធ្វើទ្រព្យដែលកប់ទុកឲ្យវិនាសទៅទេ ខ្ញុំព្រះអង្គនឹងទៅកាន់យកទ្រព្យនោះ មិនព្រមឲ្យសាបសូន្យការធ្វើដំណើរទៅកាន់យកទ្រព្យ ។ ព្រះរាជាត្រាស់ថា នែបុរសដ៏ចម្រើន បាឯង ចូរត្រឡប់វិញចុះ យើងនឹងឲ្យទ្រព្យដល់អ្នកឯងមួយមាសក ពីរមាសក ព្រះអង្គត្រាស់ព្រះរាជទានបន្ថែមឡើងដោយទំនងនេះ ដរាបដល់មួយ-

កោដិ រយកោដិ និងទ្រព្យកំណត់រាប់មិនបាន ហើយត្រាស់ឲ្យគេត្រឡប់វិញ គេក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គព្រមទទួលទ្រព្យដែលព្រះរាជទាន សូម្បីទ្រព្យដែលកប់ទុកក៏នឹងទៅយក ។ តពីនោះ ព្រះរាជាបានត្រាស់ល្អួងលោមដោយឋានន្តរ មានតំណែងសេដ្ឋីជាដើម ដរាបដល់ឲ្យតំណែងឧបរាជដោយព្រះតម្រាស់ថា យើងនឹងឲ្យលោកគ្រងរាជសម្បត្តិពាក់កណ្ដាល ចូរត្រឡប់វិញចុះ ដូច្នេះ គេទើបព្រមទទួលព្រះតម្រាស់ ។

ព្រះរាជាទ្រង់បង្គាប់អមាត្យទាំងឡាយថា ពួកអ្នកឯងចូរទៅធ្វើការកាត់សក់ពុកមាត់ពុកចង្កា ឲ្យសម្លាញ់របស់យើង ហើយឲ្យងូតទឹក តែងខ្លួនហើយនាំមករកយើង ។ ពួកអមាត្យបានទទួលធ្វើតាមបង្គាប់នោះ ។ ព្រះរាជាបែងចែករាជសម្បត្តិចេញជាពីរចំណែក ព្រះរាជទានឲ្យបុរសអ្នកធ្វើការឈ្នួលនោះគ្រប់គ្រងរាជសម្បត្តិពាក់កណ្ដាល ។ អាចារ្យពួកខ្លះ ពោលថាក៏បុរសអ្នកធ្វើការឈ្នួលនោះ គ្រងរាជសម្បត្តិនោះហើយ នៅទៅកាន់ខាងទិសឧត្តរ ដោយសេចក្ដីស្រឡាញ់ទ្រព្យកន្ទះមាសក ។ ហេតុនោះគេទើបបាននាមថា **អឌ្ឍមាសករាជ** ។

ព្រះបាទឧទ័យរាជ និងព្រះបាទអឌ្ឍមាសករាជ ទ្រង់សាមគ្គី ស្និទ្ធស្នាលគ្នាគ្រងរាជសម្បត្តិ ថ្ងៃមួយស្តេចទៅកាន់រាជឧទ្យាន ។ ព្រះបាទឧទ័យរាជ ទ្រង់លេងកីឡាក្នុងព្រះរាជ-ឧទ្យាននោះ រហូតនឿយហត់ ហើយយកព្រះសីសៈផ្ទំលើភ្លៅរបស់ព្រះបាទអឌ្ឍមាសករាជលក់ទៅ ។ កាលផ្ទំលក់ស្និទ្ធហើយ ពួករាជបរិវារក៏នាំគ្នាទៅលេងកីឡាក្នុងទីនោះៗ ។ ព្រះបាទអឌ្ឍមាសករាជ ទ្រង់ត្រិះរិះថា ប្រយោជន៍អ្វីដែលយើងនឹងសោយរាជសម្បត្តិពាក់កណ្តាលនៅជានិច្ច យើងនឹងផ្តាច់ព្រះ-ជន្មព្រះបាទឧទ័យរាជចេញ ហើយសោយរាជសម្បត្តិតែម្នាក់-ឯងល្អជាង ដូច្នេះហើយ ទើបនាំដាវចេញចាកស្រោម គិតនឹងផ្តាច់ព្រះជន្មព្រះបាទឧទ័យរាជចេញ ហើយត្រឡប់មកគិតឡើងថា ព្រះរាជាអង្គនេះបានធ្វើយើងដែលជាអ្នកទុរគត មនុស្ស-កំព្រា ឲ្យមានយសសក្តិស្មើដោយព្រះអង្គ និងតម្កល់យើងទុកក្នុងឥស្សរភាពជាធំក្រៃលែង ការដែលយើងកើតសេចក្តីប្រាថ្នានឹងសម្លាប់អ្នកដែលឲ្យយសដល់យើងដល់ត្រឹមនេះ ជារឿងដែលយើងមិនសមគួរធ្វើឡើយ គិតដូច្នេះហើយ ទើបតាំងសតិបានស៊កដាវចូលស្រោម តែត្រឡប់គិតហើយគិតទៀត រហូត

ដល់ពីរបីដង ចិត្តគិតសម្លាប់នោះមិនទាន់ស្ងប់បាន ។ ពេលនោះ ទើបតាំងព្រះទ័យដាក់ចិត្តគិតថា ចិត្តដូងនេះ កើតឡើងរឿយៗ ក៏នឹងគប្បីប្រកបយើងទុកក្នុងកម្មលាមក, ទើបរឹងព្រះទ័យ ដាក់ដាវទៅលើផែនដី ដាស់ព្រះបាទឧទ័យរាជឲ្យភ្ញាក់ពីផ្ទុំ ហើយឱនចុះទៀបព្រះបាទ ក្រាបទូលថា បពិត្រព្រះអង្គសូមព្រះអង្គ ចូរអត់ទោសដល់ខ្ញុំព្រះអង្គចុះ ។ ព្រះបាទឧទ័យ-រាជត្រាស់ថា ម្នាលសំឡាញ់ ទោសក្នុងចន្លោះរវាងលោកនិងយើងមិនមានទេ មិនមែនឬ ? មានព្រះអង្គ ខ្ញុំបានធ្វើយ៉ាងនេះៗ ។

បើដូច្នោះយើងលើកទោសឲ្យលោក ក៏កាលលោកចង់បានគ្រងរាជសម្បត្តិ ក៏ចូរគ្រងរាជសម្បត្តិចុះ ចំណែកយើងនឹងជាឧបរាជ ធ្វើការទំនុកបម្រុងលោក ។

ព្រះបាទអឌ្ឍមាសករាជក្រាបទូលថា បពិត្រព្រះអង្គខ្ញុំព្រះអង្គ មិនត្រូវការរាជសម្បត្តិ ព្រោះតណ្ហានេះនឹងឲ្យខ្ញុំព្រះអង្គទៅកើតក្នុងអបាយ ព្រះអង្គចូរគ្រប់គ្រងរាជសម្បត្តិរបស់ព្រះអង្គ ត្រឹមតែម្នាក់ឯងចុះ ខ្ញុំព្រះអង្គនឹងសូមលាបួសបួសគល់នៃកាមគុណ ខ្ញុំព្រះអង្គឃើញហើយ សេចក្តីពិត

កាមគុណនេះ ចម្រើនដល់អ្នកត្រិះរិះ ឥឡូវនេះ អំពីនេះទៅ ខ្ញុំព្រះអង្គនឹងមិនត្រិះរិះទៀតឡើយ ដូច្នេះ កាលនឹងបន្លឺឧទាន ទើបត្រាស់គាថាទី ៤ សេចក្ដីថា ៖

អទ្ទសំ កាម តេ មូលំ សង្កប្បា កាម ជាយសិ
ន តំ សង្កប្បយិស្សាមិ ឯវំ កាម ន ហោហិសិ។

ម្នាលកាម យើងបានឃើញឫសគល់របស់អ្នកហើយ ម្នាលកាម អ្នកកើតអំពីសេចក្ដីត្រិះរិះ យើងលែងត្រិះរិះអ្នកទៀតហើយ ម្នាលកាម កាលបើយ៉ាងនេះ អ្នកនឹងមិនកើតមាន (តទៅទៀតទេ) ។

បណ្ដាបទទាំងនោះ បទថា ឯវំ សេចក្ដីថា អ្នកនឹងមិនមានក្នុងខាងក្នុងរបស់យើងដោយអាការយ៉ាងនេះ ។ បទថា ន ហោហិសិ សេចក្ដីថា អ្នកនឹងមិនកើតឡើង ។ ក៏ឯកាលត្រាស់ដូច្នេះហើយ កាលនឹងសម្ដែងធម៌ដល់មហាជនអ្នកប្រកបក្នុងកាមតទៅ ទើបត្រាស់គាថា ទី ៥ សេចក្ដីថា ៖

អប្បាបិ កាមា ន អលំ ពហូហិបិ ន តប្បតិ
អហហា ពាលលបនា បរិវជ្ជេថ ជគ្គតោ ។

កាមទាំងឡាយសូម្បីតិច ក៏នៅតែមិនល្មម សូម្បីច្រើន ក៏នៅតែមិនស្កប់ស្កល់ (ដល់មហាជន) ឱមុខគួរតក់ស្លុត ឲ្យសង្វេគ នឹងការចរចាររបស់ពួកជនពាល បុគ្គល លុះតែប្រឹងប្រកបព្យាយាម (គប្បីរៀរឲ្យដាច់) ទើប ត្រាស់ដឹងបាន ។

បណ្ដាបទទាំងនោះ បទថា អហោ ជាបទសម្ដែងដល់ សេចក្ដីតក់ស្លុត ។ បទថា ជគ្គតោ ប្រែថា អ្នកព្យាយាម ចម្រើន ។ លោកពោលអធិប្បាយទុកដូច្នេះ បពិត្រមហារាជ វត្ថុកាម និងកិលេសកាមសូម្បីតិច ក៏មិនល្មមសម្រាប់មហាជន នេះ មហាជនរមែងមិនឆ្អែតដោយវត្ថុកាម និងកិលេសកាម សូម្បីច្រើន គួរសង្វេគដែលពួកជនពាលនាំគ្នាចរចារថា "រូប សំឡេងទាំងនេះ ចូរមានដល់យើង" កុលបុត្រអ្នកប្រកប សេចក្ដីព្យាយាម ចម្រើនពោធិបក្ខិយធម៌ ញុំាងវិបស្សនាឲ្យ ចម្រើនហើយ គប្បីដឹងច្បាស់រហូតដល់អស់បាន គឺដឹងច្បាស់ បានដោយការកំណត់ដឹង ការលះបង់និងការត្រាស់ដឹង ហើយ លះបាន ។

*ព្រះបាទអឌ្ឍមាសករាជ កាលសម្តែងធម៌ដល់មហាជន យ៉ាងនេះហើយ ឲ្យព្រះបាទឧទ័យរាជទ្រង់គ្រងរាជសម្បត្តិ លះមហាជន អ្នកមានមុខជោគដោយទឹកភ្នែក ស្រែកយំ ចូលហិមវន្តប្រទេស បួស ហើយញ៉ាំងឈាននិងអភិញ្ញាឲ្យកើត ។ កាលព្រះបាទអឌ្ឍមាសករាជ បួសហើយ ព្រះបាទឧទ័យរាជ កាលនឹងថ្លែងឧទានឲ្យគ្រប់ទាំងអស់ ទើបត្រាស់គាថាទី ៦ សេចក្តីថា ៖*

អប្បស្ស កម្មស្ស ផលំ មមេទំ
ឧទយោ អជ្ឈាគមា មហត្តបត្តំ
សុលទ្ធលាភោ វត មាណវស្ស
យោ បព្វជី កាមរាគំ បហាយ ។

*នេះជាផលកម្មមានប្រមាណតិចរបស់យើង ឧទយៈ បានសម្រេចនូវភាពជាធំ ឱហ្ន៎ មាណពណាបានលះនូវតម្រេកក្នុងកាម ហើយបួស មាណពនោះឈ្មោះថា បាន(លាភ)ល្អហើយ ។*

*បណ្តាបទទាំងនោះ បទថា* ***ឧទយោ*** *ព្រះបាទឧទ័យរាជ*

ត្រាស់សំដៅដល់ព្រះអង្គឯង ។ បទថា **មហត្តបត្តំ** សេចក្ដីថា ដល់ភាពជាធំ បានដល់ សម្រេចដល់នូវឥស្សរិយយសដ៏បរិបូរណ៍ ។ បទថា **មាណវស្ស** សេចក្ដីថា ឈ្មោះថា ជាលោក ដែលមាណពជាសម្លាញ់របស់យើង អ្នកប្រសើរបានល្អហើយ ។ ព្រះបាទឧទ័យរាជត្រាស់ទុកដោយមានសេចក្ដីសំដៅយកថា មាណពណាលះកាមរាគៈចេញបួស ហើយ ដូច្នេះប៉ុណ្ណោះ ។

ក៏សេចក្ដីរបស់គាថានេះ មិនមានអ្នកណាដឹង ។ មានថ្ងៃមួយ ព្រះអគ្គមហេសី ទូលសួរសេចក្ដីរបស់ព្រះគាថានឹងព្រះរាជា ។ ក៏ព្រះរាជា មានខ្ញាន់ព្រះកេសម្នាក់ឈ្មោះគន្ធមាល ។ នាយគន្ធមាលនោះ កាលនឹងតុបតែងព្រះមស្សុព្រះរាជា បានធ្វើបរិកម្មដោយកាំបិតកោរមុនហើយ ទើបដកព្រះលោមាដោយសណ្ឌាសខាងក្រោយ ។ វេលាដែលបរិកម្មដោយកាំបិតកោរ ព្រះរាជាទ្រង់មានសេចក្ដីសុខ វេលាដែលដកព្រះលោមា ព្រះរាជាទ្រង់មានសេចក្ដីទុក្ខ ។ ខ្ញាន់ព្រះកេសនោះ ប្រាថ្នានឹងឲ្យព្រះរាជា ព្រះរាជទានពរមុន និងប្រាថ្នានឹងដាក់ព្រះសីសខាងក្រោយ ។

មានថ្ងៃមួយ ព្រះរាជាបានត្រាស់ប្រាប់សេចក្ដីនោះដល់ព្រះរាជទេវីថា ព្រះនាងដ៏ចម្រើន នាយគន្ធលកប្បកៈ (ខ្ទាន់-ព្រះកេស) យើងជាមនុស្សល្ងង់ កាលព្រះរាជទេវីទូលសួរថា បពិត្រព្រះអង្គ នាយគន្ធលកប្បកៈ ធ្វើយ៉ាងណាទើបគួរត្រាស់ថា គួរនឹងដកសរសៃលោមាជាមុន ហើយទើបធ្វើបរិកម្មដោយកាំបិតកោរជាខាងក្រោយ ។ ព្រះរាជទេវី ឲ្យហៅខ្ទាន់ព្រះកេសមក ត្រាស់ថា គ្រានេះកាលដល់ថ្ងៃដែលនឹងតែងព្រះមស្សុថ្វាយព្រះរាជា លោកគប្បីដកសរសៃព្រះលោមាជាមុនហើយ ធ្វើបរិកម្មដោយកាំបិតកោរជាខាងក្រោយ កាលព្រះរាជាទ្រង់ប្រទានពរឲ្យ លោកគប្បីក្រាបទូលថា មិនត្រូវការអ្វីដទៃ សូមព្រះអង្គចូរប្រាប់សេចក្ដីនៃឧទានគាថារបស់ព្រះ-អង្គ យើងនឹងឲ្យទ្រព្យជាច្រើនដល់លោក ។ ខ្ទាន់ព្រះកេសទទួលព្រះបន្ទូលថា ល្អហើយ កាលដល់ថ្ងៃដែលនឹងតែងព្រះមស្សុ បានចាប់សណ្ដាសមុន កាលព្រះរាជាត្រាស់សួរថា នែគន្ធមាល ហេតុដូចម្ដេចអ្នកឯងទើបមិនធ្វើដូចគ្រាមុនៗ គេក្រាបទូលថា បពិត្រព្រះសម្មតិទេព ជម្មតាជាងកោរកាត់ រមែងធ្វើសូម្បីវត្ថុដែលមិនធ្លាប់ធ្វើ ទូលហើយក៏ដកព្រះលោមាមុន

ហើយធ្វើបរិកម្មដោយកាំបិតកោរក្នុងខាងក្រោយ ។ ព្រះរាជាត្រាស់ថា អ្នកឯងចូរទទួលពរ ។ ខ្មាន់ព្រះកេសក្រាបទូលថា ខ្ញុំព្រះអង្គមិនត្រូវការពរយ៉ាងដទៃ សូមព្រះអង្គចូរត្រាស់ប្រាប់សេចក្តីរបស់ឧទានគាថា ។ ព្រះរាជាទ្រង់ខ្មាសព្រះទ័យដែលនឹងត្រាស់ប្រាប់រឿងដែលព្រះអង្គជាអ្នកក្រលំបាក ទើបត្រាស់ថា បាត្រូវការពរនេះធ្វើអ្វី ចូរទទួលពរដទៃចុះ ។ ខ្មាន់ព្រះ-កេសក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គចូរទ្រង់ប្រទានពរនេះដល់ខ្ញុំព្រះអង្គចុះព្រះអង្គ ។ ព្រះរាជាទ្រង់ខ្លាចមុសាវាទកម្ម ទើបទ្រង់ទទួលពាក្យហើយ បង្គាប់ឲ្យចាត់ចែងតាក់តែងវត្ថុទាំងពួង តាមន័យដែលពោលហើយក្នុងកុម្មាស-បិណ្ឌជាតក ប្រថាប់គង់លើរតនបល្ល័ង្ក ត្រាស់បុរិមកិរិយាទាំងពួងថា ម្នាលគង្គមាល ក្នុងភពមុនយើងកើតជាអ្នកទាល់ក្រក្នុងក្រុងនេះ មានសទ្ធារក្សាសីលកន្ទះថ្ងៃ ចុតិពីអត្តភាពនោះបានមកកើតក្នុងត្រកូលក្សត្រ ឈ្មោះថា ឧទ័យរាជ ដោយហេតុនេះ យើងនឹងពោលកន្ទះគាថាខាងដើម កាលសម្ងាញ់របស់យើងលះ កាមរាគៈទៅបួសហើយ យើងជាអ្នកប្រមាទវង្វេងនៅត្រង់រាជសម្បត្តិនេះឯង ដោយហេតុនេះ យើងទើប

ពោលកន្ទះ គាថាខាងចុង ព្រះរាជាត្រាស់ប្រាប់សេចក្ដីនៃឧទាន ដោយប្រការដូច្នេះ ។

ខ្ទាន់ព្រះកេសស្ដាប់រឿងរ៉ាវនោះហើយគិតថា "បានឮថា ព្រះរាជាបានរាជសម្បត្តិនេះ ដោយការរក្សាឧបោសថកន្ទះថ្ងៃ ដែលឈ្មោះថា កុសលដែលបុគ្គលគួរធ្វើ បើដូច្នោះយើង គប្បីបួសសាងទីពឹងរបស់ខ្លួនចុះ" គិតហើយក៏លះបង់វង្សញាតិ និងភោគសម្បត្តិ សូមព្រះរាជាព្រះបរមរាជានុញ្ញាតបព្វជ្ជា ហើយទៅកាន់ហិមវន្តប្រទេស បួសជាឥសី លើកត្រៃលក្ខណ៍ ឡើង ចម្រើនវិបស្សនា ក៏សម្រេចបច្ចេកពោធិញាណ ទ្រទ្រង់ បាត្រចីវរដែលកើតឡើងដោយឫទ្ធិ ចាំវស្សានៅក្នុំគន្ធមាទន៍ ៥ វស្សា គិតថា នឹងទៅមើលព្រះបាទពារាណសី ទើបហោះមក គង់នៅលើមង្គលសិលា ក្នុងមង្គលរាជឧទ្យាន ។ អ្នកថែរក្សា ព្រះរាជឧទ្យានចាំបាន ទើបទៅក្រាបទូលព្រះរាជាថា បពិត្រ ព្រះសម្មតិទេព គន្ធមាលជាព្រះបច្ចេកពុទ្ធ ហោះមកគង់នៅ ក្នុងមង្គលរាជឧទ្យាន ។ ព្រះរាជា ទ្រង់ស្ដាប់ហើយ ប្រញាប់ ស្ដេចចេញមកដោយបំណងថា នឹងថ្វាយបង្គំព្រះបច្ចេកពុទ្ធ ។ ព្រះរាជជនី ក៏ស្ដេចចេញទៅព្រមជាមួយព្រះរាជា ។ ព្រះរាជា

ស្តេចចូលកាន់ព្រះរាជឧទ្យាន ថ្វាយបង្គំព្រះបច្ចេកពុទ្ធហើយ ប្រថាប់គង់ក្នុងទីដ៏សមគួរមួយព្រមដោយបរិស័ទ ។ ព្រះ-បច្ចេកពុទ្ធ កាលនឹងធ្វើបដិសណ្ឋារនឹងព្រះរាជា បានហៅព្រះរាជាតាមនាមត្រកូលថា ម្នាលព្រហ្មទត្ត ព្រះអង្គជាអ្នកមិនប្រមាទ គ្រងរាជសម្បត្តិដោយធម៌ បំពេញបុណ្យមានឲ្យទានជាដើមទេឬ ដូច្នេះ ហើយធ្វើបដិសណ្ឋារ ។ ព្រះរាជ-ជនីបានស្តាប់ដូចនោះ ទ្រង់ព្រះពិរោធថា គន្ធមាលនេះ មានជាតិជាអ្នកអាក្រក់លាមក ជាកូនជាងកោរកាត់ មិនស្គាល់ប្រមាណខ្លួន ហៅឱរសរបស់យើងដែលជាស្តេចផែនដី ជាក្សត្រដោយជាតិ ដោយឈ្មោះថា ព្រហ្មទត្ត ដូច្នេះ ទើបត្រាស់គាថាទី ៧ សេចក្តីថា ៖

តបសា បជហន្តិ ឆាបកម្មំ
តបសា ន្ហាបិតកុម្ភការភាវំ
តបសា អភិភុយ្យ គន្ធមាល
នាមេនាលបសជ្ជ ព្រហ្មទត្តំ ។

ពួកសត្វតែងលះបង់នូវបាបកម្ម (របស់ខ្លួន) ដោយតបៈ

លះបង់នូវការៈនៃខ្លួនជាខ្ទាន់ព្រះកេសនិងស្នូនផ្ទាំង ដោយ តបៈ នៃគន្តមាល ក្នុងថ្ងៃនេះអ្នកហ៊ានរំលោភហៅព្រហ្មទត្ត (កូនអញ) ដោយចំណោះ ព្រោះអាងមានតបៈឬ ។

គាថានោះ មានអធិប្បាយដូច្នេះ ព្រះរាជជននីត្រាស់ថា សត្វទាំងឡាយពួកនេះ រមែងលះបាបកម្មបានដោយតបៈ គឺ តបៈគុណ ដែលខ្លួនសាងសន្សំទុក តែតបៈទាំងនេះនឹងលះបង់ ការៈជាអ្នកប្រើផ្ទាំងជូសទឹក ឲ្យគេងូតបានផងឬ នៃគន្តមាល ការដែលលោកប្រើតបៈរបស់ខ្លួន សង្កត់សង្កិន ហៅឱរស របស់យើងដោយឈ្មោះថា ព្រហ្មទត្ត ក្នុងថ្ងៃនេះនោះ ជាការ មិនសមគួរឡើយ ។

ព្រះរាជាត្រាស់ឃាត់ព្រះជននីហើយ កាលនឹងប្រកាស គុណរបស់ព្រះបច្ចេកពុទ្ធ ទើបត្រាស់គាថាទី ៨ សេចក្តីថា ៖

សន្និដ្ឋិកមេវ "អម្ម" បស្សថ,
ខន្តីសោរច្ចស្ស អយំ វិបាកោ
យោ សព្វជនស្ស វន្ទិតោ ហុ,
តំ វន្ទាម សរាជិកា សមច្ចា ។

បពិត្រព្រះមាតា សូមទ្រង់ទតនូវផលនៃខន្តីនិងសោរច្ចៈ ដែលអាចឃើញជាក់ច្បាស់ដោយខ្លួនឯង (ក្នុងបច្ចុប្បន្ន) ព្រះគន្ធមាលបច្ចេកពុទ្ធនោះ ជាបុគ្គលដែលជនទាំងអស់ត្រូវថ្វាយបង្គំយើង ព្រមទាំងស្តេច និងអមាត្យនាំគ្នាថ្វាយបង្គំនូវព្រះបច្ចេកពុទ្ធនោះ ។

បណ្តាបទទាំងនោះបទថា **ខន្តិសោរច្ចស្ស** បានដល់អធិវាសនខន្តី និងសោរច្ចៈ ។ បទថា **តំ វន្ទាម** បពិត្រព្រះមាតា ឥឡូវនេះ យើងទាំងឡាយ ទាំងព្រះរាជាទាំងអមាត្យគ្រប់គ្នា នាំគ្នាថ្វាយបង្គំព្រះបច្ចេកពុទ្ធ សូមព្រះមាតាចូរទ្រង់ឃើញផលនៃខន្តិ និងសោរច្ចចុះ ។

កាលព្រះរាជា ត្រាស់ឃាត់ព្រះរាជជននី ហើយមហាជនដ៏សេស នាំគ្នាក្រោកឡើងពោលថា បពិត្រព្រះអង្គជាសម្មតិទេព កាលដែលជនថោកទាបឃើញសភាពនេះ ហៅព្រះអង្គដោយឈ្មោះ មិនសមគួរដល់ព្រះអង្គឡើយ ។ ព្រះរាជា ទ្រង់ឃាត់មហាជនហើយ ដើម្បីនឹងសម្តែងគុណនៃព្រះបច្ចេកពុទ្ធជាម្ចាស់នោះ ទើបត្រាស់គាថាចុងក្រោយ សេចក្តីថា ៖

មា កិញ្ចិ អវចុត្ថ គន្ធមាលំ

មុនិនំ មោនបថេសុ សិក្ខមានំ
ឯសោ ហិ អតរិ អណ្ណវំ
យំ តរិត្វា ចរន្តិ វីតសោកាតិ ។

អ្នកទាំងឡាយ កុំនិយាយពាក្យតិចតួចនឹងព្រះបច្ចេកពុទ្ធ ឈ្មោះគន្ធមាល ដែលជាអ្នកសិក្សាក្នុងគន្លងនៃប្រាជ្ញារបស់ពួកអ្នកប្រាជ្ញឡើយ ព្រោះថា ព្រះបច្ចេកពុទ្ធនេះ បានឆ្លងនូវអន្លង់ គឺវដ្តសង្សារ ដែលពួកបុគ្គលអ្នកប្រាសចាកសោក តែងឆ្លងហើយត្រាច់ទៅ ។

បណ្ដាបទទាំងនោះ បទថា មុនិនំ បានដល់ អាគារិកមុនី អនាគារិកមុនី សេខមុនី អសេខមុនី និងព្រះបច្ចេកមុនី ។ បទថា មោនបថេសុ សិក្ខមានំ សេចក្ដីថា អ្នកសិក្សានៅក្នុងគន្លងមុនី ពោលគឺពោធិបក្ខិយធម៌ ព្រោះជាការបដិបត្តិ ដែលជាបុព្វភាគ ។ បទថា អណ្ណវំ បានដល់ សមុទ្រគឺសង្សារ ។ ព្រះរាជាកាលត្រាស់ដូច្នេះ ហើយបានថ្វាយបង្គំ នមស្ការព្រះបច្ចេកពុទ្ធ ត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាអត់ទោសដល់ព្រះរាជជននីផងចុះ ។

ព្រះបច្ចេកពុទ្ធពោលថា ថ្វាយព្រះពរមហាបពិត្រ យើងអត់ទោសឲ្យ ។

សូម្បីពួករាជបរិស័ទ ក៏នាំគ្នាសូមខមាទោសព្រះបច្ចេក-ពុទ្ធ ។ ព្រះរាជាសូមបេ្តជ្ញាព្រះបច្ចេកពុទ្ធ ដើម្បីឲ្យគង់នៅជាមួយព្រះអង្គតទៅ ។ ព្រះបច្ចេកពុទ្ធ មិនបានថ្វាយបេ្តជ្ញាកាលបរិស័ទព្រមដោយព្រះរាជា កំពុងសំឡឹងមើលនោះឯង បានឋិតនៅក្នុងអាកាស ឲ្យឱវាទចំពោះព្រះរាជា ហើយហោះទៅកាន់ភ្នំគន្ធមាទន៍ ។

ព្រះបរមសាស្តា គ្រាទ្រង់នាំព្រះធម៌ទេសនានេះមកសម្តែងហើយត្រាស់ថា ម្នាលឧបាសកទាំងឡាយ ឈ្មោះថាការនូវរក្សាឧបោសថ ជាកិច្ចដែលបុគ្គលគួររក្សា ដោយប្រការដូច្នេះ ហើយទ្រង់ប្រជុំជាតកថា ព្រះបច្ចេកពុទ្ធក្នុងកាលនោះ បានបរិនិព្វានហើយ ព្រះបាទអឌ្ឍមាសករាជ បានមកជាព្រះអានន្ទ ព្រះរាជជននីបានមកជាព្រះមហាមាយា ព្រះ-អគ្គមហេសី បានមកជាមាតាព្រះរាហុល ចំណែកព្រះបាទឧទយៈរាជ បានមកជាតថាគត ដូច្នេះឯង ។

(ចប់ អដ្ឋកថាគង្គមាលជាតក ៥៩, ៥១២-៥៣០)

## ១១. រឿង ភិក្ខុរូបណាមួយ

ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុរូបណាមួយ ត្រាស់ព្រះធម៌ទេសនានេះថា ទុន្និគ្គហស្ស លហុនោ ជាដើម ។

បានឮថា បានមានស្រុកមួយ ឈ្មោះមាតិកគ្រាម ជិតជើងភ្នំ ក្នុងដែនរបស់ព្រះបាទកោសល ។ ខាងក្រោយថ្ងៃមួយ ភិក្ខុប្រមាណ ៦០ រូប ទៅកាន់សំណាក់របស់ព្រះសាស្តា ទូលអារាធនាឲ្យទ្រង់ត្រាស់ប្រាប់ព្រះកម្មដ្ឋាន ដរាបដល់ព្រះអរហត្តហើយ ទៅកាន់ស្រុកនោះ ចូលទៅដើម្បីបិណ្ឌបាត ។ លំដាប់នោះម្ចាស់របស់ស្រុកនោះឈ្មោះមាតិកៈណា មាតារបស់ម្ចាស់ស្រុកនោះ ឃើញភិក្ខុទាំងនោះហើយ និមន្តឲ្យគង់ក្នុងផ្ទះ ទើបអង្គាសដោយយាគូ និងភត្តដែលមានរសដ៏ក្រៃលែងផ្សេងៗ សួរថា "ពួកលោកម្ចាស់ ប្រាថ្នានឹងទៅក្នុងទីណា" ។ ភិក្ខុទាំងនោះប្រាប់ថា "មហាឧបាសិកា ពួកអាត្មាមានសេចក្តីប្រាថ្នានឹងទៅកាន់ទីតាមសេចក្តីសប្បាយ" ។ ឧបាសិកាជ្រាបថា "លោកជាម្ចាស់ទាំងឡាយ ប្រហែលជាស្វែងរកស្ថានទីសម្រាប់ចាំវស្សា

ទើបក្រាបចុះជិតជើងហើយពោលថា "បើលោកម្ចាស់ទាំងឡាយនឹងនៅក្នុងទីនេះរហូតដល់អស់ ៣ ខែ នេះសោត, ខ្ញុំម្ចាស់នឹងទទួលសរណៈ ៣ សីល ៥ (និង) ធ្វើឧបោសថកម្ម" ។ ភិក្ខុទាំងឡាយប្រឹក្សាគ្នាថា "យើងទាំងឡាយកាលអាស្រ័យឧបាសិកានេះ មិនមានសេចក្ដីលំបាកដោយភិក្ខា អាចនឹងធ្វើការរលាស់ចេញចាកភពបាន" ដូច្នេះ ហើយទើបទទួលពាក្យ ។ នាងបានជម្រះវិហារដែលជាទីនៅថ្វាយភិក្ខុទាំងនោះ ។

ភិក្ខុទាំងនោះ កាលនៅក្នុងទីនោះ ថ្ងៃមួយបានប្រជុំគ្នាហើយ ដាស់តឿនគ្នានឹងគ្នាថា "អ្នកមានអាយុ ពួកយើងមិនគួរប្រព្រឹត្តដោយសេចក្ដីប្រមាទ ព្រោះថាមហានរក ៨ រណ្ដៅ គឺ ១ សញ្ជីវៈ ២ កាលសុត្តៈ ៣ សង្ឃាដៈ ៤ រោរុវៈ ៥ មហារោរុវៈ ៦ តាបៈ ៧ មហាតាបៈ ៨ អវិចី មានទ្វារបើក (រង់ចាំ) ពួកយើង ដូចជាផ្ទះរបស់ខ្លួនពិត ។ ក៏ឯពួកយើងបានរៀនព្រះ-កម្មដ្ឋានក្នុងសំណាក់របស់ព្រះពុទ្ធទ្រង់គង់ព្រះជន្មនៅហើយ ទើបមក ។ ក៏ធម្មតាព្រះពុទ្ធទាំងឡាយ ដែលអ្នកណាៗ អ្នកអួតអាងសុម្បីត្រាច់ទៅតាមស្នាមព្រះបាទ ក៏មិនអាចឲ្យទ្រង់ប្រោស-ប្រាណបាន ។ (តែ)បុគ្គលដែលមានអធ្យាស្រ័យ ជាប្រក្រតី

ប៉ុណ្ណោះ អាចឲ្យទ្រង់ប្រោសប្រាណបាន លោកទាំងឡាយ ចូរជាអ្នកមិនប្រមាទចុះ ។ ពួកយើងមិនគួរឈរ មិនគួរអង្គុយក្នុងទីកន្លែងតែមួយជាមួយគ្នា ២ រូប ប៉ុន្តែថា ក្នុងកាលជាទីទំនុកបម្រុងព្រះថេរៈ ក្នុងវេលាល្ងាច និងកាលជាទីកិច្ចាចារក្នុងវេលាព្រឹកប៉ុណ្ណោះ ពួកយើងនឹងរួមគ្នា, (តែ) ក្នុងកាលដ៏សេសនឹងមិននៅរួមគ្នា ២ រូប ។

ក៏ម្យ៉ាងទៀត កាលភិក្ខុដែលមិនមានសេចក្ដីសប្បាយមកវាយគោំងក្នុងកណ្ដាលវិហារហើយ ពួកយើងទើបមកតាមសញ្ញានៃគោំង ហើយធ្វើថ្នាំឲ្យដល់ភិក្ខុនោះ ។

កាលភិក្ខុទាំងនោះ ធ្វើកតិកាគ្នាយ៉ាងនេះ, ថ្ងៃមួយឧបាសិកានោះឲ្យបុគ្គលកាន់កេសជ្ជៈទាំងឡាយ មានទឹកដោះថ្លានិងទឹកអំពៅជាដើម ដែលជនទាំងឡាយមានទាសៈនិងកម្មករជាដើម ហែហាមដើរទៅកាន់វិហារនោះ ក្នុងវេលាល្ងាច មិនឃើញភិក្ខុទាំងឡាយ ក្នុងកណ្ដាលវិហារហើយ ទើបសួរពួកបុរសថា "លោកម្ចាស់ទាំងឡាយ ចេញទៅក្នុងទីណាហ្ន៎" ? កាលពួកគេប្រាប់ថា "ម៉ែម្ចាស់ លោកម្ចាស់ទាំងឡាយជាអ្នកអង្គុយនៅក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃរបស់

ខ្លួនៗ (ប៉ុណ្ណោះ)" ទើបពោល(តទៅ)ថា "ខ្ញុំធ្វើយ៉ាងណាហ្ន៎ ទើបនឹងអាចជួប (ពួកលោកម្ចាស់) បាន" ។

លំដាប់នោះ មនុស្សទាំងឡាយដែលដឹងកតិកាវត្តរបស់ភិក្ខុសង្ឃ ទើបប្រាប់ចំពោះឧបាសិកានោះថា "លោកម្ចាស់ទាំងឡាយនឹងប្រជុំគ្នា ក្នុងកាលបុគ្គលមកវាយរគាំង" ។ នាងទើបឲ្យវាយរគាំង ភិក្ខុទាំងឡាយបានឮសំឡេងរគាំងហើយ ចេញអំពីទីកន្លែងរបស់ខ្លួនៗ ដោយសម្គាល់ថា "ភិក្ខុរូបខ្លះនឹងមិនមានសេចក្ដីសុខ" ។ ទើបប្រជុំគ្នាក្នុងកណ្ដាលវិហារ ។ ភិក្ខុឈ្មោះថាដើរមកដោយផ្លូវតែមួយជាមួយគ្នា សូម្បី ២ រូប រមែងមិនមាន។

ឧបាសិកាឃើញភិក្ខុមួយរូបៗ ប៉ុណ្ណោះ ដើរមកពីទីកន្លែងមួយៗ ទើបគិតថា "(ប្រហែលជា) លោកម្ចាស់ជាបុត្ររបស់យើងនឹងធ្វើការឈ្លោះ វិវាទដល់គ្នានឹងគ្នា" ដូច្នេះហើយថ្វាយ-បង្គំភិក្ខុសង្ឃ ពោលថា "លោកម្ចាស់ចម្រើន លោកទាំងឡាយបានធ្វើការឈ្លោះគ្នាឬ" ?

ភិក្ខុទាំងឡាយពោលថា "មហាឧបាសិកា ពួកអាត្មាមិនបានធ្វើការឈ្លោះ វិវាទគ្នាទេ" ។

ឧបាសិកា លោកម្ចាស់ដ៏ចម្រើន បើពួកលោកមិនមានការឈ្លោះវិវាទគ្នាទេ, កាលជាដូច្នោះ ហេតុអ្វីពួកលោកទើបមិនមកដូចកាលមកកាន់ផ្ទះរបស់ខ្ញុំម្ចាស់ មកដោយរួមគ្នាទាំងអស់, (នេះត្រឡប់) មកម្តងមួយអង្គៗ អំពីទីកន្លែងមួយៗ ។

ភិក្ខុ មហាឧបាសិកា ពួកអាត្មាអង្គុយធ្វើសមណធម៌ក្នុងទីកន្លែងមួយៗ ។

ឧបាសិកា បពិត្រព្រះគុណម្ចាស់ទាំងឡាយ ឈ្មោះថាសមណធម៌នោះគឺអ្វី ?

ភិក្ខុ មហាឧបាសិកា ពួកអាត្មាធ្វើការស្វាធ្យាយអាការ ៣២ ផ្តើមតាំងនូវការអស់ទៅ និងការសាបសូន្យក្នុងអត្តភាព ។

ឧបាសិកា លោកម្ចាស់ ការធ្វើការស្វាធ្យាយអាការ ៣២ និងការផ្តើមតាំងការអស់ទៅ ការសាបសូន្យក្នុងអត្តភាព រមែងសមគួរដល់ពួកលោកម្ចាស់ប៉ុណ្ណោះ ឬរមែងសមគួរដល់ពួកខ្ញុំម្ចាស់ផងហ្ន៎ ?

ភិក្ខុ មហាឧបាសិកា ធម៌នេះ ព្រះមានព្រះភាគមិនបានទ្រង់ហាមដល់អ្នកណាៗ ។

ឧបាសិកា បើយ៉ាងនោះ សូមពួកលោកចូរឲ្យអាការ ៣២ និងសូមប្រាប់ការផ្ដើមតាំងនូវការអស់ និងសេចក្ដីសាបសូន្យក្នុងអត្តភាពដល់ខ្ញុំម្ចាស់ខ្លះ ។

ភិក្ខុ មហាឧបាសិកា បើយ៉ាងនោះ លោកចូររៀនយក ។ ហើយឲ្យរៀនយកទាំងអស់ ។

ចាប់ផ្ដើមតាំងពីនោះ ឧបាសិកានោះ ក៏បានធ្វើការស្វាធ្យាយនូវអាការ ៣២ (និង) ផ្ដើមតាំងទុកនូវការអស់ទៅ និងសេចក្ដីសាបសូន្យទៅក្នុងខ្លួន បានសម្រេចមគ្គ ៣ ផល ៣ មុនភិក្ខុទាំងនោះតែម្ដង ។ បដិសម្ភិទា ៤ និងលោកិយអភិញ្ញា បានមកដល់ឧបាសិកានោះ ដោយមគ្គនុ៎ះឯង ។ នាងចេញចាកសុខដែលកើតអំពីមគ្គនិងផលហើយ ត្រួតមើលដោយទិព្វចក្ខុ ពិចារណាថា "កាលណាហ្ន៎ ? លោកម្ចាស់ជាបុត្ររបស់យើង ទើបនឹងសម្រេចធម៌នេះ" ហើយរំពឹង (តទៅ) ថា "លោកម្ចាស់ទាំងអស់នោះ នៅមានរាគៈ នៅមានទោសៈ នៅមានមោហៈ, លោកម្ចាស់ទាំងនោះ មិនបានមានគុណធម៌សូម្បីត្រឹមតែឈាន និងវិបស្សនាឡើយ ឧបនិស្ស័យនៃព្រះអរហត្តរបស់លោកម្ចាស់បុត្ររបស់យើង មានឬទេហ្ន៎ " ឃើញថា "មាន" ដូច្នេះហើយ

ទើបរំពឹង(តទៅ) ថា “សេនាសនៈជាទីសប្បាយមានឬមិនមានទេហ្ន៎ ” ឃើញសូម្បីសេនាសនៈជាទីសប្បាយហើយ ទើបរំពឹង (តទៅទៀត) ថា “លោកម្ចាស់ទាំងឡាយរបស់យើងមិនទាន់បានបុគ្គលជាទីសប្បាយឬហ្ន៎ ” ឃើញសូម្បីបុគ្គលជាទីសប្បាយហើយ ទើបពិចារណាថា “លោកម្ចាស់ទាំងឡាយ មិនទាន់បានអាហារជាទីសប្បាយឬហ្ន៎” ក៏បានឃើញថា អាហារជាទីសប្បាយមិនទាន់មានដល់ពួកលោក” ។ ចាប់ដើមតាំងពីនោះមក ក៏ចាត់ចែងយាគូនិងភត្ត និងរបស់ទំពាស៊ីជាអនេកនិងភោជនមានរសផ្សេងៗ ដ៏ប្រសើរ ហើយនិមន្តភិក្ខុទាំងឡាយឲ្យគង់ហើយទើបថ្វាយទឹកទក្ខិណោទក ។ ហើយបង្អោនថ្វាយដោយពាក្យថា “លោកម្ចាស់ដ៏ចម្រើន ពួកលោកម្ចាស់ពេញ-ចិត្តវត្ថុណាៗ សូមកាន់យកវត្ថុនោះៗ ឆាន់ចុះ ” ។

ភិក្ខុទាំងនោះ ទទួលយកវត្ថុទាំងឡាយមានបាយយាគូជាដើម ហើយបរិភោគតាមសេចក្ដីពេញចិត្ត ។

កាលភិក្ខុទាំងនោះ បានអាហារដែលជាទីសប្បាយ ចិត្តក៏ជាធម្មជាតិ មានអារម្មណ៍តែមួយ (តម្កល់មាំ) ។ ពួកលោកមានចិត្តតម្កល់មាំ ចម្រើនវិបស្សនា តមកកាលមិនយូរ ក៏បាន

សម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ហើយគិតថា "គួរអរគុណ ! មហាឧបាសិកា ជាទីពឹងរបស់ពួកយើង; បើពួកយើងមិនបានអាហារ ដែលជាទីសប្បាយហើយសោត, ការសម្រេចដល់មគ្គនិងផល គង់នឹងមិនបានមានដល់ពួកយើង; ឥឡូវនេះ ពួកយើងនៅចាំវស្សា បវារណាហើយ នឹងទៅកាន់សំណាក់របស់ព្រះសាស្តា" ។

ពួកលោកលាមហាឧបាសិកាថា "ពួកអាត្មា ប្រាថ្នានឹងគាល់ព្រះសាស្តា" ។ មហាឧបាសិកាពោលថា "ល្អហើយលោកម្ចាស់ទាំងឡាយ" ហើយតាមជូនដំណើរភិក្ខុទាំងនោះ, ពោលពាក្យដែលជាទីស្រឡាញ់ជាច្រើនថា "សូមលោកទាំងឡាយគប្បី(មក) សួរសុខទុក្ខ ខ្ញុំម្ចាស់ទៀត" ដូច្នេះជាដើម ហើយទើបត្រឡប់ ។

ចំណែកភិក្ខុទាំងនោះឯង ដល់ក្រុងសាវត្ថីហើយ ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីសមគួរមួយ ដែលព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ (សរីរយន្តមានចក្រ ៤ មានទ្វារ ៩) អ្នកទាំងឡាយល្មមអត់ធន់បានទេឬ ? ល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានស្រួលទេឬ ? មួយទៀត អ្នក

ទាំងឡាយ មិនលំបាកដោយបិណ្ឌបាតទេឬ ? ” ទើបក្រាបទូលថា “ខ្ញុំព្រះអង្គទាំងឡាយ ល្មមអត់ធន់បានព្រះអង្គ ល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានព្រះអង្គ, មួយទៀត ខ្ញុំព្រះអង្គទាំងឡាយ មិនបានលំបាកដោយបិណ្ឌបាតទេ, ព្រោះថាឧបាសិកាម្នាក់ ឈ្មោះមាតិកមាតា ជ្រាបវារៈចិត្តរបស់ពួកខ្ញុំព្រះអង្គ” ។ កាលពួកខ្ញុំព្រះអង្គគិតថា “ដូចម្ដេចហ្ន៎ មហាឧបាសិកា នឹងគប្បីចាត់ចែងអាហារឈ្មោះបែបនេះ ដើម្បីពួកយើង” ។ (នាង) ក៏បានចាត់ចែង អាហារថ្វាយតាមដែលពួកខ្ញុំព្រះអង្គគិតហើយ” ដូច្នេះហើយ ក៏ពោលសរសើរគុណរបស់មហាឧបាសិកានោះ ។

ភិក្ខុរូបណាមួយរូប ស្ដាប់ពាក្យសរសើរគុណរបស់មហាឧបាសិកានោះហើយ ជាអ្នកប្រាថ្នានឹងទៅក្នុងទីនោះ រៀនកម្មដ្ឋានក្នុងសំណាក់របស់ព្រះសាស្ដាហើយ ទូលលាព្រះសាស្ដាថា “បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងទៅកាន់ស្រុកនោះ” ហើយចេញចាកវត្តជេតពន ទៅដល់ស្រុកនោះដោយលំដាប់ ក្នុងថ្ងៃដែលខ្លួនចូលទៅកាន់វិហារ គិតថា “បានឮថា ឧបាសិកានេះ រមែងដឹងដល់ហេតុដែលបុគ្គលដទៃគិតហើយៗ ។ ក៏យើង

នឿយហត់ហើយ ក្នុងផ្ទៃនឹងមិនអាចបោសវិហារបាន, ដូចម្ដេចហ្ន៎ ឧបាសិកានេះនឹងគប្បីបញ្ជូនអ្នកជម្រះវិហារ មកដើម្បីយើង" ។ ឧបាសិកាអង្គុយក្នុងផ្ទះទ្រុំឯងវំពឹង ជ្រាបសេចក្ដីនោះហើយ ទើបបញ្ជូនមនុស្សទៅដោយពាក្យថា "អ្នកឯងចូរទៅជម្រះវិហារ ហើយទើបមក" ។

ចំណែកភិក្ខុក្រៅនេះ ចង់ផឹកទឹក ទើបគិតថា "ដូចម្ដេចហ្ន៎ ឧបាសិកានេះ គប្បីធ្វើទឹកផឹកលាយជុំស្ករត្នោត បញ្ជូនមកឲ្យដល់យើង" ។ ឧបាសិកាក៏បានបញ្ជូនទឹកនោះទៅឲ្យ ។ លោកគិត (ទៀត) ថា "សូមឧបាសិកា ចូរបញ្ជូនភត្តយាគូ មានរសប្រសើរ និងសម្លមកដើម្បីយើងក្នុងថ្ងៃស្អែកនេះ អំពីព្រឹកព្រលឹមចុះ" ។ ឧបាសិកាក៏បានធ្វើយ៉ាងនោះ ។ ភិក្ខុនោះ ឆាន់បបរយាគូហើយ គិតថា "ដូចម្ដេចហ្ន៎ ឧបាសិកាគប្បីបញ្ជូនរបស់ទំពាស៊ីបែបនេះ មកដើម្បីយើង" ។ ឧបាសិកាក៏បានបញ្ជូនរបស់ទំពាស្ងួម្បីនោះទៅហើយ លោកគិតថា "ឧបាសិកានេះ បញ្ជូនវត្ថុដែលយើងគិតហើយៗ គ្រប់ៗវត្ថុមក; យើងចង់ជួបឧបាសិកានោះ, ដូចម្ដេចហ្ន៎ នាងគប្បីឲ្យអ្នកកាន់ភោជនមានរសដ៏ប្រសើរផ្សេងៗដើម្បីយើង មកដោយខ្លួនឯងតែម្ដង" ។

ឧបាសិកាគិតថា “ភិក្ខុជាបុត្ររបស់យើង ប្រាថ្នានឹងឃើញយើង ប្រាថ្នាការទៅរបស់យើង” ដូច្នេះ ហើយទើបឲ្យមនុស្សក្រាន់កោជនទៅកាន់វិហារហើយ បានថ្វាយដល់ភិក្ខុនោះ ។

ភិក្ខុនោះធ្វើភត្តកិច្ចហើយ សួរថា “មហាឧបាសិកាលោកឬ ? ឈ្មោះថា មាតិកមាតា” ។

<u>ឧបាសិកា</u> ត្រូវហើយព្រះគុណម្ចាស់ ។

<u>ភិក្ខុ</u> ឧបាសិកា នាងជ្រាបចិត្តរបស់អ្នកដទៃឬ ?

<u>ឧបាសិកា</u> ព្រះគុណម្ចាស់ សួរនាងខ្ញុំធ្វើអ្វី ។

<u>ភិក្ខុ</u> ឧបាសិកាបានធ្វើវត្ថុគ្រប់យ៉ាង ដែលអាត្មាគិតហើយៗ, ព្រោះហេតុនោះ អាត្មាទើបសួរឧបាសិកា ។

<u>ឧបាសិកា</u> ព្រះគុណម្ចាស់ ភិក្ខុដែលដឹងចិត្តរបស់អ្នកដទៃក៏មានច្រើន ។

<u>ភិក្ខុ</u> អាត្មាមិនបានសួរដល់អ្នកដទៃ, សួរ(ចំពោះខ្លួន) នាងឧបាសិកា ។

សូម្បីយ៉ាងនោះ ឧបាសិកាក៏មិនបានប្រាប់ (ត្រង់ៗ) ថា “ខ្ញុំម្ចាស់ដឹងចិត្តរបស់អ្នកដទៃ” (ត្រឡប់) ពោលថា “កូនអើយ ធម្មតាមនុស្សទាំងឡាយអ្នកដឹងចិត្តរបស់អ្នកដទៃ រមែងធ្វើយ៉ាង

នោះបាន” ។

ភិក្ខុនោះគិតថា “កម្មនេះធ្ងន់ហ្ន៎ ធម្មតាបុថុជ្ជន រមែងគិតដល់អារម្មណ៍ដែលល្អខ្លះ មិនល្អខ្លះ; បើយើងគិតវត្ថុដែលមិនសមគួរហើយសោត, ឧបាសិកានេះ ក៏គប្បីញ៉ាំងយើងឲ្យដល់នូវប្រការដែលប្លែក ដូចចាប់ចោរត្រង់ផ្នូងសក់ ព្រមទាំងវត្ថុដូច្នោះ ; យើងគួរជៀសចេញទៅអំពីទីនេះ” ហើយពោលថា “ឧបាសិកា អាត្មានឹងលាទៅ” ។

ឧបាសិកា លោកនឹងទៅទីណា ព្រះគុណម្ចាស់ ។

ភិក្ខុ អាត្មានឹងទៅកាន់សំណាក់ព្រះសាស្តា ឧបាសិកា ។

ឧបាសិកា សូមលោកម្ចាស់ ចូរនៅក្នុងទីនេះសិនចុះ ។

ភិក្ខុនោះពោលថា “អាត្មានឹងមិននៅទេ ឧបាសិកា នឹងត្រូវទៅពិតប្រាកដ” ហើយបាននិមន្តចេញ (អំពីទីនោះ) ទៅកាន់សំណាក់របស់ព្រះសាស្តា ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរលោកថា ម្នាលភិក្ខុ អ្នកនៅក្នុងទីនោះ មិនបានទេឬ ?

ភិក្ខុ ជាយ៉ាងនោះព្រះអង្គ ខ្ញុំព្រះអង្គមិនអាចនៅក្នុងទីនោះបានទេ ។

ព្រះសាស្តា ម្នាលភិក្ខុ ព្រោះហេតុអ្វី ?

ភិក្ខុ បពិត្រព្រះអង្គដ៏ចម្រើន (ព្រោះថា) ឧបាសិកានោះរមែងដឹងរឿងដែលអ្នកដទៃគិតហើយៗ គ្រប់ប្រការ, ខ្ញុំព្រះអង្គគិតថា "ក៏ធម្មតាបុថុជ្ជន រមែងគិតអារម្មណ៍ដែលល្អខ្លះ មិនល្អខ្លះ; បើយើងនឹងគិតវត្ថុខ្លះដែលមិនសមគួរហើយសោត, ឧបាសិកានោះ ក៏នឹងញាំងយើងឲ្យដល់នូវប្រការដែលប្លែក ដូចចាប់ចោរត្រង់ផ្នួងសក់ ព្រមទាំងរបស់ដូច្នោះ" ដូច្នេះហើយទើបបានមក ។

ព្រះសាស្តា ម្នាលភិក្ខុ លោកគួរនៅក្នុងទីនោះឯង ។

ភិក្ខុ ខ្ញុំព្រះអង្គមិនអាចទេព្រះអង្គ ខ្ញុំព្រះអង្គនឹងនៅក្នុងទីនោះ មិនបានទេ ។

ព្រះសាស្តា ម្នាលភិក្ខុ បើយ៉ាងនោះ លោកនឹងអាចរក្សាវត្ថុមួយប៉ុណ្ណោះបានទេ ?

ភិក្ខុ បពិត្រព្រះអង្គ រក្សាអ្វី ?

ព្រះសាស្តា ត្រាស់ថា "លោកចូររក្សាចិត្តរបស់លោកនុ៎ះឯង ធម្មតាចិត្តនេះបុគ្គលរក្សាបានលំបាក, លោកចូរគ្រប់សង្កត់ចិត្តរបស់លោកទុកឲ្យបាន កុំគិតដល់អារម្មណ៍អ្វីៗ

យ៉ាងដទៃ, ធម្មតាចិត្តដែលបុគ្គលគ្របសង្កត់បានលំបាក” ដូច្នេះ ហើយទើបត្រាស់ព្រះគាថា នេះថា ៖

ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ
ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។

ការទូន្មានចិត្ត ដែលសង្កត់សង្កិនបានដោយលំបាក ជាធម្មជាតរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ រមែងជាគុណញុំាងប្រយោជន៍ឲ្យសម្រេច (ព្រោះថា) ចិត្តដែលហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្តីសុខ ។

## អធិប្បាយអត្ថគាថា

បណ្ឌិតគប្បីជ្រាបវិគ្រោះក្នុងព្រះគាថានោះ (ដូចតទៅនេះ) ។ ធម្មតាចិត្តនេះ ដែលបុគ្គលរមែងគ្របសង្កត់បានដោយលំបាក ព្រោះហេតុនោះ ទើបឈ្មោះថា ទុន្និគ្គហំ ។ ចិត្តនេះរមែងកើតនិងរលត់រហ័ស ព្រោះហេតុនោះ ទើបឈ្មោះថា លហុ នូវចិត្តដែលគ្របសង្កត់បានលំបាក ដែលកើតនិងរលត់រហ័ស នោះ ។

បាទព្រះគាថាថា យត្ថ កាមនិបាតិនោ សេចក្ដីថា រមែងធ្លាក់ទៅក្នុងអារម្មណ៍ណាមួយនុ៎ះឯង ។ ពិតមែន ចិត្តនេះ រមែងមិនស្គាល់ឋានៈដែលខ្លួនគួរបាន ឬឋានៈដែលមិនគួរបាន, ឋានៈដែលសមគួរ ឬឋានៈដែលមិនសមគួរ រមែងមិនពិចារណាមើលជាតិ មិនពិចារណាមើលគោត្រ មិនពិចារណាមើលវ័យ; រមែងធ្លាក់ទៅក្នុងអារម្មណ៍ដែលខ្លួនប្រាថ្នាតែម្យ៉ាង ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា "រមែងធ្លាក់ទៅក្នុងអារម្មណ៍តាមសេចក្ដីប្រាថ្នា" ។

ការហ្វឹកហ្វឺនចិត្តបែបនេះនោះ ជាការល្អ គឺសេចក្ដីដែលចិត្តរបស់បុគ្គលហ្វឹកហាត់ដោយអរិយមគ្គ ៤ គឺ សោតាបត្តិមគ្គ ១ សកទាគាមិមគ្គ ១ អនាគាមិមគ្គ ១ អរហត្តមគ្គ បានដល់ភាពនៃចិត្តដែលបុគ្គលធ្វើហើយ ដោយប្រការដែលចិត្តអស់អស្មិមានះបានជាការល្អ ។

សួរថា "ព្រោះហេតុអ្វី" ឆ្លើយថា "ព្រោះថា ចិត្តនេះដែលបុគ្គលទូន្មានហើយ រមែងជាហេតុនាំសុខមកឲ្យ គឺថា ចិត្តដែលបុគ្គលទូន្មានហើយ បានដល់ ធ្វើឲ្យអស់អស្មិមានះ រមែងនាំមក

នូវសេចក្ដីសុខ ដែលកើតអំពីមគ្គផល និងសុខគឺព្រះនិព្វាន ដែលជាបរមត្ថ ។

ក្នុងកាលចប់ទេសនា បរិស័ទដែលមកប្រជុំគ្នាជាច្រើន បានជាអរិយបុគ្គលមានព្រះសោតាបន្នជាដើម, ទេសនាសម្រេចប្រយោជន៍ដល់មហាជនហើយ ។

## ភិក្ខុនោះត្រឡប់ទៅកាន់មាតិកគ្រាមទៀត

ព្រះសាស្ដា កាលប្រទានឱវាទនេះ ដល់ភិក្ខុនោះហើយ ទើបទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា “ទៅចុះភិក្ខុ លោកកុំគិតអ្វីៗដទៃ ចូរនៅក្នុងទីនោះឯង” ។ ភិក្ខុនោះ បានព្រះឱវាទអំពីសំណាក់របស់ព្រះសាស្ដាហើយ ទើបបានទៅ(នៅ) ក្នុងទីនោះ, មិនបានគិតអ្វីៗ ដែលជវនឲ្យគិតខាងក្រៅឡើយ ។

ចំណែកមហាឧបាសិកា កាលត្រួតមើលដោយទិព្វចក្ខុក៏ឃើញព្រះថេរៈហើយកំណត់ (ដឹង) ដោយញាណរបស់ខ្លួនទុំះឯងថា “ឥឡូវនេះ ភិក្ខុជាបុត្ររបស់យើងបានអាចារ្យឲ្យឱវាទហើយ ទើបត្រឡប់មកទៀត” ហើយបានចាត់ចែងអាហារដែលជាទីសប្បាយ ថ្វាយដល់ព្រះថេរៈនោះ ។

ព្រះថេរៈនោះ បានភោជនដែលជាទីសប្បាយហើយ

ដោយ ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចព្រះអរហត្ត ស្ថិតនៅដោយសេចក្តីសុខដែលកើតអំពីមគ្គនិងផល គិតថា "គួរអរ-គុណមហាឧបាសិកា បានជាទីពឹងរបស់យើងហើយ យើងអាស្រ័យមហាឧបាសិកានេះ ទើបដល់នូវការត្រាច់ចេញចាកភពបាន, ហើយពិចារណាថា មហាឧបាសិកានេះ បានជាទីពឹងរបស់យើង ក្នុងអត្តភាពនេះ, ក៏កាលយើងត្រាច់អន្ទោលនៅក្នុងសង្សារ មហាឧបាសិកានោះធ្លាប់ជាទីពឹងក្នុងអត្តភាពសូម្បីដទៃៗ ឬទេ ? ហើយទើបតាមរលឹកទៅរហូតដល់អស់ ៩៩ អត្តភាព ។

សូម្បីមហាឧបាសិកានោះ ក៏ជានាងបាទបរិចារិការបស់ព្រះថេរៈនោះ ក្នុងអត្តភាពទី ៩៩ ជាអ្នកមានចិត្តប្រតិព័ទ្ធក្នុងប្រុសពួកដទៃ ទើបឲ្យសម្លាប់ព្រះថេរៈនោះចេញចាកជីវិត ។ ព្រះថេរៈ គ្រាឃើញទោសរបស់មហាឧបាសិកានោះ ត្រឹមតែប៉ុណ្ណោះហើយ ទើបគិតថា "គួរសង្វេគ មហាឧបាសិកានេះបានធ្វើកម្មធ្ងន់មកហើយ" ។

ចំណែកមហាឧបាសិកាអង្គុយក្នុងផ្ទះទុំឯង ពិចារណាថា កិច្ចនៃបព្វជិតរបស់ភិក្ខុជាបុត្ររបស់យើង ដល់ទីបំផុតហើយឬ

នៅហ្ន៎ ? ជ្រាបថា ព្រះថេរៈនោះសម្រេចព្រះអរហត្តហើយ ទើបពិចារណាក្រៃលែងឡើងទៅ ក៏ជ្រាបថា ភិក្ខុជាបុត្ររបស់យើងសម្រេចព្រះអរហត្តហើយ គិតថា គួររីករាយចិត្តពិត ឧបាសិកានេះ បានជាទីពឹងរបស់យើងយ៉ាងសំខាន់ ដូច្នេះហើយពិចារណា (តទៅទៀត) ថា "សូម្បីក្នុងកាលកន្លងហើយ ឧបាសិកានេះធ្លាប់បានជាទីពឹងរបស់យើងឬទេហ្ន៎ " ? តាមរលឹកទៅរហូតដល់អស់ ៩៩ អត្តភាព; តែយើង(នេះ)ឯងបានសេពគប់នឹងប្រុសពួកដទៃ សម្លាប់ព្រះថេរៈនោះចេញចាកជីវិតក្នុងអត្តភាពទី ៩៩, ព្រះថេរៈនេះ ក្រឡេកឃើញទោសមានប្រមាណប៉ុណ្ណោះរបស់យើងហើយ គិតថា "គួរសង្វេគឧបាសិកា បានធ្វើកម្មធ្ងន់ហើយ" នាងពិចារណា (តទៅ) ថា "យើងកាលត្រាច់អន្ទោលនៅក្នុងសង្សារ យើងមិនធ្លាប់បានធ្វើឧបការៈដល់ភិក្ខុអ្នកជាបុត្រឡើយឬហ្ន៎" ? បានរលឹកដល់អត្តភាពទី ១០០ ដែលក្រៃលែងជាង ៩៩ អត្តភាពនោះ ក៏ជ្រាបថា "ក្នុងអត្តភាពទី ១០០ យើងជាបាទបរិចារិកានៃព្រះថេរៈនោះ បានឲ្យជីវិតទានក្នុងស្ថានជាទីផ្ដាច់ចាកជីវិតមួយកន្លែង ។ គួរសប្បាយចិត្ត យើងធ្វើឧបការៈច្រើនដល់ភិក្ខុជាបុត្ររបស់យើង អន្ទុយ

*នៅក្នុងផ្ទះនុ៎ះឯង ពោលថា "សូមលោកម្ចាស់ ចូរពិចារណាមើលឲ្យវិសេសក្រៃលែងឡើង" ។*

*ព្រះថេរៈនោះ បានស្តាប់សំឡេង (របស់ឧបាសិកានោះ) ដោយសោតធាតុដែលជាទិព្វហើយ រលឹកដល់អត្តភាពទី ១០០ ឲ្យវិសេសឡើង ហើយឃើញសេចក្តីដែលឧបាសិកានោះបានឲ្យជីវិតដល់ខ្លួនក្នុងអត្តភាពនោះ ទើបគិតថា "គួរសប្បាយចិត្តឧបាសិកាធ្លាប់បានធ្វើឧបការៈដល់យើង" ដូច្នេះហើយមានចិត្តរីករាយ ពោលបញ្ហាក្នុងមគ្គ ៤ ផល ៤ ដល់ឧបាសិកា ក្នុងទីនោះឯង បានបរិនិព្វានហើយ ដោយនិព្វានធាតុដែលជាអនុបាទិសេស ។*

*រឿង ភិក្ខុរូបណាមួយ ចប់ ។*

## ១២.រឿងសត្វ៣

*(វិនយបិដក ភាគ១០ ទំព័រ៣១៤)*

*គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំង-ឡាយថា ម្នាលភិក្ខុទាំងឡាយហេតុ (នេះ) ធ្លាប់មានមកហើយ នៅខាងហិមវន្តប្បទេសមានដើមជ្រៃធំ ១ ដើម ។ សត្វ ៣ តួគឺ*

ទទា ១ ស្វា ១ ដំរី ១ ជាសម្លាញ់នឹងគ្នាតែងនៅអាស្រ័យនឹងដើមជ្រៃធំនោះ ។ សត្វទាំងនោះ មិនគោរព មិនកោតក្រែង មិនប្រព្រឹត្តស្មោះស្មើទៅវិញទៅមករកគ្នាឡើយ ។ ម្នាលភិក្ខុទាំងឡាយ សត្វជាសម្លាញ់នឹងគ្នាទាំងនោះ មានសេចក្តីត្រិះរិះថា ពួកយើងធ្វើម្តេចនឹងដឹងពិតថា នរណាជាធំពីកំណើតជាងយើងៗ ត្រូវធ្វើសក្ការៈ ធ្វើសេចក្តីគោរពរាប់អាន បូជាអ្នកនោះម្យ៉ាងទៀត យើងត្រូវឋិតនៅក្នុងឱវាទរបស់អ្នកនោះ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទទានឹងស្វាសួរដំរីថា ម្នាលសម្លាញ់ អ្នកបានរលឹកឃើញហេតុពីមុនដូចម្តេច ។ ដំរីឆ្លើយថា ម្នាលសម្លាញ់ទាំងឡាយ កាលដែលខ្ញុំនៅតូច ខ្ញុំធ្វើដើមជ្រៃនេះ ក្នុងចន្លោះភ្លៅទាំងពីរហើយដើរទៅ ចុងត្រួយ (ជ្រៃនេះ) ទល់នឹងពោះខ្ញុំ ម្នាលសម្លាញ់ទាំងឡាយ ខ្ញុំរលឹកឃើញនូវហេតុពីរមុនដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ កាលនោះទទា និងដំរីសួរស្វាថា ម្នាលសម្លាញ់ អ្នករលឹកឃើញហេតុពីមុនដូចម្តេចខ្លះ ។ ស្វាឆ្លើយថា ម្នាលសម្លាញ់ទាំងឡាយ កាលដែលខ្ញុំនៅតូច ខ្ញុំអង្គុយលើផែនដី ហើយទំពាស៊ីត្រួយជ្រៃនេះ ម្នាលសម្លាញ់ទាំងឡាយ ខ្ញុំរលឹកឃើញហេតុពីមុនដូច្នេះ ។

ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្វានិងដំរីសួរទៅទទាថា ម្នាលសម្លាញ់ អ្នករលឹកឃើញហេតុពីមុនដូម្តេចខ្លះ ។ ទទាឆ្លើយថា ម្នាលសម្លាញ់ទាំងឡាយ ក្នុងទីឯណោះ មានដើមជ្រៃធំ ១ ដើម ខ្ញុំស៊ីផ្លែរួចហើយ ហើរមកអំពីនោះ មកបន្ទោបង់វច្ចៈក្នុងឱកាសនេះ ជ្រៃនេះក៏កើតអំពីវច្ចៈរបស់ខ្ញុំ ម្នាលសម្លាញ់ទាំងឡាយ ខ្ញុំជាសត្វធំពីកំណើត តាំងអំពីកាលនោះមក ។ ម្នាលភិក្ខុទាំងឡាយ ស្វានិងដំរីបានពោលពាក្យនេះនឹងទទាថា ម្នាលសម្លាញ់ អ្នកជាធំពីកំណើតជាងយើង យើងនិងធ្វើសក្ការគោរពរាប់អានបូជាអ្នក មួយទៀត យើងនឹងតាំងនៅក្នុងឱវាទរបស់អ្នក ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទទាឲ្យស្វា និងដំរីកាន់សីលទាំង ៥ ហើយសមាទាន ប្រព្រឹត្តសីលទាំង ៥ ដោយខ្លួនឯង ។ សត្វទាំងឡាយនោះ គោរពកោតក្រែងប្រព្រឹត្តស្មោះស្មើទៅវិញទៅមករកគ្នា លុះទំលាយខន្ធ ទៅកាន់លោកខាងមុខ ក៏បានទៅក្នុងសុគតិ គឺឋានសួគ៌ ។ ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយធម៌នុ៎ះឯង ឈ្មោះតិត្តិរិយព្រហ្មចរិយៈ ។

យេ វុឌ្ឍមបចាយន្តិ នរា ធម្មស្ស កោវិទា
ទិដ្ឋេ ធម្មេ ច បាសំសា សម្បរាយោ ច សុគ្គតី។

ពួកជនដែលឈ្លាសក្នុងធម៌ គោរពក្រែងចាស់ព្រឹទ្ធាចារ្យ រមែងបានសេចក្ដីសរសើរក្នុងបច្ចុប្បន្នផង បានសុគតិក្នុងបរលោកផង ។

## ១៣_ទូតជាតក

*(សុត្តន្តបិដក ៥៨,១៤៦; អដ្ឋកថា ៥៨,៨៩)*

ព្រះសាស្ដាកាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធលោលភិក្ខុមួយរូប ទើបត្រាស់រឿងនេះ មានពាក្យចាប់ផ្ដើមថា **យស្សត្ថា ទូរមាយន្តិ** ដូច្នេះ ។ រឿងនឹងមានច្បាស់ក្នុងកាកជាតក នវកនិបាត ។ ក៏ព្រះសាស្ដាត្រាស់ហៅភិក្ខុរូបនោះមកត្រាស់ថា ម្នាលភិក្ខុ លោកជាអ្នកលោភចំពោះក្នុងឥឡូវនេះក៏ទេ សូម្បីក្នុងកាលមុន លោកក៏ជាអ្នកលោភ ក៏ព្រោះសេចក្ដីជាអ្នកលោភនោះឯង ជួនជានឹងត្រូវកាត់សីសៈដោយដាវ ។ ហើយទ្រង់នាំរឿងក្នុងអតីតមកសាធក ដូចតទៅនេះ ៖

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិនៅក្នុងព្រះនគរពារាណសី ព្រះពោធិសត្វជាឱរសរបស់ព្រះបាទព្រហ្មទត្តនោះ លូមចម្រើនវ័យក៏បានរៀនសូត្រសិល្ប-

សាស្ត្រទាំងពួង ក្នុងក្រុងតក្កសិលា លុះមព្រះជនកកន្ទងកំបាំងទៅ ក៏បានតាំងនៅក្នុងរាជសម្បត្តិ បានសោយភោជនដែលបរិសុទ្ធិ ដោយហេតុនោះ ព្រះអង្គទើបមានព្រះនាមថា ព្រះ-បាទភោជនសុទ្ធិករាជ ។ បានឮថា ព្រះអង្គទ្រង់តាំងនៅក្នុងវិធីការបែបនោះ សោយព្រះក្រយាហារដែលមានភាជនៈក្នុងមួយចំណាយអស់តម្លៃដល់ទៅមួយសែនកហាបណៈ មួយទៀតកាលសោយក៏មិនសោយខាងក្នុងព្រះរាជមណ្ឌប ព្រោះមានប្រាថ្នានឹងឲ្យមហាជន ដែលបានឃើញវិធីការសោយរបស់ព្រះអង្គ បានធ្វើបុណ្យ ទើបឲ្យសាងរតនមណ្ឌបត្រង់ទ្វារព្រះ-រាជវាំង វេលានឹងសោយក៏ឲ្យប្រដាប់រតនមណ្ឌបនោះ ហើយប្រថាប់អង្គុយលើរាជបល្ល័ង្កដែលសម្រេចដោយមាស ខាង-ក្រោមស្វេតច្ឆត្រ ហែហមដោយនាងក្សត្រិយ៍ទាំងឡាយ ទើបសោយព្រះក្រយាហារដែលមានរស ដែលមានតម្លៃដល់ទៅមួយសែនកហាបណៈ ដោយភាជនៈមាស ដែលមានតម្លៃមួយសែនកហាបណៈ ។

គ្រានោះ មានលោលបុរសម្នាក់ បានឃើញវិធីសោយ

ព្រះក្រយាហាររបស់ព្រះរាជានោះ ចង់នឹងបរិភោគភោជននោះ កាលមិនអាចនឹងអត់ទ្រាំសេចក្ដីប្រាថ្នាបាន គិតថា ឧបាយនេះល្អ ទើបស្លៀកសំពត់ឲ្យមាំហើយលើកដៃឡើងម្នាងស្រែកសំឡេងខ្លាំងៗ ថា លោកដ៏ចម្រើនទាំងឡាយ យើងជាទូតបណ្ដើរចូលទៅគាល់ព្រះរាជា ។ ក៏សម័យនោះ ក្នុងជនបទនោះ អ្នកណាៗ រមែងហាមអ្នកដែលពោលថា យើងជាទូត ព្រោះដូច្នោះ មហាជនទើបញែកចេញជាពីរផ្នែក ឲ្យឱកាស ។ បុរសនោះ ប្រញាប់ទៅស្រវាចាប់យកដុំកត្តមួយអំពីភាជនៈមាសរបស់ព្រះរាជាដាក់មាត់ ។ លំដាប់នោះ ទាហានដាវ នាំដាវចេញដោយប្រាថ្នានឹងកាត់ក្បាលរបស់បុរសនោះ ។ ព្រះ-រាជា ត្រាស់ហាមថា កុំប្រហារ ហើយត្រាស់ថា បាកុំខ្លាច ចូរបរិភោគចុះ ហើយទ្រង់លាងព្រះហស្ដប្រថាប់គង់ ។ ក៏ក្នុងវេលាសម្រេចអស់ការបរិភោគ ព្រះរាជាឲ្យប្រទានទឹកផឹក និងស្លាម្លូ ដល់បុរសនោះ ហើយត្រាស់សួរថា បុរសដ៏ចម្រើន បាពោលថា ជាទូត បាឯងជាទូតរបស់អ្នកណា ។ បុរសនោះក្រាបទូលថា បពិត្រមហារាជ ខ្ញុំព្រះអង្គ ជាទូតរបស់តណ្ហា តណ្ហាតាំងខ្ញុំព្រះអង្គឲ្យជាទូតហើយបង្គាប់បញ្ជូនមកថា បាចូរ

ទៅ ដូច្នេះហើយបានពោលគាថា ២ គាថា ដំបូងថា ៖

សត្វទាំងឡាយមកកាន់ប្រទេសឆ្ងាយ ដើម្បីសូមនូវវត្ថុនឹងបុគ្គលសូម្បីជាសត្រូវ ដើម្បីប្រយោជន៍ដល់ផ្ទៃណា ខ្ញុំព្រះអង្គជាទូតរបស់ផ្ទៃនោះ បពិត្រព្រះអង្គប្រសើរក្នុងពលរថ សូមទ្រង់កុំខ្ញាល់នឹងខ្ញុំព្រះអង្គឡើយ ។

មាណពទាំងឡាយ លុះអំណាចនៃផ្ទៃណា ទាំងថ្ងៃទាំងយប់ ខ្ញុំព្រះអង្គជាទូតរបស់ផ្ទៃនោះ បពិត្រព្រះអង្គប្រសើក្នុងពលរថ សូមទ្រង់កុំខ្ញាល់នឹងខ្ញុំព្រះអង្គឡើយ ។

បណ្ដាបទទាំងនោះ បទថា យស្សត្ថា ទូរមាយន្តិ សេចក្ដីថា សត្វទាំងនេះជាអ្នកនៅក្នុងអំណាចរបស់តណ្ហា រមែងទៅសូម្បីឆ្ងាយៗ ដើម្បីប្រយោជន៍ដល់ផ្ទៃណា ។ បទថា រថេសភ បានដល់ បពិត្រព្រះអង្គអ្នកប្រសើរជាងទ័ពរថ ។

ព្រះរាជាទ្រង់បានស្ដាប់ពាក្យរបស់បុរសនោះហើយ ទ្រង់ព្រះតម្រិះថា សេចក្ដីនេះពិត សត្វទាំងនេះជាទូតរបស់ផ្ទៃ ត្រាច់ទៅដោយអំណាចតណ្ហា និងតណ្ហាក៏រមែងចាត់ចែងសត្វទាំងនេះ បុរសនេះពោលពាក្យជាទីពេញចិត្តយើងក្រៃលែងណាស់

ទើបទ្រង់មេត្តា ដល់បុរសនោះ ត្រាស់ព្រះគាថាទី ៣ ថា ៖

ម្នាលព្រាហ្មណ៍ យើងឲ្យនូវគោសម្បុរក្រហម ១ ពាន់ ព្រមទាំងគោបាដល់អ្នក ព្រោះយើងជាទូត (របស់ផ្ទៃ) នឹង មិនឲ្យដល់អ្នកជាទូត (របស់ផ្ទៃដែរ) ដូចម្ដេចកើត យើងទាំងឡាយ សុទ្ធតែជាទូតរបស់ផ្ទៃដូចគ្នា ។

បទថា ព្រាហ្មណ នេះ ក្នុងគាថានោះ ត្រឹមតែជាពាក្យ ហៅ ។ បទថា រោហិណីនំ ប្រែថា មានពណ៌ក្រហម ។ បទថា សហ បុង្គវេន បានដល់ ព្រមនឹងគោដែលជាបរិ-នាយកមេហ្វូងដែលនឹងការពារអន្តរាយឲ្យ ។ បទថា មយម្បិ សេចក្ដីថា យើងនិងសត្វទាំងពួងដ៏សេស រមែងជាទូតរបស់ផ្ទៃនោះដូចគ្នា ព្រោះដូច្នោះ យើងជាទូតរបស់ផ្ទៃស្មើគ្នា ព្រោះហេតុអ្វី ទើបនឹងមិនឲ្យដល់អ្នកជាទូតរបស់ផ្ទៃហ្ន៎ ។

ក៏ឯគ្រាត្រាស់យ៉ាងនេះហើយ ទ្រង់មានព្រះទ័យត្រេកអរ ថា បុរសដូចលោកនេះឯង ឲ្យយើងបានស្ដាប់ហេតុដែល មិនធ្លាប់ស្ដាប់ ទើបបានប្រទានយសធំដល់បុរសនោះ ។

ព្រះសាស្ដា គ្រាទ្រង់នាំព្រះធម៌ទេសនានេះមកហើយ ទ្រង់

ប្រកាសសច្ចៈ ប្រជុំជាតក ។ ក្នុងវេលាចប់សច្ចៈ លោលភិក្ខុ តាំងនៅក្នុងអនាគាមិផល ។ ជនជាច្រើនបានជាព្រះសោតាបន្ន ជាដើម ។ លោលបុរិស ក្នុងកាលនោះ បានជាលោលភិក្ខុ ក្នុងឥឡូវនេះ ចំណែកព្រះបាទកោជនសុទ្ធិករាជ បានជាយើង តថាគត ដូច្នេះឯង ។

ចប់ ទូតជាតក ។

## ១៤_មហាធម្មបាលជាតក

(សុត្តន្តបិដក លេខ៥៩ ទំព័រ១៨៩)

ព្រះសាស្ដា កាលស្ដេចទៅព្រះនគរកបិលវត្ថុជាដំបូង គង់នៅនិគ្រោធារាម ទ្រង់ប្រារព្ធការមិនជឿរបស់ព្រះពុទ្ធបិតា ក្នុងព្រះរាជនិវេសន៍ ទើបត្រាស់រឿងនេះ មានពាក្យចាប់ផ្ដើមថា កិំវត្តេ វតំ ដូច្នេះ ។

សេចក្ដីសង្ខេបថា គ្រានោះព្រះបាទសុទ្ធោទនមហារាជ ថ្វាយបាយយាគូ និងខាទនីយៈចំពោះព្រះមានព្រះភាគ ព្រមទាំង ភិក្ខុ ២០,០០០ រូប ជាបរិវារក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គ កាលទ្រង់ធ្វើសម្មោទនីយកថាក្នុងចន្លោះភត្ត បានត្រាស់ថា ព្រះ-

អង្គវេលាដែលព្រះអង្គធ្វើសេចក្ដីព្យាយាម មានពួកទេវតាមកឈរក្នុងអាកាសប្រាប់ដល់ខ្ញុំព្រះអង្គថា សិទ្ធត្ថកុមារឱរសរបស់ព្រះអង្គ អស់ព្រះជន្មហើយ ព្រោះសោយព្រះក្រយាហារតិច, កាលព្រះសាស្ដាត្រាស់ថា មហាបពិត្រ ព្រះអង្គទ្រង់ជឿឬ ? ទើបទ្រង់ត្រាស់ថា ខ្ញុំព្រះអង្គមិនជឿទេព្រះអង្គ ទាំងហាមទេវតាដែលឈរពោលនៅក្នុងអាកាសទៀតថា ព្រះឱរសរបស់យើងមិនទាន់បានត្រាស់ជាព្រះពុទ្ធ ទៀបគល់ពោធិព្រឹក្សហើយ នឹងមិនទាន់បរិនិព្វាន ព្រះសាស្ដាត្រាស់ថា មហាបពិត្រ ក្នុងឥឡូវនេះព្រះអង្គនឹងទ្រង់មិនបានជឿយ៉ាងណា សូម្បីក្នុងកាលមុន កាលខ្ញុំព្រះអង្គកើតជាមហាធម្មបាលកុមារ កាលអាចារ្យទិសាបាមោក្ខយកឆ្អឹងពពែមកសម្ដែងប្រាប់ថា បុត្ររបស់លោកស្លាប់ហើយនេះឆ្អឹងបុត្ររបស់លោក ព្រះអង្គក៏ទ្រង់មិនបានជឿ ពោលនឹងអាចារ្យថា ក្នុងត្រកូលរបស់យើងនេះនឹងស្លាប់កំពុងនៅកំលោះនោះ មិនមានទេ, ក៏ហេតុអ្វីក្នុងឥឡូវនេះព្រះអង្គនឹងទ្រង់ជឿហ្ន៎ ? ព្រះពុទ្ធបិតាទូលអារាធនាឲ្យត្រាស់រឿងរ៉ាវ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធក ដូចតទៅនេះ ៖

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិ

នៅក្នុងនគរពារាណសី មានស្រុកធម្មបាលគ្រាម ក្នុងដែនកាសី ស្រុកនោះដែលបានឈ្មោះយ៉ាងនោះ ព្រោះជាទីនៅរបស់ត្រកូលធម្មបាលព្រាហ្មណ៍ ដែលនៅអាស្រ័យក្នុងស្រុកនោះ ប្រាកដឈ្មោះថា ធម្មបាល ព្រោះហេតុដែលរក្សាធម៌ គឺកុសលកម្មបថ ១០ ក្នុងត្រកូលរបស់គេ ដោយហោចទៅសូម្បីទាសៈនិងកម្មករក៏ឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ។

គ្រានោះ ព្រះពោធិសត្វកើតក្នុងត្រកូលនោះ បានទាមថា ធម្មបាលកុមារ គ្រាចម្រើនវ័យហើយ បិតាបានឲ្យទ្រព្យ ១ ពាន់ បញ្ជូនទៅរៀនសិល្បៈក្នុងក្រុងតក្កសិលា ធម្មបាលកុមារ ទៅក្នុងទីនោះ ហើយរៀនសិល្បៈក្នុងសំណាក់របស់អាចារ្យទិសាបាមោក្ខ បានជាប្រធានមាណពពួកអន្តេវាសិក ៥០០ នាក់ គ្រានោះបុត្រដ៏ប្រសើររបស់អាចារ្យស្លាប់ អាចារ្យមានសិស្សមាណពហែហម ព្រមដោយពួកញាតស្រែកយំ ខ្សឹកខ្សួល ធ្វើឈាបនកិច្ចសាកសពបុត្រក្នុងព្រៃជាទីចោលសាកសព ទាំងអាចារ្យទាំងសិស្ស និងពួកញាតស្រែកយំ ខ្សឹកខ្សួលនៅក្នុងទីនោះ ធម្មបាលម្នាក់ប៉ុណ្ណោះ មិនស្រែកយំ មិនខ្សឹកខ្សួល កាលមាណព ៥០០ នាក់នោះ មកពីព្រៃជាទីចោលសាកសព

ហើយ បាននាំគ្នាទៅអង្គុយរៀបរាប់នៅក្នុងសំណាក់អាចារ្យថា "អហោ ឋវេរូចោ ធាម អាចារសម្បន្នោ តរុណមាណវោ តរុណកាលេយេវ មាតាបិតូហិ វិប្បយុត្តោ មរណប្បត្តោ ឱហ្ន៍ មិនគួរបើសោះ មាណពកំលោះបរិបូរណ៍ដោយមារយាទ បែបនេះ ព្រាត់ប្រាសចាកមាតាបិតា ដល់នូវសេចក្តីស្លាប់តាំងពីនៅកំលោះតែម្តង" ធម្មបាលកុមារពោលថា "សម្មា, តុម្ហេ តរុណោ"តិ ភណថ, អថ កស្មា តរុណកាលេយេវ មរតិ, ននុ អយុត្តំ តរុណកាលេ មរិតុំ : សម្លាញ់លោកទាំងឡាយពោលថា នៅកំលោះក៏ហេតុអ្វីហ្ន៍ ទើបបាន ស្លាប់ តាំងពីនៅកំលោះ វេលាកំលោះមិនទាន់គួរស្លាប់មិនមែនទេឬ ?" ។

មាណពទាំងនោះ ពោលនឹងធម្មបាលកុមារថា នែសម្លាញ់ អ្នកមិនដឹងសេចក្តីស្លាប់របស់សត្វទាំងនេះទេឬ ?

ធម្មបាលកុមារ យើងដឹង តែមិនមានអ្នកណាស្លាប់តាំងពីនៅកំលោះ ស្លាប់កាលចាស់ហើយទាំងនោះ ។

<u>មាណពទាំងឡាយ</u> សង្ខារទាំងពួង មិនទៀង មានហើយ ត្រឡប់ជាមិនមាន មិនមែនឬ ?

ធម្មបាលកុមារ ពិតមែន សង្ខារមិនទៀងទេ តែសត្វទាំងឡាយ មិនមែនស្លាប់តាំងពីនៅកំលោះទេ ស្លាប់កាលដែលចាស់ហើយ ដល់នូវសេចក្តីមិនទៀង ។

មាណពទាំងឡាយ នែសម្លាញ់ធម្មបាល ក្នុងផ្ទះរបស់លោក មិនមានអ្នកណាស្លាប់ទេឬ ?

ធម្មបាលកុមារ ដែលស្លាប់ពីកំលោះមិនមានទេ មានតែស្លាប់ក្នុងកាលដែលចាស់ហើយប៉ុណ្ណោះ ។

មាណពទាំងឡាយ ហេតុនេះជាប្រពៃណីនៃត្រកូលរបស់លោកឬ ? ធម្មបាលកុមារ ត្រូវហើយ ជាប្រពៃណីនៃត្រកូលរបស់យើង ។

មាណពទាំងឡាយ បានស្តាប់ពាក្យរបស់ធម្មបាលកុមារដូច្នោះហើយ ទើបនាំគ្នាប្រាប់ដល់អាចារ្យ អាចារ្យហៅធម្មបាលកុមារមក សួរថា នែធម្មបាល បានឮថា ក្នុងត្រកូលរបស់អ្នកមិនមានអ្នកស្លាប់ពីកំលោះពិតមែនឬ ? ធម្មបាលកុមារ ឆ្លើយថាពិតមែន លោកអាចារ្យស្តាប់ពាក្យរបស់គេហើយ គិតថា កុមារនេះ និយាយអស្ចារ្យហួសប្រមាណ យើងនឹងទៅសំណាក់បិតារបស់កុមារនេះសួរមើល បើពិតប្រាកដ យើងនឹងបំពេញធម៌

ដូច្នោះខ្វះ អាចារ្យនោះកាលធ្វើឈាបនកិច្ចសាកសពបុត្រស្រេច ហើយ កន្លងមកបាន ៧-៨ ថ្ងៃ បានហៅធម្មបាលកុមារមក បង្គាប់ថា នែបា យើងនឹងទៅ អ្នកឯងចូរប្រាប់សិល្បៈដល់មាណពទាំងនេះ ដរាបយើងនឹងត្រឡប់មក បង្គាប់ហើយ ក៏ដាក់ឆ្អឹងពពែ ១ មកលាង យកដាក់កញ្ចប់ ឲ្យអ្នកបម្រើម្នាក់កាន់តាមទៅ ចេញពីក្រុងតក្កសិលា ទៅដោយលំដាប់ដល់ស្រុកនោះ ត្រាច់សួរដល់ផ្ទះរបស់មហាធម្មបាលថា ផ្ទះខ្លួនណា ដឹងហើយ ក៏ទៅឈរទៀបទ្វារ ។

ពួកទាសៈរបស់ព្រាហ្មណ៍ដែលឃើញមុន ក៏ទទួលឆត្រ ទទួលស្បែកជើងពីដៃរបស់អាចារ្យ និងទទួលកញ្ចប់ពីដៃរបស់អ្នកបម្រើ កាលអាចារ្យពោលថា ពួកលោកចូរទៅប្រាប់បិតារបស់កុមារ អាចារ្យរបស់ធម្មបាលកុមារបុត្ររបស់លោក មកឈរទៀបទ្វារ ពួកទាសៈទទួលពាក្យថា ល្អហើយ ហើយនាំគ្នាទៅប្រាប់, ព្រាហ្មណ៍នោះទៅជិតទ្វារដោយប្រញាប់អញ្ជើញថា ចូរមកខាងនេះចុះលោក ហើយនាំអាចារ្យឡើងផ្ទះ ឲ្យអង្គុយលើបល្ល័ង្ក ធ្វើកិច្ចគ្រប់យ៉ាងមានលាងជើងជាដើម អាចារ្យបរិភោគអាហារហើយ វេលាអង្គុយសន្ទនាគ្នាតាមសប្បាយ ទើបពោល

ថា ម្នាលព្រាហ្មណ៍ ធម្មបាលកុមារបុត្ររបស់លោកជាអ្នកមាន សតិ បញ្ញា រៀនចប់ត្រៃវេទ និងសិល្បៈ ១៨ ប្រការហើយ តែបានស្លាប់ហើយ ដោយរោគម្យ៉ាង សង្ខារទាំងឡាយមិនទៀង មែនពិត លោកកុំសោយសោកឡើយ ។

ព្រាហ្មណ៍ទះដៃសើចលាន់ឮឡើង, កាលអាចារ្យសួរថា ម្នាលព្រាហ្មណ៍ លោកសើចអ្វី ? ក៏ឆ្លើយថា កូនខ្ញុំមិនទាន់ ស្លាប់ទេ ដែលស្លាប់នោះនឹងជាអ្នកដទៃ ។ អាចារ្យពោលថា ម្នាល ព្រាហ្មណ៍ លោកបានឃើញឆ្អឹងបុត្ររបស់លោកហើយ ចូរជឿចុះ ហើយនាំឆ្អឹងចេញមកពោលថា នេះឆ្អឹងបុត្ររបស់លោក, ព្រាហ្មណ៍ពោលថា នេះនឹងបានជាឆ្អឹងពពែ ឬឆ្អឹងសុនខ តែកូនខ្ញុំមិន ទាន់ស្លាប់ទេ ព្រោះក្នុងត្រកូលរបស់យើង ៧ ជំនាន់មកហើយ មិនមានអ្នកណាធ្លាប់ស្លាប់តាំងពីកំលោះឡើយ លោកនិយាយ កុហក ។ ខណៈនោះ អ្នកទាំងអស់បានទះដៃ សើចដ៏ខ្លាំង ។ អាចារ្យឃើញសេចក្ដីអស្ចារ្យនោះហើយ មានសេចក្ដីសោមនស្ស កាលនឹងសួរថា ម្នាលព្រាហ្មណ៍ ក្នុងប្រពៃណីត្រកូលរបស់ លោកដែលមនុស្សកំលោះៗ មិនស្លាប់ បើមិនមានហេតុ គង់មិន អាចប្រព្រឹត្តទៅបាន ព្រោះហេតុណា មនុស្សកំលោះៗ ទើបមិន

ស្លាប់ ? ដូច្នេះ បានពោលគាថាទី ១ ថា ៖

អ្វីជាវត្តរបស់អ្នក អ្វីជាព្រហ្មចរិយរបស់អ្នក នេះជាផលសុចរិត ធម៌ដូចម្តេច ដែលអ្នកសន្សំល្អហើយ ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់សេចក្តីនោះដល់ខ្ញុំ ព្រោះហេតុអ្វីទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់អ្នកមិនស្លាប់ ។

បណ្តាបទទាំងនោះ បទថា **វតំ** គឺ ជាវត្តសមាទាន ។

បទថា **ព្រហ្មចរិយំ** គឺ ជាព្រហ្មចរិយដ៏ប្រសើរបំផុត ។

បទថា **កិស្ស សុចិណ្ណស្ស** សេចក្តីថា ការដែលមនុស្សនៅកំលោះៗ ក្នុងត្រកូលរបស់ពួកលោក មិនស្លាប់ជាផលនៃសុចរិត យ៉ាងណា ?

ព្រាហ្មណ៍បានស្តាប់ដូច្នោះហើយ កាលនឹងពណ៌នាគុណានុភាព ដែលជាហេតុឲ្យមនុស្សកំលោះក្នុងត្រកូលនោះមិនស្លាប់ ទើបពោលគាថាទាំងនេះថា ៖

ពួកយើងប្រព្រឹត្តធម៌ មិននិយាយកុហក វៀរនូវអំពើដ៏លាមក វៀរនូវអំពើមិនប្រសើរគ្រប់យ៉ាង ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់ ។

ពួកយើងស្តាប់ធម៌របស់អសប្បុរសផង សប្បុរសផង ប៉ុន្តែ

ពួកយើង មិនពេញចិត្តនឹងធម៌របស់ពួកអសប្បុរសទេ ពួកយើងលះបង់អសប្បុរស មិនលះបង់សប្បុរសទេ ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់ ។

ពួកយើងមានចិត្តល្អ ក្នុងកាលមុនឲ្យ កាលកំពុងឲ្យ ក៏មានចិត្តត្រេកអរ លុះឲ្យហើយ មិនក្តៅក្រហាយក្រោយ ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់ ។

ពួកយើងបានញ៉ាំងសមណព្រាហ្មណ៍ អ្នកដំណើរ ស្មូមយាចក និងអ្នកកំសត់ ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង (ក្នុងត្រកូល) របស់យើងមិនស្លាប់ ។

ពួកយើងមិនប្រព្រឹត្តកន្លងចិត្តភរិយាទេ ទាំងពួកភរិយាក៏មិនប្រព្រឹត្តកន្លងពួកយើង ពួកយើងប្រព្រឹត្តនូវព្រហ្មចរិយធម៌ លើកលែងតែភរិយាទាំងនោះចេញ ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់ ។

យើងទាំងអស់គ្នា វៀរចាកបាណាតិបាត វៀរចាកអទិន្នា-

ទាន ក្នុងលោក មិនផឹកទឹកស្រវឹង មិននិយាយកុហក ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់ ។

កូនទាំងឡាយ (របស់យើង) កើតក្នុងពួកស្ត្រីដ៏ឧត្ដម រមែងជាអ្នកប្រាជ្ញ មានប្រាជ្ញាច្រើន ជាពហុស្សូត ដឹងនូវវេទ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់ ។

មាតាបិតា បងប្អូនស្រី បងប្អូនប្រុស កូន ប្រពន្ធ និងយើង គ្រប់គ្នាប្រព្រឹត្តធម៌ ដើម្បីជាប្រយោជន៍ក្នុងលោកខាងមុខ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់ ។

ពួកខ្ញុំប្រុស ពួកខ្ញុំស្រី អ្នកចិញ្ចឹមជីវិតដោយសារ អ្នកបម្រើ និងអ្នកធ្វើការងារទាំងអស់ប្រព្រឹត្តធម៌ ដើម្បីប្រយោជន៍ក្នុងលោកខាងមុខ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់ ។

បណ្ដាបទទាំងនោះ បទថា **ធម្មញ្ចរាម** បានដល់ ប្រព្រឹត្តធម៌ គឺកុសលកម្មបថ ១០ ប្រការ កុសលកម្មគ្រប់យ៉ាងជាដើម

ថា ពួកយើងមិនសម្លាប់សត្វដោយហោចទៅ សូម្បីស្រមោចខ្មៅ ចាកជីវិត ព្រោះហេតុនៃជីវិតខ្លួន និងមិនសម្លឹងមើលវត្ថុរបស់អ្នកដទៃដោយលោភចិត្ត ដែលបណ្ឌិតគប្បីពណ៌នាឲ្យពិស្តារ ក៏ក្នុងគាថានេះ ព្រាហ្មណ៍ពោលដល់ការនិយាយមុសា តែពោលទុកដោយអំណាចនៃអកុសលកម្មដ៏ខ្ពស់ឡើងថា ដែលឈ្មោះថាបាបដែលបុគ្គលអ្នកនិយាយកុហក នឹងមិនធ្វើរមែងមិនមាន បានពួថា បុគ្គលទាំងនោះ មិននិយាយកុហក សូម្បីដោយប្រាថ្នានឹងឲ្យសើច ។

បទថា **បាបានិ** បានដល់ កម្មដ៏លាមកដែលជាហេតុឲ្យចូលដល់នរកសូម្បីគ្រប់យ៉ាង ។ បទថា **អនរិយំ** បានដល់ វៀរចាកកម្មដែលវៀរចាកភាពជាកម្មដ៏ប្រសើរ គឺដែលមិនល្អ បានដល់ មិនបរិសុទ្ធិទាំងអស់ ។ **ហិ** អក្សរ ក្នុងពាក្យថា **តស្មា ហិ អម្ហំ** នេះ ត្រឹមតែជានិបាត អធិប្បាយថា ព្រោះហេតុនេះ ក្មេងកំលោះៗ របស់ពួកយើង ទើបមិនស្លាប់ គឺដែលឈ្មោះថា អកាលមរណៈក្នុងចន្លោះ រមែងមិនមានដល់ពួកយើង បាលីថា **តស្មា ហិ អម្ហំ** ដូច្នេះក៏មាន ។ បទថា **សុណោម** ជាដើម សេចក្តីថា បានពួថា ពួកយើង ធម៌ដែលសម្តែង (ពី)កុសល

របស់សប្បុរសក៏ស្តាប់ ធម៌ដែលសម្តែង(ពី)អកុសលរបស់អសប្បុរស ក៏ស្តាប់ទាំងអស់ តែពួកយើងក៏ត្រឹមតែស្តាប់ធម៌នោះហើយប៉ុណ្ណោះ មិនពេញចិត្តធម៌របស់អសប្បុរសនោះឡើយ; តែមិនឲ្យមានការឈ្លោះ ឬវិវាទនឹងអសប្បុរសទាំងនោះ, សូម្បីស្តាប់ហើយ បានហើយក៏ប្រព្រឹត្តតាមសប្បុរស មិនលះបង់សប្បុរស សូម្បីតែមួយខណៈ, លះបង់អសប្បុរស គឺបាបមិត្តចេញហើយ ជាអ្នកសេពគប់តែកល្យាណមិត្តប៉ុណ្ណោះ ។

បទថា **សមណោ មយំ ព្រាហ្មណោ** សេចក្តីថា ម្នាលព្រាហ្មណ៍ ពួកយើងចិញ្ចឹមរក្សាសមណព្រាហ្មណ៍ គឺព្រះបច្ចេក-ពុទ្ធ ដែលមានបាបស្ងប់ហើយ មានបាបបណ្តែតចោលហើយខ្លះ សមណព្រាហ្មណ៍អ្នកតាំងនៅក្នុងធម៌ដ៏សេសខ្លះ ជនដ៏សេសមានអទ្ធិកយាចកជាដើមខ្លះ ឲ្យឆ្អែតស្កប់ស្កល់សប្បាយដោយបាយនិងទឹក ។ ក៏ក្នុងព្រះបាលីគាថានេះ ក៏មកតាមក្រោយគាថាថា **បុព្វេ ទានា** ដូចគ្នា ។ បទថា **នាតិក្កមាម** សេចក្តីថា ពួកយើងមិនប្រព្រឹត្តកន្លងចិត្តភរិយារបស់ខ្លួន ធ្វើមិច្ឆាចារក្នុងស្រីដទៃក្នុងខាងក្រៅ ។ បទថា **អញ្ញត្រ តាហិ** សេចក្តីថា ពួកយើងប្រព្រឹត្តព្រហ្មចរិយ ក្នុងស្រីដ៏សេសក្រៅពីភរិយារបស់

ខ្ជួន សូម្បីកិរិយារបស់ពួកយើង ក៏ប្រព្រឹត្តទៅក្នុងប្រុសដ៏សេស យ៉ាងនេះដូចគ្នា ។ បទថា **ជាយរេ** ប្រែថា រមែងកើត ។ បទថា **សុត្តមាសុ** គឺស្ត្រីដ៏ខ្ពស់បំផុត អ្នកមានសីលល្អទាំងឡាយ ។

សេចក្ដីនេះអធិប្បាយថា បុត្រពួកណារបស់ពួកយើង កើតក្នុងស្ត្រីដ៏ឧត្ដម អ្នកមានសីលបរិបូរណ៍ទាំងនោះ បុត្រទាំងនោះរមែងជាអ្នកមានប្រការយ៉ាងនេះ គឺជាអ្នកឆ្លាតជាដើម, សេចក្ដីស្លាប់ក្នុងចន្លោះនឹងមានដល់បុត្រទាំងនោះអំពីទីណាហ្ន៎ សូម្បីព្រោះហេតុនោះ ពួកជននៅក្មេងក្នុងត្រកូលរបស់ពួកយើងទើបមិនស្លាប់ ។

បទថា **ធម្មញ្ចរាម** បានដល់ ប្រព្រឹត្តសុចរិតធម៌ ៣ ប្រការដើម្បីប្រយោជន៍ដល់បរលោក ។ ស្រីទទួលបម្រើទាំងឡាយឈ្មោះថា ទាសី ។

ក្នុងទីបំផុត ព្រាហ្មណ៍ក៏បានសម្ដែងគុណរបស់អ្នកប្រព្រឹត្តធម៌ ដោយគាថា ២ គាថាទាំងនេះថា ៖

ធម្មោ ហវេ រក្ខតិ ធម្មចារឹ
ធម្មោ សុចិណ្ណោ សុខមាវហាតិ

ឯសានិសំសោ ធម្មេ សុចិណ្ណេ

ន ទុគ្គតឹ គច្ឆតិ ធម្មចារី ។

*ធម៌ រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ ដោយពិត ធម៌ដែលបុគ្គលសន្សំល្អហើយ រមែងនាំសុខមកឲ្យ នេះជាអានិសង្ស ក្នុងធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ។*

ធម្មោ ហវេ រក្ខតិ ធម្មចារឹ

ឆត្តំ មហន្តំ វិយ វស្សកាលេ

ធម្មេន គុត្តោ មម ធម្មបាលោ

អញ្ញស្ស អដ្ឋីនិ សុខី កុមារោតិ ។

*ធម៌ រមែងរក្សាអ្នកប្រព្រឹត្តធម៌ដោយពិត ដូចឆត្រធំ (ការពារ) ក្នុងកាលដែលភ្លៀង ធម្មបាលជាបុត្តរបស់យើង ធម៌គ្រប់គ្រងហើយ ឆ្អឹង(ដែលអ្នកនាំមកនេះ) ជាឆ្អឹងសត្វដទៃ កុមារ (ជាបុត្តរបស់យើង) មានសេចក្ដីសុខនៅឡើយ ។*

*បណ្ដាបទទាំងនោះ បទថា* ***រក្ខតិ*** *សេចក្ដីថា ធម្មតាថា ធម៌ដែលបុគ្គលរក្សាហើយនោះ រមែងត្រឡប់រក្សានូវបុគ្គលអ្នកមាន*

ធម៌ដែលខ្ញុំរក្សាហើយ ។ បទថា **សុខមាវហាតិ** គឺ រមែងនាំសេចក្ដីសុខក្នុងទេវតា និងមនុស្សទាំងឡាយ និងនិព្វានសុខមកឲ្យ ។ បទថា **ន ទុគ្គតឹ** គឺរមែងមិនទៅកាន់ទុគ្គតិ ដែលផ្សេង-ដោយទុគ្គតិមាននរកជាដើម ។

ព្រាហ្មណ៍នោះសម្ដែងថា ម្នាលព្រាហ្មណ៍ ពួកយើងរក្សាធម៌យ៉ាងនេះ សូម្បីធម៌ក៏រក្សាពួកយើងដូចគ្នា ។ បទថា **ធម្មេន គុត្តោ** គឺ ធម៌ដែលខ្ញុំរក្សាដែលដូចជាឆត្រធំការពារហើយ ។ បទថា **អញ្ញស្ស អដ្ឋីនិ** សេចក្ដីថា ក៏ឆ្អឹងដែលលោកនាំមកនេះជាឆ្អឹងរបស់សត្វដទៃ គឺរបស់ពពែក៏ដោយ របស់សុនខក៏ដោយ លោកចូរបោលឆ្អឹងទាំងនោះចេញ បុត្ររបស់យើងនៅមានសេចក្ដីសុខ ។

អាចារ្យបានស្ដាប់ដូចនោះ ទើបពោលថា ការមករបស់ខ្ញុំជាការមកល្អ មានផល មិនមែនគ្មានផលទេ ហើយមានសេចក្ដីត្រេកអរ សូមខមាទោសចំពោះបិតាធម្មបាលហើយ ពោលថា នេះជាឆ្អឹងពពែ ខ្ញុំនាំមកដើម្បីល្បងលោកមើល បុត្ររបស់លោកមិនមានរោគ (មានសេចក្ដីសុខសប្បាយ), លោកចូរឲ្យធម៌ដែលលោករក្សាដល់ខ្ញុំខ្លះ ដូច្នេះ ហើយសរសេរសេចក្ដីចុះក្នុងក្រាំង

នៅក្នុងទីនោះ ២-៣ ថ្ងៃ ហើយទៅកាន់ក្រុងតក្កសិលាឲ្យធម្ម-បាលកុមារសិក្សាសិល្បៈគ្រប់យ៉ាងហើយ បញ្ជូនទៅដោយបរិវារធំ ។

ព្រះសាស្តា គ្រាទ្រង់នាំព្រះធម៌ទេសនានេះមកសម្តែងដល់ព្រះបាទសុទ្ធោទនមហារាជហើយ ទ្រង់ប្រកាសសច្ចធម៌ ក្នុងវេលាចប់សច្ចៈ ព្រះបាទសុទ្ធោទនមហារាជបានតាំងនៅក្នុងអនា-គាមិផល ។ ព្រះទសពលទ្រង់ប្រជុំជាតកថា មាតាបិតា ក្នុងគ្រានោះ បានមកជាពុទ្ធមាតាពុទ្ធបិតាក្នុងឥឡូវនេះ, អាចារ្យ ក្នុងគ្រានោះ បានមកជាព្រះសារីបុត្រ ក្នុងឥឡូវនេះ, បរិស័ទក្នុងគ្រានោះ បានមកជាពុទ្ធបរិស័ទ ក្នុងឥឡូវនេះ, ចំណែកធម្មបាលកុមារ បានមកជាយើងតថាគត ដូច្នេះឯង ។

ចប់ មហាធម្មបាលជាតក ។

## ១៥-ជាណុស្សោណិព្រាហ្មណ៍

*(សុត្តន្តបិដក លេខ៥១ ទំព័រ១៣៩)*

*លំដាប់នោះ ជាណុស្សោណិព្រាហ្មណ៍ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ធ្វើសេចក្តីរីករាយជាមួយ នឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹក នាំឲ្យកើតសេចក្តីស្និទ្ធស្នាល ហើយអង្គុយក្នុងទីសមគួរ ។ លុះជាណុស្សោណិព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន យើងជាព្រាហ្មណ៍ តែងឲ្យទាន តែងធ្វើអំពើដែលគេគប្បីធ្វើដោយសទ្ធា ហើយឧទ្ទិសថា ទាននេះ សូមឲ្យសម្រេចផលដល់ប្រេតទាំងឡាយជាញាតិសាហិត ពួកប្រេតទាំងឡាយជាញាតិសាលោហិត សូមបរិភោគនូវទាននេះ បពិត្រព្រះគោតមដ៏ចម្រើន ចុះទាននោះនឹងសម្រេចផល ដល់ប្រេតទាំងឡាយជាញាតិសាលោហិតដែរឬទេ ប្រេតទាំងឡាយជាញាតិសាលោហិតនោះ នឹងបរិភោគនូវទាននោះបានដែរឬទេ ។*

*ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ទាននោះ សម្រេចផលក្នុងទីគួរ មិនសម្រេចផលក្នុងទីមិនគួរ ។*

បពិត្រព្រះគោតមដ៏ចម្រើន ទីដែលគួរតើដូចម្តេច ទីដែលមិនគួរតើដូចម្តេច ។

ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។ល។ មានសេចក្តីយល់ខុស បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងនរក អាហារណាជាអាហារសម្រាប់សត្វទាំងឡាយកើតក្នុងនរក សត្វនរកនោះ តែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងនរកនោះ ដោយសារអាហារនោះ សត្វនរកនោះ ឋិតនៅក្នុងនរកនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនោះឯងហៅថា ទីមិនគួរ ។

ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះជាអ្នកសម្លាប់សត្វ ។បេ។ មានសេចក្តីយល់ខុស បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតនៃតិរច្ឆានអាហារណា ជាអាហារសម្រាប់សត្វទាំងឡាយដែលកើតក្នុងកំណើតតិរច្ឆាន សត្វតិរច្ឆាននោះ ក៏ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ សត្វតិរច្ឆាននោះ ឋិតនៅក្នុងទីនោះដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេច

ផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនោះឯងហៅថា ទីមិនគួរ។

ម្នាលព្រាហ្មណ៍ ចំណែកឯបុគ្គលខ្លះក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត ។ល។ មានសេចក្ដីយល់ត្រូវ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងពួកមនុស្ស អាហារណា ជាអាហារសម្រាប់ពួកមនុស្ស បុគ្គលនោះក៏ញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ បុគ្គលនោះឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផល ដល់សត្វដែលឋិតនៅក្នុងទីណា ទីនោះឯងហៅថា ទីមិនគួរ ។

ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត ។ល។ មានសេចក្ដីយល់ត្រូវ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងពួកទេវតា អាហារណា ជាអាហារសម្រាប់ពួកទេវតា ទេវតានោះក៏ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ទេវតានោះឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ទាននោះ មិនសម្រេចផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯងហៅថា ទីមិនគួរ ។

ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។ល។ មានសេចក្តីយល់ខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងបិត្តិវិស័យ អាហារណា ជាអាហារសម្រាប់សត្វទាំងឡាយដែលកើតក្នុងបិត្តិវិស័យ ប្រេតនោះ ក៏ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ប្រេតនោះឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ឬក៏ពួកមិត្តអមាត្យក្តី ជនជាញាតិសាលោហិតក្តី ឧទ្ទិសឲ្យនូវទានណា ដល់ប្រេតនោះ អំពីលោកនេះ ប្រេតនោះក៏ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ប្រេតនោះឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះសម្រេចផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯងហៅថា ទីគួរ ។

ជាណុស្សោណិព្រាហ្មណ៍ ក្រាបទូលសួរថា បពិត្រព្រះ-គោតមដ៏ចម្រើន ចុះប្រសិនបើប្រេតជាញាតិសាលោហិតនោះ មិនបានទៅកើតក្នុងទីនោះទេ តើអ្នកណាបរិភោគទាននោះ ។

អើព្រាហ្មណ៍ ពួកប្រេតដែលជាញាតិសាលោហិតដទៃទៀតរបស់គេ គង់ទៅកើតទីនោះមិនខាន ប្រេតទាំងនោះឯងបរិភោគទាននោះ ។

បពិត្រព្រះគោតមដ៏ចម្រើន ចុះប្រសិនបើប្រេតជាញាតិសាលោហិតនោះ មិនបានទៅកើតក្នុងទីនោះទេ ទាំងពួកប្រេតជាញាតិសាលោហិតដទៃទៀតរបស់គេ ក៏មិនបានទៅកើតក្នុងទីនោះដែរ តើអ្នកណាបរិភោគទាននោះ ។

នែព្រាហ្មណ៍ ទីណាដែលស្ងាត់ចាកប្រេតទាំងឡាយ ជាញាតិសាលោហិតដោយកាលជាយូរអង្វែងនេះ ទីនោះមិនមែនជាហេតុ មិនមែនជាឱកាស គឺថាមិនធ្លាប់មានឡើយ ម្នាលព្រាហ្មណ៍ មួយទៀត ធម្មតាអ្នកឲ្យទានមិនមែនជាគ្មានផលទេ ។

## ១៦. រឿងបិដ្ឋធីតលិកប្រេត

(ព្រះសម្ពុទ្ធ ទ្រង់សម្តែងថា) បុគ្គលមិនមានសេចក្តីកំណាញ់ គួរធ្វើនូវហេតុណានីមួយឲ្យជាអារម្មណ៍ហើយ គប្បីឲ្យទាន គឺប្រារព្ធនូវបុព្វបុរសទាំងឡាយមានមាតាបិតាជាដើម ដែលរំលាងខន្ធទៅកាន់បរលោកហើយ ឬនូវទេវតាទាំងឡាយ ដែលអាស្រ័យនូវក្នុងទីទាំងឡាយ មានទីផ្ទះជាដើម នូវស្តេចធំទាំង ៤ ដែលរក្សាលោក ជាអ្នកមានយសបរិវារ គឺព្រះបាទកុវេរៈ ១ ធតរដ្ឋៈ ១ វិរូបក្ខៈ ១ វិរុឡ្ហកៈ ១ ហើយឲ្យនូវទានចុះ ជនទាំងឡាយមានស្តេចធំជាដើមនោះ ឈ្មោះថា ជាបុគ្គល

គឺទាយកនោះ បានបូជាហើយ ឯអ្នកមិនមែនជាមិនមានផល ឡើយ ។

ការយំក្តី សោកសៅក្តី ខ្សឹកខ្សួលណាដទៃក្តី បុគ្គលមិនគប្បីធ្វើទេ កិច្ចមានយំជាដើមនោះ មិនជាប្រយោជន៍ដល់អ្នកដែលទៅកាន់បរលោកឡើយ ញាតិទាំងឡាយ (ដែលទៅកាន់បរលោកនោះ) ក៏ឋិតនៅយ៉ាងនោះដដែល (ឥតបានដឹងបានឮឡើយ) ។

ចំណែកទក្ខិណាទាន ដែលបុគ្គលបានឲ្យហើយនេះឯង ជាទានតម្កល់នៅល្អក្នុងព្រះសង្ឃ រមែងសម្រេចផល ដើម្បីជាប្រយោជន៍ ដល់ញាតិដែលទៅកាន់លោកខាងនាយនោះ អស់កាលជាយូរអង្វែង តាមឋានៈ គឺទីដែលគួរសម្រេចបាន ។

ចប់ រឿងបិដ្ឋធីតលិកប្រេត ។

## ១៧_រឿងចូឡសេដ្ឋីប្រេត

(ព្រះបាទអជាតសត្រូវ ទ្រង់សួរថា) បពិត្រលោកដ៏ចម្រើន លោកជាបព្វជិត មានកាយអាក្រាត ស្គាំងស្គម ហេតុអ្វីបានជាលោកទៅកាន់ទីណា តែក្នុងវេលារាត្រី សូមលោកប្រាប់ហេតុនោះដល់ខ្ញុំ ខ្ញុំនឹងអាចចាត់ចែងទ្រព្យទាំងពួងតាម

អធ្យាស្រ័យនៃលោក ។

(ប្រេតតបថា) ក្រុងពារាណសី មានកិត្តិស័ព្ទល្បីទៅក្នុងទីឆ្ងាយ ខ្ញុំជាគហបតី មានទ្រព្យច្រើនក្នុងក្រុងពារាណសីនោះ ជាអ្នកកំណាញ់ មិនឲ្យទាន មានចិត្តជាប់នៅក្នុងអាមិសៈដល់នូវយមវិស័យ (បេតលោក) ដោយការៈទ្រុស្តសីល ។ ខ្ញុំជាបុគ្គលលំបាកដោយសេចក្តីស្រេកឃ្លាន ប្រាកដដូចជាម្ជុលចាក់នៅជានិច្ច ព្រោះអំពើអាក្រក់នោះ ទើបទៅរកញាតិ ជាហេតុនឹងបានអាមិសៈតិចតួច (ពួកមនុស្សណា) មិនឲ្យទាន មិនជឿថាផលទានមានក្នុងបរលោក (មនុស្សទាំងនោះ តែងទៅកើតជាប្រេតរងទុក្ខដូចជាខ្ញុំ) ។ ចំណែកធីតារបស់ខ្ញុំពោលរឿយៗ ថា អាត្មាអញនឹងឲ្យទានដល់បិតា ដល់ធីតាក៏បានឲ្យព្រាហ្មណ៍ទាំងឡាយ បរិភោគភោជនដែលខ្ញុំនតាក់តែង ខ្ញុំទៅកាន់អន្ធកវិន្ទនគរ ដើម្បីបរិភោគនូវភោជននោះ ។

ព្រះបាទអជាតសត្រូវ បានត្រាស់សួរទៅប្រេតនោះថា អ្នកបានទទួលផលទាន (ដែលធីតារបស់អ្នកបានតាក់តែងឲ្យហើយ) នោះ គប្បីវិលត្រឡប់វិញឆាប់ យើងនឹងធ្វើការបូជា (ដល់អ្នក) បើមានហេតុ អ្នកចូរប្រាប់ហេតុនោះដល់យើង

យើងនឹងស្តាប់ពាក្យប្រកបដោយហេតុដែលគួរជឿ ។

ប្រេតនោះ ពោលដូច្នេះហើយ បានទៅកាន់អន្ទកវិន្ទនគរនោះ ពួកព្រាហ្មណ៍បរិភោគភត្ត តែជាអ្នកមិនគួរដល់បទក្ខិណា (ព្រោះជាព្រាហ្មណ៍ទ្រុស្តសីល) ខាងក្រោយមកប្រេតនោះ ក៏ទៅនគររាជគ្រឹះវិញ ក៏ប្រាកដចំពោះព្រះភក្ត្រព្រះបាទអជាតសត្រូវ ជាធំជាងជន ។

ព្រះរាជាបានទតឃើញប្រេតមកហើយ ត្រាស់សួរថា យើងនឹងឲ្យនូវអ្វី អ្នកជាបុគ្គលឆ្អែតអស់កាលយូរ ដោយហេតុណា បើហេតុនោះមាន អ្នកចូរប្រាប់ដល់យើង ។

បពិត្រមហារាជ សូមព្រះអង្គអង្គាសព្រះពុទ្ធផង ព្រះសង្ឃផង ដោយបាយទឹកនិងចីវរ ហើយសូមឧទ្ទិសនូវទក្ខិណាទាននោះ ដើម្បីប្រយោជន៍ដល់ខ្ញុំ ខ្ញុំគប្បីជាបុគ្គលឆ្អែតឆ្អន់អស់កាលយូរ ដោយប្រការយ៉ាងនេះ ។

ក្នុងកាលនោះ ព្រះរាជាស្តេចចុះចាកប្រាសាទនោះ ហើយថ្វាយនូវទានមានឱជារសរកប្រមាណមិនបាន ដោយព្រះហស្ត ព្រះអង្គឯង ដល់ព្រះសង្ឃ ហើយក្រាបទូលអំពីទានដែលបានធ្វើចំពោះព្រះតថាគត ហើយឧទ្ទិសនូវទក្ខិណាទានដល់ប្រេត ។

ប្រេតនោះ ដែលព្រះរាជាបូជាហើយ ក៏រុងរឿងក្រៃពេក ប្រាកដ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះរាជាជាធំជាងជន ពោលថា ខ្ញុំព្រះអង្គជាយក្ស សម្រេចនូវឫទ្ធិដ៏ឧត្តម រកមនុស្សមានឫទ្ធិ ប្រាកដស្មើនឹងខ្ញុំគ្មាន ។ សូមព្រះអង្គទ្រង់ទតមើលនូវអានុភាព របស់ខ្ញុំ រកប្រមាណមិនបាននេះ ទានដ៏ឧត្តមដែលព្រះអង្គឧទ្ទិស ហើយ ឲ្យចំពោះសង្ឃ បពិត្រមនុស្សទេព ខ្ញុំព្រះអង្គ ជាបុគ្គល ឆ្អែតស្កប់ស្កល់ដោយវត្ថុទាំងឡាយច្រើនរឿយៗ សព្វកាល ក៏បាននូវសេចក្ដីសុខ ឥឡូវសូមលាទៅ ។

## ១៨-រឿងរាជបុត្តប្រេត

(ព្រះមានព្រះភាគ ត្រាស់សម្ដែងរឿងរាជបុត្តប្រេតនេះ ថា) ផលរបស់បាបកម្មទាំងឡាយ ដែលរាជបុត្តធ្វើហើយ ក្នុង កាលពីដើម គប្បីញាំញីនូវចិត្ត ព្រោះរូប សំឡេង ក្លិន រស ផ្សព្វនិងធម្មារម្មណ៍ ។ រាជបុត្ត ចូលចិត្តនឹងការរាំ ការច្រៀង ការត្រេកអរ និងការសើចចំអកឡកឡឺយដ៏ច្រើន ដើរលេងក្នុង ឧទ្យាន រួចចូលទៅក្រុងរាជគ្រឹះវិញ ។ រាជបុត្តនោះ បានឃើញ ឥសី (ព្រះបច្ចេកពុទ្ធ) ឈ្មោះសុនេត្ត លោកមានចិត្តទូន្មាន

ហើយ មានចិត្តតម្កល់មាំ ប្រាថ្នាតិច ប្រកបដោយហិរិ ត្រេកអរតែនឹងបង្ហាន់ក្នុងបាត្រដោយការស្វែងរក ។

ក្សត្រចុះពីកដំរីហើយសួរថា បពិត្រលោកដ៏ចម្រើន បានចង្ហាន់ដែរឬទេ ហើយទទួលយកបាត្ររបស់លោក លើកឡើងឲ្យខ្ពស់ បោកបំបែកបាត្រលោកលើដីរដិបរដុប ហើយសើចលេង ដើរចេញទៅ (និយាយថា) ខ្ញុំជាកូនរបស់ព្រះបាទកិតវៈ នៃកិក្ខុ លោកនឹងធ្វើអ្វីដល់ខ្ញុំ ។ ផលដ៏ក្តៅក្រហាយរបស់បាបកម្មដ៏អាក្រក់នោះឯង នាំរាជបុត្រ ឲ្យរងទុក្ខពេញពោរក្នុងនរក ។ល។ រាជបុត្រ បានធ្វើអំពើអាក្រក់ ក៏ដល់នូវសេចក្តីទុក្ខក្រៃលែងក្នុងនរក (៩០០.០០០) ឆ្នាំ ។ល។ ជនពាលទុកជាដេកផ្ងារក្តី ផ្កាប់ក្តី ផ្អៀងទៅខាងឆ្វេង ខាងស្តាំក្តី ជើងឡើងលើក្តី ឈរក្តី រមែងឆេះអស់កាលដ៏យូរ ។ល។ ជនពាល បានធ្វើអំពើអាក្រក់ ក៏ទទួលទុក្ខដ៏ក្រៃលែងក្នុងនរក ច្រើនពាន់ឆ្នាំផងច្រើនម៉ឺនឆ្នាំផង ។ បុគ្គលអ្នកមានបាបកម្ម តែងទទួលនូវសេចក្តីទុក្ខដ៏ក្រៃលែង ជាទុក្ខក្តៅផ្សា ប្រាកដដូច្នោះ ព្រោះការប្រទូសនឹងឥសី អ្នកមិនបានប្រទូស មានវត្តល្អ ។ រាជបុត្រនោះទទួលនូវសេចក្តីទុក្ខដ៏ច្រើន ក្នុងនរកនោះ អស់ឆ្នាំទាំងឡាយ

ដ៏ច្រើន ច្យុតចាកនរកនោះមក មកកើតជាប្រេត មានសេចក្តីស្រេកឃ្លាន បៀតបៀនហើយ ។ បុរសបុគ្គលដឹងទោស ជាដែនកើតនៃសេចក្តីស្រវឹង ព្រោះឥស្សរិយយសយ៉ាងនេះហើយ គប្បីលះបង់នូវសេចក្តីស្រវឹង ព្រោះតែឥស្សរិយយស ហើយប្រព្រឹត្តបន្ទាបបន្ទន់កាយ ។ ជនណា ជាបុគ្គលដែលគេសរសើរក្នុងបច្ចុប្បន្ន ជាអ្នកគោរពក្នុងព្រះពុទ្ធ ជននោះជាអ្នកប្រកបដោយប្រាជ្ញា លុះបែកធ្លាយរាងកាយទៅ រមែងកើតក្នុងឋានសួគ៌ ។

ចប់ រឿងរាជបុត្តប្រេត ៥៦,១២៣-១២៤ ។

## ១៩. រឿងសានុវាសិ

(សុត្តន្តបិដក លេខ៥៦ ទំព័រ៦៩)

(ព្រះធម្មសង្គាហកត្ថេរៈទាំងឡាយ ពោលថា) ព្រះថេរៈឈ្មោះបោដ្ឋបាទ អ្នកកើតក្នុងក្រុងកុណ្ឌី បាននៅអាស្រ័យនៅលើភ្នំឈ្មោះសានុវាសី ជាអ្នករម្ងាប់បាប មានឥន្ទ្រិយ៍រម្ងាប់ហើយ (ដោយអរិយមគ្គភាវនា) ។ មាតាបិតានិងបងប្រុសរបស់ព្រះថេរៈនោះ ជាអ្នកដល់នូវសេចក្តីលំបាក បានកើតក្នុងយមលោក (នរក) លុះច្យុតអំពីមនុស្សលោកនេះហើយ ក៏ទៅ

កាន់បេតលោក ព្រោះបាបកម្ម ពួកប្រេតទាំងនោះ ជាអ្នកដល់នូវសេចក្តីលំបាកមានទ្វារមាត់ប៉ុនរន្ធម្ជុល ត្រដាបត្រដួស មានកាយអាក្រាតស្គមកំព្រឹង ស្គុតរន្ធត់ ភ័យឡឹនឡង់ ជាអ្នកមានផលកម្មអាក្រក់ មិនហ៊ានបង្ហាញខ្លួនឲ្យគេឃើញឡើយ ។ បងប្រុសរបស់ព្រះថេរនោះ ជាអ្នកអាក្រាតតែម្នាក់ឯង ក្នុងផ្លូវបុះតៃជើងមួយ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយអវយវៈបួន គឺវារប្រញាប់ប្រញាល់ទៅបង្ហាញខ្លួនដល់ព្រះថេរៈ ។ ព្រះថេរៈមិនបានធ្វើទុកក្នុងចិត្តថា អ្នកនោះឈ្មោះនេះ ហើយក៏នៅស្ងៀមដើរហួសទៅ ឯប្រេតនោះទូលព្រះថេរៈឲ្យដឹងច្បាស់ថា បពិត្រព្រះថេរៈ ខ្ញុំព្រះករុណាត្រូវជាបង បានទៅកាន់បេតលោកហើយ ។ បពិត្រលោកដ៏ចម្រើន មាតានិងបិតារបស់លោកដល់នូវសេចក្តីលំបាក កើតក្នុងយមលោក លុះច្យុតអំពីមនុស្សលោកនេះហើយ ក៏ទៅកាន់បេតលោក ព្រោះធ្វើកម្មដ៏លាមកមាតានិងបិតាទាំងនោះ ជាអ្នកដល់នូវសេចក្តីលំបាក មានទ្វារ-មាត់ប៉ុនរន្ធម្ជុល ត្រដាបត្រដួស មានកាយអាក្រាត ស្គមកំព្រឹងស្គុតរន្ធត់ ភ័យឡឹនឡង់ ជាអ្នកមានផលកម្មអាក្រក់ មិនហានបង្ហាញខ្លួនឲ្យគេឃើញឡើយ លោកជាអ្នកមានសេចក្តីអាណិត

អាសូរ សូមអនុគ្រោះឲ្យទាន ឧទ្ទិសទៅឲ្យយើងទាំងឡាយផង មាតានិងបិតាទាំងនោះ ដែលមានកម្មអាក្រក់ នឹងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយទានដែលលោកម្ចាស់ឲ្យហើយ ។

ព្រះថេរៈផង ភិក្ខុទាំងឡាយដទៃ ១២ អង្គផង ដើរទៅបិណ្ឌបាត ហើយប្រជុំក្នុងទីជាមួយគ្នា ព្រោះហេតុនៃភត្តកិច្ច ។

ព្រះថេរៈ បាននិយាយនឹងពួកភិក្ខុទាំងអស់នោះថា លោកទាំងឡាយ សូមឲ្យនូវភត្តដែលលោកទាំងឡាយបានហើយយ៉ាងណាដល់ខ្ញុំ ខ្ញុំនឹងធ្វើសង្ឃភត្តដើម្បីអនុគ្រោះដល់ពួកញាតិ ។

ភិក្ខុទាំងនោះ បានប្រគេន (ភត្តទាំងនោះ) ដល់ព្រះថេរៈ ព្រះថេរៈបាននិមន្តសង្ឃ លុះព្រះថេរៈបានឲ្យទានហើយ ក៏ឧទ្ទិសចំពោះបិតាមាតានិងបងថា **ឥទំ មេ ញាតិនំ ហោតុ សុខិតា ហោន្តុ ញាតយោ** សូមទាននេះ សម្រេចដល់ញាតិរបស់ខ្ញុំ សូមពួកញាតិ បានដល់នូវសេចក្ដីសុខ ។

ភោជនក៏សម្រេច (ដល់ប្រេតទាំងនោះ) ក្នុងលំដាប់ដែលឧទ្ទិស (ភោជននោះ)ជាភោជនដ៏ស្អាត ថ្លៃថ្លា ឆ្ងាញ់ ជាម្ហូបមានឱជាសច្រើន ក្នុងកាលខាងក្រោយអំពីកាលបាននូវភោជននោះមក ប្រេតជាបង មានសម្បុរល្អ មានកម្លាំង មានសេចក្ដី

សុខ បានបង្ហាញខ្លួន (ដល់ព្រះថេរៈ ហើយពោលថា) បពិត្រលោកដ៏ចម្រើន សូមលោករមិលមើលនូវកោជនដ៏ច្រើន (ដែលពួកយើងបានហើយ ដោយអានុភាពនៃទានរបស់លោក) ប៉ុន្តែពួកយើងអាក្រាតនៅឡើយ បពិត្រលោកដ៏ចម្រើន ពួកយើងគួរបាននូវសំពត់ដោយប្រការណា សូមលោកព្យាយាម ដោយប្រការនោះចុះ ។

ព្រះថេរៈ បានរើសនូវកំណាត់សំពត់រេចជាយទាំងឡាយអំពីគំនរនៃសម្រាម ហើយធ្វើកំណាត់សំពត់ឲ្យជាផ្ទាំង គឺធ្វើជាចីវរ បានប្រគេនដល់ព្រះសង្ឃ ដែលមកអំពីទិសទាំងបួន ។ ព្រះថេរៈ បានឲ្យទានហើយ ឧទ្ទិសដល់បិតាមាតានិងបងថា ទាននេះចូរសម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិ បានដល់នូវសេចក្តីសុខ ។

សំពត់ទាំងឡាយ ក៏សម្រេច (ដល់ប្រេតទាំងនោះ) ក្នុងលំដាប់ដែលឧទ្ទិស លំដាប់នោះ (ប្រេតជាបង) ក៏ស្លៀកដណ្តប់សំពត់ដ៏ល្អ បានបង្ហាញខ្លួនដល់ព្រះថេរៈ ។ ប្រេតនោះ មានសម្បុរល្អ មានកម្លាំង មានសេចក្តីសុខ (បាននិយាយថា) បពិត្រលោកដ៏ចម្រើន សំពត់ជាគ្រឿងបិទបាំងកាយ ក្នុងដែន

របស់ព្រះបាទនន្ទៈ ទាំងប៉ុន្មាន (សំពត់ជាគ្រឿងបិទបាំងកាយរបស់ពួកយើង) ច្រើនលើសជាងសំពត់ជាគ្រឿងបិទបាំងកាយរបស់ទាំងនោះ ។

សំពត់ទាំងឡាយ ជាគ្រឿងស្លៀកពាក់របស់ពួកយើង គឺកោសេយ្យពស្ត្រ ខោមពស្ត្រ កប្បាសិកពស្ត្រ ជាសំពត់ធំទូលាយ មានថ្លៃច្រើន ឯសំពត់ទាំងនោះ ក៏សំយុងចុះពួជ៏អាកាស ពួកយើងនឹងស្លៀកពាក់សំពត់ទាំងនោះ តាមចិត្តស្រឡាញ់, បពិត្រលោកដ៏ចម្រើន ពួកយើងគួរបានផុះដោយប្រការណា សូមលោកព្យាយាមដោយប្រការនោះចុះ ។

ព្រះថេរៈ បានធ្វើកុដិប្រក់ស្លឹក ហើយប្រគេនដល់ព្រះសង្ឃ ដែលមកអំពីទិសទាំងបួន លុះព្រះថេរៈបានប្រគេនហើយ ឧទ្ទិសដល់បិតាមាតានិងបងថា ទាននេះចូរសម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិបានដល់នូវសេចក្តីសុខចុះ ។

ផ្ទះទាំងឡាយ ផ្ទះកំពូលទាំងឡាយ ជាទីនៅដែលញែកចែក ដែលចែកដោយប្រមាណស្មើគ្នា ក៏សម្រេច (ដល់ពួកប្រេតទាំងនោះ) ក្នុងលំដាប់ដែលឧទ្ទិស ។

(ប្រេតទាំងនោះពោលថា) ផ្ទះទាំងឡាយរបស់ពួកយើងក្នុងបេតលោកនេះយ៉ាងណា ផ្ទះទាំងឡាយក្នុងមនុស្សលោកមិនដូច្នោះទេ តែផ្ទះទាំងឡាយក្នុងឋានទិព្វទាំងឡាយយ៉ាងណា ផ្ទះទាំងឡាយ របស់ពួកយើងក្នុងបេតលោកនេះ យ៉ាងនោះដែរ ជាផ្ទះរុងរឿង អាចញុំាងទិសទាំង ៤ ឲ្យភ្លឺជុំវិញបាន ។ បពិត្រលោកដ៏ចម្រើន ពួកយើងគួរបានទឹកផឹក ដោយប្រការណាសូមលោកព្យាយាមដោយប្រការនោះចុះ ។

ព្រះថេរៈ ចាក់ទឹកបំពេញធម្មក្រក ហើយប្រគេនដល់ព្រះសង្ឃ ដែលមកអំពីទិសទាំង ៤ ។ លុះព្រះថេរៈបានប្រគេនហើយ ក៏ឧទ្ទិសចំពោះបិតាមាតានិងបងថា សូមទាននេះសម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិបានដល់នូវសេចក្តីសុខ ។

ទឹកក៏សម្រេចដល់ (ប្រេតទាំងនោះ) ក្នុងលំដាប់ដែលឧទ្ទិស ស្រះបោក្ខរណីទាំងឡាយ ដែលបុញ្ញកម្មនិម្មិតល្អហើយជ្រៅ មានជ្រុង ៤ មានទឹកដ៏ត្រជាក់ មានកំពុងល្អ ជាស្រះត្រជាក់ មានក្លិនក្រអូបប្រៀបមិនបាន ដេរដាសដោយផ្កាឈូកនិងផ្កាឧប្បល ពេញដោយលំអងលើទឹក ។ ប្រេតទាំងនោះងូតផឹក ក្នុងស្រះបោក្ខរណីនោះ ហើយបង្ហាញខ្លួនដល់ព្រះថេរៈថា

បពិត្រលោកដ៏ចម្រើន (ពួកយើងបាន) ទឹកច្រើនហើយ តែជើងទាំងឡាយរបស់ពួកយើងឈឺពុរពង ពួកយើងកាលដើរលើគ្រួសរវាំង លើស្បូវក្ដាំងនិងបន្ទា រមែងខ្ទើចៗ បពិត្រលោកដ៏ចម្រើន ពួកយើងគួរបាននូវយាន ដោយប្រការណា សូមលោកខំព្យាយាមដោយប្រការនោះចុះ ។

ព្រះថេរៈ បានស្បែកជើងមានជាន់មួយ ហើយបានប្រគេនដល់ព្រះសង្ឃដែលមកអំពីទិសទាំង ៤ ។ លុះព្រះថេរៈ បានប្រគេនហើយ ក៏ឧទ្ទិសចំពោះបិតាមាតានិងបងថា សូមទាននេះសម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិបានដល់នូវសេចក្ដីសុខ ។

ពួកប្រេតបានមកដោយរថ ក្នុងលំដាប់ដែលឧទ្ទិសហើយ (និយាយថា) បពិត្រលោកដ៏ចម្រើន ពួកយើងលោកបានអនុគ្រោះហើយ ដោយបាយផង ដោយទានទាំងពីរ គឺបានីយទាន និងយានទានផង បពិត្រលោកដ៏ចម្រើន ពួកយើងមកដើម្បីថ្វាយបង្គំលោកជាអ្នកប្រាជ្ញ ប្រកបដោយសេចក្ដីករុណាក្នុងលោក ។

ចប់ រឿងសានុវាសិ ។

# ២០-រឿងឃតបណ្ឌិត

(សុត្តន្តបិដក លេខ៥៩ ទំព័រ២០៥)

ព្រះសាស្ដា កាលទ្រង់គង់នៅក្នុងព្រះវិហារជេតវ័ន ទ្រង់ប្រារព្ធកុដុម្ពីកូនស្លាប់ ត្រាស់ព្រះធម៌ទេសនានេះ មានពាក្យចាប់ផ្ដើមថា **ឧដ្ឋេហិ កណ្ហ** ដូច្នេះ ។

សាច់រឿងដូចគ្នានឹងរឿងមដ្ឋកុណ្ឌលីនុ៎ះឯង ចំណែកក្នុងជាតកនេះ មានសេចក្ដីសង្ខេបដូចតទៅនេះ ៖

ព្រះសាស្ដា ស្ដេចចូលទៅរកឧបាសកនោះហើយត្រាស់សួរថា ម្នាលឧបាសក លោកសោកសៅចំពោះកូនស្លាប់ឬ ?

កាលឧបាសកក្រាបទូលថា ត្រូវហើយព្រះអង្គ, ព្រះអង្គទើបត្រាស់ថា ម្នាលឧបាសក បូរាណកបណ្ឌិតស្ដាប់ពាក្យរបស់បណ្ឌិតហើយ មិនសោកសៅដល់កូនដែលស្លាប់ទៅហើយ កាលដែលឧបាសកនោះក្រាបទូល អារាធនាឲ្យទ្រង់ត្រាស់រឿងរ៉ាវ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះ ៖

ក្នុងអតីតកាល ព្រះរាជាទ្រង់ព្រះនាមថាមហាវង្សៈ គ្រងរាជសម្បត្តិ នៅក្នុងអសិតញ្ជនគរ ដែនកង្សគោត្រជិតឧត្តរា-

ប្រទេស ព្រះអង្គមានព្រះរាជឱរស ២ ព្រះអង្គ មួយអង្គព្រះនាមថា**កង្ស:** មួយអង្គព្រះនាមថា**ឧបកង្ស:** មានព្រះរាជ-ធីតាមួយអង្គ ព្រះនាមថា**ទេវគព្ភា** ក្នុងថ្ងៃដែលព្រះរាជធីតានោះប្រសូត ព្រាហ្មណ៍អ្នកទាយលក្ខណៈព្យាករណ៍ទុកថា ព្រះឱរសដែលកើតក្នុងគភ៌របស់ព្រះនាងទេវគព្ភានោះ នឹងធ្វើកង្សគោត្រកង្សវង្ស ឲ្យវិនាស ព្រះរាជាមិនអាចឲ្យសម្រេចទោសព្រះ-រាជធីតាបាន ព្រោះទ្រង់ស្នេហាច្រើន សូម្បីព្រះជេដ្ឋាទាំងពីរក៏ទ្រង់ជ្រាបដូចគ្នា ព្រះរាជាតម្រង់រាជសម្បត្តិនៅរហូតដល់អស់ព្រះជន្មាយុហើយ ស្ដេចសោយទិវង្គតដោយប្រការដូច្នេះ កាលព្រះអង្គសុគតហើយ កង្សរាជឱរសបានជាព្រះរាជា ឧបកង្ស-រាជឱរស បានជាឧបរាជ ទាំងពីរព្រះអង្គ ទ្រង់ព្រះត្រិះរិះថា បើយើងនឹងឲ្យសម្រេចទោសភគិនី យើងក៏នឹងត្រូវរិះគន់ យើងនឹងមិនឲ្យភគិនីនេះដល់អ្នកណាៗ នឹងចិញ្ចឹមរក្សាដោយមិនឲ្យមានប្ដី ដូច្នេះ ទាំងពីរព្រះអង្គ ទើបឲ្យសាងប្រាសាទសសរតែមួយ ឲ្យរាជធីតានៅក្នុងប្រាសាទនោះ នាងទាសីឈ្មោះថា**នន្ទគោបា** បានជាបរិចារិការបស់ព្រះនាង ទាសៈឈ្មោះថា**អន្ធកវេណ្ឌុ** ជាស្វាមីរបស់នាងនន្ទគោបា ជាអ្នករក្សា

ព្រះនាង ។

គ្រានោះ ព្រះបាទ**មហាសាគររាជ** សោយរាជសម្បត្តិនៅក្នុងឧត្តរបថប្រទេស ព្រះអង្គមានព្រះរាជឱរស ២ ព្រះអង្គ មួយអង្គព្រះនាមថា **សាគរ** មួយអង្គព្រះនាមថា **ឧបសាគរ** ក៏បណ្តាព្រះរាជឱរស ២ ព្រះអង្គនោះ កាលព្រះជនកស្តេចសុគត សាគររាជឱរសបានជាព្រះរាជា ឧបសាគររាជឱរសបានជាឧបរាជ ឧបសាគរឧបរាជនោះជាសម្លាញ់របស់ឧប-កង្សឧបរាជ សម្រេចការសិក្សាគ្រាតែមួយជាមួយគ្នា ក្នុងត្រកូលអាចារ្យម្នាក់ ។

ឧបសាគរឧបរាជបានធ្វើមិនល្អ (ចំពោះ) នាងស្នំរបស់ព្រះម្ចាស់បង សាគររាជខ្លាចព្រះរាជអាជ្ញាជៀសទៅសំណាក់ឧបកង្សឧបរាជ ក្នុងដែនកង្សគោត្រ ឧបកង្សឧបរាជចូលគាល់ព្រះបាទកង្សរាជ ព្រះបាទកង្សរាជ ទ្រង់ប្រទានយសដ៏ធំដល់ឧបសាគរឧបរាជ ឧបសាគរឧបរាជកាលទៅគាល់ព្រះរាជា ឃើញប្រាសាទសសរតែមួយ ដែលជាទីប្រថាប់របស់ព្រះនាងទេវគព្ភា ទើបសួរថា នេះទីនៅរបស់អ្នកណា កាលជ្រាបសេចក្តីនោះហើយ ក៏មានចិត្តប្រតិព័ទ្ធ ក្នុងព្រះនាងទេវគព្ភា ។

ថ្ងៃមួយព្រះនាងទេវគព្ភា ទតព្រះនេត្រឃើញឧបសាគរឧបរាជ ទៅគាល់ព្រះរាជាព្រមជាមួយនឹងឧបកង្សឧបរាជ ទើបត្រាស់សួរថា នោះអ្នកណា ទ្រង់ជ្រាបពីនាងនន្ទគោបាថា ឱរសរបស់ព្រះបាទមហាសាគររាជ ព្រះនាមថា ឧបសាគរ ក៏មានចិត្តប្រតិព័ទ្ធក្នុងឧបសាគរឧបរាជនោះ ឧបសាគរឧបរាជឲ្យទ្រព្យនាងនន្ទគោបាហើយ ពោលថា ប្អូនស្រី នាងអាចនាំព្រះនាងទេវគព្ភាមកឲ្យយើងបានទេ ? នាងនន្ទគោបាពោលថា ការនោះមិនលំបាកទេនាយ ហើយក៏ប្រាប់រឿងនេះដល់ព្រះនាងទេវគព្ភា តាមប្រក្រតីព្រះនាងក៏មានចិត្តប្រតិព័ទ្ធ ក្នុងឧបសាគរឧបរាជហើយ លុះបានស្តាប់ដូចនោះក៏ទទួលថាល្អហើយ នាងនន្ទគោបា ឲ្យសញ្ញាដល់ឧបសាគរឧបរាជឲ្យឡើងប្រាសាទក្នុងវេលារាត្រី ឧបសាគរឧបរាជបានរួមសំវាសនឹងព្រះនាងទេវ-គព្ភា ដោយទំនងនោះរឿយៗ ព្រះនាងបានតាំងគភ៌ តមកដំណឹងព្រះនាងទ្រង់គភ៌ក៏បានប្រាកដឡើង ព្រះជេដ្ឋាទាំងពីរទើបសួរនាងនន្ទគោបា នាងនន្ទគោបាទូលសូមអភ័យហើយក្រាបទូលសេចក្តីកំបាំងនោះ ឲ្យទ្រង់ជ្រាបព្រះជេដ្ឋាទាំង ២ ព្រះអង្គទ្រង់ជ្រាបហើយ ទើបប្រឹក្សាគ្នាថា យើងមិនអាចនឹង

សម្រេចទោសប្អូនស្រីបាន បើនាងប្រសូតព្រះធីតា យើងនឹងមិនសម្រេចទោស តែបើជាព្រះឱរស យើងនឹងសម្រេចទោសចេញ ហើយប្រទានព្រះនាងទេវគព្ភាដល់ឧបសាគរឧបរាជ ព្រះនាងទេវគព្ភា ទ្រង់គភ៌គ្រប់កំណត់ហើយ ក៏ប្រសូតព្រះធីតា ព្រះជេដ្ឋាទាំងពីរ ទ្រង់ជ្រាបហើយ សប្បាយព្រះទ័យ តាំងព្រះនាមឲ្យព្រះធីតានោះថា **អញ្ជនទេវី** បានព្រះរាជទានស្រុកសួយឈ្មោះគោគវឌ្ឍមាន ដល់ក្សត្រិយ៍ទាំង ២ ឧបសាគរឧបរាជ ទើបនាំព្រះនាងទេវគព្ភា ទៅប្រថាប់ក្នុងគោគវឌ្ឍមានគាម ព្រះនាងទេវគព្ភា ក៏ទ្រង់គភ៌ទៀត សូម្បីនាងនន្ទគោបា ក៏តាំងគភ៌ក្នុងថ្ងៃនោះដូចគ្នា កាលស្រីទាំងពីរមានគភ៌គ្រប់កំណត់ហើយ ព្រះនាងទេវគព្ភាប្រសូតព្រះឱរស សូម្បីនាងនន្ទគោបា ក៏ប្រសូតធីតា ក្នុងថ្ងៃតែមួយជាមួយគ្នាទ្រាំងឯង ព្រះនាងទេវគព្ភា ខ្លាចព្រះឱរសនឹងវិនាស ដោយរាជភ័យ ទើបបញ្ជូនព្រះឱរសទៅឲ្យនាងនន្ទគោបា និងឲ្យនាងនន្ទគោបានាំធីតាមកឲ្យផ្លាស់ប្តូរគ្នាចិញ្ចឹម ។

អមាត្យទាំងឡាយ ក្រាបទូលសេចក្តីដែលព្រះនាងទេវគព្ភាប្រសូតហើយឲ្យព្រះជេដ្ឋាទាំង ២ ទ្រង់ជ្រាបព្រះជេដ្ឋា

ទាំង ២ ព្រះអង្គនោះ ត្រាស់សួរថា ប្រសូតឱរសឬធីតា កាល បានទទួលឆ្លើយថា ធីតា ទើបបង្គាប់ថា បើដូច្នោះ លោកទាំង ឡាយចូរចិញ្ចឹមទុកចុះ ព្រះនាងទេវគព្ភាប្រសូតព្រះឱរសរួម ១០ អង្គ នាងនន្ទគោបា ក៏ប្រសូតកូនស្រីរួម ១០ នាក់ បាន ផ្លាស់ឲ្យគ្នាចិញ្ចឹមដោយឧបាយនេះ ឱរសរបស់ព្រះនាង ទេវគព្ភាចម្រើននៅក្នុងសំណាក់នាងនន្ទគោបា កូនស្រីរបស់ នាងនន្ទគោបា ចម្រើននៅក្នុងសំណាក់របស់ព្រះនាងទេវគព្ភា អ្នកណាមួយ មិនបានដឹងសេចក្ដីនៃរឿងកំបាំងនោះ ។

ឱរសអង្គធំរបស់ព្រះនាងទេវគព្ភា នាមថាវាសុទេព អង្គ ទី២ នាមថាពលទេព អង្គទី៣ នាមថាចន្ទទេព អង្គទី៤ នាមថា សុរិយទេព អង្គទី៥ នាមថាអគ្គិទេព អង្គទី៦ នាមថាវរុណទេព អង្គទី៧ នាមថាអជ្ជុនៈ អង្គទី៨ នាមថាបជ្ជុនៈ អង្គទី៩ នាមថា ឃតបណ្ឌិត អង្គទី ១០ នាមថាអង្កុរៈ ឱរសទាំងនោះ បាន ប្រាកដថាបងប្អូន ១០ នាក់ ជាបុត្ររបស់អន្ធកវេណ្ហុទាសៈ ។

ក្នុងកាលខាងក្រោយមកឱរសទាំងនោះ កាលចម្រើនវ័យ ហើយមានកម្លាំងពលំច្រើន ជាអ្នកអាក្រក់ខ្លាំងក្លា ញ៉ាំងជន ដទៃឲ្យក្ដៅក្រហាយ នាំគ្នាត្រាច់ប្លន់ប្រជាជន, សូម្បីអ្នកនាំ

បណ្ណាការទៅថ្វាយព្រះរាជា ក៏នាំគ្នាប្ងន់យកអស់, មនុស្សទាំងឡាយប្រជុំគ្នា ស្រែកយំជាទុក្ខត្រង់ព្រះរាជវាំងថា បងប្អូន ១០ នាក់ ដែលជាបុត្ររបស់អន្ធកវេណ្ហុទាសៈប្ងន់ព្រំដែន, ព្រះរាជាបង្គាប់ឲ្យហៅអន្ធកវេណ្ហុទាសៈមកត្រាស់គម្រាមសួរថា ហេតុអ្វីអ្នកឯងទើបបណ្ដោយឲ្យកូនធ្វើការប្ងន់ដូច្នេះ កាលមនុស្សទាំងឡាយស្រែកយំ ជាទុក្ខដល់ទៅ ២-៣ គ្រា យ៉ាងនេះ ព្រះរាជាក៏ទ្រង់គម្រាមអន្ធកវេណ្ហុ គេខ្លាចចំពោះមរណភ័យ ទូលសូមអភ័យទោសចំពោះព្រះរាជា ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព កុមារទាំងនោះ មិនមែនបុត្ររបស់ខ្ញុំព្រះអង្គទេ ជាឱរសរបស់ឧបសាគរឧបរាជ ហើយក្រាបទូលសេចក្ដីកំបាំងនៃរឿងនោះឲ្យទ្រង់ជ្រាប ព្រះរាជាទ្រង់តក់ស្លុតព្រះទ័យ ត្រាស់សួរអមាត្យទាំងឡាយថា យើងនឹងប្រើឧបាយយ៉ាងណា ទើបនឹងចាប់កុមារទាំងនោះបាន ? កាលពួកអមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព កុមារទាំងនោះដើរចំបាប់ដោយចិត្តរីករាយ ខ្ញុំព្រះអង្គនឹងឲ្យធ្វើការច្បាំង (ប្រដាល់) ឡើងក្នុងព្រះនគរ ហើយឲ្យចាប់កុមារទាំងនោះមកកាន់ទីលានប្រយុទ្ធ សម្លាប់ចោលក្នុងទីនោះដូច្នេះ ទើបត្រាស់បង្គាប់ឲ្យ

ហៅអ្នកចំបាប់ ២ នាក់មក ម្នាក់ឈ្មោះថាវានុរៈ ម្នាក់ទៀត ឈ្មោះមុដ្ឋិកៈ ហើយឲ្យវាយស្គរប្រកាសក្នុងព្រះនគរថា រាប់អំពីថ្ងៃនេះទៅ ៧ ថ្ងៃ នឹងមានការប្រយុទ្ធគ្នា ដូច្នេះហើយឲ្យត្រៀមមណ្ឌលប្រយុទ្ធ ត្រង់លានព្រះរាជវាំង ឲ្យធ្វើរង្វង់ការពារត្រង់មណ្ឌលប្រយុទ្ធ ហើយឲ្យចងទង់និងផ្ទាំងសំពត់ ។

សំឡេងកម្រើករំពើកលាន់ឮទូទៅទាំងព្រះនគរ, ប្រជាជននាំគ្នាចងកង់រណានិងគ្រែតូចធំ ។ វានុរៈ មុដ្ឋិកៈ ក៏មកកាន់មណ្ឌលប្រយុទ្ធ ស្រែកគម្រាមទះដៃដើរទៅមក ។ សូម្បីកុមារបងប្អូនទាំង ១០ នាក់ ក៏មកហើយប្ញូន់ដណ្តើមតាមថ្នល់លក់អាហារ របស់ក្រអូប និងគ្រឿងជ្រលក់ ហើយស្លៀកដណ្តប់សំពត់ពណ៌ខៀវ ប្ញូន់ដណ្តើមយកផ្កាកម្រងគ្រឿងក្រអូប តាមទីលក់របស់ក្រអូប ឯផ្កាឈើតាមរានលក់ផ្កាឈើមកប្រដាប់ខ្លួន ផ្កាឈើ(ប្រដាប់)ត្រចៀកទាំង ២ ស្រែកគម្រាមទះដៃចូលទៅកាន់មណ្ឌលប្រយុទ្ធ ខណៈនោះវានុរៈដើរទះដៃ ពលទេពឃើញដូច្នោះ ទើបគិតថា យើងនឹងមិនប៉ះវានុរៈដោយដៃ ហើយទៅនាំខ្សែចងដំរីសេរសៃធំ មកពីរោងដំរី ស្រែកគម្រាម ហើយបោះខ្សែទៅពាន់ព័ទ្ធពោះវានុរៈ រួមចុងខ្សែទាំងពីរចូលគ្នា

ស្រែកលើកឡើងបង្វិលលើសីសៈ ហើយវាយ (បោកទៅលើ) ផែនដី បោះវិលទៅក្រៅ ។ កាលវានុរៈស្លាប់ហើយ ព្រះរាជាបង្គាប់ឲ្យមុដ្ឋិកៈអ្នកចំបាប់ ធ្វើការចំពោះតទៅ មុដ្ឋិកៈក្រោកចេញទៅស្រែកគម្រាមទះដៃ ពលទេពវាយមុដ្ឋិកៈនោះរបូតខ្ទេចទីឆ្អឹង កាលមុដ្ឋិកៈពោលថា លោកជាអ្នកចំបាប់ ខ្ញុំមិនមែនអ្នកចំបាប់ ទើបឆ្លើយថា យើងមិនយល់ថា លោកជាអ្នកចំបាប់ ឬមិនមែនអ្នកចំបាប់ ហើយចាប់ដៃទាំង ២ បោះលើផែនដីឲ្យស្លាប់ហើយ បោះវិលទៅខាងក្រៅ មុដ្ឋិកៈកាលនឹងស្លាប់បានតាំងសេចក្តីប្រាថ្នាទុកថា សូមឲ្យយើងជាយក្ខ បានស៊ីពលទេព គ្រាគេស្លាប់ទៅហើយ ទើបកើតជាយក្ខនៅក្នុងព្រៃ ឈ្មោះកាឡមត្តិកៈ ។

ព្រះរាជាស្តេចក្រោកឡើងត្រាស់ថា លោកទាំងឡាយចូរចាប់បងប្អូនទាំង ១០ នាក់នេះឲ្យបាន, ខណៈនោះវាសុទេពបោះចក្កទៅត្រូវព្រះសីសៈក្សត្របងប្អូនទាំងពីរអស់ព្រះជន្ម ។ មហាជននាំគ្នាតក់ស្លុត ភ័យខ្លាច ក្រាបចុះទៀបបាទារបស់កុមារទាំងនោះ ដោយពោលថា សូមព្រះអង្គបានជាទីពឹងរបស់ពួកខ្ញុំព្រះអង្គ កុមារទាំងនោះកាលផ្តាច់ព្រះជន្មសម្តេច

អំទាំង ២ ព្រះអង្គ ក៏កាន់យករាជសម្បត្តិអសិតញ្ជនគរ លើក មាតាបិតាឡើងគ្រងរាជសម្បត្តិ ហើយប្រឹក្សាគ្នាថា យើង ១០ នាក់ នឹងដណ្តើមយករាជសម្បត្តិ ក្នុងជម្ពូទ្វីបទាំងអស់ ហើយ បបួលគ្នាលើកចេញទៅដោយលំដាប់ ដល់អយុជ្ឈនគរ ដែល ជាទីប្រថាប់របស់ព្រះបាទកាលយោនករាជ ឡោមព័ទ្ធក្រុងទុក ទម្លាយបន្ទាយកំពែងចូលទៅចាប់ព្រះរាជា ដណ្តើមយករាជ-សម្បត្តិនៅក្នុងកណ្តាប់ដៃរបស់ខ្លួន ហើយនាំគ្នាទៅដល់ក្រុង ទ្វារវតី ។

ក៏ក្រុងទ្វារវតីនោះ មានសមុទ្របិតនៅម្ខាង មានភ្នំបិត នៅម្ខាង បានឮថា នគរនោះមានអមនុស្សរក្សា យក្ខអ្នកឈរ រក្សានគរនោះ ឃើញបច្ចាមិត្តហើយប្លែងភេទជាលា ស្រែក សំឡេងដូចលា ខណៈនោះនគរទាំងអស់ក៏អណ្តែតទៅនៅលើ កោះមួយ នៅកណ្តាលសមុទ្រ ដោយអានុភាពយក្ខ កាលពួក បច្ចាមិត្តទៅហើយ នគរក៏ត្រឡប់មកប្រតិស្ឋានដូចដើមទៀត សូម្បីគ្រានោះ យក្ខភេទលានោះដឹងថាកុមារ ១០ នាក់ បងប្អូនមក ក៏ស្រែកជាសំឡេងលាឡើង នគរក៏បណ្តែតទៅ ប្រតិស្ឋាននៅដូចដើមទៀត កុមារទាំងនោះត្រឡប់មកទៀត

យក្ខកេទលាក៏បានធ្វើដូចយ៉ាងនោះទៀត កុមារទាំងនោះកាល
មិនអាចដណ្តើមយករាជសម្បត្តិ ក្នុងក្រុងទ្វារវតីបាន ក៏នាំគ្នា
ទៅរកកណ្ហទីបាយនតាបស នមស្ការហើយសួរថា បពិត្រ
លោកម្ចាស់ដ៏ចម្រើន ខ្ញុំទាំងឡាយមិនអាចដណ្តើមយករាជ-
សម្បត្តិទ្វារវតី សូមលោកប្រាប់ឧបាយដល់ពួកខ្ញុំ ត្រឹមតែម្យ៉ាង
កាលព្រះតាបសប្រាប់ថា មានលាមួយត្រាច់នៅលើខ្នងឯ-
ណោះ លានោះឃើញពួកអមិត្តហើយស្រែកឡើង ខណៈនោះ
នគរក៏បណ្តែតចេញទៅ លោកទាំងឡាយចូរចាប់ជើងរបស់
លានោះ នេះជាឧបាយដែលនឹងឲ្យលោកដល់សេចក្តីសម្រេច
ដូច្នេះ កុមារទាំង ១០ នមស្ការព្រះតាបសហើយ ទៅដេក
ចាប់ជើង របស់លាអង្វរថា បពិត្រនាយ អ្នកដទៃក្រៅពីលោក
ចេញហើយ មិនជាទីពឹងរបស់ពួកខ្ញុំបាន កាលពួកខ្ញុំដណ្តើម
យកនគរសូមលោកកុំស្រែកឡើងឡើយ យក្ខកេទលាពោល
ថា យើងមិនអាចនឹងមិនស្រែកទេ ប៉ុន្តែថា លោក ៤ នាក់ ចូរ
មកមុន ចូរកាន់យកនង្គ័លដែកធំ ហើយវាយដែកគោលធំ ចុះ
នឹងផ្ទៃផែនដីត្រង់ទ្វារទាំង ៤ ផ្នែក កាលនគរនឹងអណ្តែតឡើង
ចូរចាប់នង្គ័លហើយជួយគ្នា យកច្រវាក់ដែកចងនឹងនង្គ័លទុក

នឹងដែកគោល នគរនឹងមិនអាចបណ្តេតទៅបានឡើយ ។

កុមារទាំងនោះទទួលថា ល្អហើយ កាលវេលាជិតយប់នោះ ក៏នាំគ្នាកាន់យកនង្គ័ល ហើយវាយដែកគោលចុះលើផែនដីត្រង់ទ្វារក្រុងទាំង ៤ ផ្នែក បិតនៅខណៈនោះ យក្ខភេទលា ក៏ស្រែកឡើង នគរផ្តើមនឹងបណ្តេតចេញ កុមារទាំងនោះឈរត្រង់ទ្វារក្រុងទាំង ៤ ផ្នែក ចាប់នង្គ័លដែក ៤ ផ្នែក យកប្រវាក់ដែកចងនឹងនង្គ័លទុកនឹងដែកគោល នគរក៏មិនអាចអណ្តែតឡើងបាន លំដាប់នោះ កុមារ ១០ នាក់ បងប្អូនក៏ចូលនគរ ផ្តាច់ព្រះជន្មព្រះរាជាហើយដណ្តើមយករាជសម្បត្តិបាន ។ កុមារទាំងនោះ បានប្រើចក្រផ្តាច់ព្រះជន្មព្រះរាជាទាំងអស់ក្នុងនគរ ៦ ម៉ឺន ៣ ពាន់នគរ ហើយមករួមគ្នានៅក្នុងក្រុងទ្វារវតី បែងចែករាជសម្បត្តិជា ១០ ចំណែក, តែមិនបាននឹកដល់អញ្ជនទេវី ជេដ្ឋភគិនីទេ តមករលឹកឡើងបាន ទើបប្រឹក្សាគ្នាថ្មីថា នឹងបែងចែកជា ១១ ចំណែក អង្កុរកុមារនិយាយឡើងថា លោកទាំងឡាយចូរឲ្យចំណែករបស់យើង ដល់អញ្ជនទេវីជេដ្ឋភគិនីចុះ យើងនឹងធ្វើការជំនួញចិញ្ចឹមជីវិត តែលោកទាំងឡាយត្រូវបែងចែកសួយក្នុងជនបទ របស់ខ្លួនឲ្យដល់យើង

គ្រប់ៗ គ្នា បងប្អូន ៩ អង្គ ទទួលថា ល្អហើយ ដូច្នេះហើយ ប្រគល់រាជសម្បត្តិចំណែករបស់អង្កុរកុមារ ឲ្យដល់អញ្ជនទេវី ជេដ្ឋភគិនី បានជាព្រះរាជា ៩ អង្គនឹងជេដ្ឋភគិនី នៅផ្សេងគ្នា ក្នុងក្រុងទ្វារវតី ចំណែកប្អូនអង្កុរកុមារ បានធ្វើការជំនួញ ។

កាលព្រះរាជាបងប្អូនទាំងនោះ ចម្រើនដោយបុត្រធីតា-តៗ មកទៀតយ៉ាងនេះ កាលកន្លងទៅយូរ ព្រះរាជមាតាបិតា ក៏អស់ព្រះជន្ម បានឮថា អាយុកាលរបស់មនុស្សក្នុងគ្រានោះ ដល់ ២០.០០០ ឆ្នាំ គ្រានោះ ព្រះឱរសជាទីស្រឡាញ់ ១ អង្គ របស់វាសុទេពមហារាជអស់ព្រះជន្ម ព្រះរាជាទ្រង់តែងសោក សៅ លះបង់សព្វកិច្ចចេញ ផ្ទុំក្រសោបព្រះហឫទ័យរអ៊ូរទាំ កាលនោះ ឃតបណ្ឌិតគិតថា វៀរយើងចេញហើយ អ្នកដទៃ ណាហ្ន៎ ឈ្មោះថា អាចកំចាត់សេចក្តីសោករបស់បងប្រុស-យើង រមែងមិនមាន យើងនឹងប្រើឧបាយកម្ចាត់សេចក្តីសោក របស់បងប្រុស គិតដូច្នេះហើយ ទើបធ្វើជាមនុស្សឆ្កួត ងើយ មើលអាកាសដើររអ៊ូរទាំទៅទូទាំងក្រុងថា លោកចូរឲ្យទន្សាយ ដល់យើង លោកចូរឲ្យទន្សាយដល់យើង ដូច្នេះ ដំណឹងលេច ឮទៅទូទាំងក្រុងថា ឃតបណ្ឌិត ឆ្កួតហើយ ។

*វេលានោះ អមាត្យឈ្មោះរោហិនេយ្យៈ ទៅគាល់ព្រះបាទវាសុទេព កាលនឹងផ្ដើមសន្ទនាជាមួយព្រះអង្គ បានពោលគាថាទី ១ ថា ៖*

*បពិត្រព្រះអង្គជាកណ្ហាយនគោត្រ សូមព្រះអង្គក្រោកឡើង ព្រះអង្គផ្ទំធ្វើអ្វី ប្រយោជន៍អ្វីដល់ព្រះអង្គដោយការផ្ទំ ក្សត្រណា ជាព្រះកនិដ្ឋភាតារបស់ខ្លួនព្រះអង្គ (ស្មើដោយ) ហឫទ័យ និងព្រះនេត្រខាងស្ដាំ ខ្យល់ចាប់រួបរឹតនូវហឫទ័យរបស់ក្សត្រ ជាព្រះកនិដ្ឋភាតានោះ បពិត្រព្រះកេសវៈ ឃតបណ្ឌិត រមែងអំពាវនាវថា (អ្នកទាំងឡាយចូរឲ្យទន្សាយដល់យើង) ។*

*កាលអមាត្យទូល (ពក់ទាក់ព្រះបាទវាសុទេព) យ៉ាងនេះហើយ ព្រះសាស្ដាត្រាស់ដឹងហើយ ទ្រង់ជ្រាបសេចក្ដីដែលឃតបណ្ឌិតមានចិត្តរឹងមាំ ទើបត្រាស់ព្រះគាថាទី ២ ថា ៖*

*ព្រះបាទកេសវៈ ទ្រង់បានសណ្ដាប់ពាក្យរបស់អមាត្យឈ្មោះរោហិនេយ្យនោះហើយ ក៏ទ្រង់ក្រោកឡើងរលះរលាំង (ស្ទុតព្រះហឫទ័យ) ត្រូវសេចក្ដីសោកក្នុងព្រះកនិដ្ឋភាតាគ្របសង្កត់ ។*

ព្រះរាជាស្តេចក្រោកឡើង ប្រញាប់ស្តេចចុះចាកប្រាសាទ ទៅរកឃតបណ្ឌិតចាប់ព្រះហស្តទាំង ២ ទុក សូម្បីកាលនឹងចរចាជាមួយឃតបណ្ឌិត បានពោលគាថាទី ៣ ថា ៖

អ្នកហេតុអ្វី ក៏មានសភាពហាក់ដូចជាមនុស្សឆ្កួត (ត្រាច់ទៅ)
កាន់នគរទ្វារវតីទាំងមូលនេះ និយាយរវើរវាយថា
ទន្សាយៗ អ្នកណាលួចយកទន្សាយរបស់អ្នកទៅឬ ។

បណ្តាបទទាំងនោះ បទថា **កេវលំ ទ្វារកំ ឥមំ** សេចក្តីថា ព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វីទើបអ្នកហាក់ដូចជាមនុស្សឆ្កួត ត្រាច់ទៅកាន់នគរទ្វារវតីទាំងមូលនេះថាទន្សាយៗ អ្នកណាលួចយកទន្សាយរបស់អ្នកទៅឬ គឺទន្សាយរបស់អ្នកឯងអ្នកណាលួចយកទៅហើយឬ ?

កាលព្រះរាជាត្រាស់យ៉ាងនេះហើយ ឃតបណ្ឌិតក៏នៅតែត្រាស់ពាក្យនោះឯងដដែលៗ ព្រះរាជាទើបត្រាស់ ២ គាថាទៀតថា ៖

អ្នកប្រាថ្នានូវទន្សាយមាស កែវមណី (លោហៈ) ឬប្រាក់ ឬក៏ទន្សាយធ្វើដោយស័ង្ខ សិលា កែវប្រពាឡ យើងនឹងឲ្យគេធ្វើទន្សាយនោះដល់អ្នក ។ (បើអ្នកមិនពេញចិត្តទន្សាយ

នោះទេ) ទន្សាយឯទៀតក្នុងព្រៃ (ដែលត្រាច់) រកស៊ីស្មៅក្នុងព្រៃ យើងនឹងឲ្យគេនាំយកទន្សាយទាំងនោះមកឲ្យអ្នក អ្នកត្រូវការ (ចង់បាន) ទន្សាយបែបណា (ចូរប្រាប់យើងក្នុងកាលឥឡូវនេះ) ។

យតបណ្ឌិត ស្ដាប់ព្រះតម្រាស់របស់ព្រះរាជាហើយ ទើបពោលគាថាទី ៦ ថា ៖

ពួកទន្សាយណា ដែលអាស្រ័យនៅលើផែនដី ខ្ញុំព្រះអង្គ
មិនប្រាថ្នាចង់បានទន្សាយទាំងនុ៎ះទេ ខ្ញុំព្រះអង្គ ប្រាថ្នាចង់
បានតែទន្សាយអំពីដួងព្រះចន្ទ្រ បពិត្រព្រះកេសរៈ សូម
ព្រះអង្គញ៉ាំងទន្សាយនោះឲ្យចុះមកដើម្បីខ្ញុំ ។

ព្រះរាជា ទ្រង់សណ្ដាប់ពាក្យរបស់យតបណ្ឌិតហើយ ទ្រង់ទោមនស្សថា ប្អូនប្រុសរបស់យើងហាក់ដូចជាឆ្កួតហើយ ដោយមិនគួរសង្ស័យ ទើបពោលគាថា ទី ៧ ថា ៖

អ្នកណាប្រាថ្នានូវរបស់ដែលមិនគួរប្រាថ្នា (ដូចជា) អ្នក
ប្រាថ្នានូវទន្សាយអំពីដួងព្រះចន្ទ្រ ម្នាលអ្នកជាញាតិ អ្នក
នោះនឹងលះបង់ជីវិតជាទីស្រឡាញ់ដោយពិត (ក៏មិនបាន
ទន្សាយអំពីដួងព្រះចន្ទ្រនោះដែរ) ។

ព្រះរាជាកាលទឹងទ្រង់ហៅព្រះកនិដ្ឋា ទើបត្រាស់ថា ប្អូន ក្នុងព្រះគាថានោះ សេចក្ដីនេះមានអធិប្បាយថា នែបា អ្នកណា ប្រាថ្នានូវរបស់ដែលមិនគួរប្រាថ្នា អ្នកនោះអ្នកជាប្អូនរបស់ យើង នឹងលះបង់ជីវិតជាទីស្រឡាញ់របស់ខ្លួនដោយពិត ។

ឃតបណ្ឌិត ស្ដាប់ព្រះរាជតម្រាស់ហើយឈរស្ងៀម ពោលថា បពិត្រម្ចាស់បង បងទ្រង់ជ្រាបថាខ្ញុំព្រះអង្គប្រាថ្នា ទន្សាយអំពីដួងព្រះចន្ទ្រ មិនបានហើយនឹងស្លាប់ ក៏ហេតុអ្វីបង ទើបសោកសៅ ដល់ឱរសដែលអស់ព្រះជន្មទៅហើយហ្ន៎ ហើយពោលគាថាទី ៨ ថា ៖

បពិត្រព្រះកណ្ហាយនគោត្រ បើព្រះអង្គទ្រង់ជ្រាបយ៉ាង នេះហើយ ព្រះអង្គទ្រង់ប្រៀនប្រដៅបុគ្គលដទៃបាន ហេតុ អ្វី (បានជាព្រះអង្គ) ទ្រង់ព្រះកន្សែងសោកស្ដាយនឹងបុត្ត ដែលទទួលមរណភាពក្នុងកាលមុនរហូតមកក្នុងថ្ងៃនេះ ។

បទថា បុរេ ជាដើម សេចក្ដីថា ឃតបណ្ឌិតពោលថា កាលជាដូច្នោះ ព្រោះហេតុអ្វីព្រះអង្គទើបទ្រង់សោកសៅដល់ ព្រះរាជឱរសដែលអស់ព្រះជន្មទៅហើយ រាប់ពីនេះទៅដល់ ៤ ខែ ដរាបមកដល់ថ្ងៃនេះហ្ន៎ ?

យតបណ្ឌិត ឈរចន្ទោះវិថីក្រាបទូលដូច្នេះថា បពិត្រព្រះម្ចាស់បង ខ្ញុំប្រាថ្នាវត្ថុដែលឃើញប្រាកដនៅពិតៗ តែម្ចាស់បង ទ្រង់សោកសៅ ដើម្បីទ្រង់ប្រាថ្នាវត្ថុដែលមិនបានប្រាកដនៅ កាលនឹងសម្ដែងធម៌ថ្វាយព្រះរាជា បានពោលគាថា ២ គាថាទៀតថា ៖

របស់ណាដែលមនុស្ស ឬអមនុស្សមិនគប្បីបានវិញ ដោយប្រាថ្នាថា (ព្រះអង្គប្រាថ្នានូវរបស់នោះថា) បុត្តរបស់យើងកើតមកហើយកុំស្លាប់ទៅវិញឡើយ ដូច្នេះ ព្រះអង្គនឹងគប្បីបានរបស់ដែលមិនគប្បីបានអំពីទីណាកើត ។ បពិត្រព្រះ-កណ្ហាយនគោត្រ ព្រះអង្គទ្រង់សោកស្ដាយនឹងបុត្រណាដែលទៅកាន់បរលោកហើយ ព្រះអង្គអាចដើម្បីនឹងនាំយកបុត្តនោះមកវិញបានដោយមន្ត ដោយមូលភេសជ្ជៈ (ថ្នាំដែលធ្វើដោយឫសឈើ) ដោយឱសថ ឬដោយទ្រព្យ មិនបានឡើយ ។

បទថា យំ ជាដើម សេចក្ដីថា យតបណ្ឌិត សម្ដែងថា មនុស្ស ឬទេវតាមិនគប្បីបានទៀត គឺមិនអាចដើម្បីបានឋានៈយ៉ាងណា គឺសេចក្ដីប្រាថ្នាយ៉ាងនេះថា បុត្ររបស់យើងដែលកើតមកហើយ កុំស្លាប់ឡើយ ព្រះអង្គទ្រង់ប្រាថ្នាឋានៈយ៉ាង

នោះ នឹងគប្បីឲ្យឋានៈដែលមិនគួរបាននោះ គឺព្រះឱរសដែលទៅបរលោក ហើយពីទីណាកើត ? គឺនឹងអាចបានដោយហេតុណា ? បានដល់ មិនអាចនឹងបានឋានៈដែលមិនគួរបាននោះ ។ អធិប្បាយថា ព្រោះហេតុនោះ ដែលឈ្មោះថា វត្ថុដែលមិនគួរបាន គឺឋានៈដែលមិនគួរបាននោះ នឹងគប្បីបានមកពីទីណាកើត ។

បទថា មន្តា គឺដោយការរាយមន្ត ។ បទថា មូល-ភេសជ្ជ គឺដោយឫសថ្នាំ ។ បទថា ឱសធេហិ គឺដោយឱសថប្រភេទផ្សេងៗ ។ បទថា ធនេន វា គឺ ឬដោយព្រះរាជទ្រព្យរាប់រយកោដិ ។ ពាក្យនេះ មានអធិប្បាយថា ព្រះអង្គទ្រង់សោកសៅដល់ព្រះឱរសអង្គណា ដែលទៅបរលោកហើយ ព្រះអង្គក៏មិនអាចនឹងនាំព្រះឱរសនោះមកបាន សូម្បីដោយការរាយមន្តជាដើមទាំងនោះ ។ ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយត្រាស់ថា នែបា ឃតបណ្ឌិត ពាក្យដែលពោលនេះគួរកំណត់ទុក អ្នកបានធ្វើឲ្យយើងបាត់សោកហើយ កាលនឹងសរសើរឃតបណ្ឌិត ទើបត្រាស់ព្រះគាថា ៤ ព្រះគាថាថា ៖

ពួកបុរសជាបណ្ឌិតប្រាកដដូច្នេះ ជាអមាត្យរបស់ព្រះ-

រាជាអង្គណា ដូចយ៉ាងអ្នកជាបណ្ឌិតបុរស ឈ្មោះថា បាន ពន្យល់(ខ្ញុំ) ក្នុងថ្ងៃនេះ (សេចក្តីសោករបស់ព្រះរាជានោះនឹងមានមកពីណា) ។ អ្នកបានស្រោចស្រពនូវយើងដែលភ្លើង គឺសេចក្តីសោកកំពុងឆេះ ឲ្យស្ងប់រម្ងាប់ ញុំាងសេចក្តីក្រវល់-ក្រវាយទាំងអស់ឲ្យរលត់ ដូចបុគ្គលយកទឹកស្រោចនូវភ្លើងដែលកំពុងឆេះឆ្នាំខ្វាញ់ ។ សរគឺសេចក្តីសោកណា ដែលអាស្រ័យក្នុងហឫទ័យ សរគឺសេចក្តីសោកនោះ យើងបានដកចេញហើយ អ្នកឈ្មោះថា បានបន្ទោបង់នូវសេចក្តីសោកព្រោះបុត្ររបស់យើង ដែលត្រូវសេចក្តីសោកគ្របសង្កត់ ។ ម្នាលមាណព យើងនោះជាអ្នកមានសរ គឺសេចក្តីសោកដកចេញហើយ ជាអ្នកប្រាស់ចាកចេសក្តីសោក ម្នាលមាណព យើងលែងសោកស្តាយ លែងយំទួញ ព្រោះបានស្តាប់នូវពាក្យរបស់អ្នក ។

បណ្តាគាថាទាំងនោះ គាថាទីមួយមានសេចក្តីសង្ខេបដូច្នេះថា បុរសដែលជាបណ្ឌិតដូច្នេះ ជាអមាត្យរបស់ព្រះរាជាសូម្បីអង្គដទៃណា ព្រះរាជាអង្គនោះ នឹងមានសេចក្តីសោកមកពីណាកើត ដូចឃតបណ្ឌិត ញុំាងយើងដែលត្រូវសេចក្តី

សោកសៅចំពោះបុត្រ គ្របសង្កត់ហើយ ឲ្យរលត់ គឺឲ្យត្រជាក់ បានដល់ ឲ្យភ្ញាក់ ដើម្បីប្រយោជន៍ដល់ការកម្ចាត់សេចក្ដីសោកដូច្នោះ ។ គាថាដ៏សេស មានសេចក្ដីដូចពោលហើយនុ៎ះឯង ។

ក្នុងអវសាន មានអភិសម្ពុទ្ធគាថា ដែលមានសេចក្ដីឆាយ ដូច្នេះថា ៖

ពួកជនណា ប្រកបដោយប្រាជ្ញា ជាអ្នកអនុគ្រោះ រមែងធ្វើយ៉ាងនេះ ទើបញ៉ាំងជនឲ្យឃ្លាតចាកសេចក្ដីសោក ដូចឃតបណ្ឌិត ញ៉ាំងព្រះជេដ្ឋា (ឲ្យរួចចាកសោក) ដូច្នោះ ។

កាលព្រះបាទវាសុទេព អ្នកដែលឃតបណ្ឌិតធ្វើឲ្យអស់សេចក្ដីសោកហើយយ៉ាងនេះ គ្រងរាជសម្បត្តិដោយកន្លងទៅនៃកាលដ៏វែងឆ្ងាយ ព្រះកុមារឱរសរបស់ក្សត្រិយ៍បងប្អូនទាំង ១០ នាក់ ប្រឹក្សាគ្នាថា គេពោលថា កណ្ហទីបាយនតាបស អ្នកមានភ្នែកដូចជាទិព្វ ពួកយើងនឹងសាកល្បងលោកមើល ទើបប្រដាប់កុមារប្រុសម្នាក់ សម្ដែងអាការដូចស្រីមានគភ៌ យកកូនកែវមរកត ចងទុកត្រង់ពោះ ហើយនាំទៅរកព្រះតាបសសួរថាបពិត្រលោកដ៏ចម្រើន ក្មេងស្រីនេះនឹងប្រសូតឬទេ ? ព្រះ-

តាបសពិចារណាមើលដឹងថា កាលវិបត្តិរបស់ក្សត្រិយ៍បងប្អូន ១០ អង្គ មកដល់ហើយ អាយុសង្ខាររបស់ពួកយើងប្រាកដយ៉ាងណាហ្ន៎ ? ក៏ដឹងថា នឹងស្លាប់ថ្ងៃនេះពិត ទើបពោលថា កុមារទាំងឡាយ ពួកលោកត្រូវការអ្វីដោយរឿងនេះ ត្រូវពួកកុមារពោលថា សូមលោកចូរប្រាប់ដល់ពួកខ្ញុំចុះលោកម្ចាស់ ទើបពោលថា តពីនេះទៅ ៧ ថ្ងៃ កុមារិកានេះ នឹងប្រសូតពកឈើចេញមក ដោយហេតុនោះ ត្រកូលរបស់វាសុទេពនឹងវិនាស ម្យ៉ាងទៀត លោកទាំងឡាយចូរយកពកឈើនោះទៅដុតហើយយកផេះទៅចោលក្នុងទន្លេ លំដាប់នោះ ព្រះកុមារទាំងនោះ ពោលនឹងព្រះតាបសថា ម្នាលជដិលកោង ធម្មតាក្មេងប្រុសប្រសូតកូនបានមិនមានឡើយ ហើយធ្វើកម្មឈ្មោះតន្តរជ្ជុកៈ ឲ្យតាបសអស់ជីវិតក្នុងទីនោះឯង ។

ក្សត្រិយ៍បងប្អូនទាំងឡាយ ហៅព្រះកុមារមកត្រាស់សួរថា ពួកអ្នកឯង សម្លាប់ព្រះតាបសព្រោះហេតុអ្វី ? កាលបានស្តាប់រឿងទាំងអស់ហើយ ទ្រង់ភ័យខ្លាច ទើបរក្សាក្មេងនោះទុក គ្រាដល់ថ្ងៃទី ៧ ឲ្យដុតពកដែលចេញពីផ្ទៃក្មេងនោះហើយ យកផេះទៅចោលក្នុងទន្លេ ផេះនោះត្រូវទឹកផាត់ទៅ

ជាប់នៅទៀបមាត់ (ប្រាំង)ម្ខាង កើតជាវែទឹកឡើងទីនោះ ។

នៅក្នុងថ្ងៃមួយជាលំដាប់មក ក្សត្រិយ៍ទាំងនោះបបួលគ្នាទៅលេងសមុទ្រ ស្តេចទៅដល់មាត់សមុទ្រហើយ ឲ្យធ្វើមហាមណ្ឌប ទ្រង់សោយទ្រង់ផឹក ទ្រង់លេងក្នុងមហាមណ្ឌប ដែលតាក់តែងស្រស់ល្អ ប្រើព្រះហស្តនិងព្រះបាទប៉ះត្រូវគ្នា តែងប្រព្រឹត្តទៅ ដោយអំណាចសេចក្តីចំអកឡកឡឺយ ទើបឈ្លោះគ្នាដ៏ធំ បែកគ្នាជាពីរពួក លំដាប់នោះ ក្សត្រិយ៍អង្គមួយកាលមិនបានមុគ្គរ (ឈើប្រទង់) យ៉ាងដទៃ ក៏កាន់ស្ទឹកវែទឹកមួយស្ទឹកវែទឹកនោះ គ្រាន់តែចាប់កាន់ប៉ុណ្ណោះ ក៏ក្លាយជាឈើអន្ទង, ព្រះអង្គទ្រង់វាយមហាជនដោយឈើអន្ទងនោះហើយវត្ថុដែលអ្នកទាំងអស់ចាប់ ដោយយល់ថាជាយ៉ាងដទៃៗ ក៏ក្លាយជាឈើអន្ទងទាំងអស់, គេទើបប្រហារគ្នានឹងគ្នា ដល់សេចក្តីវិនាសអស់, កាល(ក្សត្រិយ៍) ទាំងនោះកំពុងវិនាសក្សត្រិយ៍ ៤ អង្គគឺ វាសុទេព ពលទេព អញ្ជនទេវិកគិនី និងបុរោហិត នាំគ្នាឡើងរថគេចជៀសចេញទៅ, ពួកដែលនៅសេសសល់ (ក៏ដល់នូវសេចក្តី)វិនាសអស់ ។ ក្សត្រិយ៍ទាំង ៤ អង្គនោះឡើងរថគេចជៀសចេញទៅ ដល់ព្រៃកាឡមត្តិកៈ, ក៏

មុជ្ជិកអ្នកចំបាប់នោះដែលតាំងសេចក្ដីប្រាថ្នាទុក បានកើតជាយក្ខ នៅក្នុងព្រៃនោះ ដឹងថាពលទេពមក ក៏និម្មិតស្រុកឡើង (ក្នុង)ទីនោះ ប្លែងភេទជាអ្នកចំបាប់ត្រាច់ស្រែកគម្រាម ទះដៃថា អ្នកណាត្រូវការច្បាំង (ប្រដាល់) ពលទេពល្មមឃើញគេទាំងនោះ ក៏ពោលថា បពិត្រព្រះម្ចាស់បង ខ្ញុំនឹងចូលទៅរកច្បាំងជាមួយបុរសនេះឯង កាលវាសុទេពហាមទុំះឯង ចុះអំពីរថ ទះដៃចូលទៅរកយក្ខនោះ លំដាប់នោះ យក្ខទើបចាប់ដៃដែលលាចេញហើយស៊ីពលទេពដូចមើមឈូក ។ វាសុទេព ដឹងថាពលទេពអស់ជីវិត ទើបនាំកគិនីនិងបុរោហិតធ្វើដំណើរទៅរហូតដល់អស់មួយយប់ ល្មមភ្លឺឡើងក៏ដល់បច្ចន្តគ្រាមមួយ បន្ទាប់កគិនីនិងបុរោហិតទៅកាន់ស្រុក ត្រាស់ថា ចំអិនអាហារហើយនាំមក ខ្លួនឯងចូលទៅដេកលាក់ខ្លួននៅត្រង់គល់ឈើមួយ ។

គ្រានោះ នាយព្រានម្នាក់ ឈ្មោះជរា ឃើញគុម្ពឈើញ័រៗ យល់ថា ជ្រូកនឹងមានទីនោះ ទើបបោះលំពែងទៅ ត្រូវព្រះបាទវាសុទេព កាលវាសុទេពត្រាស់ថា អ្នកណាចាក់យើង នាយព្រាន ដឹងថាខ្លួនចាក់មនុស្ស ក៏ស្លុតចិត្តខ្លាច ប្រារព្ធនឹង

គេចបេញទៅ ព្រះរាជតាំងសតិទុក ស្តេចក្រោកឡើង ត្រាស់ហៅថា ម្នាលអ៊ំ កុំខ្លាចឡើយចូរមកចុះ កាលនាយព្រានមកហើយ ទើបត្រាស់សួរថា លោកឈ្មោះអ្វី ? កាលនាយព្រានឆ្លើយថា បពិត្រនាយ ខ្ញុំឈ្មោះជរា ក៏ទ្រង់ជ្រាបថា ន័យថាមនុស្សចាស់ (បោរាណ) ព្យាករណ៍យើងទុកថា នឹងត្រូវនាយជរាចាក់ស្លាប់ ថ្ងៃនេះយើងនឹងស្លាប់ដោយមិនមានសង្ស័យហើយត្រាស់ចំពោះនាយជរាថា នែអ៊ំ លោកកុំខ្លាចឡើយចូរមកជួយចងមុខរបួសត្រង់ជើងឲ្យយើង ឲ្យនាយព្រានជរាចងមុខរបួសហើយ ក៏បញ្ជូននាយព្រាននោះទៅ វេទនាមានកម្លាំងបានប្រព្រឹត្តទៅយ៉ាងខ្លាំងក្លា ព្រះរាជាមិនអាច នឹងសោយព្រះក្រយាហារដែលភគិនី និងបុរោហិត នាំមកបានលំដាប់នោះ ព្រះអង្គទើបត្រាស់ហៅជនទាំងពីរមក ត្រាស់ថាយើងនឹងស្លាប់ថ្ងៃនេះ ក៏លោកទាំង ២ ជាសុខុមាលជាតិ មិនអាចនឹងធ្វើការងារយ៉ាងដទៃចិញ្ចឹមជីវិតបាន ចូររៀនវិជ្ជានេះទុកហើយឲ្យសិក្សាវិជ្ជាម្យ៉ាង ហើយបញ្ជូនគេត្រឡប់ទៅ ព្រះអង្គអស់ព្រះជន្ម នៅក្នុងទីនោះឯង ក្សត្រិយ៍បងប្អូនទាំងអស់ក្រៅពីអញ្ជូនទេវីហើយ ដល់សេចក្តីវិនាសអស់ ។

ព្រះសាស្តា ត្រាទ្រង់នាំព្រះធម៌ទេសនានេះមកសម្តែងហើយ ត្រាស់ថា ម្នាលឧបាសក បោរាណកបណ្ឌិត ស្តាប់ពាក្យរបស់បណ្ឌិតហើយ កម្ចាត់សេចក្តីសោកដល់បុត្ររបស់ខ្លួនចេញបាន លោកកុំគិតដល់គេឡើយ ដូច្នេះ ហើយទ្រង់ប្រកាសសច្ចធម៌ វេលាចប់សច្ចៈ ឧបាសកតាំងនៅក្នុងសោតាបត្តិផល ។

ព្រះទសពលទ្រង់ប្រជុំជាតកថា រោហិនេយ្យអមាត្យក្នុងគ្រានោះ បានមកជាព្រះអានន្ទ ក្នុងឥឡូវនេះ វាសុទេពក្នុងគ្រានោះ បានមកជាព្រះសារីបុត្រក្នុងឥឡូវនេះ ពួកដ៏សេសក្រៅនេះ ក្នុងគ្រានោះ បានមកជាពុទ្ធបរិស័ទក្នុងឥឡូវនេះ ចំណែកឃតបណ្ឌិត ក្នុងគ្រានោះ បានមកជាតថាគតសម្មាសម្ពុទ្ធ បើកជំបូលគឺកិលេស ក្នុងលោកបានហើយដូច្នេះឯង ។

ចប់ អដ្ឋកថាឃតបណ្ឌិតជាតក ។

# ២១_ឧរគជាតក

*(សុត្តន្តបិដក លេខ៥៩ ទំព័រ០៥)*

*ព្រះសាស្ដា កាលទ្រង់គង់នៅក្នុងព្រះវិហារជេតវ័ន ទ្រង់ប្រារព្ធកុដុម្ពីម្នាក់ អ្នកមានករិយាស្លាប់ហើយ ទើបត្រាស់ព្រះធម៌ទេសនានេះ មានពាក្យចាប់ផ្ដើមថា* ***ឧរគោវ តចំ ជិណ្ណំ*** *ដូច្នេះ ៖*

*រឿងបច្ចុប្បន្ន ដូចជារឿងកុដុម្ពីដែលមានករិយាស្លាប់និងមានបិតាស្លាប់ហើយទាំះឯង ។ សូម្បីក្នុងជាតកនេះ ព្រះ-សាស្ដា ស្ដេចទៅកាន់និវេសន៍របស់កុដុម្ពីនោះ យ៉ាងនោះដូចគ្នាហើយ ត្រាស់សួរកុដុម្ពីនោះដែលមកថ្វាយបង្គំហើយអង្គុយថា អាវុសោ លោកសោកសៅឬ កាលកុដុម្ពីនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសោយសោក តាំងពីបុត្ររបស់ខ្ញុំព្រះអង្គស្លាប់ទៅហើយ ទើបទ្រង់ត្រាស់ថា អាវុសោ ឈ្មោះថា វត្ថុដែលមានការបែកធ្លាយជាធម្មតា រមែងនឹងបែក-ធ្លាយទៅ ឈ្មោះថា វត្ថុដែលមានការវិនាសទៅជាធម្មតា រមែងនឹងវិនាសទៅ ក៏ឯវត្ថុដែលមានការបែកធ្លាយ និងការវិនាសទៅនោះ នឹងមានដល់អ្នកតែម្នាក់ប៉ុណ្ណោះក៏ទេ នឹងមានក្នុងពួក*

អ្នកស្រុកតែមួយប៉ុណ្ណោះក៏ទេ ឈ្មោះថា សង្ការធម៌ គឺសេចក្ដីមិនស្លាប់ រមែងមិនមានក្នុងភពទាំងបី ក្នុងចក្រវាឡដែលប្រមាណមិនបាន សូម្បីសង្ខារតែមួយយ៉ាងដែលអាចតាំងនៅដោយការៈនោះប៉ុណ្ណោះ ឈ្មោះថា ទៀង យឺនយូរ រមែងមិន-មានទេ សត្វទាំងពួងមានសេចក្ដីស្លាប់ជាធម្មតា សង្ខារទាំង-ឡាយមានការបែកធ្លាយទៅជាធម្មតា សូម្បីបូរាណកបណ្ឌិតទាំងឡាយ កាលបុត្រស្លាប់ហើយ គិតថា វត្ថុដែលមានការវិនាសទៅជាធម្មតា វិនាសទៅហើយ ទើបមិនសោកសៅឡើយ, កាលកុដុម្ពីនោះទូលអារាធនាហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធក ដូចតទៅនេះ ៖

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងពួកស្រុកជិតទ្វារក្រុងពារាណសី សន្សំទ្រព្យសម្បត្តិទុកចិញ្ចឹមជីវិតដោយកសិកម្ម ។ ព្រះពោធិសត្វនោះមានទារក ២ នាក់ គឺបុត្រ ១ ធីតា ១ ។ ព្រះពោធិសត្វនោះ កាលបុត្រចម្រើនវ័យហើយ បាននាំនាងកុមារិកាមកពីត្រកូលដែលស្មើគ្នា ។ ដូចនោះ ជនទាំងនោះបានជា ៦ នាក់ មួយអន្លើដោយនាង-

ទាសី គឺ ព្រះពោធិសត្វ ភរិយា បុត្រ ធីតា កូនប្រសារ និង ទាសី ។ ជនទាំងនោះបានជាអ្នកព្រមព្រៀងត្រេកអរនៅជាមួយគ្នា ដោយសេចក្តីស្រឡាញ់ ។ ព្រះពោធិសត្វបានឲ្យឱវាទដល់អ្នកទាំង ៥ ដ៏សេស យ៉ាងនេះថា អ្នកទាំងឡាយចូរឲ្យទានដោយនិយាម តាមទំនងដែលរកបានប៉ុណ្ណោះ ចូររក្សាសីល ធ្វើឧបោសថកម្ម ចម្រើនមរណស្សតិ ចូរកំណត់ដល់ការ: គឺ សេចក្តីស្លាប់របស់លោកទាំងឡាយ ព្រោះសេចក្តីស្លាប់របស់សត្វទាំងនេះ ជារបស់យឺនយូរ (ធុវំ) ជីវិតមិនយឺនយូរ (អទ្ធុវំ) សង្ខារទាំងពួងមិនទៀង មានសេចក្តីសាបសូន្យទៅជាធម្មតាមែនពិត លោកទាំងឡាយចូរជាអ្នកមិនប្រមាទទាំងពេលយប់និងពេលថ្ងៃចុះ ។ ជនទាំង ៥ នោះ ទទួលឱវាទថា សាធុ ហើយជាអ្នកមិនប្រមាទចម្រើនមរណស្សតិ ។ តមកនៅថ្ងៃមួយ ព្រះពោធិសត្វ ទៅស្រែព្រមជាមួយនឹងបុត្រ ភ្ជួរស្រែ, បុត្រទាញសម្រាមពីគំនរសម្រាមមកដុត ក្នុងទីមិនឆ្ងាយពីបុត្រនោះ មានអាសិរពិសនៅក្នុងជំបូកមួយកន្ទែង ផ្សែងភ្លើងប៉ះខ្ញប់ភ្នែករបស់អាសិរពិសនោះ វាក្រោធលូនចេញមក គិតថា ភ័យកើតដល់យើង ព្រោះអាស្រ័យអ្នកនេះ ទើបខាំបុត្រប្រុស លិចទាំង

៤ ចង្កូម គេដួលចុះស្លាប់ភ្លាម ព្រះពោធិសត្វ ក្រឡេកមក មើលឃើញបុត្រប្រុសនោះដួលចុះ ទើបឈប់គោហើយទៅរក ដឹងថាបុត្រប្រុសនោះស្លាប់ហើយ ទើបលើកបុត្រនោះឡើង ឲ្យ ដេកនៅទៀបគល់ឈើមួយកន្លែង គ្របសំពត់ទុក មិនស្រែក- យំ មិនបរិទេវៈរៀបរាប់ ។ ភ្ជួរស្រែទៅបណ្ដើរ កំណត់ដល់ ភាពជាអនិច្ចំ ថា ក៏វត្ថុដែលមានការបែកធ្លាយជាធម្មតា បែក- ធ្លាយទៅហើយ វត្ថុដែលមានសេចក្ដីស្លាប់ជាធម្មតា ស្លាប់ទៅ ហើយ សង្ខារទាំងពួងមិនទៀង សម្រេចដោយសេចក្ដីស្លាប់ ។ ព្រះពោធិសត្វនោះ ឃើញបុរសអ្នកស្និទ្ធស្នាលម្នាក់ ដើរទៅ តាមផ្លូវជិតស្រែខ្លួន ទើបសួរថា នឹងទៅផ្ទះឬអ្នក កាលគេ ពោលថា បាទ, ទើបពោលថា បើយ៉ាងនោះ លោកគប្បីផ្ទៀង ចូលទៅកាន់ផ្ទះសួម្បីរបស់ពួកយើង ប្រាប់ចំពោះនាងព្រាហ្ម- ណី គេថា ថ្ងៃនេះមិនចាំបាច់នាំកត្តាហារទៅដើម្បីបុគ្គលពីរ- នាក់ដូចកាលមុនទេ គប្បីនាំអាហារទៅចំពោះសម្រាប់បុគ្គល តែម្នាក់ប៉ុណ្ណោះ និងកាលមុនទាសីតែម្នាក់ប៉ុណ្ណោះនាំអាហារ មក តែថ្ងៃនេះអ្នកទាំង ៤ គប្បីស្លៀកដណ្ដប់សំពត់ស កាន់ របស់ក្រអូបនិងផ្កាឈើមក ។ បុរសនោះទទួលពាក្យហើយទៅ

ប្រាប់ដល់នាងព្រាហ្មណីដូចយ៉ាងនោះ ។ នាងព្រាហ្មណី សួរថា នែបា ដំណឹងនេះអ្នកណាឲ្យលោកមក ? បុរសនោះឆ្លើយថា បពិត្រម៉ែម្ចាស់ ព្រាហ្មណ៍ឲ្យមក ។ នាងព្រាហ្មណីនោះ បានដឹងថា បុត្ររបស់យើងស្លាប់ហើយ ។ សូម្បីសេចក្តីវិបរិតត្រឹមតែថា សេចក្តីញ័រន្ទេត់ចិត្ត ក៏មិនបានមានដល់នាង-ព្រាហ្មណីនោះ ។ ក៏នាងមានចិត្តអប់រំទុកល្អហើយយ៉ាងនេះ ស្លៀកដណ្តប់សំពត់សកាន់របស់ក្រអូបនិងផ្កាឈើ ឲ្យកាន់អាហារ ហើយបានទៅព្រមជាមួយនឹងបុគ្គលដ៏សេស ។ សូម្បីបុគ្គលតែម្នាក់ ក៏មិនបានមានការស្រែកយំ ឬការរៀបរាប់ ។

ព្រះពោធិសត្វអង្គុយក្រោមស្រមោលម្លប់(ឈើ) ដែលបុត្រប្រុសដេកនុំៈឯងបរិភោគអាហារ ។ ក្នុងវេលាបរិភោគអាហាររួចស្រេច មនុស្សសូម្បីទាំងអស់ក៏នាំឧសមក លើកបុត្រប្រុសនោះឡើងកាន់ជើងថ្ករ បូជាដោយរបស់ក្រអូប និងផ្កាឈើហើយដុត ។ ទឹកភ្នែកសូម្បីតែមួយតំណក់ ក៏មិនបានមានដល់អ្នកណាៗ ។ ទាំងអស់គ្នាជាអ្នកចម្រើនមរណស្សតិទុកល្អហើយ ។ ដោយតេជនៃសីលរបស់ខ្លួនទាំងនោះ ភពនៃស្តេចសក្កៈទើបសម្តែងអាការក្តៅ ។ ស្តេចសក្កៈនោះទ្រង់

ពិចារណាថា អ្នកណាហ្ន៎ប្រាប់ថានឹងឲ្យយើងឃ្លាតចាកទី ទ្រង់ជ្រាបថា ភពក្តៅព្រោះគេជនៃគុណរបស់ជនទាំងនោះ ជាអ្នកមានចិត្តជ្រះថ្លា ទ្រង់ត្រិះរិះថា យើងទៅកាន់សំណាក់របស់ជនទាំងនេះ ធ្វើឲ្យគេបន្លឺសីហនាទ ក្នុងវេលាបន្លឺសីហនាទស្រេចអស់ ទើបធ្វើនិវេសន៍របស់ជនទាំងនោះ ឲ្យពេញដោយរតនៈទាំង ៧ ប្រការ ហើយមកទើបគួរ ទើបស្តេចទៅក្នុងទីនោះដោយរហ័ស ហើយប្រថាប់ឈរត្រង់ខាងព្រៃជាទីចោលសាកសព ត្រាស់ថា នែបា ពួកលោកធ្វើអ្វី ។ ជនទាំងនោះពោលថា បពិត្រអ្នកជាម្ចាស់ ពួកយើងដុតមនុស្សម្នាក់ ។ ស្តេចសក្កៈត្រាស់ថា ពួកលោកមិនមែនដុតមនុស្សទេ តែបែបនឹងសម្លាប់ម្រឹគមួយហើយ ទើបចំអិន ។ ជនទាំងនោះពោលថា បពិត្រអ្នកជាម្ចាស់ ការនោះក៏មិនមែនដែរ ពួកយើងដុតចំពោះមនុស្សប៉ុណ្ណោះ ។ ស្តេចសក្កៈ ត្រាស់ថា បើយ៉ាងនោះ គេគង់នឹងជាមនុស្សដែលមានពៀរនឹងពួកលោក លំដាប់នោះ ព្រះពោធិសត្វ ទើបពោលនឹងស្តេចសក្កៈនោះថា បពិត្រអ្នកជាម្ចាស់ គេជាបុត្រដែលកើតពីខាងក្នុងរបស់ពួកយើង មិនមែនអ្នកមានពៀរនឹងគ្នាទេ ។ ស្តេចសក្កៈត្រាស់ថា បើយ៉ាងនោះ គេគង់ជា

បុត្រដែលមិនជាទីស្រឡាញ់របស់លោក ។ ព្រះពោធិសត្វពោលថា បពិត្រអ្នកជាម្ចាស់ គេជាបុត្រដែលជាទីស្រឡាញ់ក្រៃលែងរបស់ខ្ញុំ ។ ស្ដេចសក្កៈត្រាស់ថា កាលជាដូច្នោះ ព្រោះហេតុអ្វី លោកទើបមិនស្រែកយំ ។ ព្រះពោធិសត្វនោះ កាលនឹងប្រាប់ហេតុដែលមិនយំ ទើបពោលគាថាទី ១ ថា ៖

ឧរគោវ តចំ ជិណ្ណំ ហិត្វា គច្ឆតិ សំ តនុំ
ឯវំ សរីរេ និព្ភោគេ បេតេ កាលង្កតេ សតិ ។
ឌយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ
តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតិ ។

កូនរបស់ខ្ញុំ លះបង់នូវសរីរៈហើយទៅ ដូចជាពស់លះបង់នូវសំណកចាស់ កាលបើសរីរៈប្រើប្រាស់មិនបាន ធ្វើកាលកិរិយាទៅកាន់លោកខាងមុខយ៉ាងនេះ, រាងកាយ កាលត្រូវគេដុត រមែងមិនដឹងនូវសេចក្ដីខ្សឹកខ្សួលនៃញាតិទាំងឡាយ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្ដាយចំពោះកូនខ្ញុំ៖ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

## អធិប្បាយអត្ថនៃគាថា

លោកពោលពាក្យអធិប្បាយនេះទុកថា បពិត្រអ្នកជាម្ចាស់ កូនរបស់ខ្ញុំលះបង់នូវសរីរៈរបស់ខ្លួនទៅ ដូចជាពស់លះបង់នូវសំណាកចាស់ មិនបានក្រឡេកមើល លះបង់ចោលទៅដូច្នោះ កាលសរីរៈនៃកូនរបស់ខ្ញុំនោះ វៀរជាច់ចាកជីវិតិន្ទ្រិយ ប្រើការមិនបានយ៉ាងនេះ និងកាលកូនរបស់ខ្ញុំនោះ លះបង់ទៅហើយ គឺវិលត្រឡប់ទៅហើយ ធ្វើមរណកាលហើយ ប្រយោជន៍អ្វីដោយសេចក្តីករុណា ឬសេចក្តីសោកស្តាយ ព្រោះកូនរបស់ខ្ញុំនេះ រមែងមិនដឹង សូម្បីសេចក្តីសោកស្តាយរបស់ពួកញាតិ ដូចយកលំពែងចាក់ហើយដុត រមែងមិនរលឹកដឹងសុខនិងទុក្ខដូច្នោះ ព្រោះហេតុនោះ ខ្ញុំទើបមិនសោកស្តាយដល់គេ គេទៅតាមគតិនៃខ្លួនរបស់គេហើយ ។

ស្តេចសក្កៈ ទ្រង់បានស្តាប់ពាក្យរបស់ព្រះពោធិសត្វហើយ ត្រាស់សួរនាងព្រាហ្មណីថា ម្នាលនាង គេជាអ្វីនឹងនាង ? នាងព្រាហ្មណីឆ្លើយថា បពិត្រអ្នកជាម្ចាស់ គេជាបុត្រដែលខ្ញុំបរិហារដោយគភ៌អស់ ១០ ខែ ឲ្យផឹកទឹកដោះហើយទំនុកបម្រុង ចិញ្ចឹមឲ្យចម្រើនធំធាត់ ។ ស្តេចសក្កៈត្រាស់ថា

ម្នាលនាង បិតាមិនយំ ព្រោះជាបុរសក៏លើកទុក ចំណែកហឫទ័យរបស់មាតាទន់ ព្រោះហេតុអ្វី នាងទើបមិនយំ ។ នាងព្រាហ្មណីនោះ កាលនឹងប្រាប់ហេតុដែលមិនយំ ទើបពោលគាថា ២ គាថាថា ៖

*អនព្ភិតោ តតោ អាគា អននុញ្ញាតោ ឥតោ គតោ*
*យថាគតោ តថា គតោ តត្ថ កា បរិទេវនា ។*
*ឌយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ*
*តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតិ ។*

*កូន (របស់ខ្ញុំ) ដែលមកអំពីបរលោក ខ្ញុំក៏មិនបានអង្វរគេទៅអំពីលោកនេះ ក៏ខ្ញុំមិនបានអនុញ្ញាត គេមកយ៉ាងណា គេក៏ទៅយ៉ាងនោះ ខ្សឹកខ្សួលធ្វើអ្វី ព្រោះការដែលគេទៅនោះ រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្ដីខ្សឹកខ្សួលនៃញាតិទាំងឡាយទេ ព្រោះហេតុនោះទើបខ្ញុំមិនសោកស្ដាយនឹងកូនទុ៎ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។*

*លំដាប់នោះ ស្ដេចសក្កៈ គ្រាបានស្ដាប់ពាក្យរបស់នាងព្រាហ្មណីហើយ ទើបត្រាស់សួរប្អូនស្រីថា នៃនាង គេជាអ្វី*

នឹងនាង ? ប្អូនស្រីពោលថា បពិត្រអ្នកជាម្ចាស់ គេជាបង-ប្រុសរបស់ខ្ញុំម្ចាស់ ។ ស្ដេចសក្កៈត្រាស់ថា នែនាង ធម្មតាប្អូនស្រីទាំងឡាយ រមែងមានសេចក្ដីស្រឡាញ់ក្នុងបងប្រុស ព្រោះហេតុអ្វី ទើបនាងមិនស្រែកយំ ។ ចំណែកប្អូនស្រីនោះ កាលនឹងប្រាប់ហេតុ ដែលមិនស្រែកយំឲ្យដល់ស្ដេចសក្កៈនោះ ទើបពោលគាថា ២ គាថាថា ៖

សចេ រោទេ កិសា អស្សំ តស្សា មេ កឹ ផលំ សិយា
ញាតិមិត្តសុហជ្ជានំ ភិយ្យោ នោ អរតី សិយា ។
ឌយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ
តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតិ ។

បើខ្ញុំយំទួញ ខ្ញុំនឹងស្គាំងស្គម កាលខ្ញុំនោះយំទួញ នឹងមានផលដូចម្ដេច សេចក្ដីមិនត្រេកអររបស់ពួកញាតិមិត្ត និងសម្លាញ់របស់យើង គប្បីមានដោយក្រៃលែង រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្ដីខ្សឹកខ្សួលនៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្ដាយនឹងបងនុ៎ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

គ្រាស្ដេចសក្កៈ ទ្រង់បានស្ដាប់ពាក្យនៃស្រីដែលជាប្អូន

ស្រីហើយ ទើបត្រាស់សួរភរិយារបស់បុត្រដែលស្លាប់នោះថា នែនាង គេជាអ្វីនឹងនាង ? ភរិយា ឆ្លើយថា បពិត្រអ្នកជាម្ចាស់ គេជាស្វាមីខ្ញុំ ។ ស្តេចសក្កៈត្រាស់ថា ធម្មតាស្ត្រីទាំងឡាយ កាលស្វាមីស្លាប់ទៅ រមែងជាស្រីមេម៉ាយ ឥតមានទីពឹង ព្រោះហេតុអ្វីទើបនាងមិនស្រែកយំ ។ ចំណែកភរិយានោះ កាលប្រាប់ហេតុដែលមិនស្រែកយំដល់ស្តេចសក្កៈនោះ ទើបពោលគាថា ២ គាថាថា ៖

យថាបិ ទារកោ ចន្ទំ គច្ឆន្តមនុរោទតិ
ឯវំ សម្បទមេវេតំ យោ បេតមនុសោចតិ ។
ឧយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ
តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតិ ។

ទារកយំទារព្រះចន្ទ្រដែលកំពុងចរទៅយ៉ាងណា បុគ្គលដែលសោករកអ្នកស្លាប់ទៅកាន់លោកខាងមុខ នេះឯងជាគ្រឿងប្រៀបធៀបយ៉ាងនោះដែរ រាងកាយកាលត្រូវគេដុតរមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួល នៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្តាយនឹងប្តីនុ៎ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

## អធិប្បាយអត្ថនៃគាថា

ពាក្យដែលជាគាថានោះមានសេចក្ដីថា ទារកខ្ចីមិនដឹងវត្ថុដែលគួរនិងមិនគួរ វត្ថុដែលគួរបាននិងមិនគួរបាន ក្នុងទីណាទីមួយ អង្គុយនៅលើភ្លៅរបស់មាតា ឃើញព្រះចន្ទ្រពេញវង់ក្នុងខែថ្ងៃពេញបូណ៌មី ចរទៅក្នុងអាកាស រមែងស្រែកយំថា ម៉ែ ចូរឲ្យព្រះចន្ទ្រដល់ខ្ញុំ ម៉ែ ចូរឲ្យព្រះចន្ទ្រដល់ខ្ញុំ ដូចេ្នះយ៉ាងណា សេចក្ដីដល់ព្រមឧបមេយ្យក៏ដូច្នោះដែរ គឺការស្រែកយំរបស់អ្នក សោកស្ដាយដល់អ្នកដែលលះបង់ទៅ គឺស្លាប់ទៅហើយនោះ សម្រេចសេចក្ដីឧបមេយ្យដូច្នោះ ទាំងមិនមានប្រយោជន៍ក្រៃលែង ជាងពាលទារកដែលស្រែកយំ ចង់បានព្រះចន្ទ្រសូម្បីនេះ ព្រោះហេតុអ្វី ? ព្រោះពាលទារកតូចនោះស្រែកយំទារព្រះចន្ទ្រ ដែលមានចំណែកស្វាមីរបស់ខ្ញុំម្ចាស់ស្លាប់ហើយ ឥឡូវនេះ មិនប្រាកដទេ សូម្បីគេយកលំពែងចាក់ដុត ក៏មិនដឹងអ្វី ។

ស្ដេចសក្កៈ ទ្រង់បានស្ដាប់ពាក្យរបស់ករិយា ហើយទើបត្រាស់សួរទាសី ថា នៃនាង គេជាអ្វីនឹងនាងឯង ? ទាសីឆ្លើយថា បពិត្រអ្នកជាម្ចាស់ គេជាម្ចាស់របស់ខ្ញុំ ។ ស្ដេចសក្កៈ

ត្រាស់ថា នាងបានត្រូវបុរសនេះបៀតបៀន វាយហើយប្រើប្រាជក ព្រោះហេតុនោះ នាងឯងទើបមិនស្រែកយំ ព្រោះគិតថា បុរសនេះផុតទៅល្អហើយ ។ ទាសីពោលថា បពិត្រអ្នកជាម្ចាស់ លោកកុំនិយាយយ៉ាងនោះ ពាក្យដែលលោកនិយាយនេះ មិនសមគួរដល់នាងខ្ញុំនេះ អយ្យបុត្តរបស់ខ្ញុំម្ចាស់ ដល់ព្រមដោយខន្តិ មេត្តា និងសេចក្តីអាណិត ជាអ្នកដូចជាបុត្រដែលខ្ញុំម្ចាស់ឲ្យចម្រើនធំធាត់លើទ្រូង ។ ស្តេចសក្កៈ ត្រាស់ថា កាលជាដូច្នោះ ព្រោះហេតុអ្វី ទើបនាងមិនស្រែកយំ ។ ចំណែកទាសីនោះ កាលនឹងប្រាប់ហេតុដែលមិនស្រែកយំដល់ស្តេចសក្កៈនោះ ទើបពោលគាថា ២ គាថាថា ៖

យថាបិ ឧទកកុម្ភោ ភិន្នោ អប្បដិសន្ធិយោ
ឯវំ សម្បទមេវេតំ យោ បេតមនុសោចតិ ។
ឧយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ
តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតិ ។

ក្អមទឹកដែលបែកធ្លាយ តវិញមិនជាប់យ៉ាងណា បុគ្គលសោកស្តាយនឹងអ្នកស្លាប់ទៅកាន់លោកខាងមុខ នេះឯងជាគ្រឿងធៀបក៏យ៉ាងនោះដែរ រាងកាយកាលត្រូវគេដុត

រមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួល នៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងម្ចាស់ទុំ គតិណា ជារបស់គេ គេក៏ទៅកាន់គតិនោះ ។

ពាក្យដែលជាគាថានោះមានសេចក្តីថា ក្អមទឹកដែលគេលើកឡើង របូតធ្លាក់បែក ៧ ចំរៀក រមែងមិនអាចនឹងតំរៀបភ្ជាប់ គ្រឿងទាំងនោះហើយ ធ្វើឲ្យត្រឡប់ជារបស់ប្រក្រតី បានទៀត យ៉ាងណា សេចក្តីសោកស្តាយរបស់អ្នកសោកស្តាយចំពោះអ្នកដែលស្លាប់ទៅកាន់លោកខាងមុខហើយនោះ ក៏ឲ្យសម្រេចសេចក្តីឧបមេយ្យដូច្នោះ ព្រោះមិនអាចធ្វើអ្នកស្លាប់ឲ្យរស់ឡើងវិញបានទៀត ម្យ៉ាងទៀត អ្នកមានឫទ្ធិមិនអាចតភ្ជាប់ក្អមដែលបែកហើយ ឲ្យពេញដោយទឹក ដោយអានុភាពនៃឫទ្ធិ យ៉ាងណា សូម្បីអ្នកដែលស្លាប់ហើយ អ្នកណាៗ ក៏មិនអាចធ្វើឲ្យត្រឡប់ជាប្រក្រតីដូចដើម សូម្បីដោយកម្លាំងឫទ្ធិបាន ដូច្នោះ ។ គាថាក្រៅនេះ មានសេចក្តីបានពោលហើយក្នុងគាថាមុនទាំងនោះ ។

ស្តេចសក្កៈ ទ្រង់ស្តាប់ធម្មកថារបស់អ្នកទាំងអស់ហើយ ទ្រង់ជ្រះថ្លាត្រាស់ថា លោកទាំងឡាយជាអ្នកមិនប្រមាទចម្រើន

មរណាសន្នតិហើយ ចាប់ផ្តើមតាំងពីនេះទៅ លោកទាំងឡាយ កុំធ្វើការងារដោយដៃរបស់ខ្លួន យើងជាស្តេចសក្កទេវរាជ យើងនឹងធ្វើរតនៈទាំង ៧ ប្រការ ដែលប្រមាណមិនបាន ទុកក្នុងផ្ទះរបស់ពួកលោក លោកទាំងឡាយចូរឲ្យទាន រក្សាសីល ចូរធ្វើឧបោសថកម្ម ចូរជាអ្នកមិនប្រមាទចុះ គ្រាឲ្យឱវាទដល់ជនទាំងនោះហើយ ទ្រង់ធ្វើផ្ទះឲ្យមានទ្រព្យប្រមាណមិនបាន ហើយស្តេចជៀសចេញទៅ ។

ព្រះសាស្តា គ្រាទ្រង់នាំព្រះធម៌ទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចៈហើយប្រជុំជាតក ។ ក្នុងវេលាចប់សច្ចៈ កុដុម្ពីតាំងនៅក្នុងសោតាបត្តិផល ។ ទាសីក្នុងគ្រានោះ បានជានាងខុជ្ជុត្តរា ធីតាបានជានាងឧប្បលវណ្ណា បុត្របានជាព្រះរាហុល មាតាបានជានាងខេមា ចំណែកព្រាហ្មណ៍បានជាយើងតថាគត ដូច្នេះឯង ។

ចប់ អដ្ឋកថាឧរគជាតក ។

## ២២. រឿងប្រេតជាមាតានៃព្រះសារីបុត្ត ទី២

*(ព្រះសារីបុត្តសួរថា)* ម្នាលស្រីស្គម មានឆ្អឹងជំនីរគោម នាងជាស្រីអាក្រាត មានរូបមានសម្បុរអាក្រក់ក្រៃពេក មានខ្លួនស្គាំងស្គម មានខ្លួនរវាមទៅដោយសរសៃ នាងជាអ្វី មកឈរនៅទីនេះ ។

*(នាងប្រេតតបថា)* អំពីមុន ខ្ញុំជាមាតាបង្កើតរបស់លោក ក្នុងជាតិទាំងឡាយដទៃ មកកើតក្នុងកំណើតនៃប្រេត ពេញប្រៀបដោយសេចក្ដីស្រេកឃ្លាន បរិភោគទឹកមាត់ ដែលគេស្ដោះចោល ទឹកសម្បោរ ស្ទួស ខ្ទាញ់រាវ (នៃសាកសព) ដែលគេដុត និងឈាមនៃស្រីទាំងឡាយដែលសម្រាលកូន និងឈាមនៃដំបៅនឹងប្រមុះ និងក្បាលដាច់ មានសេចក្ដីស្រេកឃ្លានគ្របសង្កត់ ខ្ញុំបរិភោគនូវខ្ទុះនិងឈាមដែលជាប់នឹងសរីរៈនៃស្រីនិងបុរស នូវខ្ទុះនិងឈាមនៃបសុសត្វ និងមនុស្សទាំងឡាយ ខ្ញុំមិនមានទីពឹង មិនមានទីលំនៅ ដេកតែលើទីស្មសាន ដូចក្រែលោកម្ចាស់ជាបុត្ត សូមលោកម្ចាស់ឲ្យទានដើម្បីខ្ញុំ លុះឲ្យ

ហើយ ចូរឧទ្ទិសផលដល់ខ្ញុំ គិតធ្វើដូចម្តេចហ្ន៎ ឲ្យខ្ញុំគប្បីបានរួចអំពីការបរិភោគនូវខ្ទុះនិងឈាម ។

ព្រះអគ្គសាវក មានទាមថា ឧបតិស្សៈ លុះបានស្តាប់ពាក្យនៃនាងប្រេត ជាមាតាហើយ មានចិត្តប្រកបដោយករុណា បានហៅព្រះមោគ្គល្លាន ១ ព្រះអនុរុទ្ធ ១ ព្រះកប្បិន ១ ឲ្យធ្វើនូវកុដិទាំងឡាយ ៤ ខ្នង ហើយវេរកុដិផង ឲ្យបាយនិងទឹកផង ចំពោះសង្ឃដែលមកអំពីទិសទាំង ៤ ហើយឧទ្ទិសទក្ខិណាទានដល់មាតា ។ វិបាកក៏កើតឡើង ក្នុងលំដាប់ដែលឧទ្ទិសហើយ ភោ-ជនាហារ គឺទឹកផឹក និងសំពត់ (ក៏កើតឡើង) នេះជាផលនៃទក្ខិ-ណាទាន លំដាប់នោះ (ស្រីនោះ) ស្អាត មានសំពត់ស្លៀកពាក់ស្អាតបាត ទ្រទ្រង់នូវសំពត់ដ៏ឧត្តមជាងសំពត់ដែលកើតក្នុងដែនកាសី មានគ្រឿងវត្ថាករណៈដ៏វិចិត្របានចូលទៅរកព្រះកោលិត។

(ព្រះកោលិតសួរថា) ម្នាលនាងទេវធីតា នាងមានសម្បុរល្អមកឈរនៅ (ទីនេះ) ភ្លឺស្វាងទូទៅសព្វទិសទាំងឡាយ ដូចជាផ្កាយព្រឹក ឯសម្បុរប្រាកដដូច្នោះ កើតឡើងដល់នាង ដោយហេតុ

ដូចម្ដេច ផលនៃសុចរិត សម្រេចដល់នាងក្នុងទីនេះ ដោយហេតុដូចម្ដេច បានជាភោគៈណានីមួយ ដែលជាទីពេញចិត្ត កើតឡើងដល់នាង

ម្នាលនាងទេវធីតា មានអានុភាពច្រើន យើងសូមសួរនាង នាងកាលកើតជាមនុស្ស តើបានធ្វើបុណ្យដូចម្ដេច នាងជាទេវធីតា មានអានុភាពភ្លឺផ្លេកយ៉ាងនេះ ទាំងសម្បុរនាង ក៏ភ្លឺសព្វទិស ដោយបុញ្ញកម្មដូចម្ដេច ។

(ប្រេតតបថា) អំពីមុន ខ្ញុំជាមាតារបស់ព្រះសារីបុត្ត ក្នុងជាតិទាំងឡាយដទៃ មកកើតក្នុងកំណើតនៃប្រេត ពេញប្រៀបដោយសេចក្ដីស្រេកឃ្លាន បរិភោគតែទឹកមាត់ ដែលគេស្ដោះចោល ទឹកសម្បោរ ស្លេស្ម និងខ្ទាញ់រាវ (នៃសាកសព) ដែលគេដុត និងឈាមនៃស្រីទាំងឡាយដែលសម្រាលកូន និងឈាមនៃដំបៅនឹងប្រមុះ និងក្បាលដាច់ ខ្ញុំមានសេចក្ដីស្រេកឃ្លានគ្របសង្កត់ បរិភោគនូវខ្ទុះនិងឈាមដែលជាប់នឹងសរីរៈនៃស្ត្រីនិងបុរស នូវខ្ទុះនិងឈាមនៃបសុសត្វ និងមនុស្សទាំងឡាយ ខ្ញុំមិនមានទីពឹង

ទីពំនាក់អាស្រ័យ ដេកតែលើទីស្មសានដូចគ្រែ ។ ខ្ញុំត្រេកអរ ដោយទាននៃព្រះសារីបុត្ត ទើបមិនមានភ័យក្នុងទីណាៗ បពិត្រ លោកដ៏ចំរើន ខ្ញុំមកដើម្បីថ្វាយបង្គំលោកជាអ្នកប្រាជ្ញ ប្រកប ដោយសេចក្តីករុណា ក្នុងលោក ។

ចប់ រឿងប្រេត ជាមាតានៃព្រះសារីបុត្ត ទី២ ។

## ២៣-រឿងកុមារប្រេត ទី៥

(ព្រះសង្គីតិកាចារ្យទាំងឡាយ ពោលថា) ញាណរបស់ ព្រះសុគត មានសភាពអស្ចារ្យ ដូចព្រះសាស្តាទ្រង់ព្យាករនូវ បុគ្គលថា បុគ្គលពួកខ្លះ ជាអ្នកមានបុណ្យក្រាស់ បុគ្គលពួកខ្លះ ជាអ្នកមានបុណ្យស្តើង ។ កុមារនេះ ដែលគេបោះបោល ក្នុងព្រៃ ស្មសាន បានញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយទឹកដោះដែល ហូរចេញអំពីមេដៃ (នៃទេវតា) អស់មួយរាត្រី ។ យក្ស និងភូត ទាំងឡាយក្តី ពស់ទាំងឡាយក្តី មិនបៀតបៀនកុមារ អ្នកមាន បុណ្យធ្វើហើយទេ សូម្បីតែពួកឆ្កែ ក៏មកលិទ្ធជើងទាំងគូ របស់

កុមារនេះដែរ ពួកបក្សីក្អែក ពួកចចក ក៏មកចោមជុំវិញ (កុមារនេះ) ។ ហ្វូងសត្វស្វាបទាំងឡាយ ក៏នាំយកមន្ទិលភគិចេញ ឯក្អែកទាំងឡាយ ក៏នាំយកអាចម៍ក្អែកចេញ មនុស្សនិងអមនុស្សពួកខ្លះមិនបានចាត់ចែងរក្សានូវកុមារនេះទេ មិនបានចាត់ចែងនូវឱសថនិងការអប់ដោយគ្រាប់ស្ពៃ (ដល់កុមារនេះទេ) ។ សូម្បីតែពួកមនុស្ស ក៏មិនរៀននូវការប្រកបនូវនក្ខត្តឫក្ស ទាំងមិនបានរោយ-រាយនូវធញ្ញជាតិគ្រប់មុខ លើកុមារដែលមានសភាពដូច្នោះ ដែលដល់នូវសេចក្ដីលំបាកយ៉ាងក្រៃលែង គេនាំមកក្នុងពេលយប់ហើយបោះចោលក្នុងព្រៃស្មសាន ព្រះពុទ្ធដែលទេវតានិងមនុស្សបូជា បានឃើញកុមារនោះ ដូចជាដុំនៃទឹកដោះខាប់ កំពុងតែញាប់ញ័រ ប្រកបដោយសេចក្ដីសង្ស័យ នៅសល់តែជីវិត លុះព្រះពុទ្ធមានប្រាជ្ញាស្មើដោយផែនដីបានឃើញហើយ ទើបព្យាករថា កុមារនេះនឹងបានជាអ្នកមានត្រកូលដ៏ប្រសើរផង នឹងមានភោគៈផងក្នុងនគរនេះ ។

(ពួកឧបាសកបានសួរថា) វតដូចម្ដេច ព្រហ្មចរិយៈដូចម្ដេច នេះជាផលនៃវត ឬព្រហ្មចរិយៈដូចម្ដេច ដែលកុមារនេះបានសន្សំល្អហើយ បានជាកុមារនេះដល់នូវសេចក្ដីវិនាសដល់ម៉្លេះ ហើយត្រឡប់បាននូវឫទ្ធិ គឺទិព្វសម្បត្តិដល់ម៉្លោះនោះវិញ ។

(ព្រះសង្គីតិកាចារ្យទាំងឡាយពោលថា) ពួកជនបានធ្វើនូវការបូជាដ៏ឧឡារិកចំពោះព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ទារកនោះមានចិត្តរវើយរវាយក្នុងការបូជានោះ ទារកនោះបានពោលវាចាអាក្រក់ ជាវាចាមិនគួរចង់ព្វ ក្នុងទីប្រជុំនៃសប្បុរស ទារកនោះបន្ទោបង់សេចក្ដីត្រិះរិះចេញហើយ ក៏ត្រឡប់បាននូវសេចក្ដីត្រេកអរនិងសេចក្ដីជ្រះថ្លា ក្នុងកាលជាខាងក្រោយ ទារកនោះបានបម្រើព្រះតថាគត ព្រះអង្គគង់នៅក្នុងវត្តជេតពន ដោយយាគូអស់ ៧ ថ្ងៃ ។ នោះជាវត នោះជាព្រហ្មចរិយៈរបស់កុមារនោះ នេះជាផលនៃវត ឬព្រហ្មចរិយៈនោះ ដែលកុមារនេះសន្សំល្អហើយ បានជាកុមារនេះដល់នូវសេចក្ដីវិនាសដល់ម៉្លេះ ហើយត្រឡប់បាននូវឫទ្ធិ គឺទិព្វសម្បត្តិដល់ម៉្លោះនោះវិញ ។ លុះកុមារ

នោះឋិតនៅក្នុងមនុស្សលោកនេះ អស់មួយរយឆ្នាំ ជាអ្នកបរិបូណ៌ ដោយកាមទាំងពួង ដល់បែកធ្លាយរាងកាយទៅកាន់កពថ្មី ក៏បាន ជាកូននៃសក្កទេវរាជ ។

ចប់ រឿងកុមារប្រេត ទី ៥ ។

## ២៤.រឿងសេរិនីប្រេត ទី៦

(ឧបាសកបានសួរស្រីប្រេតថា) ម្នាលនាងស្អុម មានឆ្អឹង ជំនីរគោម នាងជាស្រីអាក្រាត មានរូបមានសម្បុរអាក្រក់ ជាស្រី ស្គមរីមរៅមដោយសរសៃ នាងជាអ្វី មកឈរក្នុងទីនេះ ។

(ស្រីប្រេតឆ្លើយថា) បពិត្រអ្នកដ៏ចំរើន ខ្ញុំជាស្រីប្រេត ដល់ នូវសេចក្តីលំបាក កើតក្នុងយមលោក បានធ្វើនូវកម្មដ៏លាមក (លុះ ច្យុត) អំពីមនុស្សលោកនេះហើយ បានទៅកាន់បេតលោក ។

(ឧបាសកសួរថា) អំពើអាក្រក់ដូចម្តេច ដែលនាងបានធ្វើ ហើយដោយកាយវាចា ចិត្ត នាង (ច្យុត) អំពីមនុស្សលោកនេះ បានទៅកាន់បេតលោក ដោយផលនៃកម្មដូចម្តេច ។

(ស្រីប្រេតឆ្លើយថា) ខ្ញុំបានរើសទ្រព្យគេកន្លះមាសកៈ ត្រង់កំពង់ទាំងឡាយ ដែលមិនមានទោស គឺមិនមានអ្នកណាមួយឃាត់ ខាំងកាលដែលទេយ្យធម៌ទាំងឡាយ កំពុងមានគ្រប់គ្រាន់ ខ្ញុំមិនបានធ្វើនូវទីពឹងចំពោះខ្លួនសោះ ។ ខ្ញុំស្រេកទឹក ចូលទៅរកស្ទឹង ស្ទឹងក៏ប្រែទៅជាទទេ ខ្ញុំចូលទៅជ្រកម្លប់ ក្នុងកាលកំពុងក្តៅស្រមោលក៏ប្រែទៅជាក្តៅ ។ ឯខ្យល់ដែលដូចភ្លើងសោត ក៏ក្តៅ កាយមកដល់ខ្ញុំ បពិត្រអ្នកដ៏ចំរើន ខ្ញុំគួរ (រង)ទុក្ខមានសម្រេកជាដើមនេះ នឹងបាបកម្មដទៃដ៏លាមកលើសលុបជាងសេចក្តីទុក្ខមានសម្រេកជាដើមនោះ ។ អ្នកគួរទៅកាន់ហត្ថិនីបុរី ហើយជម្រាបមាតារបស់ខ្ញុំថា ខ្ញុំបានឃើញកូនស្រីរបស់នាងដល់នូវសេចក្តីលំបាក កើតក្នុងយមលោក បានធ្វើនូវកម្មដ៏លាមក (ច្យុត)អំពីមនុស្សលោកនេះ បានទៅកាន់បេតលោក ។ ទ្រព្យដែលខ្ញុំទុកក្នុងទីទុំះមាន តែខ្ញុំមិនបានប្រាប់ទ្រព្យនោះ (ឯទ្រព្យទាំងនោះ) ចំនួន៤ សែនកហាបណៈ ក្រោមបល្ល័ង្ក(របស់)ខ្ញុំ ។ មាតារបស់ខ្ញុំនោះ ចូរឲ្យទានដើម្បីខ្ញុំផង ចូរចិញ្ចឹមជីវិតផង ដោយទ្រព្យនោះចុះ

មាតារបស់ខ្ញុំឲ្យទានហើយ ចូរឧទ្ទិសទក្ខិណាទានដល់ខ្ញុំផង ខ្ញុំនឹងជាអ្នកដល់នូវសេចក្តីសុខ បានសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាងក្នុងកាលនោះ ។

ឧបាសកនោះ ទទួលស្តាប់ពាក្យប្រេតនោះថា ប្រពៃហើយ រួចក៏ទៅកាន់ហត្ថិនីបុរី បានប្រាប់ដល់មាតារបស់ស្រីប្រេតនោះថា ខ្ញុំបានឃើញកូនស្រីរបស់នាង ដល់នូវសេចក្តីលំបាក កើតក្នុងយមលោក បានធ្វើកម្មដ៏លាមក (ច្យុត)អំពីមនុស្សលោកនេះទៅកាន់បេតលោក កូនស្រីរបស់នាងនោះ បានផ្តាំនឹងខ្ញុំក្នុងបេតលោកនោះថា អ្នកអញ្ជើញទៅកាន់ហត្ថិនីបុរី ហើយជម្រាបដល់មាតារបស់ខ្ញុំថា ខ្ញុំបានឃើញកូនស្រីរបស់នាង ដល់នូវសេចក្តីលំបាកក្នុងយមលោក បានធ្វើកម្មដ៏លាមក (ច្យុត)អំពីមនុស្សលោកនេះទៅកាន់បេតលោក ។ ទ្រព្យដែលខ្ញុំទុកក្នុងទីនុ៎ះមាន តែខ្ញុំមិនបានប្រាប់នូវទ្រព្យនោះ (ឯទ្រព្យទាំងនោះ) ចំនួន ៤ សែនកហាបណៈនៅខាងក្រោមបល្ល័ង្ក(របស់ខ្ញុំ) ។ សូមមាតាឲ្យទានដើម្បីខ្ញុំផង ចូរចិញ្ចឹមជីវិតផង ដោយទ្រព្យនោះចុះ មាតារបស់ខ្ញុំ លុះឲ្យទាន

ហើយ សូមឧទ្ទិសនូវទក្ខិណាទានដល់ខ្ញុំផង ខ្ញុំនឹងជាអ្នកដល់នូវសេចក្តីសុខ បានសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាងក្នុងកាលនោះ ។

ក៏ក្នុងលំដាប់នោះ មាតានោះបានឲ្យទាន លុះឲ្យហើយ បានឧទ្ទិសនូវទក្ខិណាទានដល់ស្រីប្រេតនោះ ស្រីប្រេតក៏បានដល់នូវសេចក្តីសុខផង មាតានោះចិញ្ចឹមជីវិត ដោយងាយផង ។

ចប់ រឿងសេរិនីប្រេត ទី៦ ។

## ២៥-និធិកណ្ឌសូត្រ

និធឹ និធេតិ បុរិសោ គម្ភីរេ ឧទកន្តិកេ[2]
អត្ថេ កិច្ចេ សមុប្បន្នេ អត្ថាយ មេ ភវិស្សតិ
រាជតោ វា ទុរុត្តស្ស ចោរតោ បីឡិតស្ស វា
ឥណស្ស វា បមោក្ខាយ ទុព្ភិក្ខេ អាបទាសុ វា
ឯតទត្ថាយ លោកស្មឹ និធិ នាម និធិយ្យតិ ។

បុរសកប់កំណាប់ទ្រព្យទុកក្នុងទីជ្រៅ ជាទីបំផុតនៃទឹក ដោយគិតថា កាលបើកិច្ចដែលត្រូវការកើតឡើងហើយ ទ្រព្យនេះ

---

២ ឱ. ឧទកន្តិកេ ។ អដ្ឋកថាយំ ឦទិសោយេវ ហោតិ ។

នឹងបានជាប្រយោជន៍ដល់អាត្មាអញ ដែលត្រូវពួកបច្ចាមិត្ត ពោលបង្កាច់ នឹងបានដោះខ្លួនចេញពីស្តេច ឬត្រូវចោរបៀតបៀន នឹងបានដោះខ្លួនចេញពីចោរ នឹងបានដោះបំណុល ឬក្នុងពេលទុរភិក្ស ឬក៏ក្នុងកាលអន្តរាយទាំងឡាយ ធម្មតាកំណាប់ដែលគេកប់ទុកក្នុងលោក ដើម្បីប្រយោជន៍នេះឯង ។

តាវស្សុ និហិតោ សន្តោ គម្ភីរេ ឧទកន្តិកេ
ន សព្វោ សព្វទាយេវ[៣] តស្ស តំ ឧបកប្បតិ
និធិ វា ឋានា ចវតិ សញ្ញា វាស្ស វិមុយ្ហតិ
នាគា វា អបនាមេន្តិ យក្ខា វាបិ ហរន្តិ នំ
អប្បិយា វាបិ ទាយាទា ឧទ្ធរន្តិ អបស្សតោ
យទា បុញ្ញក្ខយោ ហោតិ សព្វមេតំ វិនស្សតិ ។

កំណាប់ដែលបុគ្គលកប់ក្នុងទីជ្រៅ មានទីបំផុតទល់នឹងទឹកដល់ម៉្លោះ កំណាប់ទ្រព្យទាំងអស់នោះ ក៏មិនសម្រេចដល់បុគ្គលនោះសព្វកាលទេ ដ្បិតថា កំណាប់ទ្រព្យរមែងឃ្លាតទៅចាកទីខ្លះ សេចក្តីចំណាំរបស់បុគ្គលនោះ រមែងវង្វេងទៅ

---

៣ . ឱ.ម. ឯវ ។

ខ្លះ នាគទាំងឡាយ រមែងនាំជញ្ជូនទៅខ្លះ ពុំនោះសោត ពួកយក្សនាំយកទ្រព្យនោះទៅខ្លះ អ្នកទទួលមត៌ក ដែលមិនជាទីស្រឡាញ់ រមែងគាស់យកនូវកំណប់ទ្រព្យនោះ កាលខ្លួនមិនឃើញខ្លះ ខ្លួនអស់បុណ្យទៅវេលាណា កំណប់ទាំងអស់នោះ រមែងវិនាសបាត់បង់ទៅក្នុងវេលានោះ ។

យស្ស ទានេន សីលេន សញ្ញមេន[៤] ទមេន ច
និធិ សុនិហិតោ ហោតិ ឥត្ថិយា បុរិសស្ស វា
ចេតិយម្ហិ ច[៥] សង្ឃេ វា បុគ្គលេ អតិថីសុ វា
មាតរិ បិតរិ វាបិ[៦] អថោ ជេដ្ឋម្ហិ ភាតរិ
ឯសោ និធិ សុនិហិតោ អជេយ្យោ អនុគាមិកោ
បហាយ គមនីយេសុ ឯតំ អាទាយ គច្ឆតិ
អសាធារណមញ្ញេសំ អចោរហរណោ[៧] និធិ ។

កំណប់ទ្រព្យដែលស្ត្រី ឬបុរសណា បានកប់ទុកល្អហើយ ដោយទាន សីល ដោយការសង្រួម និងដោយការទូន្មានខ្លួន ក្នុងចេតិយ ក្នុងសង្ឃ ក្នុងបុគ្គល ក្នុងពួកភ្ញៀវ ឬមួយក្នុង

---

៤ ឱ.ម. សំយមេន ។ ៥ ឱ. វ ។ ៦ ម. ចាបិ ។ ៧ ឱ.ម. អចោរាហរណោ ។

មាតា ក្តីបិតា ឬថា ក្តីបងប្រុសស្រីដែលជាច្បង កំណប់ទ្រព្យនុ៎ះ ចាត់ជាកំណប់ទ្រព្យ ដែលកប់ទុកប្រពៃហើយ នរណាៗ មិនគប្បីផ្ចាញ់បានជាកំណប់ទ្រព្យ ដែលជាប់តាមខ្លួនទៅ កាលភោគៈទាំងឡាយដែលខ្លួនត្រូវលះបង់ហើយទៅ ខ្លួនរមែងកាន់យកនូវកំណប់ទ្រព្យ គឺបុណ្យនុ៎ះទៅ កំណប់ទ្រព្យគឺបុណ្យ មិនទូទៅដល់ពួកជនដទៃ ជារបស់ដែលចោរលួចទៅមិនបាន ។

កយិរាថ ធីរោ បុញ្ញានិ យោ និធិ អនុគាមិកោ
ឯស ទេវមនុស្សានំ សព្វកាមទទោ និធិ
យំ យំ ទេវាភិបត្ថេន្តិ សព្វមេតេន លព្ភតិ ។

កំណប់ទ្រព្យ គឺបុណ្យណា ជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញគួរធ្វើនូវកំណប់ទ្រព្យ គឺបុណ្យនោះ កំណប់ទ្រព្យ គឺបុណ្យនុ៎ះឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ដល់ទេវតានិងមនុស្សទាំងឡាយ ពួកទេវតានិងមនុស្សទាំងឡាយ ប្រាថ្នាណាស់នូវផលណាៗ ផលទាំងពួងនោះៗ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។

សុវណ្ណតា សុសរតា សុសណ្ឋានំ សុរូបតា

អាធិបច្ចំ[៨] បរិវារោ សព្វមេតេន លព្ភតិ ។

*ភាពជាអ្នកមានពណ៌សម្បុរផូរផង់ មានសំឡេងពីរោះ ទ្រង់ទ្រាយល្អ រូបល្អ ជាអធិបតី មានយសបរិវារ ផលទាំងអស់រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។*

បទេសរជ្ជំ ឥស្សរិយំ ចក្កវត្តិសុខំ បិយំ

ទេវរជ្ជម្បិ ទិព្វេសុ សព្វមេតេន លព្ភតិ ។

*ភាពជាស្តេចប្រទេសរាជ ឥស្សរិយយស សេចក្តីសុខរបស់ស្តេចចក្រពត្តិជាទីស្រឡាញ់ ភាពជាស្តេចនៃទេវតា ក្នុងទេពនិកាយទាំងឡាយ ផលទាំងអស់ រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។*

មានុស្សិកា ច សម្បត្តិ ទេវលោកេ ច យា រតិ

យា ច និព្វានសម្បត្តិ សព្វមេតេន លព្ភតិ ។

*សម្បត្តិជារបស់មនុស្សណាផង សេចក្តីត្រេកអរ ក្នុងទេវលោកណាផង សម្បត្តិគឺព្រះនិព្វានណាផង សម្បត្តិទាំងអស់រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។*

មិត្តសម្បទមាគម្ម យោនិសោ វេ បយុញ្ជតោ

---

៨ ឱ.ម. អធិបច្ចំ ។

វិជ្ជាវិមុត្តិវសីភាវោ សព្វមេតេន លព្ភតិ ។

ភាពនៃបុគ្គលកាលអាស្រ័យមិត្តសម្បទា បើប្រកបសេចក្តីព្យាយាម ដោយឧបាយដែលត្រូវ ជាអ្នកស្ទាត់ក្នុងវិជ្ជា និងវិមុត្តិ ឥដ្ឋផលទាំងអស់ បានដោយកំណាប់ទ្រព្យគឺបុណ្យនោះ ។

បដិសម្ភិទា វិមោក្ខា[៩] ច យា ច សាវកបារមី

បច្ចេកពោធិ ពុទ្ធភូមិ សព្វមេតេន លព្ភតិ ។

បដិសម្ភិទា វិមោក្ខ សាវកបារមីញាណ បច្ចេកពោធិញាណ និងពុទ្ធភូមិណាៗ ឥដ្ឋផលទាំងអស់ រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។

ឯវំ មហាត្ថិកា[១០] ឯសា យទិទំ បុញ្ញសម្បទា

តស្មា ធីរា បសំសន្តិ បណ្ឌិតា កតបុញ្ញតន្តិ។

បុញ្ញសម្បទានេះ ឲ្យសម្រេចប្រយោជន៍ដ៏ធំ ដោយប្រការដូច្នេះ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ ជាធីរជន ទើបសរសើរនូវភាពនៃបុគ្គលជាអ្នកមានបុណ្យធ្វើទុកហើយ ។

ចប់ និធិកណ្ឌសូត្រ ។

---

៩ ម. វិមោក្ខោ ។ ១០ ម. មហិទ្ធិកា ។

# ២៦_វេលាមសូត្រ

*(សុត្តន្តបិដក លេខ៤៩, ទំព័រ៧៧)*

*(២០) សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពនរបស់អានាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលគហបតី ទានក្នុងត្រកូលអ្នកនៅតែឲ្យដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ទានក្នុងត្រកូលខ្ញុំព្រះអង្គនៅតែឲ្យដែរ តែទាននោះឯងសៅហ្មង គឺបាយបុងអង្ករនិងទឹកជ្រក់ជាគំរប់ពីរ ។ ម្នាលគហបតី បុគ្គលឲ្យទានសៅហ្មងក្តី ឲ្យទានថ្លៃថ្លាក្តី តែឲ្យទាននោះមិនគោរព ធ្វើសេចក្តីមិនគោរពកោតក្រែងហើយឲ្យ មិនឲ្យដោយដៃខ្លួនឯង បោះឲ្យ យល់ថាមិនមានផលហើយឲ្យ វិបាករបស់ទាននោះៗ កើតក្នុងត្រកូលណាៗ ចិត្តក៏មិនឱនទៅ*

ដើម្បីប្រើប្រាស់នូវភត្តដ៏ថ្លៃថ្លា ចិត្តមិនឱនទៅដើម្បីប្រើប្រាស់នូវសំពត់ថ្លៃថ្លា ចិត្តមិនឱនទៅដើម្បីប្រើប្រាស់យានដ៏ថ្លៃថ្លា ចិត្តមិនឱនទៅដើម្បីប្រើប្រាស់ក្នុងកាមគុណ ៥ ដ៏ថ្លៃថ្លា មួយទៀត ពួកជនណា ដែលជាកូនក្តី ប្រពន្ធក្តី ទាសៈក្តី អ្នកបំរើក្តី កម្មករក្តី របស់បុគ្គលនោះ ជនទាំងនោះមិនស្តាប់ មិនផ្ទង់ត្រចៀកស្តាប់ រមែងបញ្ជូនចិត្តទៅក្នុងអារម្មណ៍ដទៃ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលគហបតី ព្រោះថា វិបាកនៃកម្មទាំងឡាយ ដែលបុគ្គលធ្វើដោយមិនគោរព រមែងមានយ៉ាងនេះឯង ម្នាលគហបតី បុគ្គលឲ្យទានសៅហ្មងក្តី ថ្លៃថ្លាក្តី តែឲ្យទាននោះដោយគោរព ធ្វើសេចក្តីកោតក្រែងហើយឲ្យ ឲ្យដោយដៃខ្លួនឯង មិនបោះឲ្យ យល់ថាមានផលហើយឲ្យ វិបាករបស់ទាននោះៗ កើតក្នុងត្រកូលណាៗ ចិត្តក៏រមែងឱនទៅ ដើម្បីប្រើប្រាស់ភត្តដ៏ថ្លៃថ្លា ចិត្តរមែងឱនទៅ ដើម្បីប្រើប្រាស់សំពត់ដ៏ថ្លៃថ្លា ចិត្តរមែងឱនទៅដើម្បីប្រើប្រាស់យានដ៏ថ្លៃថ្លា ចិត្តរមែងឱនទៅ ដើម្បីប្រើប្រាស់ក្នុងកាមគុណ ៥ ដ៏ថ្លៃថ្លា មួយទៀត

ពួកជនណា ដែលជាកូនក្តី ប្រពន្ធក្តី ទាសៈក្តី អ្នកបំរើក្តី កម្មករក្តី របស់បុគ្គលនោះ ជនទាំងនោះរមែងស្តាប់ ផ្ទង់ត្រចៀកស្តាប់ មិនបញ្ជូនចិត្តទៅក្នុងអារម្មណ៍ដទៃឡើយ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលគហបតី ព្រោះថាវិបាករបស់កម្មទាំងឡាយ ដែលបុគ្គលធ្វើដោយគោរព រមែងមានយ៉ាងនេះឯង ។ ម្នាលគហបតី កាលពីព្រេងនាយ មានព្រាហ្មណ៍ ឈ្មោះវេលាម លោកបានឲ្យទាន ជាមហាទាន មានសភាពយ៉ាងនេះគឺបានឲ្យភាជន:មាស ៨៤.០០០ ដែលពេញដោយប្រាក់ បានឲ្យភាជន៍ ប្រាក់ ៨៤.០០០ ដែលពេញដោយមាស បានឲ្យភាជន៍សំរិទ្ធ ៨៤.០០០ ដែលពេញដោយប្រាក់ បានឲ្យដំរី ៨៤.០០០ ដែលមានគ្រឿងអលង្ការមាស មានទង់ជ័យមាស ព្រមទាំងបាំងដោយបណ្តាញមាស បានឲ្យរថ ៨៤.០០០ ដែលពាសដោយស្បែកសីហៈ ដែលពាសដោយស្បែកខ្លាធំ ពាសដោយស្បែកខ្លាដំបង ពាសដោយសំពត់កម្ពល់ មានពណ៌លឿង មានគ្រឿងអលង្ការមាស មានទង់ជ័យមាស បិទបាំង

ដោយបណ្តាញមាស បានឲ្យមេគោ ៨៤.០០០ សម្រាប់រូតបន្ទរ (ទឹកដោះ) មានភាជន៍សំរិទ្ធសម្រាប់ត្រង បានឲ្យនាងកញ្ញា ៨៤.០០០ ដែលពាក់កែវមណីនិងកណ្ឌាល បានឲ្យបល្ល័ង្ក ៨៤.០០០ ដែលក្រាលដោយព្រំ ក្រាលដោយកម្រាលរោមមានពណ៌ស ក្រាលដោយកម្រាលរោម មានផ្កាជាចង្កោម ក្រាលដោយកម្រាលដ៏ប្រសើរ ធ្វើពីរោមម្រឹគឈ្មោះ មានខ្នើយមានពណ៌ក្រហមទាំងពីរខាង ព្រមទាំងពិតានមានពណ៌ក្រហម បានឲ្យកោដិ[11] នៃសំពត់ ៨៤.០០០ គឺសំពត់ធ្មីមានសាច់ល្អិត សំពត់សូត្រមានសាច់ល្អិត សំពត់អម្បោះមានសាច់ល្អិត បាច់និយាយថ្វី ដល់បាយ ទឹក បង្អែម ភោជនគ្រឿងលាប ទីដេក ដូចជាស្ទឹងតែងហូរទៅ ម្នាលគហបតី អ្នកប្រហែលជាមានសេចក្តីសំគាល់នូវវេលាមព្រាហ្មណ៍នុ៎ះ យ៉ាងនេះថា ក្នុងសម័យនោះវេលាមព្រាហ្មណ៍ ជាបុគ្គលដទៃដោយពិត (ក្រៅពីតថាគត) លោកបានឲ្យទាននោះជាមហាទាន ។

[11] កោដិក្នុងទីនេះ សំដៅយក សំពត់សាដក ១០ ហៅថា មួយកោដិ ។ អដ្ឋកថា ។

ម្នាលគហបតី ហេតុនុ៎ះ អ្នកមិនត្រូវយល់យ៉ាងនេះឡើយ ក្នុងសម័យនោះ វេលាមព្រាហ្មណ៍ ក៏គឺតថាគត ទានដែលតថាគតបានឲ្យនោះជាមហាទាន ។ ម្នាលគហបតី មិនមានទក្ខិណេយ្យបុគ្គលណាមួយ ក្នុងទាននោះទេ មិនមានបុគ្គលណាមួយសំអាតទក្ខិណាទាននោះទេ ។ ម្នាលគហបតី វេលាមព្រាហ្មណ៍បានឲ្យទានណា ដែលឈ្មោះថាមហាទាន នឹងបុគ្គលណាញុំាងបុគ្គលដែលមានទិដ្ឋិល្អ ១ រូប (សោតាបន្នបុគ្គល) ឲ្យបរិភោគ ទាននេះ ជាទានមានផលច្រើនជាងមហាទាន បុគ្គលណាញុំាងបុគ្គលដែលមានទិដ្ឋិល្អ ១០០ រូបឲ្យបរិភោគ នឹងបុគ្គលណាញុំាងបុគ្គលជាសកទាគាមី ១ រូបឲ្យបរិភោគ ។បេ។ បុគ្គលណា ញុំាងបុគ្គលជាសកទាគាមី ១០០ រូបឲ្យបរិភោគ នឹងបុគ្គលណា ញុំាងបុគ្គលជាអនាគាមី ១ រូបឲ្យបរិភោគ បើបុគ្គលណា ញុំាងបុគ្គលជាអនាគាមី ១០០ រូបឲ្យបរិភោគ នឹងបុគ្គលណា ញុំាងបុគ្គលជាព្រះអរហន្ត ១ រូបឲ្យបរិភោគ បុគ្គលណា ញុំាងបុគ្គលជាព្រះអរហន្ត ១០០ រូបឲ្យបរិភោគ

នឹងបុគ្គលណា ញុំាងព្រះបច្ចេកពុទ្ធ ១ អង្គឲ្យបរិភោគ បុគ្គលណា ញុំាងព្រះបច្ចេកពុទ្ធ ១០០ រូបឲ្យបរិភោគ នឹងបុគ្គលណា ញុំាងព្រះតថាគត អរហន្តសម្មាសម្ពុទ្ធឲ្យបរិភោគ បុគ្គលណា ញុំាងព្រះសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យបរិភោគ នឹងបុគ្គលណា ឲ្យគេធ្វើវិហារ ឧទ្ទិសចំពោះសង្ឃមកពីទិសទាំង ៤ បុគ្គលណា មានចិត្តជ្រះថ្លាដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង នឹងបុគ្គលណា មានចិត្តជ្រះថ្លាសមាទាននូវសិក្ខាបទទាំងឡាយ គឺចេតនាវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆារ វៀរចាកមុសាវាទ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ដោយការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ បុគ្គលណា មានចិត្តជ្រះថ្លា សមាទាននូវសិក្ខាទាំងឡាយ គឺចេតនាវៀរចាកបាណាតិបាត ។បេ។ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ដោយការផឹកនូវទឹកស្រវឹង គឺសុរានឹងមេរ័យដោយហោចទៅ បុគ្គលណា ចំរើននូវមេត្តាចិត្តសូម្បីអស់កាលត្រឹមតែមួយរូតទឹកដោះគោប៉ុណ្ណោះ ការចំរើន

មេត្តាចិត្តនេះ របស់បុគ្គលទាំងនោះ មានផលច្រើន ជាងទាន នោះទៅទៀត ។ ម្នាលគហបតី វេលាមព្រាហ្មណ៍ បានឲ្យទាន ជាមហាទានណានឹងបុគ្គលណា ញុំាំងបុគ្គលមានទិដ្ឋិ ១ រូបឲ្យ បរិភោគ បុគ្គលណា ញុំាំងបុគ្គលដែលមានទិដ្ឋិល្អ ១០០ រូបឲ្យ បរិភោគ នឹងបុគ្គលណា ញុំាំងបុគ្គលជាសកទាគាមី ១ រូបឲ្យ បរិភោគ ។បេ។ បុគ្គលណា ញុំាំងបុគ្គលជាសកទាគាមី ១០០ រូបឲ្យបរិភោគ នឹងបុគ្គលណា ញុំាំងបុគ្គលជាអនាគាមី ១ រូប ឲ្យបរិភោគ បើបុគ្គលណា ញុំាំងបុគ្គលជាអនាគាមី ១០០ រូប ឲ្យបរិភោគ នឹងបុគ្គលណា ញុំាំងបុគ្គលជាព្រះអរហន្ត ១ រូប ឲ្យបរិភោគ បុគ្គលណា ញុំាំងបុគ្គលជាព្រះអរហន្ត ១០០ រូប ឲ្យបរិភោគ នឹងបុគ្គលណា ញុំាំងព្រះបច្ចេកពុទ្ធ ១ អង្គឲ្យ បរិភោគ បុគ្គលណា ញុំាំងព្រះបច្ចេកពុទ្ធ ១០០ រូបឲ្យបរិភោគ នឹងបុគ្គលណា ញុំាំងព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ឲ្យ បរិភោគ បុគ្គលណា ញុំាំងព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យ បរិភោគ នឹងបុគ្គលណា ឲ្យគេធ្វើវិហារ ឧទ្ទិសចំពោះសង្ឃមក

ពីទិសទាំង ៤ បុគ្គលណា មានចិត្តជ្រះថ្លាដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង នឹងបុគ្គលណា មានចិត្តជ្រះថ្លា សមាទាននូវសិក្ខាបទទាំងឡាយ គឺចេតនាវៀរចាកបាណាតិបាត ។បេ។ វៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ ដោយការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ដោយហោចទៅ នឹងបុគ្គលណា ចំរើននូវមេត្តាចិត្ត សូម្បីអស់កាលត្រឹមតែមួយរូតទឹកដោះគោប៉ុណ្ណោះ នឹងបុគ្គលណា ចំរើននូវអនិច្ច-សញ្ញា សូម្បីអស់កាលគ្រាន់តែផ្ទាត់ម្រាមដៃប៉ុណ្ណោះ ការចំរើននេះ មានផលច្រើនជាងទាននោះទៅទៀត ។

ចប់ វេលាមសូត្រ ។